ព្រះរាជាណាចក្រកម្ពុជា

ក្រសួងសិក្សាធិការ

បណ្ណាល័យ
LIBRARY
INSTITUT

# ពង្សាវតារ
# នៃ
# ប្រទេសកម្ពុជា



ជ១០.
៤៩

ព.ស ២៤៩៥ គ.ស ១៩៥២

www.budinst.gov.kh www.elibraryofcambodia.org

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីហ្សូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ការុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh        www.elibraryofcambodia.org

ប ១០.៤៩

ព្រះរាជាណាចក្រកម្ពុជា

ក្រសួងសិក្សាធិការ

# ពង្សាវតារ

# នៃ

# ប្រទេសកម្ពុជា

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

ភ្នំពេញ

រោងពុម្ពព្រះបរមរាជវាំង

៤៧១៣/៥៥

ព.ស ២៤៩៥ គ.ស ១៩៥២

www.budinst.gov.kh www.elibraryofcambodia.org

សៀវភៅនេះក្រសួងសិក្សាធិការ បានប្រគល់ឱ្យគណៈកម្មការពិនិត្យមើលនិងរៀបរៀងឡើងវិញក្នុង គ.ស ១៩៥១ ។

មានលោក អ្នកឧកញ៉ា អ៊ុំ-ឈាងស៊ុន ប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ ជាអធិបតី

លោក ឈឹម-សុខ . អ៊ុំ-ឈុំ . ស៊ុន-ស៊ុយ . ស្រី-ស៊ុំ . ព្រំ-មុត . សាយ-អុន . ត្រឹង-ម៉ិល ជាសមាជិក

លោក ឈឹម-សុខ ជំនាញខាងពង្សាវតារកម្ពុជរដ្ឋ បានតែងបញ្ចូលនិងរៀបរៀងសៀវភៅនេះជាថ្មីឡើងវិញ តាមលំដាប់វចាក្យគ្រហើយមានបន្ថែមសេចក្ដីពិស្ដារ ដែលសម្ដេចក្សត្រិយមាលិកាទ្រង់និពន្ធដាក់បញ្ចូលក្នុងសៀវភៅនេះទៀតផង ។

⌘

⌘ ⌘

www.budinst.gov.kh www.elibraryofcambodia.org

## អំពីសករាជ

ពាក្យារការនេះ **ប្រើពុទ្ធសករាជខ្លះ និង គ្រិស្តសករាជខ្លះ**

**ពុទ្ធសករាជ** សរសេរកាត់ **ព.ស** ។

**គ្រិស្តសករាជ** សរសេរកាត់ **គ.ស** ។

ដែលហៅថាពុទ្ធសករាជ គឺកាលរាប់តាំងពីថ្ងៃដែល **ព្រះសម្មាសម្ពុទ្ធសមណគោតម** ដ៏ជាព្រះបរមគ្រូនៃយើងទាំងឡាយទ្រង់ព្រះបរមនិព្វានទៅ (ថ្ងៃពេញបូណ៌មីខែពិសាខ) **ត្រូវជា ៥៤៣ ឆ្នាំ** មុនគ្រិស្តសករាជ ។

-ដែលហៅថា**គ្រិស្តសករាជ** គឺកាលរាប់តាំងពីថ្ងៃដែល **ព្រះយេស៊ូប្រសូត** (គឺព្រះពុទ្ធរបស់ជាតិថាភាំងទាទា) ព្រះអង្គប្រសូតនៅថ្ងៃ **២៥ធ្នូ ត្រូវជា ៥៤៣ ឆ្នាំ** ក្រោយព្រះពុទ្ធសករាជ ។

-ឯ**មហាសករាជ** ខ្មែរយើងប្រើតាមប្រទេសឥណ្ឌៀផ្នែកក្រោម ត្រូវជា ៦២១ ឆ្នាំក្រោយព្រះពុទ្ធសករាជ, ៧៨ឆ្នាំក្រោយគ្រិស្តសករាជ ។

## អំពីសតវត្ស

ដែលហៅថា**សតវត្ស** គឺកំណត់កាលក្នុង១០០ឆ្នាំ ប្រៀបដូចជា :

| | | | | | | |
|---|---|---|---|---|---|---|
| សតវត្ស | ទី ១ | គឺរាប់តាំងពីឆ្នាំទី | ១ | នៃសករាជទៅដល់ឆ្នាំទី | ១០០ |
| - | ទី ២ | - | ទី ១០១ | - | ទី ២០០ |
| - | ទី ៣ | - | ទី ២០១ | - | ទី ៣០០ |
| - | ទី ៤ | - | ទី ៣០១ | - | ទី ៤០០ |
| - | ទី ៥ | - | ទី ៤០១ | - | ទី ៥០០ |

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

| | | | | | |
|---|---|---|---|---|---|
| សតវត្ស | ទី ១០ | គឺរាប់តាំងពីឆ្នាំ | ទី ៩០១នៃសករាជទៅដល់ឆ្នាំទី | | ១០០០ |
| - | ទី ១១ | - | ទី ១០០១ | - | ទី ១១០០ |

www.budinst.gov.kh www.elibraryofcambodia.org

| | | | | | | |
|---|---|---|---|---|---|---|
| - | ទី ១២ | - | ទី ១១០១ | - | ទី ១២០០ |
| - | ទី ១៣ | - | ទី ១២០១ | - | ទី ១៣០០ |
| - | ទី ១៤ | - | ទី ១៣០១ | - | ទី ១៤០០ |
| - | ទី ១៥ | - | ទី ១៤០១ | - | ទី ១៥០០ |

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

សតវត្សទី ២០ គឺពីឆ្នាំ ១៩០១ ដល់ឆ្នាំ ២០០០ ។

ដូចយើងសព្វថ្ងៃនៅក្នុងឆ្នាំ ១៩៥១ នៃគ្រិស្តសករាជគឺក្នុងសតវត្សទី ២០ នៃគ្រិស្តសករាជ បើជាព្រះពុទ្ធសករាជវិញ ២៤៩៣ ត្រូវនៅក្នុងសតវត្សទី ២៥ ។

## មូលដ្ឋាន



**១-សិលាចារឹក** : កាលពីដើមមហាក្សត្រិយ៍ប្រទេសកម្ពុជាមានភោគសម្បទនឹងឫទ្ធីចេស្តា ហើយបានសាងប្រាសាទស្តុកស្តម្ភជាច្រើន ឯប្រាសាទទាំងនោះ សព្វថ្ងៃគេឃើញនៅមានសំណល់ពាសពេញក្នុងព្រះនគរ ។ នៅកំពែងប្រាសាទទាំងនោះ មានប្រាសាទនគរធំនិងនគរវត្តជាដើម គេឃើញមានអក្សរខ្មែរបុរាណជាភាសាសំស្ក្រឹត ឬជាភាសាបាលី ។

ឯសិលាចារឹកទាំងនោះ មានប្រយោជន៍ណាស់ ពីព្រោះគេចារឹកលើថ្មរៀងៗតាម រាជ្យស្តេចទុកអោយព្រះរាជវង្សានុវង្សតំណតក្រោយៗមកដឹងឫទ្ធីបារមី នៃអម្ចាស់ផែនដីនីមួយៗ ។

www.budinst.gov.kh www.elibraryofcambodia.org

ខ្មែរទាំងឡាយនោះអ្នកចេះជ្រៅជ្រះយ៉ាងណាក្តី ពុំអាចមើលអក្សរចារឹកទាំងនោះបានឡើយ មានតែលោកអ្នកប្រាជ្ញបារាំងសែសម្នាក់នាមលោកអេយមូនីញ៉េ មើលប្រែអក្សរនោះបានមុនគេ ហើយដោយសារតែសិលាចារឹកទាំងនេះ ទើបយើងថាកាលពីដើម ប្រទេសកម្ពុជា ជាប្រទេសមួយមានភោគសម្បត្តិនិងបុទ្ធានុភាពចេស្តានៅខាងចុងបូព៌ាប្រទេស ។

**របាក្សត្រ** : យើងនឹងឃើញនៅខាងមុខទៀតថា នគរខ្មែរយើងស្គាល់តែអំពីមានទុក្ខវេទនាជាច្រើនរយឆ្នាំ កាលនោះមានជាតិជិតខាងឈ្នានិះ នឹងភោគសម្បត្តិនគរយើង ក៏ចូលមកលុកលុយរាតត្បាតជារឿយៗ ។ មានសេចក្តីមួយទៀតគួរអោយធុចចិត្តណាស់ គឺអស់ខ្មែរគ្នាឯងគួរតែប្រួតគ្នាតយុទ្ធនឹងសត្រូវពីក្រៅ ត្រឡប់ទៅជាចូលចិត្តតែឈ្លោះដណ្តើមអំណាចនឹងគ្នាឯង ៗ ច្បាំងតែនឹងគ្នាឯងទៅវិញ រួចស្តេចសោយរាជ្យក៏ទ្រង់ចាកចេញពីទីក្រុងនគរធំ យាងមកគង់នៅខាងត្បូងវិញ មហាក្សត្រទាំងនោះដោយពុំសូវមានភោគសម្បត្តិ នឹងអោយសាងប្រាសាទថ្មធំៗ ហើយនឹងឱ្យចារឹកអំពីបុទ្ធិចេស្តានៅលើថ្មពុំបាន ក៏ស្តេចត្រាស់បង្គាប់ឱ្យអ្នកចេះអក្សរជ្រៅជ្រះ គឺក្រុមបណ្ឌិតតែងជារបាក្សត្រកត់ទុកអំពីរឿងដែលជាសំខាន់ៗ ក្នុងផែនដីសេចក្តីនីមួយៗ ។

ជំពូកមួយទៀត ក្សត្រនគរជិតខាង គឺ នគរយួន នគរសៀម នគរចិន គេក៏ឱ្យមានតែងរបាក្សត្រទុកដែរ ហើយដោយស្តេចនគរទាំងនោះតែងតែមានព្រះរាជសារទៅវិញទៅមក ឬមានចម្បាំងនឹងនគរខ្មែរយើងនោះ គេឃើញនៅក្នុងរបាក្សត្រនគរទាំងនោះមានរឿងជាច្រើន និយាយអំពីនគរខ្មែរយើងដែរ ។

**រឿងដែលអ្នកប្រទេសដទៃបានកត់ទុក** : កាលនោះជាយូរអង្វែងណាស់មក ហើយមានអ្នកប្រទេសដទៃជាច្រើន បានមកមើលនគរកម្ពុជា ដំបូងគឺចិន រួចប្រហែលក្នុងគ្រិស្តសករាជ ១៤០០ មានអ្នកប្រទេសអឺរ៉ុបមក (គឺពរទុគេស៍ អេស្បាញ៉ុល ហុល្លងដេ) ឯអ្នកប្រទេសអឺរ៉ុបទាំងនោះខ្លះជាអ្នកជំនួញខ្លះជាអ្នកប្រដៅសាសនា ចូលមកប្រដៅគ្រិស្តសាសនា ដល់អ្នកទាំងនោះត្រឡប់ទៅស្រុកវិញ ក៏សរសេរកត់ទុកអំពីពិធីមានដែលបានឃើញបានឮនៅនគរកម្ពុជា ហើយដោយសាររឿង ដែលគេបានកត់

www.budinst.gov.kh www.elibraryofcambodia.org

ទុកនេះទៀត ទើបយើងរៀបរៀងពង្សាវតារ នៃប្រទេសកម្ពុជាយើងនេះបាន ។




# ភាគទី ១

**២-កំណើតនគរ** : កាលនោះជាយូរលង់ណាស់មកហើយ កន្លែងនគរកម្ពុជានិងស្រុកយួនកូសាំងស៊ីន សព្វថ្ងៃមានសុទ្ធតែទឹកសមុទ្រ ឯឈូងសមុទ្រនោះខាងកើតទល់នឹងជួរភ្នំស្រុកយួនអណ្ណាម ខាងជើងទល់នឹងជួរភ្នំដងរែក ខាងលិចទល់នឹងជួរភ្នំកំចាយ នៅក្នុងឈូងសមុទ្រនោះមានកោះជាច្រើន ហើយទន្លេមេគង្គគឺទន្លេធំហូរនាំដីល្បប់មកចាក់បំពេញឈូងនោះក្នុងមួយឆ្នាំៗ ជាច្រើនឥតគណនា ដូច្នេះឈូងនោះក៏មានដីដុះបន្តិចម្តងៗ ហើយដីដែលដុះដោយដុំៗនោះក៏ជាប់រហូតទៅ គឺយ៉ាងដូច្នេះហើយកំណើតនគរកម្ពុជានិងស្រុកយួនកូសាំងស៊ីនសព្វថ្ងៃ គឺដំបូងកើតនគរកម្ពុជា រួចស្រុកកូសាំងស៊ីន ។ ឯភ្នំដែលគេមើលឃើញនៅកណ្តាលវាលសព្វថ្ងៃ គឺជាកោះចាស់ៗដែលមាននៅក្នុងឈូងសមុទ្រនោះ ។

កាលបើដីដុះបន្តិចម្តងៗ ក៏មានមនុស្សចូលមកនៅវាលតាមដីនោះ នៅជាក្រុមជាពួកតាមជាតិ មានមេនាយកមិនចំណុះចុះចូលគ្នាទេ ។ ឯមនុស្សទាំងនោះជាមនុស្សដើម គ្មានសំលៀកបំពាក់ទេ ប្លង់សក់ពីក្រោយ ហើយខ្លះសាក់ពាសពេញទាំងខ្លួនផង អ្នកផ្នែកខាងដីខ្ពស់ ច្រើនរកស៊ីបរបាញ់សត្វ អ្នកផ្នែកខាងដីទំនាបដែលនៅមានទឹកលិចខ្លះរកស៊ីនេសាទត្រី ហើយនៅសង់ផ្ទះបែបជាខ្ទម ឬដោយទូក ។

www.budinst.gov.kh www.elibraryofcambodia.org

កាលសម័យនោះ មានចិនទេសចរមកឃើញ ហៅថាប្រទេសហ៊្វូណន រាប់តាំងពីសមុទ្រខាងត្បូងរហូតដល់ខាងជើង ទល់នឹងប្រទេសចិន ខាងកើតទល់នឹងប្រទេសចាម (កន្លែងប្រទេសអណ្ណាមសព្វថ្ងៃ) ខាងលិចទៅដល់ទន្លេមេណាម (ក្នុងប្រទេសសៀមសព្វថ្ងៃ) ។

**នគរគោកធ្លក ឬ នគរខ្មែរ** : កាលសម័យដីដុះនោះ ដុះបានជាទួលមួយ ហៅថា **ទួលគោកធ្លក ឬ កោះគោកធ្លក** (ពីព្រោះមានដើមធ្លកមួយដុះនៅទួលនោះ ហើយដែលសព្វថ្ងៃ ហៅថា អង្គរបុរី ក្នុងស្រុកព្រៃកប្បាស ខេត្តតាកែវ) ។

ឯបណ្ដាជនដើមដែលចូលមកនៅកោះគោកធ្លកនេះជាជាតិ **ខេមរៈ** ឬ **ខ្មែរ** គេលើកស្ត្រីម្នាក់ជាមេនាយក ស្ត្រីនេះក្រោយពីបានមកឡើងជាមហេសីយកព្រះនាមថា **សោមា** (គឺកូនព្រះចន្ទ) ចិនទេសចរហៅថាព្រះនាង **លីវយី** ។

គឺនគរគោកធ្លកនេះហើយ ដែលជាដើមកំណើតប្រទេសខ្មែរយើង ។

**អំពីជ្វាព្រាហ្មណ៍ចូលលុក** : ដែលហៅថា **ជ្វាព្រាហ្មណ៍** គឺកាលនោះមានជាតិឥណ្ឌៀកាន់លទ្ធិព្រាហ្មណ៍ (ព្រហ្មញ្ញសាសនា) នៅផ្នែកជាយខាងអគ្នេយ៍ នៃប្រទេសឥណ្ឌៀ មានជាតិកលិង្គ (ក្លិង្គ) ជាដើម ចាកចេញពីប្រទេសមកវាតទីតាំងនៅប្រទេសជ្វា (ជវា) ផាក់ជាចំណុះនៅលាយឡំនឹងគ្នា ពួកជ្វាក៏ទៅជាលទ្ធិព្រាហ្មណ៍ទាំងអស់ ហេតុនេះបានជាហៅថា **ជ្វាព្រាហ្មណ៍** ។

ក្នុងសតវត្សទី ១ នៃគ្រិស្តសករាជ រវាងឆ្នាំទី ៦៨ ត្រូវគ្នានឹងពុទ្ធសករាជ ៦១១ មានពួកជ្វាព្រាហ្មណ៍លើកទ័ពតាម នពមាត៌ា (គឺតាមសមុទ្រ) ចូលមកវាយយកនគរកោះគោកធ្លក គឺមេកងទ័ព នាមហ៊្វុនទៀនវេលាដែលនគរកោះគោកធ្លកមានហើយ ក៏ឡើងជាស្ដេចសោយរាជសម្បត្តិនៅទីនោះ ហើយយកស្ត្រីមេនាយកកោះគោកធ្លកនោះជាជាយា តាំងនាមឡើងឱ្យហៅថា ព្រះនាង **សោមា** (កូនព្រះចន្ទ) ។

កិច្ចដំបូងនៃព្រះបាទហ៊្វុនទៀន គឺទ្រង់បង្ហាត់បង្រៀនអ្នកស្រុកឱ្យចេះស្លៀកពាក់ឡើង តាំងដើមពីព្រះនាងសោមាទ្រង់ឱ្យយកសំពត់ប្រវែងមួយអាវមកបត់ជាពីរប្រវែងស្មើគ្នា កាត់រៀលត្រង់ផ្នត់សំរាប់ច្រហកក្បាលពាក់គ្របខ្លួន (ក្រោយមកគេដេរភ្ជិតជាយសងខាងកើតបានជាអាវបំពង់វែង ដែលស្រីជ្វា-ចាម-ខ្មែរប្រើ) ។ ឯប្រុសដល់

www.budinst.gov.kh www.elibraryofcambodia.org

រាជ្យក្រោយមក គេឱ្យយកសំពត់មួយផ្ទាំងចងប៉ុងព័ទ្ធបែបជាអៀមបិទបាំងកេរ្តិ៍ខ្មាស ។

-ព្រះបាទហ៊ុនទៀនទិងព្រះនាងសោមា ទ្រង់មានព្រះរាជនិវេសមួយព្រះអង្គជាដំណាតវង្សជាប់ជាង ២០០ឆ្នាំ (ដល់រវាង គ.ស ២៤៥) ។

-ព្រះរាជាដែលមានបុទ្ធានុភាពជាងគេគឺ ព្រះបាទហ្វាន់ម៉ាន់និងព្រះបាទហ្វាន់ស៊ីយ៉ុន ។

-ព្រះបាទហ្វាន់ម៉ាន់ ទ្រង់បានវាយយកប្រទេសជិតខាងនៅផ្នែកប្រទេសសៀមខាងក្រោមសព្វថ្ងៃ (គឺផ្នែកខាងត្បូង) រហូតទៅដល់ប្រទេស "ជ្វាម៉ាឡាយូ" ផង (គឺម៉ាឡាកាសព្វថ្ងៃ) បញ្ចូលដាក់មកជាចំណុះព្រះអង្គ ។

-ព្រះបាទហ្វាន់ស៊ីយ៉ុន (ជាព្រះរាជបុត្រនៃព្រះបាទហ្វាន់ម៉ាន់ សោយរាជសម្បត្តិរវាង គ.ស ២៥០) ទ្រង់បានចងព្រះរាជមេត្រីនឹងស្តេចក្រុងចិន ហើយទ្រង់បានបង្ហាត់បង្រៀនអ្នកស្រុកអោយបានចេះដឹងតាមសម័យឡើង ។

**សេចក្តីពិស្តារ** : ព្រះពុទ្ធសាសនាកាលកន្លងទៅហើយ ទឹកសមុទ្រស្រកទៅក្រឡាប្រថពីផុះឡើងជាទួលធំមួយ មានដើមធ្លកផុះកណ្តាលទួល ក្រោយមកក្រឡាប្រថពីផុះឡើងធំទូលាយ មានមនុស្សម្នាមហាជនតាំងឡើងជាភូមិលំនៅ បណ្តាជនសន្មតនាមទីនោះ ហៅថាទួលគោកធ្លក សន្មតនាមហៅថាប្រទេសខ្មែរ ឬ (ខមះ) ។

រវាងព.ស ៦១១ ប្រទេសខ្មែរតាំងឡើងជាព្រះនគរសន្មតនាមនគរហៅថា នគរគោកធ្លក តាមសម័យហេតុកាលទឹកសមុទ្រស្រកទៅក្រឡាប្រថពីផុះឡើងជាទួល មានដើមធ្លកផុះកណ្តាលទួល . . . ។

ស្តេចសោយរាជ្យនគរគោកធ្លក ចេញពីវង្ស កម្ពុស្វាយម្ភូវ៉ា ។

ជនជាតិប្រទេសក្រៅលើកព្យុហៈ ចូលមកក្នុងនគរគោកធ្លក មេកងដែលនាំមកមាននាម "ហ៊ុនទៀន" មកបានស្តេចក្សត្រីគោកធ្លកធ្វើជា ជាយា មានរាជនិវេសអង្គមួយ សោយរាជ្យដំណពីព្រះមាតា . . . ។

ប្រទេសខ្មែរកាលតាំងឡើងជា ព្រះនគរពុំទាន់រួមមូលជាឥស្សរៈរវាង ក្រោយនោះផ្លាស់នាម ព្រះនគរគោកធ្លក ហៅថា "**ឥន្ទ្របសិលា**" ក្រោយមកទៀតផ្លាស់នាមនគរគក្កសិលា" ហៅថានគរ "**ឥន្ទបត្តបុរីសោធរៈ**" ក្រោយមកទៀតទ្រង់ផ្លាស់នាមនគរឥន្ទ

www.budinst.gov.kh www.elibraryofcambodia.org

បត្ត ហៅថាមហានគរក្រុងកម្ពុជាធិបតី សិរីឥន្ទបត្ត កុរុរដ្ឋរាជធានី . . . ។

ឯពាក្យ កម្ពុជៈនោះ មានសព្ទខ្លះថាកើតមាស-កើតប្រាក់ច្រើន ឯនាមនគរកម្ពុជានេះ កាលដើមសរសេរជា កម្ពោជៈ ពាក្យថាកម្ពោជៈនេះជានាមត្រកូលរបស់ជនពួកមួយ ដែលអាងថាជាខ្សែលោហិត ជាប់មកពី នាគនហុស ជាធំក្នុងប្រទេសហៅហាយបុណសិទ្ធិ គឺមហាកោសលបុរាណ ។

ពាក្យថាកម្ពោជៈនោះ បានសេចក្តីថាចេញមកពីនាមផ្កាយព្រះសៅរ៍ ដែលហៅថាកម្ពលនាគពោជ ពាក្យថាព្រឹសភនទ្ធរាសី ។

ពួកជាតិពោជ ជាពួករាប់អានព្រះគោ និងផ្កាយព្រះសៅរ៍មកជាសាសនាព្រះឥសូរលើកយកគោមកជាជំនិះព្រះឥសូរ ចេញពីផ្កាយព្រះសៅរ៍ជាធំនៃព្រឹសភរាសី ។

ប្រទេសខ្មែរនេះ កាលតាំងឡើងជាព្រះមហានគរជនជាតិក្នុងប្រទេស ចែកចេញជា ៤ត្រកូល គឺត្រកូលក្សត្រិយ៍ ១, ត្រកូលព្រាហ្មណ៍ ១, ត្រកូលវេស្ស ១, ត្រកូលសូទ្រ ១ ។

**ក្សត្រិយ៍**ជាត្រកូលអ្នកចំបាំង មាននាទីប្រាបប្រាម អ្នកដែលមិននៅក្នុងអំណាចចាត់ការស្ពានព្រះនគរគ្រប់គ្រងប្រជាជនដែលនៅក្នុងព្រះរាជអាណាចក្រ ការសិក្សារបស់ក្សត្រិយ៍ទៅដោយវិធីចំបាំង និងការគ្រប់គ្រងប្រជាជនជាតិប្រទេស ។

**ព្រាហ្មណ៍**ជាត្រកូលធ្វើគ្រូអាចារ្យប្រដៅស្តេច ប្រដៅប្រជាជនក្នុងប្រទេស រាប់ថាមាននាទីនៃសាសនាការសិក្សារបស់ព្រាហ្មណ៍ ។

**វេស្ស** ជាត្រកូលអ្នករកស៊ីធ្វើស្រែចំការច្បារដំណាំ លក់ចេញទិញចូលតាមការរបរផ្សេងៗ ។

**សូទ្រ** ជាត្រកូលទាសកម្មករតែយកខ្លួន ឬកូនចៅចូលទៅនៅស៊ីឈ្នួលបំរើអ្នកទាំងពួងតាមត្រូវការ ។

ជនទាំង ៤ត្រកូលនេះឆ្ងាយផ្សេងពីគ្នា មិននៅជិតគ្នា មិនរួមភាជនៈនឹងគ្នាបានឡើយ ។

ក្សត្រិយ៍ប្រទេសខ្មែរនេះ បែបច្បាប់ប្រពៃណី ព្រះរាជពិធីលទ្ធិទំនៀម ទាំងសាសនា ចេញមកពីប្រទេសឥណ្ឌៀ វិធីអក្សរខ្មែរនិងសព្ទវចនៈ ចេញមកពីលិទ្ធិសំ

www.budinst.gov.kh www.elibraryofcambodia.org

ស្ក្រឹត បើទឹងតែងរឿងរ៉ាវអ្វីៗ ឬនឹងចុះលាយលក្ខណ៍អក្សរ ក្នុងសិលាចារឹក សុទ្ធសឹង ប្រើសព្ទសំស្ក្រឹតទុកជាគោល ដូចមានសិលាចារឹកជាប្រធាន ទើបព្រះមហារាជាអម្ចាស់ ផែនដីក្រុងកម្ពុជា ទ្រង់ប្រតិបត្តិតាមលទ្ធិសៃយសាស្រ្ត ទាំងលិទ្ធិពុទ្ធសាសន៍ ។

សម្តេចក្សត្រី មាលិកា

**៣-** អំពីជាតិឥណ្ឌៀចូលមកលុក ក្រោយទៀតតាំងពីព្រះបាទកោណ្ឌញ្ញជយវរ្ម័ន រាជ្យព្រះថោងកន្លងរហូតមកដល់ខាងក្រោយ ពាក់កណ្តាលសតវត្សទី ៥នៃគ្រិស្តសករាជ មានជាតិឥណ្ឌៀទៀត មកលុកប្រទេសគោកធ្លក ។ ជាតិឥណ្ឌៀម្តងនេះមកពីផ្នែកខាងត្បូងនៃប្រទេសឥណ្ឌៀ មានជាតិកម្ពុជាមកជាមួយផង មេកងទ័ពនោះជាជាតិព្រាហ្មណ៍ ត្រកូលកោណ្ឌញ្ញ ចូលមកយកបានប្រទេសគោកធ្លក ឡើងសោយរាជសម្បត្តិ ទ្រង់ព្រះនាមព្រះបាទកោណ្ឌញ្ញជយវរ្ម័ន ហើយទ្រង់ដាក់នាមរាជធានីដែលទ្រង់គង់នៅឱ្យហៅថា "**វ្យាធបុរៈ**" (សព្វថ្ងៃហៅដោយក្លាយថា **អង្គរបុរី** ក្នុងស្រុកព្រៃកប្បាសខែត្រតាកែវ) ។ មួយពួកទៀតទៅតាំងរាជធានីនៅ "**សម្ភុបុរៈ**" សព្វថ្ងៃហៅដោយក្លាយថា **សំបូរ** ក្នុងខែត្រក្រចេះ) ។

ព្រះបាទកោណ្ឌញ្ញជយវរ្ម័ន មានឫទ្ធានុភាពណាស់ មាននគរជាច្រើនចំណុះព្រះអង្គ ទ្រង់បានចងព្រះរាជមេត្រីនឹងស្តេចក្រុងចិនយកជាកំលាំងច្បាំងនឹងចាម ហើយនឹងជាតិជិតខាងដែលនៅខាងកើត ទ្រង់ច្បាំងឈ្នះចាមនោះដោយមានព្រះរាជមេត្រីនឹងស្តេចក្រុងចិននេះ ។

ព្រះបាទកោណ្ឌញ្ញជ័យវរ្ម័ន ទ្រង់បានណែនាំអ្នកស្រុកឱ្យចេះដឹងក្នុងការចំរើនគ្រប់ផ្លូវ ទ្រង់កាន់លិទ្ធិព្រាហ្មណ៍គោរពព្រះឥសូរ ។

ហេតុនេះបានក្នុងរាជ្យព្រះអង្គមានរូប "លិង្គ" ជាច្រើនពាសពេញព្រះនគរ ។

ព្រះបាទកោណ្ឌញ្ញជយវរ្ម័ន ទ្រង់ព្រះរាជសុរវណ្ណគតនៅរវាង គ.ស ៥១៤ ។

**ព្រះបាទភវវរ្ម័នជាស្តេចផ្លាស់នាមនគរដាក់ថានគរកម្ពុជា :**

លុះអំណើះក្រោយព្រះបាទកោណ្ឌញ្ញជយវរ្ម័ន កន្លងមកដល់រវាងដើមសតវត្សទី ៦ព្រះ

www.budinst.gov.kh www.elibraryofcambodia.org

រាជាធិរាជនៅក្រុងវ្យាធបុរៈ ក៏ទ្រង់ព្រះរាជសុវណ្ណគតទៅ ហើយស្ដេចដែលធ្លាប់ចំណុះទាំងប៉ុន្មានក៏បះបោរឡើងចង់យកឯករាជ្យរៀងអង្គ ប៉ុន្តែនៅពេលនោះមានស្ដេចអង្គមួយជាតិ **កម្ពុជៈ** នៅវ្យាធបុរៈឆ្លៀវឆ្លាព្រមទាំងមានឫទ្ធានុភាពឡើងយករាជសម្បត្តិនៅវ្យាធបុរៈ ជាព្រះរាជាធិរាជវាយបង្ក្រាបស្ដេចដែលបះបោរទាំងប៉ុន្មាននោះដាក់ជាចំណុះព្រះអង្គទាំងអស់ រួចទ្រង់ព្រះនាមព្រះអង្គថា ព្រះបាទ **ភវវរ្ម័ន** ហើយទ្រង់ផ្លាស់នាមប្រទេសឱ្យហៅថា **ប្រទេសកម្ពុជា** ។

ព្រះបាទភវវរ្ម័ន ជាក្សត្រិយ៍ឆ្លៀវឆ្លាណាស់ ក្នុងការសឹកសង្គ្រាមទ្រង់វាយប្រទេសជិតខាងនឹងឆ្ងាយទៅទៀត រហូតដល់ផ្លូវភ្នំដងរែកចុះចាក់បបូខបខ្វាចទាំងអស់ យកប្រទេសទាំងនោះបញ្ចូលមកព្រះរាជនគរឱ្យធំឡើង ។

**៤-អំពីក្សត្រិយ៍សោយរាជ្យក្រោយព្រះបាទភវវរ្ម័ន :**

ឯព្រះមហាក្សត្រិយ៍ទាំងប៉ុន្មានព្រះអង្គ ដែលសោយរាជ្យក្រោយព្រះបាទភវវរ្ម័ន ក៏សឹងតែមានរិទ្ធានុភាពដូចជាព្រះបាទភវវរ្ម័នដែរ ។

កាលសម័យនោះ មានចិនទេសចរបានមក ឃើញកត់ទុកថានៅព្រះរាជធានី **ឥសានបុរៈ** ក្នុងរាជ្យព្រះបាទ **ឥសានវរ្ម័ន** ដែលឡើងសោយរាជ្យពី គ.ស ៦១០ (រាជធានីនេះប្រហែលជាមិនមែនវ្យាធបុរៈទេ ប្រហែលជានៅខាងជើង) មានប្រាសាទរាជស្ថាននឹងទេវស្ថានជាង ២០ ០០០ ។

ចិនទេសចរនោះបានកត់ទុកទៀតថា កាលនោះស្ដេចទ្រង់ព្រះពស្ត្រព្រះភូសាក្រហម ហើយល្អស្អាតមានជរជាផ្កាភ្ញីនៅព្រះកាណ៌ទ្រង់ព្រះរយ៉ាមាស ព្រះកេសទ្រង់ព្រះមង្កុដមាសដាំពេជ្រ ហើយនឹងត្បូងមានតម្លៃផ្សេងៗ នៅជៀតព្រះអង្គស្ដេចមានមនុស្សដុតឈើក្រអូបក្នុងជើងមាសថ្វាយជានិច្ច ។

ប៉ុន្តែដល់មកខាងក្រោយពាក់កណ្ដាលនៃសតវត្សទី ៨ (ក្រោយរាជ្យព្រះបាទជយវរ្ម័នទី ១ ព្រះបាទជយវរ្ម័ននេះសោយរាជ្យដល់ឆ្នាំ ៦៦៧) មិនដឹងជាមានរឿងហេតុដូចម្ដេចបានជាស្ដេចកម្ពុជាខាងត្បូង (វ្យាធបុរៈ) និងខាងជើង (សម្ភុបុរៈ) ទ្រង់បែកសាមគ្គីមិត្រ ហើយដល់មកក្នុង គ.ស ៧៨៧ ក៏មានពួកជ្វាចូលមកច្បាំងលុកកម្ពុជាខាងត្បូង ។

www.budinst.gov.kh www.elibraryofcambodia.org

៥. អំពីថ្វាចូលលុកនគរក្មេងគ្រិស្តសករាជ ៧៨៧ :

កាលនៅក្នុងគ្រិស្តសករាជ ៧៨៧ មានពួកជ្វាប្អូនមកពីកោះជ្វាច្បាំងលុកលុយរាត ស្បាតឆ្នេរសមុទ្រប្រទេសឥណ្ឌូចិនទាំងអស់ ហើយមានខ្លះចូលមកលុកលុយនគរកម្ពុជា យើងផ្នែកខាងត្បូងផង (វ្យាធបុរៈ) យកដាក់ជាចំណុះឱ្យនាំស្លួយសារអាករទៅថ្វាយ ស្ដេចស្រុកកោះជ្វា ។

ж ж ж

# ភាគទី ២

## ៦. ព្រះបាទជ័យវរ្ម័នទី ២

(៨០២-៨៦៩)

ប៉ុន្តែដល់មកដើមសតវត្សទី ៩ គឺក្នុងឆ្នាំ ៨០២ មានក្សត្រិយ៍ខ្មែរមួយព្រះអង្គ ទ្រង់ស្ដេចមកពីស្រុកជ្វា មកយករាជសម្បត្តិ ។

ឯក្សត្រនេះប្រហែលជាជ្វាប្អូនំនាំជាឈ្លើយទៅស្រុកជ្វា កាលដែលចូលមកលុកក្នុង ឆ្នាំ ៧៨៧នោះ ។ កាលបើស្ដេចបានមកដល់ហើយ ។ទ្រង់ច្បាំងយករាជ្យបានជ័យជំនះ ហើយទ្រង់ឡើងសោយរាជ្យសម្បត្តិទ្រង់ព្រះនាម ព្រះបាទជ័យវរ្ម័នទី ២ (គ.ស ៨០២) ហើយទ្រង់ឱ្យឈប់លែងនាំស្លួយសារអាករទៅថ្វាយស្ដេចស្រុកជ្វា ។

ទ្រង់ផ្លាស់រាជធានីពីវ្យាធបុរៈ ទៅគង់នៅខាងជើងបឹងទន្លេសាបវិញ ដើម្បីឱ្យឆ្ងាយ ពីសមុទ្រដែលអាចឱ្យសត្រូវចូលមកបានដោយងាយ ទ្រង់គង់នៅភ្នំគូលែនមានប្រាសាទ ព្រះរាជដំណាក់ ហៅថាប្រាសាទមហិន្ទ្រា រួចទ្រង់សាងព្រះរាជវាំងមួយទៀតនៅបឹង មាលា (ចំងាយប្រហែល ៣ គ.ម ពីភ្នំគូលែន) ។

**អំពីព្រះទេវរាជានិងពួកបារគូ** : ដើម្បីនឹងសំដែងបុទ្ធានុភាពឱ្យគេគោរពព្រះអង្គ ដូចជាព្រះទេវលោក ព្រះអង្គទ្រង់ព្រះដំរិះឱ្យស្ថាងរូបជាដំណាងព្រះរូបព្រះអង្គ ដាក់ព្រះ នាមថាព្រះទេវរាជា ហើយបើកាលណាព្រះអង្គស្ដេចយាងទៅគង់នៅទីកន្លែងណាៗក្ដី ព្រះអង្គតែងតែឱ្យយកព្រះរូបនោះទៅជាមួយផង ។ ព្រះអង្គបង្កើតឱ្យមានក្រុម ព្រាហ្មណ៍បុរោហិត សំរាប់ធ្វើពិធីបុណ្យថ្វាយព្រះទេវរាជានេះ ។ ឯពួកបារគូដែលរក្សា

www.budinst.gov.kh www.elibraryofcambodia.org





ព្រះខាន់នៅក្នុងព្រះរាជវាំងភ្នំពេញសព្វថ្ងៃ គឺពួកព្រាហ្មណ៍បុរោហិត តាំងពីកាលនោះមក រីឯព្រះខាន់នោះទៀតក៏សាងតាំងពីផែនដីព្រះបាទជ័យវរ្ម័នទី ២ នេះមកដែរ ។

**អំពីប្រាសាទជាគំរូ** : ព្រះបាទជ័យវរ្ម័នទី ២ ជាក្សត្របានសាងប្រាសាទជាគំរូ ប្រាសាទសំខាន់ដែលទ្រង់បានសាង គឺប្រាសាទព្រះខាន់(នៅជិតនគរធំដែលសាងក្រោយ)ហើយនឹងប្រាសាទសាទបន្ទាយឆ្មារនៅខាងជើងបាត់ដំបង ។

ព្រះបាទជ័យវរ្ម័នទី ២ ជាព្រះមហាក្សត្រិយ៍ ទ្រង់បានបង្កើតសឹងតែគ្រប់របៀបរាជ ការផែនដី និងរបៀបសាសនាតរៀងមក (សាសនាព្រាហ្មណ៍) ។

**៧.ក្សត្រិយ៍សោយរាជ្យក្រោយព្រះបាទជ័យវរ្ម័នទី ២ :**

ក្សត្រិយ៍ទាំងអំពាលម៉ាន ដែលសោយរាជ្យតក្រោយព្រះបាទជ័យវរ្ម័នទី២រៀងមក ក៏យកព្រះនាមវរ្ម័នខាងចុងដែរ ហើយសុទ្ធតែជាក្សត្រិយ៍សឹកសង្គ្រាមច្បាំងយកស្រុកបញ្ចូលនគរឱ្យធំឡើង ។ កាលណាមានជ័យជំនះម្តងៗ ក្សត្រិយ៍ទាំងនោះទ្រង់រឹបយកភោគសម្បត្តិហើយចាប់សត្រូវនាំជា

ឈើយមកប្រើឱ្យសាងប្រាសាទធំៗ ។ កាលនោះ នគរខ្មែរយើងមានបុទ្ធានុភាពថ្កុំថ្កើង រុងរឿងណាស់ ប៉ុន្តែមានជាតិចាមនៅខាងកើតនគរខ្មែរយើងនោះ ចូលមកច្បាំងកើតកោលាហលម្តងដែរ ។

ឯមហាក្សត្រិយ៍ដែលមានព្រះកេរ្តិ៍នាមជាងគេនោះ គឺព្រះបាទឥន្ទ្រាវរ្ម័នទី ១ ជាប់ជាព្រះរាជវង្សនៃព្រះបាទជយវរ្ម័ន និងព្រះបាទយសោវរ្ម័ន ។

## ព្រះបាទឥន្ទ្រាវរ្ម័នទី ១

(ពីគ្រិស្តសករាជ ៨៧៧ ដល់ ៨៨៩)

ក្សត្រិយ៍នេះមានព្រះនាមល្បី ដោយទ្រង់បានសាងប្រាសាទបាគោ (ប្រាសាទធំកល់ព្រះគោ) និងបាគង ឯប្រាសាទទាំងពីរនេះក៏ល្អណាស់ដែរ ។ មួយទៀតមានសេនាបតីរបស់ព្រះអង្គម្នាក់បានចាត់ចែងឱ្យសាងប្រាសាទបញ្ជ (បាយ័ន) ។ តាមសិលាចារឹកថា ព្រះបាទឥន្ទ្រាវរ្ម័នជាក្សត្រិយ៍សឹកសង្គ្រាម ប៉ុន្តែគេមិនដឹងជាទ្រង់ច្បាំងនឹងជាតិប្រទេសណា ។

## ៨-ព្រះបាទយសោវរ្ម័ន

(ពីគ្រិស្តសករាជ ៨៨៩ ដល់ ៩០៨)

ក្សត្រិយ៍នេះជាព្រះរាជបុត្រនៃព្រះបាទឥន្ទ្រាវរ្ម័នទី ១ ទ្រង់មានព្រះនាមល្បីជាងគេទាំងអស់ មានសិលាចារឹកអួតថាទ្រង់ប្រកបគ្រប់លក្ខណៈ ចារឹកមួយថាជាស្តេចមានព្រះរូបល្អអស្ចារ្យ ចារឹកមួយទៀតថា ជាស្តេចខ្លាំងពូកែស្ទាប់ស្ទែងកាប់តែមួយព្រះខាន់ដាច់ដែកឬដុំលង្ហិនជាបីកំណាត់ ចារឹកមួយទៀតថា ជាស្តេចប្រាជ្ញលើសលែងអ្នកប្រាជ្ញទាំងឡាយ ។

**អំពីចម្បាំងនឹងគ្នាក្នុងស្រុកហើយនឹងចាម** : កាលព្រះបាទយសោវរ្ម័នទ្រង់ទើបនឹងឡើងសោយរាជសម្បត្តិនោះ ព្រះអង្គបានធ្វើសង្គ្រាមយ៉ាងធំជាមួយនឹងក្សត្រមួយព្រះអង្គ ដែលដណ្តើមរាជសម្បត្តិពីព្រះអង្គ ក្នុងទីចម្បាំងនោះព្រះបាទយសោវរ្ម័ន ទ្រង់ហៀបតែនឹងបរាជ័យ គេនឹងធ្វើគតព្រះអង្គបានទៅហើយ ប៉ុន្តែមានសេនាព្រះអង្គបួននាក់រងឈ្នះឡើងវិញ ។

www.budinst.gov.kh www.elibraryofcambodia.org



## ៥. អំពីសាងអង្គរធំ

(ប្រហែលក្នុងគ្រិស្តសករាជ ៩០០)

ក្រោយសឹកសង្គ្រាមក្នុងស្រុកនេះ ទ្រង់ព្រះដំរិះធ្វើបន្ទាយមួយយ៉ាងធំហើយមាំផង ដើម្បីនឹងការពារព្រះអង្គនឹងពួកសត្រូវ ឯបន្ទាយនោះហៅ យសោធបុរៈ ឬឥន្ទបត្ថ មហានគរគឺអង្គរធំសព្វថ្ងៃ ។

ក្រៅអំពីចម្បាំងនឹងគ្នាក្នុងស្រុក ព្រះបាទយសោវរ្ម័នទ្រង់បានធ្វើសង្គ្រាមនឹងចាមទៀត ជាតិចាមនេះឈ្នានិះភោគសម្បទហើយនឹងបូទ្ធាបារមីនគរខ្មែរយើង ក៏លើកទ័ពមកច្បាំងជាច្រើនផង ប៉ុន្តែលើកមកម្តងណាក្តី ព្រះបាទយសោវរ្ម័នទ្រង់វាយដេញថយខ្ចាត់ខ្ចាយទៅវិញអស់ទៅ ។ ក្នុងចម្បាំងនឹងចាមនេះ មានម្តងព្រះបាទយសោវរ្ម័នទ្រង់ហៀបតែនឹងបរាជ័យ គេនឹងធ្វើគតព្រះអង្គបានទៅហើយ ប៉ុន្តែមានពួកសេនារបស់ព្រះអង្គរងឈ្នះឡើងវិញ ។

កាលព្រះបាទយសោវរ្ម័នទ្រង់ព្រះរាជសុវណ្ណគត នគរខ្មែរយើងខាងជើងទល់នឹងព្រំប្រទល់ចិន ខាងលិចទល់នឹងទន្លេសាលូអង់ (ក្នុងស្រុកភូមា-កុឡា) ។

ព្រះបាទយសោវរ្ម័ន ទ្រង់ផាព្រះមហាក្សត្រប្រសប់គ្រប់គ្រងផែនដីណាស់ ព្រះអង្គបង្កើតឱ្យមានពន្ធដារ ហើយចាត់ឱ្យតែងច្បាប់កាត់ទោសយ៉ាងធ្ងន់ៗ អស់ទាំងពួកចោរប្លន់និងចោរលួច ។

www.budinst.gov.kh www.elibraryofcambodia.org

## ១០-ព្រះបាទជយវរ្ម័ន

(៩២៨-៩៤២)

ក្សត្រនេះជាព្រះអនុជនៃព្រះបាទយសោវរ្ម័ន ផណ្ដើមយករាជសម្បត្តិពីព្រះភគិនិយា គឺព្រះរាជបុត្រព្រះបាទយសោវរ្ម័ន ។



អង្គរវត្ត(ពីខាងមុខ)

កាលក្រោយព្រះបាទយសោវរ្ម័ន ទ្រង់ព្រះរាជសុគតទៅនោះ នគរខ្មែរយើងក៏នៅមានឫទ្ធិថ្កុំថ្កើងដែរ ហើយក្សត្រដែលសោយរាជ្យក្រោយៗមក ក៏ទ្រង់ចេះតែសាងប្រាសាទតទៅទៀត ប៉ុន្តែកាលនោះទទួលមានសឹកសង្គ្រាមនឹងគ្នាក្នុងនគរជាច្រើនផងនាំឲយឫទ្ធិអាចឱ្យជាតិជិតខាង គឺចាមហ៊ានលើកទ័ពមកច្បាំង ។

### អំពីចាកចោលអង្គរធំ

(ពីគ្រិស្តសករាជ ៩៣០ ដល់ ៩៥០)

ដោយប្រហែលជាមិនសព្វព្រះទ័យនឹងក្រុងនគរធំ ឬដោយចង់បង្ហាញបុទ្ធានុភាព ឬដោយមានសឹកសង្គ្រាមនឹងគ្នាក្នុងស្រុក ក៏មិនដឹងបានជាព្រះបាទជយវរ្ម័នទី ៤ ទ្រង់ចាកចេញពីអង្គរធំយាងទៅគង់នៅឯកោះកែ (គតីរ) ក្នុងខែត្រកំពង់ធំសព្វថ្ងៃ ។ (ប្រហែលក្នុងគ្រិស្តសករាជ ៩៣០) ។ ឯក្រុងអង្គរធំដែលព្រះបាទយសោវរ្ម័នសាងទុកនោះក៏ទុកចោលទទេឥតមានមនុស្សនៅ ។

www.budinst.gov.kh www.elibraryofcambodia.org

## ១១-ព្រះរាជេន្ទ្រវរ្ម័នទី ២

(៩៤៤-៩៦៨)

ព្រះអង្គនេះជាព្រះរាជបុត្រនៃព្រះបាទជយវរ្ម័នទី ៤ ឡើងសោយរាជសម្បត្តិនៅកោះកេបានមួយឆ្នាំ ទ្រង់យាងមកគង់ឯនគរធំវិញ (៩៤៥) ហើយទ្រង់រៀបចំជួសជុលឡើងវិញ ត្រាស់បង្គាប់ឱ្យសាងប្រាសាទរាជដ្ឋាន ទេវដ្ឋានថ្មីថែមទៀតផង ។

ព្រះបាទរាជេន្ទ្រវរ្ម័នទី ១ ទ្រង់បានច្បាំងនឹងចាមច្រើនផង ស្ដេចវាយយកនគរចាមដាក់ជាចំណុះឱ្យនាំសួយសារអាករមកថ្វាយព្រះអង្គ ។

កាលព្រះបាទរាជេន្ទ្រវរ្ម័ន ទ្រង់ព្រះរាជសុវណ្ណកោដ្ឋទៅនោះ នគរខ្មែរយើងមានស្រុកចំណុះជាង ៦០ ។

## ១២- ព្រះបាទជយវរ្ម័នទី ៥

(៩៦៨-១០០២) នឹងព្រះពុទ្ធសាសនា

ព្រះអង្គនេះជាព្រះរាជបុត្រនៃព្រះបាទរាជេន្ទ្រវរ្ម័នទី ២ ។

កាលគ្រានោះព្រះពុទ្ធសាសនាក៏មានគេកាន់គោរពបូជាច្រើនហើយដែរ ប៉ុន្តែអស់ស្ដេចផែនដីទ្រង់នៅតែកាន់ព្រហ្មញ្ញសាសនា កាលក្នុងរាជ្យព្រះបាទរាជេន្ទ្រវរ្ម័នទី ១ នោះមានសេនាបតីម្នាក់ជាអ្នកកាន់ព្រះពុទ្ធសាសនា បានចាត់ចែងឱ្យសាងព្រះពុទ្ធរូបជាច្រើនដំកល់ក្នុងអង្គរធំ ។ នៅក្នុងរាជ្យព្រះបាទជយវរ្ម័នទី ៥ ពួកព្រាហ្មណ៍បុរោហិតដែលធ្លាប់គោរពសម្ដេចព្រះទេវរាជានោះ ក៏មកគោរពសាសនាទាំងពីរនេះវិញបាន គឺព្រះពុទ្ធសាសនានិងព្រហ្មញ្ញសាសនា ។

¤ ¤ ¤

### សេចក្ដីពិស្តារ

**អំពីព្រះពុទ្ធសាសនា** - មានដំណែលនៅក្នុងកំពែងមហានគរ នៅជិតប្រាសាទសិលាដែលមាននាមហៅថា "យសោធរគីរី "ពាក្យសាមញ្ញហៅថា "បាយ័ណ្ឌ " ឬបាពួន " ដំណែលនោះមានទីវិហារចាស់និងព្រះពុទ្ធរូបធំអង្គមួយ សម្មតិនាមព្រះពុទ្ធរូបអង្គនោះហៅថា "ព្រះពុទ្ធគោកធ្លក" ។ ឯព្រះវិហារនិងព្រះពុទ្ធគោកធ្លកនោះ តាម

www.budinst.gov.kh www.elibraryofcambodia.org

សេចក្ដីអនុម៉ានឃើញថាសាងក្នុងរវាង ព.ស ១៤៨៦ (គ.ស ៩៤៣) គណៈដែលព្រះមហារាជាអម្ចាស់ផែនដីក្រុងកម្ពុជាទ្រង់កាន់លិទ្ធិពុទ្ធសាសនាជាម្ចួនមាំ ។

មានសិលាចារឹកផែនមួយថ្លែងសេចក្ដីថា សេនាបតីរូបមួយនាម ឬងារជា "ក្វិនទ្រារិម៉ាខាណា" ស្ថាងរូបព្រះសុគតមុនី នៅប្រាសាទបាទជុំមខ្ជះ នៅមហានគរខ្ជះ ។

-ព្រះពុទ្ធសាសនាមកសន្ថិតនៅក្នុងមហានគរក្រុងកម្ពុជា នៅរវាងព.ស ៩៩៣ (គ.ស ៤៥០) ។ ដល់ ព.ស ១០៣៣ (គ.ស ៤៩០) ព្រះមហារាជាអម្ចាស់ផែនដីមហានគរក្រុងកម្ពុជាទ្រង់ទទួលព្រះពុទ្ធសាសនាមកកាន់ជាម្ចួនមាំ អ្នកដែលធ្លាប់កាន់ស័យសាសន៍ ក៏ត្រឡប់មកកាន់ព្រះពុទ្ធសាសនាជាច្រើន ។

-ព្រះពុទ្ធអង្គទ្រង់ទុកព្រះសាសនានិងភាសាមគធៈ រឿងអ្វីដែលជារឿងធម្មពុទ្ធសាសនានោះគោលធំនៅភាសាបាលីភាសាមគធៈ ។

**សម្ដេចក្សត្រិយ៍ - មាលិកា**

## ១៣- ព្រះបាទសុរិយាវរ្ម័នទី ១

(ពីគ្រិស្តសករាជ ១០០២ ដល់ ១០៤៩)

ក្សត្រនេះ ត្រូវជាព្រះរាជវង្សានុវង្សនៃព្រះបាទយសោវរ្ម័ន ទ្រង់បានឡើងសោយរាជសម្បត្តិដោយសង្គ្រាម (ជាប់រវាង ៣ឆ្នាំ) ។

**អំពីចងស្ពានមេត្រីនឹងប្រទេសចិននឹងប្រទេសចាម** - ដើម្បីនឹងបង្ក្រាបអស់ទាំងស្ដេចចំណុះ ដែលបះបោរនៅជួរភ្នំដងរែកនិងទន្លេមេណាមនោះ ព្រះបាទសុរិយាវរ្ម័នទី ១ ស្ដេចចងស្ពានមេត្រីនឹងនគរចិនហើយនឹងនគរចាម ឯសេចក្ដីមេត្រីនេះជាប្រយោជន៍ការពារនឹងយួនផង ពីព្រោះគាលនោះជាតិយួន មកតាំងនៅខាងជើងប្រទេសចាមហើយ (ត្រង់កន្លែងប្រទេសយួនតុង្កឹងសព្វថ្ងៃ) ហើយប្រាថ្នានឹងដើររាយយកប្រទេសគេ ។

ព្រះបាទសុរិយាវរ្ម័នទី ១ ស្ដេចក៏ទំនុកបំរុងព្រះពុទ្ធសាសនាណាស់ដែរ ហេតុនេះបានជាដល់ព្រះអង្គទ្រង់ព្រះរាជសុវណ្ណគោដ្ឋទៅ គេថ្វាយព្រះនាមព្រះអង្គជាព្រះនិព្វានបាទ ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះបាទសុរិយាវរ្ម័នទី ១ ស្ដេចបានសាងប្រាសាទនៅភ្នំជីសូរ (ក្នុងស្រុកបាទិ) ហើយនឹងប្រាសាទនៅភ្នំសណ្ដក ។

ព្រះបាទសុរិយាវរ្ម័នទី ១ ទ្រង់ព្រះរាជសុវណ្ណគតនៅ គ.ស ១០៤៧ សោយរាជ្យបាន ៤៧ ឆ្នាំ ។

## ១៤. ព្រះបាទឧទយាទិត្យាវរ្ម័ន

(ពីគ្រិស្តសករាជ ១០៤៩ ដល់ ១០៧៩)

ក្សត្រនេះជាព្រះរាជនត្តានៃព្រះបាទសុរិយាវរ្ម័នទី ១ ។

ក្នុងរាជក្សត្រនេះ នគរពុំសូវបានសប្បាយទេ ពីព្រោះមានចម្បាំងបួនលើក ចម្បាំងនឹងចាមពីរលើក ចម្បាំងនឹងពួកក្បត់ក្នុងស្រុកពីរលើក ប៉ុន្តែមានមេទ័ពរបស់ព្រះអង្គម្នាក់ខ្លាំងពូកែចេះតែមានជ័យជំនះគ្រប់អន្លើ ។

## ព្រះបាទសុរិយាវរ្ម័នទី ២

(ពី គ.ស ១១១២ ដល់ ១១៦២)

ព្រះមហាក្សត្រនេះសោយរាជ្យ អយ្យកោព្រះនាមធរណិន្ទ្រាវរ្ម័ន ហើយកាលដើមរាជ្យព្រះអង្គក៏មានចម្បាំងនឹងគ្នាក្នុងនគរជាយូរឆ្នាំដែរ មានសេនាសង្គ្រាមស្លាប់អស់ជាច្រើន ។

**អំពីច្បាំងយកនគរចាម** - កាលបើស្រុកបានសាន្តត្រាណហើយព្រះបាទសុរិយាវរ្ម័នទី ២ ស្ដេចក៏លើកទ័ពទៅច្បាំងនឹងចាម វាយយកនគរបានហើយដាក់ក្សត្រខ្មែរមួយព្រះអង្គឱ្យសោយរាជ្យនៅនគរនោះ (ក្នុងគ្រិស្តសករាជ ១១៤៥) ។ ប៉ុន្តែដល់មក គ.ស ១១៥៩ ចាមប្រើចយកនគរជាឯករាជ្យវិញ ។

**អំពីសាងប្រាសាទអង្គរវត្ត** - រាជ្យព្រះបាទសុរិយាវរ្ម័នទី ២ ជារាជ្យមានជ័យជំនះសប្បាយថ្កុំថ្កើងណាស់ ពីព្រោះព្រះអង្គច្បាំងយកនគរចាមបាន បណ្ដាជនខ្មែរ ស្គាល់តែសេចក្ដីសុខក្សេមក្សាន្តបរិបូណ៌ដោយភោគសម្បត្ត ។

ព្រះបាទសុរិយាវរ្ម័នទី ២ ស្ដេចបានប្រោសឱ្យសាងប្រាសាទនគរវត្ត ដ៏ជាប្រាសាទល្អលើសលែងប្រាសាទខ្មែរទាំងឡាយ ។

www.budinst.gov.kh www.elibraryofcambodia.org



អង្គរវត្ត

ព្រះបាទសុរិយាវរ្ម័នទី ២ ជាមហាក្សត្រឈ្លាសវៃគ្រប់គ្រងផែនដីណាស់ ទ្រង់គោរព បូជាសាសនាទាំងពីរ គឺព្រហ្មញ្ញសាសនានិងព្រះពុទ្ធសាសនា ដើម្បីឱ្យប្រជាជនធ្វើតាម កុំឱ្យមានកើតហេតុក្នុងព្រះរាជនគរដោយសារតែលទ្ធិសាសនា ។

ព្រះបាទសុរិយាវរ្ម័នទី ២ នេះហើយដែលខ្មែរច្រើនស្គាល់ថាព្រះបទុមសូរិវង្ស ។

## ព្រះបាទជ័យវរ្ម័នទី ៧

(១១៦២-១២០១)

ព្រះមហាក្សត្រនេះ ត្រូវជាព្រះភត្តិទិយោជីដូនមួយនឹងព្រះបាទសុរិយាវរ្ម័នទី ២។

-កាលចុងរាជ្យព្រះបាទសុរិយាវរ្ម័នទី ២ ចាមប្រែចជាឯករាជ្យវិញ ប៉ុន្តែដល់មក ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី ៧ នេះ ព្រះបាទជ័យវរ្ម័នទ្រង់វាយយកបានដាក់ជាចំណុះ វិញទៀត (គ.ស ១១៩៧) ហើយដាក់មហាឧបរាជខ្មែរឱ្យទៅត្រួតត្រារហូតដល់ គ.ស ១២២០ ។

-ប៉ុន្តែនៅពេលដែលបេះតែមានសង្គ្រាមនឹងចាមជាញឹកញយ អស់ទាំងស្តេចស្វយ ដែលធ្លាប់ចំណុះតាំងពីដើមទៅខាងជើងគឺក្នុងប្រទេសសៀមនិងលាវសព្វថ្ងៃ ក៏ផ្ទៀត បះបោរព្រាថ្វាយកជាឯករាជ្យដែរ ព្រះបាទជ័យវរ្ម័នទ្រង់ស្តេចទៅបង្ក្រាបរាបអស់រហូត

www.budinst.gov.kh www.elibraryofcambodia.org



ដល់ **លួងព្រះបាង** (កាលនោះឈ្មោះថា "សិរីធម៌គីរី" ក្នុងប្រទេសលាវ) ហើយផ្នែកខាងលិចគឺក្នុងប្រទេសសៀមទ្រង់ឱ្យសម្តេចនៅនគររាជ (ដែលហៅថា "ក្វារ៉ុត") ទៅឆ្អែតបង្ក្រាបរហូតដល់ក្រុង**សុខោទ័យ** (សព្វថ្ងៃស្គាល់ថា "**សុកូថៃ**")ក្នុងប្រទេសសៀម ហើយដែលជាតិថៃឬសៀមមកតាំងនៅជាដំបូង ហៅថា "ស្យាមប្រទេស" ។

-ដូច្នេះកាលសម័យព្រះមហាក្សត្រនគរធំ ប្រទេសកម្ពុជាយើងមានឫទ្ធានុភាពនូវចេស្តាណាស់ព្រំព្រះរាជនគរខាងជើងទល់នឹងប្រទេសចិន ខាងលិចទល់នឹងប្រទេសភូមា (ប៉ារម៉ានីក្រោមសព្វថ្ងៃ និងប្រទេសភូឡាប៉ារម៉ានីលើ) ខាងត្បូងទល់នឹងសមុទ្រ ខាងកើតទល់នឹងប្រទេសចាម កន្លែងប្រទេសយួនអណ្ណាមសព្វថ្ងៃ) ។

-ព្រះបាទជយវរ្ម័នទី ៧ មិនត្រឹមតែជាមហាក្សត្រខ្លាំងពូកែខាងសឹកសង្គ្រាមប៉ុណ្ណោះទេ ទ្រង់ប្រសប់គ្រប់គ្រងផែនដីណាស់ទៀតផង ទ្រង់បានប្រោសឱ្យរៀបច្បាប់គ្រប់ដំណែងសំរាប់ព្រះនគរឱ្យចំរើនឡើង ហើយទ្រង់ឱ្យសាងគ្រឹហាឋាន ទូវមន្ទីរព្យាបាលរោគជាច្រើនផងនៅក្នុងព្រះរាជនគរ សំរាប់កែរោគប្រជាជន ។

០ ០ ០

www.budinst.gov.kh www.elibraryofcambodia.org

## ពត៌មានក្រោយព្រះបាទជ័យវរ្ម័នទី ៧

-តាំងពីក្រោយព្រះបាទជ័យវរ្ម័នទី ៧មក គឺតាំងពីដើមសតវត្សទី ១៣ រហូតដល់ចុង (ពី គ.ស ១២០១ រហូតដល់ ១៣០០) គេពុំសូវដឹងពត៌មានច្បាស់លាស់ទេ គេគ្រាន់តែដឹងថាកាលគ្រានោះព្រះរាជនគរមានកើតកោលាហលជាធំអស្ចារ្យ ។

-សៀមចេះតែលើកទ័ពចូលមកច្បាំងជាញឹកញយ ព្រាផ្ងារវាយយក "នគរធំ" ហើយយកខ្មែរដាក់ជាចំណុះប្រទេសសៀមវិញ នៅនាទីស្បែននគរធំ មានក្តីហិនហោចអស់ ហើយដោយហេតុនេះបានជាមហាឧបរាជខ្មែរ ដែលទៅត្រួតប្រទេសចាម ដោះបង់ចោលប្រទេសចាម នាំសេនាបតីពលខ្មែរចូលមកព្រះរាជនគរខ្មែរវិញ (ក្នុង គ.ស ១២២០) ហើយតាំងពីឆ្នាំនេះមកប្រទេសចាមក៏បានទៅជាឯករាជ្យវិញ ។

វិបរិតមួយទៀតគឺចំបាំងក្នុងលិទ្ធិសាសនា គឺព្រះពុទ្ធសាសនានិងព្រហ្មញ្ញសាសនា ពីព្រោះកាលនោះធម៌ព្រះពុទ្ធជ្រួតជ្រាបជាច្រើនណាស់ទៅហើយក្នុងបណ្តាជន ហេតុនេះបានជាតាំងពីក្រោយ គ.ស ១៣០០មក ព្រះរាជាដែលសោយរាជ្យឈប់លែងយកព្រះនាម "វរ្ម័ន" យកព្រះនាមជាភាសាបាលីវិញ ហើយលើកព្រះពុទ្ធសាសនាជាធំក្នុងព្រះរាជនគរ ។

## អំពីសៀម ឬថៃ

-ជាតិសៀមឬថៃនេះ កំណើតពីប្រទេសតំណៀមកវាតទីជាយូរលង់ណាស់មកហើយ (ប្រហែល ៨ សតវត្សមុនគ្រិស្តសករាជ) តាំងនៅខាងនិរតីនៃប្រទេសចិន ដ៏មានខែត្រចិនយុណាង់នៅពីខាងកើត ខែត្រទីបេនៅពីខាងលិច ប្រទេសភូម៉ាទៅពីខាងត្បូង ។ ហើយដល់រវាងសតវត្សទី ២ នៃ គ.ស តាំងជាព្រាំមួយរាជាដែលចិនហៅថា "ណានចៅ" ។

**ប្រទេសសៀម** - ប្រទេសដែលសព្វថ្ងៃហៅថាសៀម កាលពីដើមនាយជាប្រទេសជនជាតិខ្មែរចំណុះ ព្រះមហាក្សត្រកម្ពុជាតាំងពីកើតព្រះរាជនគរកម្ពុជាមក (គឺតាំងពីរវាងសតវត្សទី ៥មក) ។ ប៉ុន្តែក្រោយមកមានជាតិ **មន** កំណើតពីប្រទេសតំណៀផ្នែកខាងអាគ្នេយ៍ហៅថា គលិង្គឬក្លឹង្គ ចូលមកវាតទីនៅដែនសុវណ្ណភូមិ ក្រោយ

www.budinst.gov.kh www.elibraryofcambodia.org

មកហៅថាក្រុង **ហានុវាចតី** សព្វថ្ងៃហៅថា "វង្គុន" ហើយឯជាតិមននេះសព្វថ្ងៃហៅថា ភូមា" ។ ជាតិមននេះ កាលបើចូលមកនៅហើយក៏ប្រស្រ័យនឹងគ្នានឹងជាតិខ្មែរ នាំខ្មែរឱ្យបះបោរនិងដកខ្លួនពីចំណុះព្រះរាជអាណាចក្រនៃព្រះមហាក្សត្រកម្ពុជា ហេតុនេះបានជាហៅថាមនខ្មែរ ។

លុះយូរក្រោយមកពួកសៀម ថៃកើតហេតុនឹងចិន នៅពុំបានក៏ចាកចេញពីខែត្រយុណាន់ មកវាតត្បាតប្រទេសភូឡា ប្រទេសលាវផ្នែកលើ រួចចុះមកដល់ប្រទេសមន-ខ្មែរ វាតទីតាំងនៅក្រុង "សុខោទ័យ" (ពេលក្រោយពាក់កណ្ដាលសតវត្សទី ១១ នៃ គ.ស គឺរវាងឆ្នាំ ១០៨០) វាយយកដែនមន-ខ្មែរខ្លះ ដែលធ្លាប់ចំណុះព្រះមហាក្សត្រកម្ពុជាដាក់ជាចំណុះចងបាច់នឹងពួកមន-ខ្មែរ ហើយចេះតែញុះញង់ឱ្យពួកមន-ខ្មែរបះបោរច្បាំងនឹងព្រះមហាក្សត្រកម្ពុជា ។

លុះដល់រាជ្យព្រះចៅ **ពញាវោច** សោយរាជ្យនៅក្រុងសុខោទ័យ ព្រះរាជានេះក៏ប្រមូលពួកជនជាតិ ដែលធ្លាប់តែចំណុះព្រះមហាក្សត្រកម្ពុជា ដកយកប្រទេសជាឯករាជ្យដែលសព្វថ្ងៃហៅថាប្រទេសសៀម (ក្នុងសតវត្សទី ១៣ ខាងដើមនៃ គ.ស គឺក្រោយរាជ្យព្រះបាទជយវរ្ម័នទី ៧) ហេតុនេះបានជាព្រះមហាឧបរាជកម្ពុជា ដែលនៅឆ្វេតប្រទេសចាមនោះ ក៏បោះបង់ចោលប្រទេសចាមនាំសេនារេហ៍ពលខ្មែរចូលមកប្រទេសកម្ពុជាវិញ ក្នុងរវាង គ.ស ១២២០ ដើម្បីនឹងជួយការពារព្រះរាជនគរកម្ពុជា។

## អំពីការសាងនៃព្រះមហាក្សត្រជាន់ដើម

រាជ្យព្រះបាទជយវរ្ម័នទី ២ រហូតមកដល់រាជ្យព្រះបាទជយវរ្ម័នទី ៧ (គឺពី គ.ស ៨០២ មកដល់ ១២០១) ក្នុងកំឡុង ៤០០ ឆ្នាំគឺតាំងពីក្សត្រខ្មែរបានសាងការសំខាន់ៗច្រើន មានសល់ទុកនៅដល់សព្វថ្ងៃ ហើយមានជនបរទេសមកមើលសរសើរជាច្រើនផង ។

ការសំខាន់ដែលសាងទាំងប៉ុន្មាននោះចែកដូចខាងក្រោមនេះ :

១-ប្រាសាទសាងបូជាព្រះទីទេពនគរវត្ត ប្រាសាទព្រះខាន់ ។

២-ប្រាសាទជាបរមរាជវាំង សំរាប់ស្ដេចផែនដីគង់ ។

www.budinst.gov.kh www.elibraryofcambodia.org

៣-កំពែងបន្ទាយការពារសត្រូវ គឺកំពែងនគរធំ ។

៤-ថ្នល់និងស្ពានកាត់ឆ្ពាពីក្រុងមួយទៅក្រុងមួយ ។

៥-មន្ទីរព្យាបាលរោគសំរាប់ថែរក្សាអ្នកជម្ងឺ គឺជម្ងឺឃ្លង់ជាដើម ។

ការសាងអស់ទាំងនេះមានច្រើននៅក្បែរទន្លេសាប និងជើងភ្នំដងរែក ការសាង នេះត្រូវមានពួកកម្មករ ពួកពលនិងពួកឈ្លើយ ដែលចាប់បានក្នុងសង្គ្រាមជាច្រើនពាន់ ទើបសាងបាន ។

**ប្រាសាទសំខាន់ៗ**- ប្រាសាទដែលល្បីឈ្មោះជាងគេ មានដូចខាងក្រោមនេះ ។

**ប្រាសាទបន្ទាយឆ្មារ** - ប្រាសាទនេះនៅខាងជើងភ្នំដងរែក(ក្នុងខែត្របាត់ដំបង) គឺព្រះបាទជយវរ្ម័នទី ២ សាង ប្រហែលក្នុងគ្រិស្តសករាជ៨៥០។

ប្រាសាទបាគោ **បាគង** **លលៃ** ទាំងបីនេះ នៅខាងកើត សៀមរាបគឺព្រះបាទឥន្ទ្រាវរ្ម័នទី ១ សាងពីគ្រិស្តសករាជ ៨៧៧ ដល់ ៨៨៩ ។

ប្រាសាទបាយ័ន (បព្វត) ប្រាសាទនេះល្អស្អាតមួយដែរ សាងនៅក្នុងក្រុង អង្គរធំក្នុងរវាង គ្រិស្តសករាជ ៨៨០ ដល់ ៩០០ (គឺក្នុងរាជ្យព្រះបាទឥន្ទ្រាវរ្ម័ន) ។



**បន្ទាយនគរធំ** -បន្ទាយនេះ គឺព្រះបាទយសោវរ្ម័ន សាងប្រហែល នៅគ្រិស្តសករាជ ៩០០ ។ បន្ទាយ នេះធំលើសលែងបន្ទាយទាំងឡាយ កំពែងមួយជ្រុងៗប្រវែងប្រហែល៣

www.budinst.gov.kh www.elibraryofcambodia.org

គីឡូម៉ែត្រ ។ (បរិវេណជុំវិញប្រហែល ១៣ គ.ម) ។

**អង្គរវត្ត** - ប្រាសាទនេះគឺព្រះបាទសុរិយាវរ្ម័នទី ២ តាំងចាប់សាងប្រហែលនៅក្នុងគ្រិស្តសករាជ ១១២០ ។ ប្រាសាទនេះល្អព្រមទាំងរចនា ប៉ុន្តែរចនានោះហាក់ដូចជាធ្វើពុំទាន់ស្រេច ។

**ប្រាសាទបឹងមាលា** - ប្រាសាទនេះ គឺព្រះបាទជ័យវរ្ម័នទី ២សាងកាលពីដើម



រាជ្យព្រះអង្គ ។ នៅដោយកំពែងប្រាសាទគេឃើញមានគំនូរចំលាក់ជារឿងនិយាយពីបណ្ដាជនខ្មែរកាលគ្រានោះ ។

## របៀបនិងសណ្ដាប់ស្រុកពីដើម

**គេហស្រុក** - កាលក្នុងផែនដីព្រះមហាក្សត្រវង្សវរ្ម័ន ភេទប្រទេសខ្មែរយើងសឹងតែប្រហែលសភាពសព្វថ្ងៃនេះដែរ គេឃើញមានវាលធំៗ ហើយព្រៃញឹកដោយដុំ ប៉ុន្តែគ្មានដំណាំដូចសព្វថ្ងៃនេះទេ នៅតាមមាត់ទន្លេគេឃើញសុទ្ធតែព្រៃឫស្សីក្រាសជិត។

កាលនោះមានតែផ្លូវថ្នល់ទីខាងជើង ហើយនឹងទីក្បែរបឹងទន្លេសាបទេ ពីព្រោះនៅទីអស់នេះស្ដេចអម្ចាស់ផែនដីទ្រង់ឱ្យលើកថ្នល់ធំៗ មានទាំងស្ពានថ្មផងឆ្លងកាត់ស្ទឹង ពីក្រុងមួយទៅក្រុងមួយ ។

**អំពើបណ្ដាជន** - ជាតិខ្មែរសម្បុរសាឯម ឬងសក់ទាំងប្រុសទាំងស្រី សំលៀក

www.budinst.gov.kh www.elibraryofcambodia.org

ពាក់ ស្បៀកតែសំពត់
:ម្យ៉ាះ ដងខ្លួននៅទទេ
:នតែស្តេចម្ចាស់ផែនដី
ងនាម៉ឺន សព្វមុខមន្ត្រី
បមានសំលៀកបំពាក់
ពល្អ។ ឯសំលៀកបំពាក់
ពនេះយកមកពី ប្រទេស
ទេ ពីព្រោះកាលនោះខ្មែរ



នទាន់ចេះចិញ្ចឹមនាងទេ ស្រីៗក៏ពុំទាន់ចេះត្បាញដែរ ដូច្នេះសំពត់ដែលបណ្ដាជ
ស្លៀកពាក់ពុំសូវល្អទេ ។

**អំពីទីលំនៅ** - បណ្ដាជនខ្មែរនៅផ្ទះរោងដោលប្រក់ស្លឹកឬស្បូវ ក្នុងផ្ទះរាស្ត្រ
ានជើងម៉ា នៅកន្លែងដេកមានតែកន្ទេលកក់ឬកន្ទេលផ្តៅ ។

ឯធនធានក្នុងស្រុកទាំងប៉ុន្មានជារបស់ស្តេចផែនដីនិងនាម៉ឺនទាំងអស់ ។

**អំពីរបររកស៊ី** - នៅស្រុកស្រែអាណាប្រជានុរាស្ត្រខ្មែររកស៊ីធ្វើស្រែជាដើម ។



អ្នកអស់នោះក៏មានរកស៊ីបរបាញ់និងនេសាទត្រីដែរ ។ នៅក្រុងជុំវិញព្រះបរមរាជវាំ
មានជាងច្រើនពាន់ប្រសប់នឹងចារ ហើយនឹងឆ្លាក់ថ្មណាស់ ឯជាងនេះសំរាប់ធ្វើការ
សាងប្រាសាទស្តេចផែនដី ។ ហេតុនេះបានជាជាប់មកដល់សព្វថ្ងៃនេះ មានខ្មែរ

www.budinst.gov.kh www.elibraryofcambodia.org

ប្រសប់ខាងការរចនា ។

**សស្ត្រាវុធ** - ខ្មែរយើងពីដើមមិនចេះធ្វើកាំភ្លើងទេ បើកាលណាទៅច្បាំងប្រើតែលំពែងធ្នូ ហើយនឹងដាវខ្លួងដាវខរ ហើយនឹងខែលសំរាប់ការពារខ្លួន ។

**អ្នកតាឬអរក្ខទេវតា** -បណ្តាជនខ្មែរយើងពីដើមជឿថានៅលើដី ក្នុងទឹកដោយព្រៃមានអ្នកតា ហើយនឹងខ្មោចបិសាចមើលមិនឃើញទេ ឯអ្នកតាមានអ្នកតាល្អអ្នកតាអាក្រក់ អ្នកតាអាក្រក់មានច្រើនជាង តែតែងតែប្រព្រឹត្តបទអាក្រក់ បើកាលណាមនុស្សស្លាប់តែហោងនឹងជម្ងឺអាសន្នរោគនោះ មានមនុស្សខ្លះថាអ្នកតាធ្វើទាំងអស់ ដូចជាស្លាប់និងលង់ទឹកក្តី ស្រុកអត់បាយក្តី ប៉ុន្តែមានគ្រូធ្មប់ចេះសែនព្រេនមិនឱ្យអ្នកតាអស់នោះខឹង ធ្វើទុក្ខទោសបាន ។

សព្វថ្ងៃនេះនៅមានខ្មែរជាច្រើននៅឡើយ ជឿថាមានអ្នកតាល្អ អ្នកតាអាក្រក់ដែរ ហើយគេតែងតែសែនព្រេនឱ្យជាធម្មតា ។

**ព្រហ្មញ្ញសាសនានិងបណ្តាជន** - លុះដល់ផ្ទាព្រាហ្មណ៍ចូលលុកលុយយកស្រុកហ្វូណន(គោះគោកធ្លក) អ្នកស្រុកក៏ត្រឡប់មកកាន់ព្រហ្មញ្ញសាសនាតាមផ្ទាព្រាហ្មណ៍វិញ ពីព្រោះផ្ទាអស់នោះកាន់ព្រហ្មញ្ញសាសនា។

ឯជាតិកម្ពុជាដែលចូលមកនៅក្នុងសតវត្សទី ៥នៃគ្រិស្តសករាជនោះ ក៏កាន់ព្រហ្មញ្ញសាសនាដែរ។

ក្នុងសាសនានេះគេច្រើនគោរពព្រះបីព្រះអង្គគឺ :



ព្រះឥសូរ

www.budinst.gov.kh www.elibraryofcambodia.org

១-ព្រះព្រហ្មជាព្រះបង្កើតភពមណ្ឌល គេសាង ព្រះរូបដំណាង មានព្រះហស្ត៤ ព្រះភក្ត្រ ៤ ។

២-ព្រះឥសូរ ជាព្រះមានឫទ្ធិខាងសិល្បសាស្ត្រ គេសាងព្រះរូបដំណាង មានព្រះនេត្រ៣ ហើយ មានព្រះចន្ទនៅលើព្រះកេស ។

៣-ព្រះនារាយណ៍ (ឬព្រះវិស្ណុ) ជាព្រះជួយទ្រ ទ្រង់សត្វលោក ខាងចំណេះវិជ្ជាទាំងឡាយ មាន ការរចនាជាដើម ។ គេសាងព្រះរូបជាដំណាង មានព្រះហស្តកាន់ស័ង្ខផ្កាឈូកហើយនឹងដំបង។



ព្រះនារាយណ៍

ព្រះមហាក្សត្រកម្ពុជាយើងពីដើម កាន់ព្រហ្ម សាសនាទាំងអស់ រហូតមកដល់សតវត្សទី ១៤ នៃគ្រិស្តសករាជ ហើយប្រាសាទដែលស្តេចសាង ប៉ុន្មាននោះ ច្រើនតែសាងថ្វាយព្រះក្នុងព្រហ្ម សាសនា។ ក្នុងលិទ្ធិព្រហ្មសាសនានេះ បណ្តា ជនត្រូវចែកជា ៤ក្រុមគឺ :

១-ក្រុមព្រាហ្មណ៍បុរោហិតឬអ្នកប្រាជ្ញ .

២-ក្រុមនាយសង្គ្រាម (មេកាយោធាសង្គ្រាម) និងសេនាសង្គ្រាមជ័យ ។

៣-ក្រុមកុដុម្ពិកឬក្សេត្រាធិការ និងពាណិជ្ជការ (គឺក្រុមអ្នក ស្រែចំការច្បារដំណាំនិងជំនួញ ផ្សេងៗ)។ ៤-ក្រុមជាងទាំងពួង។ គេមើលងាយណាស់ពួកជាងៗ ចូលលាយឡំនឹងពួកក្រុមគេឯ ទៀតពុំបានឡើយ គេទុកដូច



www.budinst.gov.kh www.elibraryofcambodia.org

ជាប្រឡាក់ខ្លួនត្រូវផុះលាងចេញឱ្យភាប់ ។



**ព្រះពុទ្ធសាសនា** - ព្រះពុទ្ធសាសនាជាសាសនាផ្សាយចេញពីប្រទេសឥណ្ឌាដែរ ព្រះពុទ្ធសាសនានេះគឺសាសនាព្រះសមណគោតមជាអម្ចាស់ មានតាំងពី ៥៤០ ឆ្នាំមុនគ្រិស្តសករាជចូលមក ស្ថិតនៅនគរកម្ពុជាក្នុងសតវត្សទី ៥ នៃគ្រិស្តសករាជ ។

កាលនោះអ្នកដែលធ្លាប់កាន់ព្រហ្មញ្ញសាសនា មានអ្នកខ្លះចូលមកកាន់ព្រះពុទ្ធសាសនាវិញ ហើយភាសាប្រសើរក្នុងសាសនានេះ គឺភាសាបាលីនិងសំស្ក្រឹត ។ លុះយូរលង់មក អ្នកកាន់ព្រះពុទ្ធសាសនាក៏កាន់តែមានច្រើនឡើង ហើយដល់មកក្នុងសតវត្សទី ១៤ នៃគ្រិស្តសករាជ លើកដំកើងតែព្រះពុទ្ធសាសនាមួយជាធំក្នុងព្រះនគរ។ បានជាគេចូលចិត្តកាន់ព្រះពុទ្ធសាសនានេះ ពីព្រោះជាសាសនាសុខុមត្រជាក់ជាងព្រហ្មញ្ញសាសនា ជាសាសនាមិនរើសមុខ មិនថាអ្នកមានអ្នកក្រ បំបាត់លែងឱ្យមាន ក្រុមបណ្ដាជនអ្នកខ្ពស់អ្នកទាបទៅទៀត ។

ឯពុទ្ធសាសនាដែលខ្មែរយើងកាន់សព្វថ្ងៃ បរិសុទ្ធប្រពៃណាស់ ភាសាប្រសើរគឺភាសាបាលី បានជាមានព្រះពុទ្ធវចនៈទុកមកក្រោយនេះ ដោយសារមានព្រះសង្ឃនិមន្តទៅរៀនហើយចម្លងគម្ពីរពីលង្កាទ្វីបប្រហែលក្នុងសតវត្សទី ១២ នៃគ្រិស្តសករាជ ។

⌖ ⌖ ⌖

## សេចក្ដីពិស្ដារ

ឯពុទ្ធសាសនាជាគោល ខាងបរិយុត្តិធម៌ ពុទ្ធចក្រ ឯសៃយសាស្ត្រ អំពីទ្វារទសមាស និងពិធីផ្សេងៗជាសួស្ដី (សំ. ស្វស្តិ) មង្គលខាងអាណាចក្រ ។

www.budinst.gov.kh www.elibraryofcambodia.org

ក្រោយនោះតាំងច្បាប់រាជសាសន៍ ច្បាប់សៃយសាសន៍ ពុទ្ធសាសន៍ មានរាជាគណៈសង្ឃ ។

ឯមហារាជគ្រូនិងមន្ត្រី ខាងព្រាហ្មណ៍ ស្តេចតែងតាំងឱ្យមានដរាបណា ដរាបនោះ ឯវិធីប្រើអក្សរ ប្រើសព្ទតាមបែបសំស្ក្រឹត ជាឧត្តមពាក្យ ចាទបំពេញសេចក្ដីសំគាល់នៃភាសាខ្មែរ នៃបរិយាយនៃបរិសិទ្ធិសព្ទ ឬពាក្យសាស្ត្រ ញត្តិទាំងឡាយ នៃពាក្យប្រើគ្រប់ប្រភេទ សុទ្ធសឹងប្រើពាក្យសំស្ក្រឹតទុកជាធំ ។

អក្សរខ្មែរ ភាសាខ្មែរ ចេញមកពីលទ្ធិសំស្ក្រឹត ប្រទេសខ្មែរកាលតាំងឡើងជាមហានគរ ប្រើតែសព្ទសំស្ក្រឹត ទាំងសព្ទសំស្ក្រឹតស្មោះ និងសព្ទសំស្ក្រឹតផ្លែងខ្មែរ មានច្រើនអនេកបរិមាណ ក្នុងពាក្យកាព្យគតិនៃភាសាខ្មែរ ក៏សឹងបញ្ចូលពាក្យសំស្ក្រឹតទុកជាធំ ឯវចនគតិរបស់ប្រទេសជាតិ ហើយជាពាក្យដ៏ពិរោះ សំភូមិជាភាសាខ្ពស់ ភាសាដើម ។

អ្នកប្រាជ្ញប្រទេសខ្មែរសម័យមុន លើកពាក្យសំស្ក្រឹតទុកជាធំ ព្រោះភាសាសំស្ក្រឹតជាដើមពាក្យនៃភាសាខ្មែរ ពួករឿងបុរាណជារឿងរ៉ាវអ្វីៗ នឹងចុះលាយលក្ខណ៍អក្សរក្នុងសិលាចារឹកក្ដី សុទ្ធសឹងប្រើពាក្យសំស្ក្រឹតទុកជាគោល ដូចមានសិលាចារឹកជាប្រធាន អ្នកប្រាជ្ញសំបុត្រគ្រប់ភាសា ទទួលស្គាល់ពាក្យសំស្ក្រឹត ថាជាឧត្តម ព្រមទាំងពាក្យប្រើប្រាស់ប្រភេទវិទ្យា ។

**សម្ដេចក្សត្រិយ៍ - មាលិកា**

៙ ៙ ៙

# ភាគទី ៣

## ប្រទេសកម្ពុជាសម័យក្រោយព្រះមហាក្សត្រិយ៍ "ទវ៉ុន "

គឺតាំងពីសតវត្សទី ១៤ មក (ពី គ.ស ១៣០០មក)

## ព្រះបាទស្រីសក់ផ្ដែម

(រវាងពី គ.ស ១២៩០ ដល់ ១៣០៧)

(សុវណ្ណបត្រក្នុងរាជ្យជា: ព្រះបាទសម្ដេចព្រះបរមមហាបពិត្រ ធម្មិកមហារាជាធិរាជ)

www.budinst.gov.kh www.elibraryofcambodia.org

-ព្រះរាជាដែលសោយរាជសម្បត្តិ តពីព្រះមហាក្សត្រវង្ស "វ៉ន" មកគឺព្រះបាទត្រសក់ផ្អែម ទ្រង់សោយរាជសម្បត្តិពីរវាង គ.ស ១២៩០ ដល់ ១៣០៧ ។

-ព្រះរាជវង្សានុវង្សនៃព្រះបាទត្រសក់ផ្អែម សោយរាជសម្បត្តិតរៀងៗមក ។

## ព្រះស្រីលំពង្សរាជា

(ពី គ.ស ១៣៤៧ ដល់ ១៣៥៣)

## ព្រះឧបរាជ ស្រីសុរិយោទ័យ

(ពី ១៣៥៣)

## អំពីសៀមចូលមកច្បាំងវាយយកនគរធំបានជាដំបូង

(គ.ស ១៣៥៣)

## ព្រះស្រីលំពង្សរាជា និងឧបរាជស្រីសុរិយោទ័យ

ទាំងពីរព្រះអង្គនេះ ត្រូវជាព្រះរាជនត្តានៃព្រះបាទត្រសក់ផ្អែម (គឺជាព្រះរាជបុត្រនៃព្រះសិទ្ធន្ត) ។

-កាលនៅចុងរាជ្យ ព្រះបាទស្រីលំពង្សរាជា ព្រះរាជាសៀមព្រះនាមឧតុង លើកទ័ពមកច្បាំងនឹងព្រះលំពង្សរាជា ប្រាថ្នាវាយយកនគរធំ ហើយយកខ្មែរដាក់ជាចំណុះប្រទេសសៀម ។ កាលនោះរាជធានីសៀម(ឬថៃ) នៅអយុធ្យា ហៅថា ក្រុងទេព (ណាងស្នោ) ។

ឯសង្គ្រាមនោះធំណាស់ ហើយយូរផង ទទួលព្រះលំពង្សរាជាទ្រង់ព្រះឈួន ហើយទ្រង់ព្រះរាជសុវណ្ណគតនៅ គ.ស- ១៣៥៣ ព្រះរាជអនុជគឺព្រះឧបរាជព្រះស្រីសុរិយោទ័យ ទ្រង់រងសង្គ្រាមឡើងតយុទ្ធនឹងសៀមសមើមអស្ចារ្យ ប៉ុន្តែសៀមទំលាយទ្វារពីខាងកើតចូលលុកនគរធំនោះទៅ សៀមក៏យកនគរធំបាន(ក្នុង គ.ស ១៣៥៣) ប៉ុន្តែច្បាំងជាងមួយឆ្នាំទើបយកបាន ។

កាលបើសៀមវាយឆ្វាយយកនគរធំបានហើយ សៀមក៏ចូលតាំងនៅហើយលុកលុយពីយកមហាសម្បត្តិអាណាចក្រអស់ គំពេជ្រ មាស ប្រាក់ កែវ កង ទ្រព្យរបស់ដម្លៃផ្សេងៗ និងកន្ទេលមាស-ប្រាក់ ហើយនឹងសេះ-ដំរី-រាជរថ ។ល។ ចាប់

www.budinst.gov.kh www.elibraryofcambodia.org

យកខ្មែរជាឈ្លើយប្រហែល ១០,០០០ នាក់ ឱ្យជញ្ជូនដឹកនាំទៅឯប្រទេសសៀម (ក្រុងអយុធ្យា គឺក្រុងទេព) ។

ប៉ុន្តែកាលដែលទ័ពខ្មែរបរាជ័យចាញ់សៀមនោះ ពួកមេទ័ពខ្មែរនិងពួកបារគូ បុរោហិតចោមរោមយកគ្រឿងកកុធភណ្ឌ បណ្តោះចេញរួច ។

សៀមតាំងនៅនគរធំជាប់រវាង ៤ឆ្នាំ (គឺតាំងពី គ.ស ១៣៥៣ ដល់ ១៣៥៧) មានទាំងតាំងនាម៉ឺនសៀមឱ្យត្រួតខែត្រខ្លះទៀតផង ។

## ព្រះបាទស្រីសុរិយោវង្ស

(ពី គ.ស ១៣៥៧ ដល់ ១៣៦៦)

ព្រះរាជានេះត្រូវជាព្រះភគនិយោនៃព្រះលំពង្សរាជា និងព្រះស្រីសុរិយោទ័យ ។

តាំងពីវេលាដែលកំពុងសង្គ្រាមនឹងសៀម ព្រះស្រីសុរិយោវង្សទ្រង់តែប្រារព្ធទៅកេណ្ឌសេនារេហ៍ពលរហូតដល់ស្រុកលាវ ដើម្បីនឹងយកមកតយុទ្ធនឹងសៀម លុះដល់ គ.ស ១៣៥៧ ទ្រង់ស្តេចមកដល់វាយកំចាត់សៀមពីនគរធំបានទេវិញ ហើយទ្រង់ក៏បានទទួលព្រះរាជាភិសេកជាស្តេចអម្ចាស់ផែនដីឡើង ពី គ.ស ១៣៥៧ ដល់ ១៣៦៦ ។

-កាលក្នុងរាជ្យព្រះបាទស្រីសុរិយោវង្សនេះ ព្រំប្រទល់ប្រទេសកម្ពុជាយើង ខាងកើតរហូតទៅដល់ **ដូងណៃ** (សព្វថ្ងៃហៅថា ណូណៃ ខែត្រចាបៀ ក្នុងប្រទេសយួនកូសាំងស៊ីន) ខាងលិចតាំងពីខែត្រ **នាងរង់អង្គរាជ** (ពីអគ្នេយ៍នៃខែត្រអង្គរាជដែលសព្វថ្ងៃ ហៅថា កូរ៉ាត) រហូតទៅដល់ឈូងសមុទ្រសៀម ខាងជើងរហូតដល់ **ស្លាបខ្សាច់គោកខណ្ឌ** (សព្វថ្ងៃនៅនាដែនឧបុន) ។

## ព្រះបាទព្រះធម្មសោកា

(ពី គ.ស ១៣៧៣ ដល់ ១៣៩៤)

## អំពីសៀមវាយយកនគរធំបានក្នុងលើកទី ២

(គ.ស ១៣៩៤)

-ព្រះធម្មសោកា ជាព្រះរាជបុត្រនៃព្រះលំពង្សរាជា ។

www.budinst.gov.kh www.elibraryofcambodia.org

-កាលចុងរាជ្យព្រះអង្គ (គ.ស ១៣៩៤) សៀមលើកទ័ពមកព័ទ្ធបន្ទាយនគរធំម្តងទៀត ឡោំង ៧ ខែស្លាប់អស់សេនារេហ៍ពលជាច្រើន តែវាយយកនគរធំពុំបានឡើយ លុះតែប្រើឧបាយមួយយ៉ាងធំ ហើយដោយមានមេទ័ពខ្មែរក្បត់ពីរនាក់ចូលនឹងគំនិតសៀមនោះផង ទើបសៀមទំលាយទ្វារបន្ទាយនគរធំពីខាងលិច បានចូលមកលុកច្បាំងកាប់ចាក់គ្នាក្នុងក្រុង ហើយឯព្រះបាទធម្មសោកាក៏ទ្រង់សុគតក្នុងសង្គ្រាមនោះទៅ (គ.ស ១៣៩៤) សៀមក៏តាំងនៅនគរធំ ។

-តមកមិនដឹងជាមានរឿងហេតុដូចម្តេច សៀមក៏ថយចេញអស់ពីនគរធំទៅវិញ (ប្រហែលជាមានរឿងហេតុនៅឯប្រទេសសៀម) ហើយនៅឯប្រទេសកម្ពុជាយើងនេះ គេថ្វាយរាជសម្បត្តិមកព្រះស្រីសុរិយោវង្សទី ២ ។

## ព្រះស្រីសុរិយោវង្សទី ២

(ពី គ.ស ១៤០១ ដល់ ១៤១៧)

-ព្រះរាជានេះជាព្រះរាជបុត្រនៃព្រះឧបរាជសុរិយោទ័យ ដែលសុគតក្នុងសង្គ្រាមកាលសៀមវាយយកនគរធំដំបូង ។

❁ ❁ ❁

## សេចក្តីពិស្តារ

ព.ស ១៧៨១ (គ.ស ១២៣៨)

-ព្រះរួងតាំងក្រុងសុខោទ័យ ស្រុកសៀមលើកលែងឡើងក្រុងកម្ពុជា ។

ព.ស ១៨៩៣ (គ.ស ១៣៥០) សៀមតាំងក្រុងអយុធ្យា ក្រោយនោះព្រះចៅរាមាធិបតីទី ១ (អូថោង)កំរើបចិត្តគិតចង់បានក្រុងកម្ពុជាធិបតីឱ្យទៅឡើងក្រុងស្រីអយុធ្យា រវាង ព.ស ១៨៩៥ (គ.ស ១៣៥២) ឱ្យព្រះរាមមេសួនរាជបុត្រជាមេទ័ពព្រះស៊ីសុវត្ថិរាជនត្តាជាទ័ពស្រួចលើកមកវាយក្រុងកម្ពុជា នោះព្រះរាជនិរសជាមហាឧបរាជក្រុងកម្ពុជាលើកព្យុហៈចេញទៅទទួលរណាយុទ្ធ ខាងសៀមបរាជ័យខ្ទេច ព្រះស៊ីសុវត្ថិក្ស័យព្រះជន្មលើកភរាជគជេន្ទ្រ ។

-ទាហានខ្មែរមានជ័យជំនះសៀមប៉ុណ្ណោះហើយមិនរាំងការពារប្រទេស មិនយូរប៉ុន្មាន

www.budinst.gov.kh www.elibraryofcambodia.org

សៀមលើកទ័ពមកជាថ្មីវិញទៀត សៀមតាំងចោមព្រះមហានគរក្រុងកម្ពុជាជាប់១០ខែ។

-មានគ្រោះកាលបណ្តាលហេតុ ផែនដីនឹងឱ្យមានទុក្ខវិនាសទៅផ្សេងៗ ក្នុងខណៈនោះព្រះបាទជាអម្ចាស់ផែនដីក្រុងកម្ពុជាទ្រង់ព្រះប្រឈួន ទ្រង់ព្រះសុរគតក្នុងចំណោម កិច្ចសព្វនោះឮទៅមេទ័ពសៀម ខាងសៀមក៏លើកទ័ពចូលមកកាន់ព្រះមហានគរ ព្រះមហាឧបរាជក្រុងកម្ពុជាជាស្តេចចេញទទួលរណយុទ្ធ ក្ស័យព្រះជន្មក្នុងព្រះរាជសង្គ្រាមយុទ្ធ ។ ខាងសៀមមានជ័យជំនះ កៀរគ្រួខ្មែរយកទៅក្រុងស្យាមជាច្រើន តាំងនាម៉ឺនសៀមឱ្យនៅរវាងក្រុងកម្ពុជាមហានគរ ។

-ក្រោយនោះព្រះស្រីសុរិយោវង្ស ស្តេចខ្មែរតាំងបញ្ចុះបញ្ចូលអស់សេនាទាហានបានច្រើន ក៏ចាត់អស់នាម៉ឺនសៀមចេញពីព្រះមហានគរក្រុងកម្ពុជាធិបតី ហើយរៀបពិធីប្រាបួភិសេកទ្រង់ព្រះនាមព្រះបាទសម្តេចព្រះស្រីសុរិយោវង្សឡើងសោយរាជសម្បត្តិជាអម្ចាស់ផែនដីក្រុងកម្ពុជាមហានគរ ។

ក្រោយនោះរវាង ព.ស ១៩២៨ (គ.ស ១៣៨៥) ព្រះបាទសម្តេចព្រះស្រីសុរិយោវង្ស ស្តេចព្រះរាជដំណើរដោយស្នូទព្យុហ៍ទៅសង្កត់ខែត្រខ្មែរ ដែលសៀមដណ្តើមយកទៅគ្រប់គ្រង ជារបស់សៀមនោះបានមកជាអាណាខែត្រក្រុងកម្ពុជាវិញជាច្រើនខែត្រ . . . ។

រវាងក្រោយមក ព្រះបាទសម្តេចព្រះស្រីសុរិយោវង្ស អម្ចាស់ផែនដីក្រុងកម្ពុជាធិបតី ស្តេចលើកព្យុហ៍ដើម្បីនឹងសងសឹកសៀម តាំងទ័ពនៅស្រុកជលបុរី ។

ខាងសៀមលើកទ័ពទទួលរណយុទ្ធ ខ្មែរនិងសៀមយុទ្ធនាជាសមារថ ខាងសៀមបាញ់កាំភ្លើងមក ត្រូវឆ្នាំងរំសេវឆេះឡើង ភ្លើងរាលដាលពាសពេញ ។

-ព្រះបាទសម្តេចព្រះស្រីសុរិយោវង្ស អម្ចាស់ផែនដីក្រុងកម្ពុជា ស្តេចដោះព្រះអង្គចេញពីចំណោមពួកសេនាទាហានបាក់ទ័ព ខាងសៀមមានជ័យជំនះលើកមកសង្កត់ព្រះមហានគរក្រុងកម្ពុជា ខ្មែរនិងសៀមធ្វើសង្គ្រាមនឹងគ្នា ជាច្រើនមិនឈ្នះមិនចាញ់ សៀមក៏តាំងចោមព្រះមហានគរជាយូរច្រើនខែ ក្រោយមកមានមន្ត្រីខ្មែរក្បត់ចូលនឹងសៀម ខាងសៀមមានជ័យជំនះបែកព្រះមហានគរក្រុងកម្ពុជាធិបតី នោះព្រះបរមរាជាស្យាម តាំងព្រះនគរឥន្ទ្ររាជបុត្រ ឱ្យគ្រងក្រុងកម្ពុជាមហានគរ ហើយកៀរគ្រួខ្មែរយក

www.budinst.gov.kh www.elibraryofcambodia.org

ទៅសៀមជាច្រើន យកទាំងពញា "កែវ" ពញា "ទៃ" មន្ត្រីខ្មែរនិងរូបព្រះគោ រូបសិង្ហ សត្វទៅផងជាច្រើន ។

ព្រះបាទសុរិយោវង្សទី ២ នេះ ទ្រង់សោយរាជសម្បត្តិបាន ១៦ឆ្នាំ ទ្រង់ព្រះរាជសុវណ្ណគត ទ្រង់មានព្រះរាជបុត្រាមួយព្រះអង្គ ព្រះនាម **ព្រះពញាយ៉ាត** ព្រះជន្មទើបបាន ១៧ វស្សា ។

## ព្រះបរមសុខា

(ពី គ.ស ១៤១៧ ដល់ ១៤២០)

-ព្រះរាជានេះជាព្រះភគិនិយោនៃព្រះស្រីសុរិយោវង្សទី ២ ។

-កាលចុងរាជ្យព្រះអង្គ (គ.ស ១៤២០) សៀមលើកទ័ពមកនគរធំម្តងទៀត ព្រះបរមសុខាក៏ទ្រង់សុគតក្នុងសង្គ្រាម សៀមយកនគរធំបានហើយតាំងនៅ លុះដល់រវាង គ.ស ១៤២១ ទើបព្រះពញាយ៉ាត ទ្រង់វាយកំចាត់សៀមបានទៅវិញ ។

**ព្រះបាទត្រសក់ផ្អែម**

→ **ព្រះសិទ្ធានរាជា**

→ **ព្រះស្រីសុរិយោទ័យ**

→ **ព្រះស្រីសុរិយោវង្សទី ២**

→ **ព្រះបាទពញាយ៉ាត**

## ព្រះបាទសម្តេចព្រះពញាយ៉ាត

(ពី គ.ស ១៤២១ ដល់ ១៤៦២)

**ក្រុងចតុមុខ**

www.budinst.gov.kh www.elibraryofcambodia.org

-ព្រះបាទពញាយ៉ាត កាលបើទ្រង់វាយកំចាត់សៀមចេញពីនគរធំបានហើយ ទ្រង់ក៏ឡើងគ្រងរាជសម្បត្តិនៅនគរធំ (ឥន្ទបត្ត) បានជិត ៥ឆ្នាំ ទ្រង់ព្រះដំរិះឈ្វេងថានៅជិតសៀមពេក (រាជធានីសៀមនៅក្រុងអយុធ្យា ឬជាក្រុងទេព-ណាងស្នោ) ក៏ទ្រង់ផ្លាស់រាជធានី ពីនគរធំមកតាំងនៅទួលបាសាន ស្រុកស្រីសន្ធរ (ស្រីសឈរ) ពីព្រោះឈ្វេងថាមានទន្លេមេគង្គរាំងផ្លូវសៀម ហើយជាស្រុកដែលទ្រង់ធ្លាប់គង់នៅផង កាលមុនស្តេចទៅវាយកំចាត់សៀមនោះ ។ ទ្រង់គង់នៅទួលបាសានបានរវាងមួយឆ្នាំ ទ្រង់ផ្លាស់មកគង់នៅចតុមុខ ដែលសព្វថ្ងៃហៅថាភ្នំពេញ ពីព្រោះទួលបាសានទឹកជំនន់លិចក្នុងរដូវវស្សា ។

ឯក្រុងថ្មីនេះដោយស្ថិតនៅទីដ៏ប្រសើរដូច្នេះ ពុំយូរប៉ុន្មានក៏បានឡើងទៅជាកំពង់ជំនួញមួយយ៉ាងសំខាន់ មានចិននិងជ្វាមកនៅពាសពេញ ។

ព្រះបាទសម្តេចព្រះពញាយ៉ាតទ្រង់គ្រងរាជ្យបាន ១២ឆ្នាំ ទើបទ្រង់ទទួលព្រះរាជាភិសេក ។

ព្រះបាទពញាយ៉ាត ស្តេចបានចាត់ព្រះរាជទូតឱ្យនាំសារជាដីរ និងវត្ថុឯទៀតដ៏ប្រសើរទៅថ្វាយស្តេចស្រុកចិន ។

ឯភ្នំពេញសព្វថ្ងៃមិនមែននៅចាប់តាំងពីកាលនោះមកទេ មានចាកចោលទៅវិញក្នុងរាជ្យស្តេចក្រោយ ទើបតែព្រះបាទសម្តេចព្រះនរោត្តម ទ្រង់ស្តេចយាងមកនៅគង់វិញ (ក្នុង គ.ស ១៨៦៧) ហើយជាប់រហូតមកដល់សព្វថ្ងៃ ។

ព្រះនរាយណ៍រាមាធិបតី (ពីគ.ស ១៤៦២ ដល់ ១៤៦៧) ព្រះនរាយណ៍រាមាធិបតី ជាព្រះរាជបុត្រច្បងនៃព្រះបាទពញាយ៉ាត សោយរាជសម្បត្តិពីព្រះវររាជបិតា ហើយទ្រង់គង់នៅចតុមុខដដែល បាន ៥ ឆ្នាំទ្រង់ព្រះរាជសុវណ្ណគត ។

**ព្រះស្រីរាជា** (ពី គ.ស ១៤៦៧ ដល់ ១៤៧៤)

**ព្រះសុរិយោទ័យ** (ពី គ.ស ១៤៦៨ ដល់ ១៤៧៤)

**ព្រះធម្មោរាជាធិ ១** (ពី គ.ស ១៤៦៨ ដល់ ១៤៩៨)

ព្រះនរាយណ៍រាមាធិបតី ទ្រង់ព្រះរាជសុវណ្ណគតទៅ ព្រះរាជអនុជព្រះនាមស្រី

www.budinst.gov.kh www.elibraryofcambodia.org

រាជាសោយរាជ្យស្នង ប៉ុន្តែទ្រង់សោយរាជ្យបានរវាងតែមួយឆ្នាំ ព្រះភគ អង្គព្រះនាមព្រះសុរិយោទ័យជាព្រះរាជបុត្រនៃព្រះនរាយណ៍រាមាធិបតី ប ទ័ពមកច្បាំងដណ្ដើមយករាជសម្បត្តិ ទទួលពេលនោះសៀមក៏លើកទ័ពមក [illegible]ទៅ ខែត្រខាងលិចដែរ ព្រះស្រីរាជាទ្រង់លើកទ័ពទៅច្បាំងនឹងសៀម ទុកងារឱ្យព្រះអនុជ ព្រះនាមព្រះធម្មោរាជាច្បាំងនឹងព្រះសុរិយោទ័យ លុះព្រះស្រីរាជាទ្រង់មានជ័យជំនះលើ សៀមហើយ ទ្រង់ត្រឡប់មកយករាជសម្បត្តិវិញ ព្រះធម្មោរាជាមិនព្រមថ្វាយ រួចក៏ បែកព្រះនគរជាបីផ្នែក ព្រះធម្មោរាជាគង់នៅក្រុងចតុមុខយកទៅខាងលិច តាំងពីខែត្រ សំរោងទង (កំពង់ស្ពឺ) រហូតដល់ឈូងសមុទ្រសៀម ឯខាងកើតនិងខាងត្បូងតាំងពី កោះស្លាកែត ដែលនៅជាកណ្ដាលនៃទន្លេក្រៅ (ទន្លេមេគង្គផ្នែកក្រោមភ្នំពេញ) និងទន្លេក្នុង (គឺទន្លេបាសាក់ឬទន្លេមាត់ជ្រូក) ចាប់តាំងពីល្វាឯមរហូតដល់ព្រៃនគរ ព្រមទាំងពាមកញ្ជើរផង (គឺដល់សមុទ្រខាងត្បូង) ។

ឯព្រះស្រីរាជាទ្រង់គង់នៅស្រុកបរិបូរ (អាមរបុរៈ) ទ្រង់យកជាព្រះរាជអាណា ចក្រនៃព្រះអង្គ ត្រើយខាងលិចនៃទន្លេមេគង្គ តាំងពីខេត្តកំពង់ឆ្នាំងទៅខាងលិចទល់ នឹងប្រទេសសៀម ខាងជើងរហូតដល់ព្រមទាំងខែត្រស្ទឹង ខាងជើងភ្នំដងរែក ។

រីឯព្រះស្រីសុរិយោទ័យគង់នៅស្រុកស្រីសន្ធរ យកខែត្រផ្នែកខាងកើតទន្លេមេគង្គ ទាំងអស់ រហូតដល់ម្លូងណៃ(ដូណៃ) បារៀទល់នឹងប្រទេសចាម លើកតែខែត្រល្វាឯម និងព្រៃនគរ ជារបស់ព្រះធម្មោរាជា ។

**អំពីកិច្ចការណ៍ពីងសៀមជាដំបូង** : ព្រះធម្មោរាជា ព្រះរាជាទាំងបីព្រះអង្គដែល ចែកព្រះនគរជាបីផ្នែក រាជាណាចក្រនេះនៅមិនបានសុខយូរទេ បានប្រមាណតែបីឆ្នាំ ពីព្រោះព្រះធម្មោរាជាមានព្រះរាជសព្វអក្សរទៅដល់សៀម សុំឱ្យមកជួយឧបត្ថម្ភ ដើម្បី ផ្ដាច់យកនគរឱ្យបានមូលមកលើព្រះអង្គមួយ ស្ដេចសៀមក៏លើកទ័ពចូលមកក្រុងកម្ពុជា ភ្ជាមព័ទ្ធអញ្ជើញយកព្រះស្រីរាជានិងព្រះសុរិយោទ័យ នាំយកទៅស្រុកសៀម ទុកតែ ព្រះធម្មោរាជាមួយព្រះអង្គ សោយរាជសម្បត្តិជាម្ចាស់ផែនដីប្រទេសកម្ពុជា (គ.ស ១៤៧៤) ។

-ព្រះធម្មោរាជាអស់មានសេចក្ដីបារម្ភអ្វីទៀតឡើយ ក៏ទ្រង់ប្រារព្ធគ្រប់គ្រងផែនដី

www.budinst.gov.kh www.elibraryofcambodia.org

ដោយនូវព្រះរាជធម៌ ។

-ព្រះធម្មោរាជាទ្រង់មានវិជ្ជាជ្រៅជ្រះណាស់ ក្នុងព្រះត្រៃបិដកទ្រង់គោរពបូជាក្នុងព្រះសិរីរតនត្រៃណាស់ ទ្រង់បានសាងព្រះវិហារព្រះចេតិយ នូវប្រាសាទនៅភ្នំសន្ទុក (ក្នុងស្រុកសន្ទុកខែត្រកំពង់ធំសព្វថ្ងៃ) បូជាព្រះសិរីរតនត្រៃ ហើយទ្រង់អោយសាងសាលាទានទៀតផង សំរាប់ធ្វើទានឱ្យអ្នកក្រីក្រលំបាក ។

-នៅក្នុងរាជ្យព្រះបាទធម្មោរាជា គេទាក់បានដំរីសមួយនៅខែត្រពោធិសាត់ មកថ្វាយព្រះអង្គ ។

៚ ៚ ៚

## សេចក្ដីពិស្ដារ

-ព្រះបាទពញ្ញាយ៉ាត ព្រះរាជបុត្រព្រះបាទសម្ដេចព្រះស្រីសុរិយោវង្ស តាំងបញ្ចុះបញ្ចូលអស់មុខមន្ត្រី សេនាទាហានបានច្រើនទ្រង់ប្រារព្ធរកទីជ័យភូមិនិងតាំងក្បួនពិជ័យសង្គ្រាម ឃើញថាស្រុកស្រីសឈរជាទីមួនមាំ ក៏ស្ដេចមកតាំងនៅទីនោះ ទើបត្រាស់ប្រើក្បារកមនុស្សឱ្យធ្វើឧបាយកលចូលទៅនៅគាល់បំរើ ស្ដេចសៀមនោះមានមហាតលិកពីរនាក់ ទទួលព្រះរាជអាសានាំស៊ុំគ្រប័ក្ខពួក ១២នាក់ ចូលថ្វាយខ្លួននៅគាល់បំរើព្រះឥន្ទ្ររាជា មាននិកាសខ្មែរ ១២នាក់ លុកព្រះឥន្ទ្ររាជា ស្ដេចសៀមក្ស័យព្រះជន្មទៅព្រះបាទពញ្ញាយ៉ាត ស្ដេចលើកកងទ័ពតាមពួកមហាតលិក ចូលចោមព្រះមហានគរនោះពួកខ្មែរក្នុងព្រះនគរបះកាប់សំលាប់ពួកសៀមស្លាប់អស់ជាច្រើន ហើយបើកទ្វារព្រះមហានគរចេញទទួលព្រះពញ្ញាយ៉ាត អញ្ជើញស្ដេចឡើងគ្រងរាជសម្បត្តិជាម្ចាស់ផែនដីក្រុងកម្ពុជាមហានគរ ។

ព្រះបាទពញ្ញាយ៉ាត ស្ដេចប្រាបប្រាមអរិន្ទ្ររាជៈភិររាបទាប ហើយរៀបពិធីប្រាព្ធភិសេក ទ្រង់ព្រះនាមព្រះបាទសម្ដេចព្រះបរមរាជាធិរាជរាមាធិបតី ព្រះស្រីសុរិយោវ៉ង្សធម្មិកមហារាជា បរមនាថបរមបពិត្រ ស្ថិតនាព្រះមហាប្រាសាទសិលា មិនយូរប៉ុន្មានទ្រង់ព្រះដំរិះយល់ឃើញថាក្រុងកម្ពុជា មហានគរនេះជារាជបតិប័ក្ស នឹងក្រុងស្រីអយុធ្យា កាលពីដើមមនុស្សម្នាមហាជនមាននៅក្រាសគ្រួនមាំមួន ឥឡូវសៀមវាយយកបាន

www.budinst.gov.kh www.elibraryofcambodia.org

យកទៅច្រើនខែត្រ ។ដែលទៅជារបស់យើង ក៏សៀមផាត់កៀរត្រូវយកទៅអស់ជាច្រើន បើយើងនឹងគិតលើកទ័ពទៅវាយយកខែត្រទាំងនោះមកវិញ ក៏យល់ជាពុំបានដោយយើងទើបនឹងតាំងខ្លួនថ្មី សេនាទាហានមិនល្មមនឹងប្រើការ ស្បៀងអាហារក៏ពុំបរិបូណ៌ បើប្រសិនខាងសៀមលើកទ័ពមកទៀត នឹងយកខែត្រណាជារបាំងក្រៅនោះគ្មានផ្ទះ នឹងតិតថយពីក្រុងទៅស្អាងក្រុងឯខែត្រស្រីសឈរ បើជាសៀមលើកទ័ពមកនឹងបានចាត់ចេញទទួលតាមរយ:ខែត្រ ។

ឯអស់សេនាបតី មន្ត្រីខ្ញុំរាជការក្រាបថ្វាយបង្គំព្រមតាមព្រះរាជបរិហារ ទើបត្រាស់បង្គាប់ក្រសួងមេកងការឱ្យមកស្អាងព្រះរាជវាំង នៅទីទួលបាសានក្នុងខែត្រស្រីសឈរ លុះស្អាងព្រះរាជវាំងទំនាបមួយស្រេចហើយ ហោរាថ្វាយពិជ័យឫក្សឧត្តមព្រះបាទសម្តេចព្រះព្រះបរមរាជា ចៅពញាយ៉ាត ស្តេចព្រះរាជដំណើរចេញចាកប្រាសាទរតន៍សិលា ចុះព្រះទីនាំងនាវាព្រមអស់ព្រះបរមរាជវង្សានុវង្ស ចតុស្តម្ភ ខ្ញុំព្រះរាជការសេនា :

ព្រឹទ្ធាមាត្យបាទបរិចារ បារគូបុរោហិតហោរាចារ្យ តាមហែរស្តេចព្រះរាជដំណើរដល់ខែត្រស្រីសឈរ ប្រថាប់ទីព្រះរាជវាំងកាត់ទួលបាសាន ត្រាស់បង្គាប់ឧកញ៉ាតេជោបុរាជ ចៅហ្វាយខែត្រកំពង់ស្វាយឱ្យកេណ្ឌរាស្ត្រស្អាងនៅទីទន្លេចតុមុខខេត្តភ្នំពេញយកដីទៅចាក់ទីព្រះរាជវាំងខ្វះ ទៅចាក់ទីមុខភ្នំពេញខ្វះឱ្យខ្ពស់ កុំឱ្យទឹកឡើងលិច ទីដែលជីកនោះជ្រៅទៅជាបឹង សទ្ធតហៅថាបឹងតេជោ ជាប់នាមមកដល់ឥឡូវនេះ ហើយជីកព្រែកជំរងទឹកទុកនៅក្នុងព្រះបរមរាជវាំង សំរាប់ខ្ញុំព្រះរាជការខាងក្នុងប្រើខ្ចបព្រាំងខ្ចបវស្សា ព្រែកនោះពាក្យសាមញ្ញហៅថាព្រែកពាមផ្ទុង រហូតមកទើបចាក់ដីលុបក្នុង គ.ស ១៩៣០ នេះឯង ។

ព្រះបាទសម្តេចព្រះបរមរាជា ចៅពញាយ៉ាតទ្រង់ព្រះជរាប្រទានព្រះរាជនិរសាធិរាជព្រះនារាយណ៍រាជារាមាធិបតី ។

ព្រះបាទសម្តេចព្រះនារាយណ៍រាជារាមាធិបតី ទ្រង់ព្រះសុវណ្ណគតទៅ រាជសម្បត្តិផ្លូវបានព្រះស្រីសុរិយោទ័យ ព្រះរាជនិរសនៃព្រះបាទសម្តេចព្រះនារាយណ៍រាជា នោះព្រះស្រីរាជា ជាព្រះរាជបិតុលាផតើ្តមយករាជសម្បត្តិ ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះស្រីសុរិយោទ័យ ព្រះរាជឱរសាធិរាជ នៃព្រះបាទសម្តេចព្រះនារាយណ៍រាជាធិរាជរាមាតាំងឡើងជាអម្ចាស់ផែនដីផ្នែកត្រើយខាងកើត ។

ក្រោយទៀតតាំងឡើង ជាអម្ចាស់ផែនដីបីព្រះអង្គ គឺព្រះស្រីរាជា ព្រះស្រីសុរិយោទ័យ ព្រះធម្មរាជា :

ដើមឡើយព្រះស្រីរាជា ព្រះបិតុលាដណ្តើមយករាជសម្បត្តិពីព្រះស្រីសុរិយោទ័យជាព្រះភាគនិយោ ។

ព្រះធម្មរាជា ជាព្រះរាជអនុជដណ្តើមយករាជសម្បត្តិពីព្រះស្រីរាជា ជាព្រះរៀមឯព្រះធម្មរាជាព្រះមាតាសៀមជាប់វង្សនឹងសៀមពីងឱ្យជួយ ។

**សម្តេចក្សត្រិយ៍ មាលិកា**

ព្រះបាទធម្មរាជាទ្រង់សោយរាជសម្បត្តិរហូតដល់ គ.ស ១៤៩៨ ទ្រង់ព្រះរាជសុវណ្ណគតទៅ ព្រះអដ្ឋិព្រះអង្គ ដំកល់នៅក្នុងព្រះចេតិយភ្នំសន្ទុក ជិតព្រះវិហារនិងព្រះចេតិយដែលទ្រង់សាងបូជាព្រះរតនត្រ័យ ។

## ព្រះបាទសុគន្ធបទ

(ពី គ.ស ១៤៩៨ ដល់ ១៥០៥)

ព្រះបាទធម្មរាជា ព្រះរាជសុវណ្ណគតទៅ ព្រះរាជបុត្រច្បងនៃព្រះអង្គនាមព្រះស្រីសុគន្ធបទ សោយរាជសម្បត្តិតមក ។

ព្រះបាទស្រីសុគន្ធបទ នៅពេលក្រោយបន្តិចដែលទ្រង់ទទួលព្រះរាជាភិសេកទ្រង់ស្តេចទៅគង់ឯទួលបាសាន ដំណែលចាស់នៃព្រះរាជអយ្យកោ (ព្រះបាទពញាយ៉ាត) ។ ព្រះរាជអនុជនាមព្រះអង្គចន្ទ គង់នៅចតុមុខ ។

ក្នុងរាជ្យព្រះស្រីសុគន្ធបទ មានបះបោរមួយជាយួរអង្វែង ហៅថាបះនាយ "កន" នាយកននេះជាពលព្រះហើយគាប់នឹងស្តេចអម្ចាស់ផែនដីណាស់ (ព្រះសុគន្ធបទ) ទ្រង់ព្រះរាជទានងារជា "ហ្លួងព្រះស្តេច" ចាងហ្វាងសម្បុកាវី ត្រួតលើពលព្រះ ។ ហ្លួងព្រះស្តេចកន បញ្ចេញអំណាចខ្លាំងពេកអស់នាម៉ឺនសព្វមុខមន្ត្រីក្តៅក្រហាយ ក៏រករឿងបង្ខុសទូលស្តេចឱ្យយកទោសដល់ជីវិត ហ្លួងព្រះស្តេចកនដឹងខ្លួនក៏រត់រួច ទៅ

www.budinst.gov.kh www.elibraryofcambodia.org

ប្រមូលកងទ័ពបានជាច្រើន លើកយកមកច្បាំងនឹងព្រះស្រីសុគន្ធបទ ទ័ពហ្លួងព្រះស្ដេចកនមានជ័យជំនះសឹងតែគ្រប់អន្លើ ដល់ក្រោយបំផុត ហ្លួងព្រះស្ដេចកនធ្វើគតព្រះស្រីសុគន្ធបទបាន ហើយតាំងខ្លួនជាស្ដេចឡើងហៅថា ស្ដេចកនបាន ១០ឆ្នាំ គឺតាំងពីឆ្នាំ ១៥០៥ ដល់ឆ្នាំ ១៥១៥ ។

ព្រះបាទអង្គចន្ទទី ១ (១៥១៥-១៥៥៥) កាលគ្រានោះព្រះអនុជព្រះស្រីសុគន្ធបទ គឺព្រះអង្គចន្ទ ដែលស្ដេចដោះព្រះអង្គពីចតុមុខទៅគង់នៅឯស្រុកសៀម ដោយឱបាយស្ដេចកនទោះ ទ្រង់លើកទ័ពមកច្បាំងនឹងស្ដេចកន កាប់សំលាប់គ្នាជាច្រើន ឆ្នាំរួចដល់នឹងសំរេចព្រះអង្គចន្ទទ្រង់សំលាប់ស្ដេចកនបានក្នុងបន្ទាយស្រឡប់(ក្នុងស្រុកបាភ្នំពី គ.ស ១៥១៥) ។

-ព្រះអង្គចន្ទក៏ទ្រង់ឡើងសោយរាជសម្បត្តិ ។

## ព្រះបាទអង្គចន្ទទី ១

(ពី គ.ស ១៥១៥ ដល់ ១៥៥៥)

កាលព្រះបាទអង្គចន្ទទ្រង់បានសោយរាជសម្បត្តិ ហើយក្រោយបន្តិចស្ដេចសៀមចាត់សាររាជទូតឱ្យមកទារដំរីស ដែលមានមកតាំងអំពីរាជព្រះបាទធម្មរាជា ទ្រង់ពុំព្រមឱ្យដំរីសនោះ ។

៖ ៖ ៖

**សេចក្ដីពិស្ដារ** - ព្រះបាទសម្ដេចព្រះស្រីសុគន្ធបទ ជាម្ចាស់ផែនដីប្រទេសកម្ពុជាទ្រង់សព្វព្រះរាជហឫទ័យនឹងស្រីម្នាក់ជាកូនស្រីពីជ័យនាត ជានាយពលទ្រង់លើកឡើងជាព្រះស្នំឯក មានរាជបុត្រមួយព្រះអង្គ ឯនាងព្រះស្នំនេះមានប្អូនប្រុសមួយឈ្មោះនាយកន ថ្វាយខ្លួនធ្វើជាខ្ញុំព្រះរាជការ ព្រះបាទជាម្ចាស់ផែនដីទ្រង់ព្រះមេត្តាប្រោសតាំងនាយកន ឱ្យធ្វើងារជាហ្លួងព្រះស្ដេចចាងហ្វាងព្រះរាជសម្បត្តិ ស្ដីត្រួតត្រាលើពលព្រះ ។

ក្រោយនេះហ្លួងព្រះស្ដេច "កន" ប្រែចិត្តគិតក្បត់រត់ចេញពីក្រុងទៅបញ្ចុះបញ្ចូលរាស្ត្រខែត្រក្រៅ ឯនាងព្រះស្នំជាបង ប្រើបំរើចេញទៅនិយាយបញ្ចុះបញ្ចូលហ្លួងព្រះ

www.budinst.gov.kh www.elibraryofcambodia.org

ស្តេច ឱ្យចូលមកធ្វើរាជការដូចដែលវិញ នោះហ្លួងព្រះស្តេច "កន" ទទួលនឹងចូលមកធ្វើរាជការវិញ តែមិនបានចូលមក នាងព្រះស្នំប្រើបំរើឱ្យទៅនិយាយជាច្រើនផង ហ្លួងព្រះស្តេចចេះតែនិយាយបណ្តោះបណ្តែ ពុំទាន់ហ៊ានក្បត់ពេញមុខនៅឡើយ ដោយគិតញញើតទៅសម្តេចព្រះអនុជាធិរាជចៅពញាចន្ទ្រ ជាស្តេចធំមានព្រះប្រីជាឈ្លាសវៃនៃរាជកិច្ចផ្សេងៗ ហើយអស់ពួកមន្ត្រីខុំព្រះរាជការធំ-តូច ក៏ចុះចូលកោតញញើតជាច្រើន ទើបហ្លួងព្រះស្តេច "កន" ប្រើឧបាយផ្សាយពាក្យថា : ព្រះបាទជាអម្ចាស់ផែនដីទ្រង់ជ្រាបថា ពួកចៅហ្វាយស្រុកខែត្រក្រៅ គិតក្បត់ចូលនឹងចៅពញាចន្ទ្រ ជាព្រះអនុជគិតដណ្តើមរាជសម្បត្តិ បានជាទ្រង់ត្រាស់ ប្រើហ្លួងព្រះស្តេចឱ្យចេញមករកកេណ្ឌកងទ័ព លើកទៅចាប់ព្រះរាជអនុជចៅពញាចន្ទ្រ ហើយថានឹងលើកចៅពញាយសរាជាជាព្រះឱរស ជាគួយហ្លួងព្រះស្តេចកននោះ ឱ្យឡើងសោយរាជសម្បត្តិ ជាម្ចាស់ផែនដីក្រុងកម្ពុជា ? ។

ក្រោយនោះហ្លួងព្រះស្តេច "កន" ឱ្យធ្វើព្រះរាជប្រកាសជាសេចក្តីព្រះករុណាជាអម្ចាស់លើត្បូងត្រាស់បង្គាប់ឱ្យហ្លួងព្រះស្តេច "កន" ចេញទៅជាមេកងឱ្យលើកទ័ពទៅធ្វើគត សម្តេចព្រះអនុជចៅពញាចន្ទ្រ បើឈ្មោះណាទទួលយកអាសា ចាប់ព្រះអនុជចៅពញាចន្ទ្របាន នឹងឱ្យរង្វាន់ជាមាសមួយរយដំឡឹង ហើយហ្លួងព្រះស្តេច "កន" តាំងមេកងឱ្យចេញទៅសង្កត់រាស្ត្រខែត្រក្រៅ ។ ឯខុំរាជការនូវអស់ប្រជានុរាស្ត្រ បានឮថាមានប្រកាសដូច្នោះ ក៏យល់ថាជាមែន ហើយស្រដីខ្សឹបខ្សៀវគ្នា ពាក្យនោះរឹងរឹតតែឮទូទៅទាំងព្រះនគរ បវររាជធានី ។

ឯសម្តេចព្រះអនុជចៅពញាចន្ទ្រ បានទ្រង់ជ្រាបហេតុដូច្នោះ ក៏ទ្រង់ព្រះចិន្តាថាពាក្យដែលឮនេះប្រហែលជាមែន បានជាសម្តេចព្រះជេដ្ឋាធិរាជទ្រង់ព្រះសណ្ឋិតស្ងៀមទើបទ្រង់ព្រះដំរិះថា នឹងនៅឱ្យទើសទាស់ចិត្ត ដើរចេញឱ្យស្រឡះទៅជាជាង ទ្រង់ព្រះចិន្តាដូច្នោះហើយ ស្តេចក៏នាំអស់មហាតលិក ៥០ នាក់ ដោះព្រះអង្គចេញពីក្រុងភ្នំពេញចតុមុខស្វែស្វតទៅក្រុងស្រីអយុធ្យា ។

ឯហ្លួងព្រះស្តេច "កន" បានដឹងថាសម្តេចព្រះរាជអនុជចៅពញាចន្ទ្រ ស្តេចចេញពីព្រះនគរក្រុងកម្ពុជា ក៏មានសេចក្តីអំណរទើបប្រឹក្សានឹងនាយទ័ពនាយកង កាល

www.budinst.gov.kh www.elibraryofcambodia.org

ពីដើមយើងគិតញញើត តែចៅពញាចន្ទ្រអង្គមួយនេះ ក្រៅពីនោះមិនឃើញនរណានឹងហ៊ានក្លាចេញតាំងតនឹងយើងបានឡើយ ។

តាំងអំពីនោះមកហ្លួងព្រះស្តេច "កន" ក៏កំរើបចិត្តគិតឡើងក្សត់ពេញមុខ លើកទ័ពទៅច្បាំងនឹងម្ចាស់ផែនដី ដេញស្តេចពីព្រះបរមរាជវាំង ហើយលើកតាមទៅធ្វើគតប្ដូងព្រះជន្មអម្ចាស់ផែនដីនៅតំបន់ស្ទឹងសែន ក្នុងខែត្រកំពង់ស្វាយ ។

ឯហ្លួងព្រះស្តេច "កន" តាំងខ្លួនឡើងជាស្តេចម្ចាស់ផែនដី តាំងទីក្រុងនៅចុងខែត្រស្ទឹងឃ្មុំ ទល់នឹងខែត្របាភ្នំ រីឯសម្តេចព្រះអនុជចៅពញាចន្ទ្រដែលគង់នៅក្រុងស្រីអយុធ្យា បានទ្រង់ជ្រាបថាហ្លួងព្រះស្តេច "កន" ក្សត់ប្ដូងព្រះជន្ម ព្រះបាទសម្តេចព្រះជេដ្ឋាធិរាជសោយទីវង្គតទៅហើយ ទើបស្តេចថ្វាយបង្គំលាព្រះចៅក្រុងស្យាមនឹងស្តេចមកក្រុងកម្ពុជា នោះព្រះបាទសម្តេចព្រះចៅចក្រពត្តិ ពុំព្រមបើកឱ្យស្តេចចេញមក ។

ក្រោយនោះចៅពញាចន្ទ្រ ទ្រង់ព្រះដំរិះថា ធ្វើឧបាយឱ្យឃើញថាមានមង្គលហត្ថី (ដំរីស) បរិសុទ្ធកើតក្នុងព្រៃប្រទល់ដែនក្រុងកម្ពុជា មានសំបុត្រចៅហ្វាយស្យាមខែត្រខាងឯកើត បកចូលទៅក្រុងស្រីអយុធ្យាថា : បានឃើញដានដំរី ហើយមានរោមដំរីជ្រុះជាប់ជាច្រើនអន្លើ ។ ព្រះបាទសម្តេចព្រះចៅចក្រពត្តិ ម្ចាស់ផែនដីក្រុងស្រីអយុធ្យា បានទ្រង់ជ្រាបហេតុដូច្នោះ ទើបប្រជុំអស់សេនាបតីយល់ឃើញថា គួរតែប្រើឱ្យចៅពញាចន្ទ្រចេញទៅទាក់ដំរីស ថាឡើតចៅពញាធ្លាប់ទាក់ដំរីបានពីគ្រាមុនមកស្រេចហើយ ព្រះចៅចក្រពត្តិត្រាស់សួរទៅចៅពញាចន្ទ្រ នោះចៅពញាចន្ទ្របាននិកាស (ពេញបំណង) ហើយក៏ទទួលអាសាចេញទាក់ដំរី សុំពល ៥០០ នាក់ នឹងព្រះសែងដាវស្រោមមាសមួយ? ឱ្យស្តេចចេញទាក់ដំរីល្អចំឡែក . . . ។

ចៅពញាចន្ទ្រស្តេចចេញពីក្រុងស្រីអយុធ្យា ស្រូតស្រូតមកប្រជុំកងទ័ពនៅបន្ទាយស្វាយ ហើយហួសមកបញ្ចុះបញ្ចូលខែត្រពោធិសាត់-បរិបូណ៌និងខែត្រគ្រើយខាងលិចបានព្រមចូលហើយរៀបពិធីសង្គ្រាមសេកសន្ទតិ ព្រះនាមហៅថាព្រះច័ន្ទ្ររាជា តាំងធ្វើសង្គ្រាមនឹងស្តេច "កន" ជាង ៤ ឆ្នាំ ។

ព្រះច័ន្ទ្ររាជាប្រាបប្រាមស្តេច "កន" មានជ័យជំនះ ហើយរៀបពិធីប្រាប្តាភិសេក

www.budinst.gov.kh www.elibraryofcambodia.org

ទ្រង់ព្រះនាមថា "ព្រះបាទសម្តេចព្រះបរមរាជាធិរាជ រាមាធិបតីព្រះស្រីសុរិយោពម៌ាមហារាជា" តាំងទីក្រុងនៅលង្វែក ក្រោយមកស្តេចទាក់ដំរីសបាន ព្រះចៅចក្រពត្តិក្រុងស្រីអយុធ្យាមានសុភអក្សរ មកសុំដំរីស ព្រះបាទសម្តេចព្រះបរមរាជាចៅពញាច័ន្ទ្រ មិនព្រមថ្វាយដំរីស . . . ។

ក្រោយនោះទៀតព្រះចៅចក្រពត្តិក្រុងស្រីអយុធ្យា មានសុភអក្សរបង្គាប់មកឱ្យក្រុងកម្ពុជានាំសួយទៅថ្វាយ នោះព្រះបាទសម្តេចព្រះបរមរាជាចៅពញាច័ន្ទ្រ ពុំព្រមថ្វាយសួយ ព្រះចៅចក្រពត្តិទ្រង់ព្រះពិរោធន៍ ត្រាស់បង្គាប់ឱ្យលើកទ័ពមកច្បាំងតាំងនៅខែត្រសៀមរាប ព្រះបាទសម្តេចព្រះបរមរាជាចៅពញាច័ន្ទ្រ អម្ចាស់ផែនដីក្រុងកម្ពុជា ស្តេចលើកអស់សេនាទាហានចេញទៅទទួលច្បាំងក្នុងខែត្រសៀមរាប ខាងសៀមបរាជ័យ លើកទ័ពត្រឡប់ទៅវិញ ។

ក្រោយនោះព្រះចៅចក្រពត្តិក្រុងស្រីអយុធ្យា ត្រាស់ប្រើពញារាជវាំងសាន់ ឱ្យលើកទ័ពជលមាគ៌ ត្រាស់ប្រើចៅពញានងសវណ្ណគលោក្យ ជាព្រះរាជបុត្រព្រះបាទសម្តេចព្រះស្រីរាជាស្តេចខ្មែរ ដែលព្រះចៅចក្រពត្តិយកធ្វើជាព្រះរាជបុត្របុញ្ញធម្ម និងពញាមហាមន្ត្រី ឱ្យលើកទ័ពស្ថលមាគ៌ ចេញពីក្រុងស្រីអយុធ្យា ។

ព្រះបាទសម្តេចព្រះបរមរាជាចៅពញាច័ន្ទ្រ ស្តេចលើកព្យុហៈរាជគជេន្ទ្រ ចេញពីក្រុងលង្វែកទៅទទួលរណយុទ្ធនៅខែត្រពោធិសាត់ នោះព្រះអង្គសវណ្ណគលោក្យក្ស័យព្រះជន្ម លើករាជគជេន្ទ្រខាងសៀមបរាជ័យ ឯពញារាជវាំងសាន់ ជាមេទ័ពសៀមជលមាគ៌ លើកទ័ពមកប្រទះច្បាំងនឹងទ័ពឧកញ៉ាក្រឡាហោមនោះ រេហ៍ពលសៀមស្លាប់អស់ជាច្រើន ក៏បាក់ទ័ពត្រឡប់ទៅវិញ ។

ព្រះបាទសម្តេចព្រះរាជាចៅពញាច័ន្ទ្រ ទ្រង់មានជ័យជំនះលើទ័ពសៀម ហើយត្រាស់បង្គាប់ឱ្យប្រដាប់គារព្រះមេរុ ប្រទានភ្លើងព្រះសព រួចហើយមានពិធីឆ្លងសម្ពោធព្រះអដ្ឋិ យកពាទព្រះស្រីមាស ព្រះរាជទ្រព្យ ព្រះអង្គសវណ្ណគលោក្យជាព្រះរៀមមួយ ទ្រង់បរិច្ចាគពានព្រះស្រីមាស ព្រះរាជទ្រព្យព្រះអង្គមួយ ស្ថាងព្រះពុទ្ធរូបបដិមាករពីរព្រះអង្គ ទ្រង់បរិច្ចាគព្រះរាជទ្រព្យស្ថាងព្រះវិហារមួយ ព្រះចេតិយមួយព្រះពុទ្ធរូបទាំងពីរព្រះអង្គប្រដិស្ឋានក្នុងព្រះវិហារដែលទ្រង់កសាងនោះ សន្មតនាមវត្តនោះហៅថាវត្ត

www.budinst.gov.kh www.elibraryofcambodia.org

ពោធិ៍មានបុណ្យ តាមសម័យហេតុដើម ថាមានដើមពោធិ៍មួយដើមស្លាប់មកជាយូរ ហើយ ត្រឡប់លូតលាស់សន្ធឹករស់ឡើងវិញ ទ្រង់បរិច្ចាគព្រះរាជទ្រព្យធ្វើបុណ្យឱ្យទានចែករង្វាន់ដល់សេនាទាហាន ដែលនៀយហត់ក្នុងការព្រះរាជសង្គ្រាម ។

**សម្ដេចក្សត្រិយ៍ មាលិកា**

កាលបើដូច្នោះ សៀមក៏លើកទ័ពចូលមកក្នុងនគរខ្មែរ ប៉ុន្តែសៀមចាញ់គ្រប់តែអន្ទើ ហើយត្រឡប់ទៅស្រុកវិញអស់ក្នុងឆ្នាំ ១៥២៨ ។ ដល់រំលង ៥ឆ្នាំក្រោយមកទៀត សៀមលើកទ័ពជាច្រើនតាមមកជើងគោកផង តាមសមុទ្រផង ប៉ុន្តែសៀមចាញ់ទៅទៀត ក្នុងឆ្នាំ ១៥៣៣ ។

អំពីទីលង្វែកឡើងជារាជធានីប្រទេសកម្ពុជា (១៥២៥) ដល់សៀមបាក់ទ័ពទៅស្រុកវិញអស់ហើយ ក្នុងឆ្នាំ ១៥២៨ នោះព្រះអង្គច័ន្ទទ្រង់លើកទីក្រុងមកតាំងនៅលង្វែកវិញ ហើយទ្រង់គង់នៅទីនោះ ពីព្រោះជាទីងាយការពារសត្រូវជាងនៅទីពោធិសាត់ ។

ព្រះអង្គច័ន្ទទ្រង់សោយរាជសម្បត្តិបាន ៤០ ឆ្នាំ មានរាស្ត្រស្រឡាញ់ច្រើនណាស់ ពីព្រោះជាស្ដេចល្អទ្រង់ធម៌ មានព្រះទ័យសប្បុរសជ្រះថ្លាសទ្ធាក្នុងព្រះពុទ្ធសាសនាណាស់ ទ្រង់បានសាងវត្តជាច្រើន ក្នុងព្រះរាជនគរមាននៅឧត្តុង្គជាដើម ។

-ព្រះអង្គទ្រង់ព្រះរាជសុវណ្ណគតក្នុង គ.ស ១៥៥៥ ទ្រង់មានទុកព្រះនាមប្រសើរណាស់ក្នុងព្រះរាជពង្សាវតារ ។

✧ ✧ ✧

## ព្រះបាទសម្ដេចព្រះបរមរាជា

(ពី គ.ស ១៥៥៥ ដល់ ១៥៦៧)

ព្រះរាជានេះជាព្រះរាជបុត្រនៃព្រះបាទសម្ដេចព្រះអង្គច័ន្ទទី ១ សោយរាជសម្បត្តិតពីព្រះវររាជបិតា យកក្រុងលង្វែកដដែលជាព្រះរាជធានី ។

-កាលដើមរាជ្យព្រះអង្គ (ក្នុង គ.ស ១៥៥៧) ជាតិភូមាលើកទ័ពមកវាយលុកប្រទេសសៀម ព្រះបរមរាជា ក៏ទ្រង់ឆ្លៀតយកឱកាសនោះ លើកទ័ពទៅវាយ

www.budinst.gov.kh www.elibraryofcambodia.org

សៀមវិញ យកខេត្តខ្មែរខាងលិច ដែលខ្ញុំបាត់បង់ទៅសៀមនោះមកវិញ មានខេត្តចន្ទបុរ (ចន្ទបុរះឬចន្ទបុរី) និងខេត្តទគរាជ (ត្រាត)ជាដើម ផាក់សេនានាហានខ្មែរមួយចំណែកឱ្យនៅត្រួតត្រាហើយកៀរយកគ្រួខ្មែរនិងសៀម មកប្រទេសកម្ពុជាជាច្រើនពាន់ (៧០ ០០០ នាក់) ។

ព្រះបាទបរមមិន្ទរាជាទ្រង់បានជ័យជំនះលើជាតិលាវទៀត ហើយទ្រង់ចាប់យកលាវជាឈ្លើយបានច្រើនពាន់នាក់ ដាក់ឱ្យនៅក្នុងស្រុកបារាយ (ក្នុងខេត្តកំពង់ធំសព្វថ្ងៃ) និងស្រុកជើងព្រៃ (ក្នុងខេត្តកំពង់ចាមសព្វថ្ងៃ) គ.ស ១៥៦០ ។

ដល់ក្រោយមកទៀត (ក្នុង គ.ស ១៥៦២) សៀមលើកទ័ពមកច្បាំងប្រាថ្នាកំចាត់សេនាខ្មែរ ដែលនៅត្រួតខេត្តខាងលិច មានខេត្តចន្ទបុរជាដើម ព្រះបរមមិន្ទរាជា ក៏លើកទ័ពទៅតយុទ្ធជាប់ជាអង្វែងកាល សៀមមិនបានសំរេច ក៏សុំចុះព្រមជា (ក្នុង គ.ស ១៥៦៤) ហើយធ្វើសន្ធិសញ្ញារាជមេត្រីនៅ គ.ស ១៥៦៧ ។

**ព្រះសត្ថាទី ១** (ព្រះនាមក្នុងរាជ្យជាព្រះមហាមហិន្ទរាជា ពី គ.ស ១៥៦៧ ដល់ ១៥៧៥)

-ព្រះបាទព្រះបរមមិន្ទរាជា ទ្រង់ព្រះរាជសុវណ្ណគត ពី គ.ស ១៥៦៧ ក្នុងព្រះជន្ម ៥៦ វស្សា ។

ព្រះរាជបុត្រច្បងទ្រង់ព្រះនាមព្រះសត្ថា (ទី១) សោយរាជសម្បត្តិតមក ។ ព្រះរាជអនុជទ្រង់ព្រះនាមព្រះសុរិយោពណ៌ ជាព្រះមហាឧបរាជហើយក្រោយមកជាព្រះឧបយោរាជ ។

នៅក្នុងឆ្នាំដែលព្រះបរមមិន្ទរាជាទ្រង់ព្រះសុវណ្ណគតនោះ (គ.ស ១៥៦៧) ក៏ជាពេលដែលទ្រង់ត្រូវចុះព្រះហត្ថលេខា នៅសន្ធិសញ្ញារាជមេត្រីណាត់អំពីព្រំប្រទល់ប្រទេសទាំងពីរនោះផង ព្រះរាជនិរសមហាឧបរាជព្រះសត្ថាទ្រង់ចុះព្រះហស្តលេខាជំនួស ។

លុះប្រមាណបួនឬប្រាំខែក្រោយ ព្រះបាទសត្ថាទ្រង់ព្រះរាជសម្បត្តិ ព្រះរាជាភូមាទៅក្រុងហង្សាវតី (ក្រុងរង្គូនសព្វថ្ងៃ) លើកទ័ពមកចូលលុកដល់ព្រះរាជធានីសៀម (ក្រុងអយុធ្យា) ព្រះរាជាសៀមក៏មានព្រះរាជសារអត្ថូរាចុះលាយលក្សណ៍ សុំកងទ័ព

www.budinst.gov.kh www.elibraryofcambodia.org

ខ្មែរអោយទៅជួយ ។ ព្រះសត្ថាដោយទ្រង់ឈ្វេងយល់ថា ប្រទេសសៀមនិងប្រទេសខ្មែរទើបនឹងព្រះរាជមេត្រីនឹងគ្នា បើមិនជួយផងនឹងពុំអាចបិតថេរនឹងគ្នាតទៅ ព្រះសត្ថាក៏ទ្រង់ចាត់កងទ័ព ហើយឱ្យព្រះអនុជមហាឧបរាជព្រះស៊ុរិយោពណ៍ ជាស្តេចចមពលនាំទៅជួយសៀម លុះជួយសៀមច្បាំងឈ្នះភូមាហើយ ស្តេចសៀមពុំមានកិត្តិគុណឡើយ មើលងាយព្រះមហាឧបរាជខ្មែរ ព្រះស្រីស៊ុរិយោពណ៌ ទុកដូចជាស្តេចចំណុះ ។

លុះមិនយូរប៉ុន្មាន ព្រះរាជាភូមាលើកទ័ពមកច្បាំងនឹងសៀមទៀត ព្រះសត្ថាទ្រង់បានឱកាសនោះ ក៏ឱ្យលើកទ័ពទៅវាយខែត្រសៀមខាងកើត (គឺខាងលិចប្រទេសកម្ពុជាយើង) កៀរគ្រួខ្មែរសៀមបានមកជាច្រើន ។

## ព្រះបាទជ័យជេដ្ឋាទី ១ ឬព្រះជ័យចេស្តា

(ពី គ.ស ១៥៧៥ ដល់ ១៥៩៣)

## អំពីសៀមវាយយកក្រុងលង្វែកបាន

ក្នុង គ.ស ១៥៩៣

ក្នុង គ.ស ១៥៧៥ ព្រះបាទសុទ្ធាទ្រង់ដាក់រាជសម្បត្តិ ប្រទានមកព្រះរាជបុត្រច្បងនៃព្រះអង្គព្រះនាមព្រះជ័យជេដ្ឋា ព្រះជន្មទើបបាន ១០វស្សា តាំងព្រះរាជបុត្រាអនុជបន្ទាប់ព្រះនាមព្រះពញាតន់ ព្រះជន្ម ៦វស្សាជាព្រះឧបរាជ ដាក់ព្រះអនុជមហាឧបរាជ ព្រះស្រីស៊ុរិយោជាព្រះឧបយោរាជ ហើយទ្រង់យកទីជាព្រះឧបយោរាជ រាជានុសិទ្ធិ ។ កិច្ចដែលដាក់រាជ្យ ប្រទានមកព្រះជ័យជេដ្ឋា ហើយដែលដាក់ព្រះស្រីស៊ុរិយោជាព្រះឧបយោរាជនេះ មាននាម៉ឺនសព្វមុខមន្ត្រីធំជាច្រើនអាក់អន់ចិត្តជាខ្លាំង ពុំសូវយកចិត្តទុកដាក់ធ្វើរាជការឱ្យមាំមួន កាលបើដូច្នេះក៏មានអសន្តិសុខ ចលាចលក្នុងព្រះរាជនគរ ។

សៀមឃើញនគរកម្ពុជាកំពុងតែកើតអសន្តិសុខ ចលាចលដូច្នេះ ក៏ឆ្លៀតក្នុងឱកាសនោះ លើកទ័ពមកច្បាំងវាយចូលមកពន្ធឡោមដល់ក្រុងលង្វែក ប៉ុន្តែវាយយកមិនបាន សៀមចាញ់បាក់ទ័ពត្រឡប់ទៅស្រុកវិញអស់ (គ.ស ១៥៨៣) ។

ដប់ឆ្នាំក្រោយមក (គ.ស ១៥៩៣ ព្រះជ័យជេដ្ឋាព្រះជន្មបាន ២៨វស្សាហើយ)

www.budinst.gov.kh www.elibraryofcambodia.org

សៀមលើកទ័ពយ៉ាងធំអស្ចារ្យ មកច្បាំងនឹងខ្មែរយើងទៀត តាមជើងគោកផង តាមសមុទ្រផង (កាលនោះដែនយួនក្បួសាំងស៊ីទសព្វថ្ងៃនៅជារបស់ខ្មែរយើងទាំងអស់) ។ ឯខ្មែរយើងក៏កេណ្ឌតាំងកងទ័ពធំសម្បើមណាស់ ទៅដាក់ត្រៀមនៅក្របកន្ទែង ព្រះឧបយោរាជស្រីសុរិយោទ្រង់ត្រៀមទ័ពនៅបន្ទាយបរិបូរ ។ ប៉ុន្តែនៅតែចាញ់សៀមគ្រប់អន្លើទៀត ទាំងខាងត្បូង ទាំងខាងជើង ទាំងខាងលិច ។ ពីខាងលិចសៀមវាយផ្ទាយខែត្របាត់ដំបង (ដោយមេកងទ័ពនៅបាត់ដំបងពុំសូវយកចិត្តទុកដាក់ផង) ចូលមកវាយផ្ទាយពោធិសាត់ទៀត រហូតមកដល់បរិបូរ ព័ទ្ធឡោមព្រះឧបយោរាជស្រីសុរិយោ ប៉ុន្តែបានមួយយប់ ព្រះស្រីសុរិយោទ្រង់វាយកាត់ចេញពីបន្ទាយ ដោះព្រះអង្គមកឯបន្ទាយរាជធានីលង្វែក ។ ព្រះសត្ថានិងព្រះជ័យជេដ្ឋា ទ្រង់ដោះព្រះអង្គពីបន្ទាយលង្វែកទៅឯស្រីសន្ធរ រួចទៅឯស្ទឹងត្រែង នៅតែព្រះស្រីសុរិយោការពារក្រុងលង្វែក សៀមលើកទ័ពពីបរិបូរ មកព័ទ្ធឡោមក្រុងលង្វែក ពេលនោះទ័ពខ្មែរតយុទ្ធនឹងសៀមក៏សំបើមណាស់ដែរ ប៉ុន្តែនៅតែចាញ់សៀម សៀមក៏ចូលលុកក្រុងលង្វែក ឡោមឃុំព្រះស្រីសុរិយោនិងព្រះរាជវង្ស នាំទៅឯស្រុកសៀម ។

ព្រះសត្ថានិងជ័យជេដ្ឋាទាំងពីរព្រះអង្គ ទ្រង់ព្រះរាជសុវណ្ណគតនៅស្ទឹងត្រែង(ក្នុង ព.ស ១៥៩៤) ប៉ុន្តែគេយកព្រះអដ្ឋិមកដំកល់ទុកនៅក្នុងចេតិយមួយនៅវត្តសម្បូរ ។

## ពត៌មានកាលសម័យសៀមវាយយកបានបន្ទាយលង្វែក

កាលសៀមវាយយកក្រុងលង្វែកបាននោះ វាចូលលុកក្នុងក្រុង រួចវាដុតភ្លើងឆេះបំផ្លាញអស់ ឯអស់មនុស្សពេញការចំនួន ៩ម៉ឺននាក់ ដែលមាននៅក្នុងខែត្រនោះ ក៏សៀមវាចាប់យកជាឈ្លើយ នាំទៅស្រុកវាអស់ ហេតុនេះបានជាចំណេរគមកបណ្ដាជនខ្មែរខ្វះខ្វាំងពូកែ ។

តាំងពីខូចបន្ទាយលង្វែកមក មហានគរកម្ពុជា ក៏ត្រឡប់ទៅជានគរតូចមួយគេស្ទើរមិនស្គាល់ផង នៅចុងបូព៌ាប្រទេសនេះ ហើយគេទុកជាស្រុកស្វយធគរសៀម ។

⊠ ⊠ ⊠

www.budinst.gov.kh www.elibraryofcambodia.org

**សេចក្តីពិស្តារ** - ព.ស ២១១២ ប.ស ១៩៣០ ឆ្នាំរោងសំរិទ្ធិស័ក ក្រុងហង្សាវតី លើកទ័ពមកវាយក្រុងស្រីអយុធ្យា ។

មានទងត្រាក្រុងស្រីអយុធ្យាមកក្រុងកម្ពុជា សុំកងទ័ពខ្មែរឱ្យទៅជួយក្រុងស្រីអយុធ្យា ច្បាំងនឹងទ័ពក្រុងហង្សាវតី . . .

ព្រះបាទសម្តេចព្រះបរមមហិន្ទ្រា ជាអម្ចាស់ផែនដីក្រុងកម្ពុជា បានទ្រង់ជ្រាបថាកងទ័ពក្រុងហង្សាវតី លើកមកវាយក្រុងស្រីអយុធ្យា ទើបត្រាស់ប្រឹក្សាអស់សេនាបតីថាក្រុងកម្ពុជាធិបតីនិងព្រះនគរក្រុងស្រីអយុធ្យាទើបនឹងជាផ្លូវ ព្រះរាជមេត្រីគ្នាគ្រានេះមានបច្ចាមិត្រជើងសឹក បើនឹងមិនជួយព្រះរាជមេត្រីក៏ពុំចិតថេរថេរកាលតទៅ អស់សេនាបតីក៏យល់ព្រមតាមព្រះរាជអធ្យាស្រ័យ ។

ព្រះបាទជាអម្ចាស់ផែនដីត្រាស់បង្គាប់ ព្រះស្រីសុរិយោព្រះរាជអនុជមហាឧបរាជឱ្យស្តេចជាចមពល លើកទ័ពទៅជួយក្រុងស្រីអយុធ្យាច្បាំងនឹងទ័ពក្រុងហង្សាវតី. . .

គ្រាដែលទ័ពក្រុងហង្សាវតី លើកត្រឡប់ទៅវិញហើយ នោះសម្តេចព្រះនរេសួន-ព្រះឯកាទសរថ្មក៏លើកទ័ពស្តេចដោយវិធិជលមាគ៌ា គ្រាដែលដល់ដំបន់ពោធិ៍បីដើម នោះសម្តេចព្រះនរេសួន ទតព្រះនេត្រឃើញទូកព្រះទីនាំង សម្តេចព្រះស្រីសុរិយោមហាឧបរាជក្រុងកម្ពុជានិងទូកនាយទ័ពនាយកងខ្មែរ ចតនៅតែសម្តេចព្រះស្រីសុរិយោមហាឧបរាជក្រុងកម្ពុជា ពុំបានម៉បក្រាប នោះសម្តេចព្រះនរេសួនទ្រង់ពិរោធន៍ឱ្យបង្ហង់ទូកព្រះទីនាំង ហើយបង្គាប់ហ្លួងជៃបូរិន្ទ្រាឱ្យយកក្បាលលាវឈ្លើយដោតត្រង់មុខទូកព្រះទីនាំង សម្តេចព្រះស្រីសុរិយោ ព្រះរាជអនុជមហាឧបរាជក្រុងកម្ពុជាធិបតី សម្តេចព្រះនរេសួននិងព្រះរាជអនុជ ក៏ស្តេចចូលព្រះនគរ. . .

ចំណែកខាងសម្តេចព្រះស្រីសុរិយោ ព្រះរាជអនុជ-មហាឧបរាជក្រុងកម្ពុជា បានទ្រង់ទតព្រះនេត្រឃើញដូច្នោះក៏តូចព្រះទ័យ គ្រាដែលស្តេចត្រឡប់ដល់ក្រុងលង្វែកឡើងគាល់ព្រះបាទសម្តេចព្រះបរមជេដ្ឋាធិរាជ ក្រាបបង្គំទូលថា សឹងត្រាស់ប្រើខ្ញុំព្រះអង្គឱ្យទៅជួយការសង្គ្រាមក្រុងស្រីអយុធ្យា ក្នុងគ្រានោះបានសេចក្តីអប្បយស ដោយព្រះនរេសួនមើលងាយឱ្យកាត់ក្បាលលាវឈ្លើយ មកដោតប្រេបទូកខ្ញុំព្រះអង្គ សេចក្តីក្តៅ សេចក្តីអាម៉ាស់ស្ទើរតែមិនឃើញមេឃឃើញដី ព្រះបាទសម្តេចព្រះបរមមហិន្ទ្រា

www.budinst.gov.kh www.elibraryofcambodia.org

ជាអម្ចាស់ផែនដីក្រុងកម្ពុជា បានទ្រង់ព្រះសណ្ដាប់ប្រាប់ហេតុដូច្នោះ ទ្រង់ព្រះពិរោធន៍ មានព្រះរាជតម្រាស់ថាយើងក៏ជាក្សត្រ គេក៏ជាក្សត្រ មកមើលងាយគ្នាដូច្នេះណាឡើយ ក្រុងកម្ពុជា និងក្រុងស្រីអយុធ្យានឹងជាផ្លូវព្រះរាជមេត្រីអង្វែងទៅបាន . . .

ដល់ខែកត្តិកឆ្នាំម្សាញ់ឯកស័ក ព.ស ២១១៣ ច.ស ៩៣១ ម្ចាស់ផែនដីក្រុងហង្សាវតី លើកទ័ពមកដោយផ្លូវស្រុងជាងថោងគណៈទ័ពក្រុងហង្សាវតី លើកទៅដល់ក្រុងស្រីអយុធ្យាបានដឹងដំណឹងដល់ក្រុងកម្ពុជា ព្រះបាទជាអម្ចាស់ផែនដីក្រុងកម្ពុជាធិបតី តែសម្ដេចចៅហ្វ៉ាទលហះឯកអគ្គមហាសេនាបតី ជាមេទ័ពលើកទៅវាយខែត្រសៀមខាងកើតកៀរគ្រួខ្មែរ-សៀមបានមកជាច្រើន . . .

ឆ្នាំម្សាញ់ត្រីស័ក ព.ស ២១២៤ ច.ស ៩៤៣ ព្រះបាទសម្ដេចធរស្ងួន ព្រះឯកាទសរដ្ឋព្រះចៅក្រុងស្រីអយុធ្យា លើកទ័ពមកចោមក្រុងលង្វែកបីខែ ខាងក្រុង កម្ពុជាធ្វើយុទ្ធនាជាសមាថ ខាងស្យាមខូចទាហានជាច្រើន ក៏លើកទ័ពត្រឡប់ទៅវិញ ខាងខ្មែរក្រុងកម្ពុជាបានឈ្នះស្យាមប៉ុណ្ណេះហើយ ក៏ធ្វេសប្រហែសលែងទាហានអស់ទៅ កន្លងពីរឆ្នាំស្យាមលើកទ័ពទាំងជលមាគ៌-សថលមាគ៌ ។

ព្រះបាទសម្ដេចព្រះនរេសួន ព្រះឯកាទសរដ្ឋជាចមពលសថលមាគ៌ លើកទ័ពមកដល់ខែត្របាត់ដំបង នោះចៅហ្វាយខែត្របាត់ដំបងមិនទទួលច្បាំង ខាងស្យាមលើកទ័ពចូលមកដល់ខែត្រពោធិសាត់ ចៅហ្វាយខែត្រពោធិសាត់លើកទ័ពចេញទទួលច្បាំងបាក់ទ័ពត្រឡប់មក ។

សម្ដេចព្រះស្រីសុរិយោ ព្រះរាជអនុជ មហាឧបរាជ តាំងទ័ពនៅខែត្របរិបូរ ក៏បាក់ទ័ពត្រឡប់ចូលមក . . .

ខាងស្យាមបាននិកាសក៏រុករានចូលមកតាំងឡោមក្រុងលង្វែក ព្រះបាទសម្ដេចព្រះនរេសួន ឱ្យតែងជាសំបុត្រមេទ័ពស្យាមឱ្យបំរើខ្មែរកាន់យកមកថ្វាយព្រះបាទអម្ចាស់ផែនដីក្រុងកម្ពុជា ក្នុងសេចក្ដីសំបុត្រនោះថា ឱ្យម្ចាស់ផែនដីក្រុងកម្ពុជាចេញទៅទទួលសាពីភក្ដិ បើមិនចេញទៅទទួលចុះចាញ់ទេ កំណត់បីថ្ងៃនឹងមូលផែនដីក្នុងមួយប៉ប្រិចភ្នែក ។

ព្រះបាទជាអម្ចាស់ផែនដីក្រុងកម្ពុជា បានទ្រង់ជ្រាបសេចក្ដីសំបុត្រមេទ័ពស្យាម

www.budinst.gov.kh www.elibraryofcambodia.org

ហើយទ្រង់តាំងព្រះរាជហឫទ័យដោយទ្ធរព្រះមានៈក្សត្រិយ៍ ដល់តំរប់បីស្ទះ គ្រាស់បង្គាប់ឱ្យទាហានបាញ់កាំភ្លើងធំ-តូចច្បាំងគ្នាទាំងថ្ងៃទាំងយប់ ទំពក្រុមទ័ពកំលាំង ខាងសៀមលើកចូលបែកក្រុងលង្វែកនៅខែចេត្រឆ្នាំវក នៅក្នុងបញ្ចស័ក ព.ស ២១២៦ ច.ស ៩៤៥ ព្រះជ័យចេស្ដា ព្រះរាជឱរស្សាធិរាជនិងមហាតលិក ២០នាក់រត់ចេញពីក្រុងកម្ពុជាទៅស្រុកលាវ ។

បែកក្រុងលង្វែកក្នុងខណៈនោះ ដោយចៅហ្វាយខែត្របាត់ដំបងក្បត់ចូលនឹងសៀម ។

**សម្ដេចក្សត្រី មាលិកា**

ដល់ជិតពាក់កណ្ដាល គ.ស ១៥០០ នគរកម្ពុជាពុំដែលទៅមកកាន់នឹងប្រទេសអឺរុបឡើយ ពីព្រោះកាលនោះផ្លូវដំណើរឆ្ងាយ ហើយពិបាកណាស់ ផ្លូវកប៉ាល់ភ្លើងពុំទាន់មាន ហើយព្រែកជីកធំ ដែលហៅថាព្រែកស៊ុយអែសនោះក៏នៅពុំទាន់មានដែរ ម្ល៉េះសំពៅដែលមកពីប្រទេសអឺរុប ធ្វើដំណើរជិតមួយឆ្នាំទើបដល់ ពីព្រោះត្រូវវាងតាមជ្រោយបោនអេស្បេរង្ស ។

**អំពីជាតិពរទុគេស៍** - ឯផ្លូវដែលទៅមកនោះពិបាកមែន ប៉ុន្តែក៏គង់មានអ្នកប្រទេសអឺរុបមកនគរកម្ពុជា ក្នុង គ.ស ១៥៥០ គេឃើញមានជាតិពរទុគេស៍ទាំងនោះចូលមកនៅក្នុងនគរយើងបំណងនឹងធ្វើជំនួញ ហើយមានអ្នកប្រដៅសាសនាកាតូលិក មកតាំងព្រះវិហារគ្រិស្ដជាដំបូងនៅពញាឮផង ។ មានពរទុគេស៍ខ្លះនៅជាប់ក្នុងនគរ ហើយយកប្រពន្ធខ្មែរមានកូននៅតៗរហូតដល់សព្វថ្ងៃនេះ នៅភូមិចូលសាសនាកាតូលិកក្រុងភ្នំពេញក៏មានដែរ ។

**អំពីជាតិអេស្ប៉ាញ៉ូល** - កាលនោះជាតិអេស្ប៉ាញ៉ូលនេះមានតាំងលំនៅឋានជាឱត្តុង្គឧត្តម នៅស្រុកម៉ានិលហើយៗមកដល់នគរកម្ពុជាក្រោយជាតិពរទុគេស៍បន្តិច ពិតមែនតែជាតិទាំងពីរនេះដណ្ដើមមិត្តគ្នា ប៉ុន្តែពរទុគេស៍ម្នាក់ឈ្មោះឌិអ៊ីគោ-បេលូស្ស និងអេស្ប៉ាញ៉ូលម្នាក់ឈ្មោះ រុអេស បួស-កាស្ទីយ៉ា នាំអេស្ប៉ាញ៉ូលពីស្រុកម៉ានិលមកច្បាំងដណ្ដើមយករាជសម្បត្តិពីព្រះបាទរាមាជើងព្រៃ មកថ្វាយព្រះបាទពញាតន់សោយរាជ្យ

www.budinst.gov.kh www.elibraryofcambodia.org

ព្រះបាទពញាគន់ស្តេចសងកុណា ឌីអីគោ-បេល្លូសូ និង រុអេស-ប្លាស វិញ ទ្រង់តាំងឱ្យធ្វើជាចៅហ្វាយខែត្រ ។

**អំពីជាតិហុល្លង់ដេ** - ជាតិហុល្លង់ដេនៅនគរខាងជើង នគរបារាំងសែស ជានគរទំនាបហើយរងារណាស់ ជាតិនេះជាអ្នកប្រសប់ខាងធ្វើជំនួញហើយហ៊ានដើរសមុទ្រណាស់ កាលនោះមានជាតិហុល្លង់ដេនេះតាំងទីលំនៅៗស្រុកជ្វា ហើយចង់ធ្វើជំនួញនៅនគរកម្ពុជា ក៏ចុះសំពៅពីរបើកមកដល់ស្រុកខ្មែរយើង ក្នុង គ.ស ១៦០២។

ដល់ឃើញជាតិហុល្លង់ដេមក ជាតិពរទុគេសមានសេចក្តីឈ្នានីស ក៏សំលាប់ហុល្លង់ដេទាំងពីរសំពៅនោះទៅ ប៉ុន្តែមានហុល្លង់ខ្លះចូលតាំងផ្ទះជំនួញយ៉ាងសំខាន់បានក្នុងនគរហើយ ស្តេចផែនដីខ្មែរនិងចៅហ្វាយស្រុក ហុល្លង់ដេស្រុកជ្វាក៏តែងតែធ្វើសារទៅវិញទៅមកជាញឹកញយ ហុល្លង់ដេធ្វើជំនួញបានណាស់ ដូច្នេះជាតិពរទុគេសមានសេចក្តីឈ្នានីស ក៏រករឿងសំលាប់ហុល្លង់ដេជាច្រើនផង ហើយរឹបយកទំនិញផងដោយហេតុដូច្នេះបានជាហុល្លង់ដេឈប់ធ្វើជំនួញនឹងនគរកម្ពុជាទៅ ។



**អំពីបារាំងសែស** - បារាំងសែសដែលមកនគរកម្ពុជាមុនគេនោះ គឺអ្នកប្រដៅសាសនាកាតូលិកម្នាក់ឈ្មោះលោក ឌីឡាម៉ុត មកតាំងព្រះវិហារគ្រិស្តនៅពញាឮ ក្នុង គ.ស ១៥៨៥ ប៉ុន្តែនៅមិនបាន ពីព្រោះពរទុគេសកំចាត់ចេញទៅ ដល់រំលងមួយរយ

www.budinst.gov.kh www.elibraryofcambodia.org

ឆ្នាំមកមានបារាំងសែសម្នាក់ទៀតឈ្មោះលូ៊ធីសីរ៉ុយមក ប៉ុន្តែព័រទុគេស៍កំចាត់ចេញទៀត ។

យើងនឹងឃើញនៅខាងមុខទៀត អំពីរឿងហេតុដែលបារាំងសែសមកតាំង ជាអ្នកទំនុកបំរុងព្យាបាលនគរកម្ពុជាយើងនេះ ។

៚ ៚ ៚

ប្រទេសកម្ពុជាតាំងពីខូចបន្ទាយលង្វែកមកដល់ គ.ស ១៦០០ (គឺតាំងពីឆ្នាំ ១៥៩៣ ដល់ ១៦០០) ។

តាំងពីសៀមវាយយកបានបន្ទាយលង្វែក ក្រុងរាជធានីលង្វែកនេះ ក៏បោះបង់ចោលរហូតដល់សព្វថ្ងៃ ឯព្រះរាជាដែលសោយរាជ្យឬគ្រងរាជ្យជាដំណាមកដល់ គ.ស ១៦០០ ក៏ពុំបានយីនហើយគង់នៅឯស្រុកស្រីសន្ធរ ។ ក្នុងរវាង ៦ ឆ្នាំនេះ មានព្រះរាជា ៤ ព្រះអង្គសោយរាជ្យឬគ្រងរាជ្យ ។

## ១~ព្រះបាទរាមាជើងព្រៃ

(ពី គ.ស ១៥៩៤ ដល់ ១៥៩៦)

កាលសៀមវាយយកបន្ទាយលង្វែកហើយ សៀមមិនចេញពីប្រទេសកម្ពុជាទេ មានទ័ពសៀមតាំងនៅក្រុងលង្វែក ទើបតែព្រះវង្សរាមាជើងព្រៃ ទ្រង់កេណ្ឌកងទ័ពតាំងពីស្រុកស្រីសន្ធរ ទៅវាយកំចាត់ទ័ពសៀមចេញ ព្រះរាមាជើងព្រៃទ្រង់ឡើងសោយរាជសម្បត្តិ ។

ប៉ុន្តែព្រះរាមាជើងព្រៃទ្រង់គង់នៅក្នុងរាជ្យមិនបានយូរទេ ពីព្រោះមានបារាំងជាតិពរទុគេស៍ម្នាក់ឈ្មោះ ឌីអីគោ-បេលូសូ(Diego Belloso)និងបារាំងជាតិអេស្ប៉ាញ៉ុលម្នាក់ ប្លាស-រ៉ូវិស (Blas Ruviz) ធ្វើគតព្រះអង្គយករាជសម្បត្តិថ្វាយព្រះពញាតន់ជាព្រះរាជបុត្រនៃព្រះសត្ថា ហើយដែលបានតាំងជាព្រះឧបរាជ ។

ឌីអីគោ-បេលូសូ និង ប្លាស-រ៉ូវិស នេះដែលព្រះបាទសត្ថានិងព្រះជ័យជេដ្ឋាទ្រង់ព្រះរាជមេត្តាប្រោសណាស់ ។

www.budinst.gov.kh www.elibraryofcambodia.org

## ២-ព្រះបាទពញាតន់

(ពី គ.ស ១៥៨៦ ដល់ ១៥៩៧)

ព្រះបាទពញាតន់កាលបើទ្រង់រាជសម្បត្តិហើយ ទ្រង់ព្រះរាជទានតាំង ឌីអ៊ីគោ-បេល្លូសូ ជាស្តេចត្រាញ់ដីត្បូងឃ្មុំ ប្លាស-រ៉ូវីស ជាស្តេចត្រាញ់ដីទ្រាំង ការតាំងជាតិដទៃជាចៅហ្វាយស្រុកនេះ ក៏បណ្តាលឱ្យកើតចលាចលឡើង ពួកចាមនិងជ្វាត្បូងឃ្មុំបះបោរលើកជាកងទ័ពឡើង ឌីអ៊ីគោ-បេល្លូសូ និង ប្លាស-រ៉ូវីស មានជ័យជំនះលើចាមនិងជ្វាមួយលើកហើយ ដល់មួយលើកក្រោយទៀតបរាជ័យចាញ់ចាមជ្វា ហើយក៏ស្លាប់ទាំងពីរនាក់ក្នុងសង្គ្រាមទៅ ឯព្រះបាទពញាតន់ទ្រង់ក៏លើកទ័ពទៅតយុទ្ធនឹងចាមជ្វាទៀត ហើយក៏សុគតក្នុងសង្គ្រាមទៅទៀត (គ.ស ១៥៩៧) ។

## ៣-ព្រះបាទពញាអាន

(ពី គ.ស ១៥៩៧ ដល់ ១៥៩៩)

ព្រះរាជានេះជាព្រះរាជបុត្រព្រះបរមឥន្ទរាជា (គឺជាព្រះអនុជនៃព្រះសត្ថានិងព្រះស៊ីរិយោពណ៌) ។

ចូលមកក្នុងរាជ្យព្រះអង្គនេះ ចាមនិងជ្វាក៏នៅតែបះបោរទៀត ព្រះបាទព្រះពញាអានទ្រង់វាយបង្ក្រាបបានអស់ហើយ ទទួលមានមនុស្សរបស់ព្រះអង្គម្នាក់ធ្វើគតព្រះអង្គ (គ.ស ១៥៩៩) ។

## ៤-ព្រះបាទពញាយុទ

(ពី គ.ស ១៥៩៩ ដល់ ១៦០០)

ព្រះរាជានេះជាព្រះរាជបុត្រនៃព្រះសត្ថា ព្រះមាតាឈាវ គ្រងរាជ្យដល់ គ.ស ១៦០០ ។

## ព្រះបាទស្រីស៊ីរិយោពណ៌

(ពី គ.ស ១៦០០ ដល់ ១៦១៨)

ព្រះរាជានេះជាព្រះអនុជ-មហាឧបរាជនៃព្រះបាទសត្ថាទី ១ រួចជាឧបយោរាជ

www.budinst.gov.kh www.elibraryofcambodia.org

ហើយដែលសៀមអញ្ជើញព្រមទាំងព្រះរាជវង្សជាំទៅឯស្រុកសៀម កាលសៀមវាយយកបានបន្ទាយលង្វែក ។

ទាម៉ឺនសព្វមុខមន្ត្រីខ្មែរអស់សេចក្តីសង្ឃឹម ទឹងមានស្តេចផែនដីប្រកបដោយអានុភាព ក៏ព្រមព្រៀងទៅសុំព្រះចៅក្រុងសៀម យកព្រះស្រីសុរិយោពណ៌និងព្រះរាជវង្សត្រឡប់មកក្រុងកម្ពុជាវិញ ឃាំងតែព្រះជ័យជេដ្ឋា(ទី២) មួយព្រះអង្គជាព្រះរាជបុត្រច្បងទុកនៅឯក្រុង ក្រុងអយុធ្យា ។ ព្រះចៅសៀមក៏ចាត់សេនាហើពលហែហមព្រះស្រីសុរិយោពណ៌ចូលក្រុងកម្ពុជា តាមសមុទ្រដល់កំពត រួចក្រោយមកព្រះស្រីសុរិយោពណ៌ទ្រង់ស្តេចយាងមកគង់នៅឯល្វាឯម (ស្រុកព្រៃល្វាផ្អែម) ។

ព្រះបាទស្រីសុរិយោពណ៌ កាលបើទ្រង់បានទទួលរាជសម្បត្តិហើយ ទ្រង់តាំងបង្ក្រាបបណ្តាជននៅខែត្រនានាដែលបះបោរ ប្រទះនឹងព្រះពញាយុម ដែលគ្រងរាជ្យមុនព្រះអង្គ ប៉ុន្តែព្រះពញាយុម នៅតែពុំសុខព្រះទ័យនឹងព្រះស្រីសុរិយោពណ៌ទៀត ។ រួចអំពីនេះព្រះពញាយុម បំបាស់បណ្តាជននៅផ្នែកខែត្រខាងជើង (ខែត្រជីក្រែងកំពង់ស្វាយ) ឱ្យបង្កើតចលាចលឡើង (គ.ស ១៦១១) ព្រះស្រីសុរិយោពណ៌ ក៏ទ្រង់លើកទ័ពទៅវាយខ្ចាត់ខ្ចាយអស់ ចាប់បានព្រះពញាយុម ឱ្យគេធ្វើគតទៅ ។ សៀមឃើញមានហេតុក្នុងព្រះនគរ ដូច្នេះលើកទ័ពចូលមក ប៉ុន្តែទ័ពព្រះស្រីសុរិយោពណ៌វាយខ្ចាត់ខ្ចាយដេញទៅស្រុកវិញអស់ ។ រួចព្រះនគរក៏បានសេចក្តីទៀងមក ហើយមកដល់គ.ស ១៦១៨ ព្រះបាទស្រីសុរិយោពណ៌ទ្រង់នឿយណាយនឹងគ្រប់គ្រងផែនដី ហើយទ្រង់មានសុខភាព ទ្រង់មានព្រះរាជអក្ខរាទៅដល់ព្រះជ័យជេដ្ឋា ជាព្រះរាជបុត្រច្បងឯក្រុងអយុធ្យា ព្រះឱង្ការថានឹងដាក់រាជសម្បត្តិប្រទានមកព្រះរាជឱរស ព្រះជ័យជេដ្ឋាទ្រង់ក៏ទូលសុំព្រះចៅក្រុងអយុធ្យាចូលមកក្រុងកម្ពុជា ព្រះចៅសៀមនិងខ្មែរហែហមមកលុះស្តេចមកដល់រាជធានីល្វាឯម ព្រះវររាជបិតា (ព្រះស្រីសុរិយោពណ៌) ក៏ទ្រង់ដាក់រាជសម្បត្តិប្រទានមកព្រះជ័យជេដ្ឋា(គ.ស ១៦១៨) ។ ព្រះស្រីសុរិយោពណ៌ទ្រង់ព្រះរាជសុវណ្ណគត ក្នុងមួយឆ្នាំក្រោយក្នុងព្រះជន្ម ៦៤ វស្សា (គ.ស ១៦១៩) ។

* * *

www.budinst.gov.kh www.elibraryofcambodia.org

## ព្រះបាទជ័យជេដ្ឋាទី ២

(ពី គ.ស ១៦១៨ ដល់ ១៦២៨)

-អំពីតាំងឧត្តុង្គជាព្រះរាជធានី (គ.ស ១៦២០)

-អំពីយួនសុំចូលមកតាំងនៅជាដំបូង នៅជាយខាងត្បូងនៃព្រះរាជនគរ (ព្រៃនគរ) (គ.ស ១៦២៣) ។

ព្រះបាទជ័យជេដ្ឋាទី ២ ទ្រង់ទទួលរាជសម្បត្តិក្នុងព្រះជន្ម ៤២វស្សា ។ ព្រះរាជអនុជបន្ទាប់នៃព្រះអង្គព្រះនាមឧទ័យ (ព្រះជន្ម ៣៩វស្សា)ជាទីឧបរាជ។

ក្នុង គ.ស ១៦២០ ព្រះជ័យជេដ្ឋាទ្រង់ផ្លាស់រាជធានីពីល្វាឯមទៅតាំងនៅឯឧដុង្គ (ហៅថាឧដុង្គមានជ័យ) ។ នៅក្នុងឆ្នាំជាមួយ (១៦២០) ព្រះរាជាប្រទេសយួន ដង្វៃព្រះរាជបុត្រីមួយព្រះអង្គប្រកបដោយរូបឆោមលោមពណ៌ មកថ្វាយព្រះជ័យជេដ្ឋាជាព្រះរាជមេត្រី ព្រះជ័យជេដ្ឋាក៏ទ្រង់ព្រមលើកឡើងជាព្រះមហេសី ។

ដល់ ២ឆ្នាំក្រោយមក (គ.ស ១៦២៣) សៀមលើកទ័ពមកច្បាំងពីរលើក ប៉ុន្តែចាក់ទ័ពចាញ់ថយទៅស្រុកវិញ ។ នៅក្នុងឆ្នាំជាមួយ (គ.ស ១៦២៣) ព្រះរាជាយួនមានព្រះរាជសារមកដល់ព្រះជ័យជេដ្ឋា សុំឱ្យយួនចូលមកតាំងនៅរកស៊ីនៅជាយខាងត្បូងនៃព្រះរាជនគរ គឺទីក្រុងព្រៃនគរសព្វថ្ងៃ ហើយសុំអំពីមុខក្រសួងគយទៀតនៅទីនោះ ដើម្បីនឹងជួយទ្រទ្រង់យួនដែលតាំងនៅរកស៊ី ព្រះជ័យជេដ្ឋាក៏ទ្រង់យល់ព្រម ។ ព្រះជ័យជេដ្ឋាទ្រង់ព្រះសុរគ្គតនៅ គ.ស ១៦២៨ ។

## ព្រះបាទធម្មរាជា រាជសំភារៈ (ព្រះពញាតូ)

(ពី គ.ស ១៦២៩ ដល់ ១៦៣៤)

ព្រះរាជានេះជាព្រះរាជបុត្រនៃព្រះជ័យជេដ្ឋាទី ២ (មិនមែនព្រះរាជបុត្រពីព្រះមហេសីយួនទេ) ។ តាំងពីកុមារ ព្រះវររាជបិតាបានផ្សំទុកជាគូនឹងស្ដេចក្សត្រីមួយព្រះអង្គព្រះនាមព្រះនាងបុប្ផាវតី ហើយកាលព្រះវររបិតាព្រះរាជសុរគ្គត ទ្រង់នៅក្នុងព្រះផ្នួសនៅឡើយ ព្រះឧទ័យជាព្រះបិតុលាទទួលរាជការផែនដី (ពី គ.ស ១៦២៨ ដល់ ១៦២៩) ។ នៅពេលនោះ ព្រះឧទ័យបានព្រះនាងបុប្ផាវតីជាព្រះជាយា ។

www.budinst.gov.kh www.elibraryofcambodia.org

-លុះដល់ព្រះរាជសំភារចាកព្រះផ្នួសមក (គ.ស ១៦២៩) ព្រះឧទ័យយកទីឧបយោរាជ ។ ប៉ុន្តែព្រះរាជសំភារទ្រង់សព្វព្រះរាជហឫទ័យខាងអក្សរសាស្ត្រវីរបណ្ឌិត ទ្រង់មិនគង់នៅក្រុងឧដុង្គទេ ទ្រង់ស្ដេចមកគង់នៅឯកោះឃ្លោក (ខ្សាច់កណ្ដាលសព្វថ្ងៃ) ដើម្បីនឹងបំពេញកិច្ចក្នុងអក្សរសាស្ត្រ ទុករាជការផែនដីឱ្យព្រះឧទ័យគ្រប់គ្រង ។

មួយឆ្នាំក្រោយ (ក្នុង គ.ស ១៦៣០) ព្រះបាទរាជសំភារ ទ្រង់ព្រះតិរះព្រមព្រៀងនឹងក្សត្រមួយព្រះអង្គ នាំទ័ពចូលទៅវាយយកខេត្រនគររាជ (គ្រាត) ពីសៀមមកវិញ ប៉ុន្តែវាយយកមិនបានជ័យមកវិញ កៀរគ្រួបានមកជាច្រើននៅខេត្រនគរសៀមរាប ។

លុះក្រោយមកព្រះនាងបុប្ផាវតីវិលបានមកជាព្រះមហេសី នៃព្រះរាជសំភារគង់នៅកោះឃ្លោក ព្រះឧទ័យទ្រង់ក្រោធ ឱ្យលើកទ័ពជំមានទាហ៊ានពរទុគេស៍ផង មកចាប់ព្រះបាទរាជសំភារ ។ទ្រង់តយុទ្ធនឹងទ័ពនោះ ប៉ុន្តែមិនឈ្នះទ្រង់ដោះដៃព្រះអង្គទៅដល់ទីមួយ ទ័ពហ្លួងចេញទៅទាន់ធ្វើគតព្រះអង្គនៅទីនោះ (ស្រុកកញ្ជរ-ក្នុងខេត្រក្រចេះសព្វថ្ងៃ) ។

## ព្រះបាទអង្គនទទី ១ (ព្រះពញាន្ទ)

(ពី គ.ស ១៦៣៤ ដល់ ១៦៤០)

កាលបើព្រះឧទ័យធ្វើគតព្រះបាទរាជសំភារហើយ គេថ្វាយរាជសម្បត្តិព្រះអង្គទង (ព្រះពញាន្ទ) ។

**សេចក្ដីពិស្ដារ** - ព្រះម៉ែយ្យរបុប្ផាវតី ជាត្តគុណាធំនឹងព្រះរាជសំភារចៅពញា "ទ្វ" ព្រះបរមរាជបិតាផ្សំតាំងអំពីព្រះកុមារមក ក្រោយនោះចៅពញា "ត្ន" ចេញទៅទ្រង់ព្រះផ្នួស នោះព្រះបាទសម្ដេចព្រះបរមរាជបិតាទ្រង់ព្រះសុវណ្ណគតទៅ ។

សម្ដេចព្រះឧទ័យរាជ ព្រះរាជបិតុលាទទួលរាជការផែនដី យកព្រះនាងបុប្ផាវតីធ្វើជាព្រះជាយា ឱ្យហៅថាព្រះម៉ែយ្យរបុប្ផាវតី ក្រោយនោះចៅពញា "ត្ន" ដាក់ព្រះផ្នួសឡើងសោយរាជសម្បត្តិជាអម្ចាស់ផែនដីក្រុងកម្ពុជា ទ្រង់ព្រះនាមព្រះបាទសម្ដេចព្រះស្រីធម្មរាជាធិរាជរាមាធិបតី ពាក្យទូលឆ្លើយថាព្រះរាជសំភារថ្ងៃវិសេស គង់នៅព្រះ

www.budinst.gov.kh www.elibraryofcambodia.org

រាជវាំងកោះឃ្លោក សម្ដេចព្រះឧទ័យរាជា ព្រះរាជបិតុលា ដាក់ព្រះអង្គជាព្រះឧបយោរាជ គង់នៅព្រះរាជវាំងក្រុងឧដុង្គ ។

ព្រះបាទសម្ដេចព្រះស្រីធម្មរាជា ព្រះរាជសំភាររអម្ចាស់ផែនដីក្រុងកម្ពុជា មិនដាច់ព្រះហឫទ័យនឹងព្រះនាងបុប្ផាវតី ប្រកួតប្រកាន់មានសុភអក្សរទៅវិញទៅមកដោយបុរោនិភាស ក្រោយនោះព្រះរាជសំភាររអម្ចាស់ផែនដីក្រុងកម្ពុជា ទ្រង់ណាត់ឱ្យព្រះនាងបុប្ផាវតីស្ដេចទៅជួបនៅឯត្រើយពោធិ៍ព្រះបាទ ហើយស្ដេចនាំនាងបុប្ផាវតីទៅឯព្រះរាជវាំងកោះឃ្លោក ។

សម្ដេចព្រះឧទ័យរាជាព្រះរាជបិតុលាបានជ្រាបហើយ មានបង្គាប់ទាហានពរទុគេស៍ឱ្យលើកជាទ័ពឱ្យទៅចាប់ ។

ខាងព្រះរាជសំភាររអម្ចាស់ផែនដី ត្រាស់បង្គាប់ឱ្យលើកទាហានខ្មែរទាហានចិនទទួលច្បាំង ខាងព្រះរាជសំភាររអម្ចាស់ផែនដីខូចទាហានជាច្រើន ព្រះរាជសំភារទ្រង់ឈ្វេងយល់ថា ជើងសឹកខ្លាំងហួស ស្ដេចដោះព្រះអង្គចេញទៅដល់ទីមួយជាទីរបោះព្រៃ មានដើមត្នោតជាច្រើន ស្ដេចឡើងលើដើមត្នោត ឯពួកអរិទ្ធរាជភេរីក៏ដេញស្ដេចប្រកិតទៅ ។

ព្រះរាជសំភារម្ចាស់ផែនដី ទ្រង់យល់ថាមិនរួចព្រះអង្គហើយ ទ្រង់ចាប់ព្រះទម្រង់ត្រីមុខ កាត់ត្រួយត្នោតហើយទ្រង់រាជនិពន្ធ ពុំទាន់ចប់សេចក្ដី កងទ័ពបច្ចាមិត្រលើកមកដល់ ឃើញព្រះអង្គគង់លើដើមត្នោតក៏លើកកាំភ្លើងតំរង់នឹងបាញ់ ព្រះរាជសំភារតាំងព្រះរាជហឫទ័យដោយសេចក្ដីមហាក្សត្រិយ៍ ទ្រង់រាព្រះហស្ត ហើយមានព្រះរាជដម្រាស់ដោយព្រះសូរសៀងយ៉ាងខ្លាំងថា ៖ ហាំងអប្បល័ក្សណ៍ វាចោមបាញ់អ្នកព្រះរាជសំភារពីលើចុងត្នោត មិនកោតចេស្ដា អ្នកយកហត្ថា រាំងឃាំងឃាត់ ។

សេចក្ដីចារនឹងស្លឹកត្នោត ដូចមានខាងក្រោមនេះ ៖

"សាធុសម្ដាយ កុំបីរាយមាយ នឹងផ្លូវកាមា នាំឱ្យវង្វេងក្នុងវដ្តសង្សារ ស្លាប់ទៅកាលណា បានសោយតែទុក្ខ" ។

"ព្រោះតែស្រី នាំឱ្យអប្រិយ ដូចត្រីក្នុងភក់ បើបុរសផង ចង់ឆ្លងនរក កុំឱ្យវិវក់ដូចខ្ញុំច្នេះណា" ។

www.budinst.gov.kh www.elibraryofcambodia.org

"ពីព្រះកាមេ ឥឡូវទាល់តែ ក្សិណក្ស័យជន្មា សូវស្លាប់ទៅគាប់ ឱ្យជាប់ធម្មា សូមអស់ទេវា ជួយជាទិព្វញាណ" ។

"ទើបព្រះភូមិន្ទ្រ ទ្រាយណ៍ធម្មឱន្រ្ទ ទ្រង់ឧទ្ទិស្ថាន ពីនេះទៅមុខ សូមកុំឱ្យបាន ជាព្រះពុទ្ធញាណ ស្រង់សត្វទាំងឡាយ" ។

"ឱអ្នកទាំងពួង ជាទាហានហ្លួង នាំយកទៅថ្វាយ ព្រះបិតុលា បានជ្រាបផិប្បាយ កុំឱ្យរាយមាយ នឹងផ្លូវកាមេ" ។

ទ្រង់ព្រះរាជនិពន្ធចប់ហើយ ក៏ទម្លាក់ចុះមក ពួកទាហានពរទុគេស៍ ថ្វាយគ្រាប់មាសធ្លាក់ព្រះអង្គពីលើចុងត្នោត ។

ក្នុងខណៈនោះព្រះរាជសំភារព្រះជន្ម ៣០វស្សា សិរីរាជសម្បត្តិ ៥វស្សា ក្នុងព្រះរាជពង្សាវតារក្រុងកម្ពុជា ថាអស់ព្រះជន្មក្នុងខណៈធ្លាក់ព្រះអង្គពីលើចុងត្នោត ដំណើងផ្សេងមួយទៀតថា ចាប់ព្រះអង្គយកមកសំរេចទោសឯក្នុងក្រុង សម្តេចព្រះឧទ័យរាជាអាងថា ព្រះអង្គជាព្រះរាជបិតុលាក៏ធ្វើរំលោភដោយសេចក្តីទុច្ចរិត ក្នុងរវាងក្រោយនេះមកដល់គ្រាឥឡូវនេះ អ្នកទាំងពួងដឹងថាព្រះរាជសំភារ លួចព្រះជាយានៃសម្តេចព្រះឧទ័យរាជា ជាព្រះបិតុលា ។

ឯសេចក្តីដែលពិតគឺសម្តេចព្រះឧទ័យរាជា ព្រះបិតុលាបំណងនឹងផណ្តើមយករាជសម្បត្តិ ហើយផណ្តើមយកនាងបុប្ផវតី ជាព្រះមហេសីតូតុណាង៉ាន់ នៃព្រះរាជសំភារជាព្រះភគិនិយោធិរាជ ។ ខាងព្រះរាជសំភារជាអម្ចាស់ផែនដី ក៏តាំងព្រះរាជហឫទ័យផណ្តើមយកព្រះនាងបុប្ផវតីវិញឱ្យខាងតែបាន ។

ឯសម្តេចព្រះឧទ័យរាជាជាព្រះបិតុលា មិនតាំងព្រះអង្គជាព្រះរាជបិតុលា ប្រព្រឹត្តព្រះអង្គជាបទឧក្រិដ្ឋ ផណ្តើមតូតុណាង៉ាន់ ទីមហេសីព្រះរាជសំភារជាព្រះភគិនិយោ ហើយជាម្ចាស់ផែនដី ១ បង្ខំផណ្តើមយកស្រីព្រះជន្មមិនគ្រប់១៨ឆ្នាំនេះ ២ ហេតុតែស្រីនោះត្រឡប់ទៅរកម្ចាស់ផែនដីដែលតូតុណាង៉ាន់វិញ ដូច្នេះសម្តេចព្រះឧទ័យរាជាហ៊ានលើកទាហានទៅចោមចាប់អម្ចាស់ផែនដី ធ្វើពិធីកម្មផល់អស់ព្រះជន្មទាំងពីរព្រះអង្គដូច្នោះ សម្តេចព្រះឧទ័យរាជាត្រូវមានទោសឧក្រិដ្ឋបីសណ្ឋាន ។

សម្តេចក្សត្រីយ៍ មាលិកា

www.budinst.gov.kh www.elibraryofcambodia.org

## ព្រះបាទអង្គនន (ព្រះពញាននូ)

ជាអនុជនៃព្រះរាជសំភារ ។ ក្នុងរាជ្យព្រះរាជានេះ គ្មានពត៌មានអ្វីជាសំខាន់ទេ មានតែបះបោរបន្តិចបន្តួចនៅក្នុងតំបន់មួយ (រលាំងទ្រាល) ដែលជាតិឥណ្ឌៀម្នាក់ (ក្លិង្គ)បំបាស់ ព្រះអង្គតន់ទ្រង់បង្ក្រាបបានទៅវិញភ្លាម ចាប់អ្នកជាតិឥណ្ឌៀមេបំបាស់នោះបានហើយគេសម្លាប់ចោលទៅ ។

ព្រះបាទអង្គនងទ្រង់ព្រះរាជសុវណ្ណគតនៅក្នុង គ.ស ១៦៤០ ។

## ព្រះបាទអង្គនន់ទី ១

(ពី គ.ស ១៦៤០ ដល់ ១៦៤២)

ព្រះរាជានេះជាព្រះរាជបុត្រច្បងនៃព្រះឧទ័យ ទ្រង់ទើបតែនឹងសោយរាជសម្បត្តិបានរវាងជាងមួយឆ្នាំ ព្រះអង្គច័ន្ទធ្វើគតព្រមទាំងព្រះឧទ័យ យករាជសម្បត្តិ (គ.ស ១៦៤២) ។

## ព្រះបាទរាមាធិបតីចន្ទឬព្រះអង្គចន្ទមហាម៉ាត់អ៊ីព្រាហ៊ីម

(ពី គ.ស ១៦៤២ ដល់ ១៦៥៨)

ព្រះរាជានេះជាព្រះអនុជ នៃព្រះបាទរាជសំភារនឹងព្រះបាទអង្គតន់ ប៉ុន្តែពីព្រះមាតាលាវ ទ្រង់មានពួកចាមនិងជ្វាជាច្រើនចូលបិត្តនឹងព្រះអង្គណាស់ ទ្រង់យកស្រីជ្វាជាព្រះជាយា ហើយក្រោយមកទ្រង់ចូលសាសនាមហាម៉ាត់ ហេតុនេះបានជាគេហៅថាព្រះអង្គច័ន្ទមហាម៉ាត់ ឬព្រះអ៊ីព្រាហ៊ីម ។

កាលបើរាជសម្បត្តិបានមកព្រះអង្គនន់ទី ១ ព្រះអង្គច័ន្ទទ្រង់មានសេចក្តីអាក់អន់ព្រះរាជហឫទ័យ ពីព្រោះទ្រង់ក៏ជាព្រះរាជបុត្រនៃព្រះជ័យជេដ្ឋាទី ២ដែរ ។ កាលបើដូច្នេះ មានកាលមួយព្រះអង្គច័ន្ទទ្រង់ព្រមព្រៀងនឹងពួកចាមជ្វា ដល់ពេលមួយពួកចាមនិងជ្វា និងព្រះអង្គបះឡើងធ្វើគតព្រះឧទ័យហើយនឹងព្រះបាទអង្គនន់ ជាម្ចាស់ផែនដីព្រមទាំងព្រះរាជវង្សផង ។ កាលនោះមានព្រះរាជបុត្រានៃព្រះឧទ័យបីព្រះអង្គដោះព្រះអង្គ មួយព្រះអង្គព្រះនាមអង្គអឹមរត់ទៅជ្រកនៅព្រះមាតានៃអង្គច័ន្ទ ពីរព្រះអង្គ

www.budinst.gov.kh www.elibraryofcambodia.org

ទៀតទ្រង់នាមព្រះពញាសួរ ដែលក្រោយមកបានសោយរាជ្យជាព្រះបាទបទុមរាជា ហើយនឹងព្រះអង្គតន់រត់ទៅជ្រកនៅឯព្រះមហេសីយួនមេម៉ាយនៃព្រះជ័យជេដ្ឋា (គ.ស ១៦៤២) ។

កាលបើធ្វើគតព្រះឧទ័យនិងព្រះអង្គនន់ទី ១ រួចហើយ ព្រះអង្គច័ន្ទទ្រង់ឡើងសោយរាជសម្បត្តិ ទ្រង់ព្រះនាមថា ព្រះបាទសម្តេចរាមាធិបតីចន្ទ ហើយទ្រង់តាំងព្រះអង្គអឹម ដែលជាព្រះរាជបុត្រនៃព្រះឧទ័យ ហើយដែលរត់មកជ្រកនៅនឹងព្រះមាតានៃព្រះអង្គនោះជាព្រះកែវហ្វា ។

ព្រះអង្គច័ន្ទទ្រង់ច្រើនប្រកបនូវក្តីក្រេវក្រោធ ហើយដោយទ្រង់ចូលសាសនាមហាម៉ាត់ទៀតផង ទ្រង់ច្រើនមេត្តាប្រោសពួកចាមនិងជ្វា ទ្រង់តាំងចាមនិងជ្វាខ្លះជានាម៉ឺនធំៗ ។ កាលបើចូច្នោះក៏មានសេចក្តីក្តៅក្រហាយជាខ្លាំងក្នុងបណ្តាជនខ្មែរ រួចព្រះពញាសួរ (ព្រះបទុមរាជា) និងព្រះអង្គតន់ដែលជាព្រះរាជបុត្រនៃព្រះឧទ័យ ហើយដែលរត់ជៀតនៅនឹងព្រះមហេសីយួន នោះប្រឹក្សានឹងមហេសីបានសេចក្តីសំរេចទៅពឹងព្រះរាជាយួនឱ្យជួយ ។

អំពីយួនចាប់ព្រះបាទរាមាធិបតីច័ន្ទ យកទៅឃុំទុកនៅឯប្រទេសយួន (គ.ស ១៦៥៨) ។

ព្រះពញាសួរនិងព្រះអង្គតន់ ក៏ទ្រង់ទៅពឹងស្តេចស្រុកយួនឱ្យជួយ ស្តេចផែនដីនេះក៏ចាត់ទ័ពមួយមកវាយនគរកម្ពុជាក្នុង គ.ស ១៦៥៨ ហើយចាប់ព្រះបាទរាមាធិបតីច័ន្ទបានយកទៅឃុំឯស្រុកយួន ហើយទ្រង់សុគតនៅទីនោះក្នុងមួយឆ្នាំក្រោយ (គ.ស ១៦៥៩) ។

## ព្រះបាទបទុមរាជា (ពញាសួរ)

(ពី គ.ស ១៦៥៨ ដល់ ១៦៧២)

លុះយួននាំព្រះរាមាធិបតីច័ន្ទ ទៅឯស្រុកយួនហើយ ព្រះបទុមរាជាទ្រង់សោយរាជសម្បត្តិ ។ កាលដើមរាជ្យព្រះអង្គ (គ.ស ១៦៦០) មានបះបោរពួកចាមនិងជ្វាទៅខែត្រត្បូងឃ្មុំ ព្រះបទុមរាជាទ្រង់លើកទ័ពទៅវាយខ្ចាត់ខ្ចាយអស់ មេបះបាក់ទ័ពរត់

www.budinst.gov.kh www.elibraryofcambodia.org

ទៅខែត្រសៀមរាប រួចឆ្លងចូលទៅប្រទេសសៀមព្រមទាំងព្រះរាជបុត្របីព្រះអង្គនៃព្រះរាមាធិបតីច័ន្ទ និងមនុស្សដែលជាបក្សពួកទៀតផងជាច្រើន (២២២៤ នាក់) ។

រួចអំពីនេះមក ប្រទេសកម្ពុជាក៏បានស្ងប់សុខរហូតមកដល់ គ.ស ១៦៧២ (ចុងរាជ្យព្រះបទុមរាជា) ទើបព្រះជ័យជេដ្ឋា(ទី៣) ជាព្រះរាជសុណិសានៃព្រះអង្គ ធ្វើគតព្រះអង្គយករាជសម្បត្តិ (ព្រះជ័យជេដ្ឋានេះ ត្រូវជាព្រះភគិនិយោនៃព្រះអង្គផង ពីព្រោះជាព្រះរាជបុត្រនៃព្រះអង្គនន់ទី ១ ដែលព្រះរាមាធិបតីច័ន្ទធ្វើគតយករាជ្យនោះ) ប៉ុន្តែព្រះជ័យជេដ្ឋាគង់នៅមិនបានយូរ បានតែរវាង ៦ ខែ ពីព្រោះព្រះអគ្គមហេសីនៃព្រះបទុមរាជា ញុះពួកចាមនិងជ្វាឱ្យធ្វើគតទៅវិញ (គ.ស ១៦៧៣) ។

## ព្រះបាទជ័យជេដ្ឋាទី ៤

(ពី គ.ស ១៦៧៥ ដល់ ១៧០៦)

### អំពីព្រះអង្គនន់ (ទី២) ប្រជែងនឹងព្រះបាទជ័យជេដ្ឋាទី ៤

អំពីខែត្របារៀ (បារាយ) បៀងហ្វានិងយ៉ានិញ (ព្រៃនគរ) បានទៅយួន (គ.ស ១៦៩៩) ។

ព្រះបាទជ័យជេដ្ឋាទី ៤ ជាព្រះរាជបុត្រនៃព្រះបទុមរាជា ។

ព្រះអង្គនន់ជាព្រះរាជបុត្រនៃព្រះអង្គអឹម ជាព្រះអនុជនៃព្រះបទុមរាជា (មិនបានសោយរាជ្យទេ) ហើយដែលរត់ទៅជ្រកព្រះមាតារាមាធិបតីច័ន្ទ កាលព្រះរាមាធិបតីច័ន្ទធ្វើគតព្រះឧទ័យនឹងព្រះអង្គនន់ទី ១ យករាជ្យ ។

កាលបើធ្វើគតព្រះជ័យជេដ្ឋា (ទី៣)បានហើយ ព្រះរាជវង្សានុវង្សនាម៉ឺនសព្វមុខមន្ត្រី ព្រមព្រៀងលើកព្រះអង្គជ័យជាព្រះរៀមនៃព្រះជ័យជេដ្ឋាទី ២ ជាស្តេចអម្ចាស់ផែនដី ប៉ុន្តែទ្រង់នៅគង់មិនបានយូរទេ បានរវាងមួយឆ្នាំ ពីព្រោះព្រះអង្គនន់ (ទី២) និងព្រះអង្គតន់ ដែលជាព្រះអនុជហើយជាគូនឹងព្រះបទុមរាជា លើកទ័ពមកច្បាំងធ្វើគតព្រះអង្គ ។

កាលបើដូច្នោះព្រះជ័យជេដ្ឋាទី ៤ ទ្រង់បារម្ភ តាំងជាទ័ពសងសឹកនឹងព្រះអង្គនន់វិញ ។ ឯសង្គ្រាមតទល់នឹងព្រះអង្គនន់នេះធំសំបើមអស្ចារ្យ ហើយយូរឆ្នាំផង លុះតែ

www.budinst.gov.kh www.elibraryofcambodia.org

ដល់ គ.ស ១៦៩១ ទើបព្រះអង្គទន់សុំចុះចូលមកគង់នៅបន្ទាយស្រីសន្ធរ ហើយសុគតនៅទីនោះ (គ.ស ១៦៩១) ព្រះអង្គទន់យកយួនធ្វើជាពួក ហើយគង់នៅឯព្រៃនគរ ហេតុនេះហើយបានជាយួនចេះតែហ៊ានទន្ទ្រានចូលមកនៅដែនកូសាំងស៊ីន ពិតមែនតែនៅក្នុងព្រះរាជអាណាចក្រខ្មែរនៅឡើយ ។ ទ័ពខាងព្រះអង្គទន់មានយួនផងម៉ុងណាមានចិនផង ហើយថែមទាំងសៀមបញ្ជោះជួយទៀតផង កើតមកច្បាំងនឹងព្រះជ័យជេដ្ឋាជាញឹកញយ ប៉ុន្តែលើកមកច្បាំងម្តងណាក្តីចេះតែបរាជ័យចាញ់ព្រះបាទជ័យជេដ្ឋា ។

ដល់ គ.ស ១៦៩១ ព្រះអង្គទន់អស់សេចក្តីសង្ឃឹម ក៏សុំចុះចូលព្រះបាទជ័យជេដ្ឋា ហើយគង់នៅបន្ទាយស្រីសន្ធរ លុះតែសុគតនៅទីនោះ ។

តាំងពីរួចពីសង្គ្រាមព្រះអង្គទន់នេះមក ព្រះរាជនគរក៏បានសេចក្តីសុខសាន្តត្រាណ លុះដល់ គ.ស ១៦៩៩ មាននាម៉ឺនស្បត់ម្នាក់ (ឈ្មោះឧកញ៉ានរិនអិម) ទៅអន្ទងយួនមកច្បាំងប្រាថ្នានឹងបំផុតរាជ្យស្តេចយករាជសម្បត្តិ ប៉ុន្តែទ័ពហ្លួងវាយខ្ចាត់ខ្ចាយទេះវិញអស់ ថយទៅតាំងនៅខែត្រយ៉ានិញ (ព្រៃនគរ) បារៀ (បាភយ) និងបៀងហ្វាជាប់រហូតដល់សព្វថ្ងៃ (គ.ស ១៦៦៩) ។

## ព្រះបាទអង្គអិម

(រាជ្យលើកទី ១ ពី គ.ស ១៧០០ ដល់ ១៧០១)

ព្រះបាទជ័យជេដ្ឋាទី ៤ ទ្រង់នឿយណាយព្រះកាយពល ទ្រង់ដាក់រាជសម្បត្តិប្រទានមកព្រះសុណិសាជន ព្រះអង្គព្រះនាមព្រះអង្គអិម (គ.ស ១៧០០)ដែលទ្រង់បានតាំងជាព្រះកែវហ្វា ។ ព្រះអង្គអិមនេះត្រូវជាព្រះភាគិនេយ្យា ជីដូនមួយព្រះអង្គផង ពីព្រោះជាព្រះរាជបុត្រនៃព្រះអង្គទន់ដែលប្រជែងរាជ្យ ។ ប៉ុន្តែព្រះកែវហ្វាអង្គអិមសោយរាជ្យបានតែរវាងមួយឆ្នាំ ទ្រង់ឈប់ (១៧០១) ព្រះបាទជ័យជេដ្ឋាក៏ទ្រង់វិលមកទទួលរាជសម្បត្តិទៀត ប្រទានមកព្រះរាជបុត្រនៃព្រះអង្គព្រះនាមព្រះធម្មរាជា (គ.ស ១៧០២) ព្រះធម្មរាជានៅកុមារពេក បានតែពីរឆ្នាំ ព្រះបាទជ័យជេដ្ឋាទ្រង់វិញមកទទួលរាជសម្បត្តិទៀត (ដល់ ១៧០៤) រួចមកបានពីរឆ្នាំទៀត (ដល់ គ.ស ១៧០៦)

www.budinst.gov.kh www.elibraryofcambodia.org

ព្រះធម្មរាជាក៏ដល់ព្រះជន្មទទួលរាជសម្បត្តិបាន (ព្រះជន្ម ១៧ ព្រះវស្សា) ព្រះបាទជ័យជេដ្ឋាទ្រង់ដាក់រាជសម្បត្តិ ប្រទានរហូតមកព្រះធម្មរាជា (គ.ស ១៧០៦) ។

កាលនៅចុងរាជ្យព្រះជ័យជេដ្ឋាទី ៤ (ក្នុង គ.ស ១៧០៥) មានពតិមានអ្នកកើតព្រះរាជាលាវ សោយរាជ្យនៅក្រុងវៀងច័ន្ទន៍ត្រូវព្រះរាជាលាវមួយវង្សផ្សេងទៀតផ្តើមយករាជសម្បត្តិបាន នាំសេនាររហ័ពល (ទាំងអស់ប្រហែល ៥ ០០០នាក់) មកសុំព្រះបាទជ័យជេដ្ឋាទី ៤ពំនាក់អាស្រ័យនៅនគរកម្ពុជា ព្រះបាទជ័យជេដ្ឋាក៏ទ្រង់ទទួលហើយដាក់ឱ្យនៅជិតភូមិលាវមួយហៅថាភូមិ (បារាយណ៍ក្បត់ជុំ) ក្នុងស្រុកបាទីជាប់ព្រៃកប្បាស បានជាឱ្យឈ្មោះយ៉ាងនេះ ពីព្រោះពួកលាវដែលព្រះបាទបរមិន្ទរាជាចាប់យកជាឈ្លើយ ដាក់ឱ្យនៅស្រុកបារាយណ៍ ក្នុងសតវត្សទី ១៦ នោះ ចេះតែបះបោរក្នុងរាជ្យព្រះរាជាក្រោយ ហើយដាក់ឈ្មោះភូមិជាភូមិ "បារាយណ៍ក្បត់ជុំ" ។

ព្រះបាទជ័យជេដ្ឋាទី ៤ ជាស្តេចអម្ចាស់ផែនដី មានព្រះកិត្តិនាមប្រសើរមួយដែរក្នុងព្រះរាជពង្សាវតារ ទ្រង់បានឱ្យអស់អ្នកប្រាជ្ញទូវនាម៉ឺនស្រាវជ្រាវរកច្បាប់ សំរាប់ប្រើក្នុងព្រះរាជនគរ ដែលវិនាសកាលចាក់បែកក្រុងលង្វែកនោះផ្ទៀងផ្ទាត់រង់ឡើងវិញទុកប្រើតមក (សព្វថ្ងៃគេច្រើនថា "ច្បាប់ព្រះជ័យចេស្តា")។

## ព្រះបាទធម្មរាជាទី ២

(ពី គ.ស ១៧០៦ ដល់ ១៧១០)

អំពីព្រះកែវហ្វាអង្គអិម ច្បាំងផ្តើមយករាជ្យពីព្រះធម្មរាជាវិញ (គ.ស១៧១០)។

ព្រះបាទធម្មរាជាទ្រង់សោយរាជ្យជាអម្ចាស់ផែនដី ។ កាលនោះពួកលាវដែលមកតាមព្រះរាជាលាវ ហើយដែលបានតាំងនៅជិតពួកលាវ "ភូមិបារាយណ៍ក្បត់ជុំ" ក្នុងខែត្របាទីនោះបានជួបគ្នា យកគ្នាជាកំលាំងបង្កហេតុបះបោរឡើង ព្រះបាទធម្មរាជាទ្រង់បានចាត់កងទ័ព ឱ្យទៅវាយបង្ក្រាបរត់ខ្ចាត់ខ្ចាយ ខ្លះរត់ចូលព្រៃ ខ្លះទៅដល់ដែនភ្នំសាំងស៊ីន (កាលនោះនៅជារបស់ខ្មែរនៅឡើយ) ខ្លះរត់ទៅជ្រកនៅព្រះកែវហ្វាអង្គអិម ។

ព្រះកែវហ្វាអង្គអិមបានឱកាសនេះ យកលាវជាពួកដាក់ងារឱ្យមេកងលាវកេណ្ឌ

កំលាំងពីខាងត្បូង បានទាំងយួនចំនួន ២០ ០០០ នាក់ទៀតផង លើកទ័ពចូលមកពីខាងត្បូង ឯព្រះអង្គអិមទៅកេណ្ឌរេហ៍ពលពីខាងជើង លើកទ័ពចូលមកវាយផ្ទប់ក្រុងឧដុង្គ ព្រះធម្មរាជាក៏ត្រូវគេព័ទ្ធឡោមជាប់នៅក្រុងឧដុង្គ ប៉ុន្តែមានមួយយប់ទ្រង់ដោះព្រះអង្គចេញរួច ព្រមទាំងព្រះរាជអនុជព្រះនាមព្រះអង្គតន់នឹងព្រះរាជបុត្រាមួយព្រះអង្គផង ភៀសទាំងបីព្រះអង្គចូលទៅស្រុកសៀម (រាជធានីស្រីអយុធ្យា) ។ ព្រះកែវហ្វាអង្គអិមក៏ឡើងសោយរាជសម្បត្តិ (គ.ស ១៧១០) ។ (អំពីរឿងនេះ បានជាមានលាវនៅដល់សព្វថ្ងៃក្នុងខែត្រស្វាយរៀង នៅភូមិក្សេត្រ ក្នុងស្រុកកំពង់ត្របែក នៅភូមិជាងដែក) ។

## ព្រះបាទកែវហ្វាអង្គអិម

(រាជ្យលើកទី ២ ពី គ.ស ១៧១០ ដល់ ១៧២២)

### ព្រះបាទកែវហ្វាដាក់ព្រះនគរកម្ពុជាជាចំណុះសៀម (គ.ស ១៧២២)

នៅពេលក្រោយដែលព្រះបាទកែវហ្វាអង្គអិមឡើងសោយរាជ្យ បន្តិចមានព្រះរាជទូតពីព្រះចៅសៀម នាំព្រះរាជសព្វអក្សរមកព្រះបាទកែវហ្វាអង្គអិមថា ឱ្យថ្វាយរាជសម្បត្តិទៅព្រះធម្មរាជាវិញ ព្រះបាទអង្គអិមមិនព្រម ព្រះចៅសៀមក៏ស្ងៀមនៅ ។

លុះដល់ គ.ស ១៧២២ ព្រះចៅសៀមចាត់កងទ័ពយ៉ាងធំមកច្បាំងនឹងព្រះបាទកែវហ្វាអង្គអិម យករាជសម្បត្តិថ្វាយព្រះធម្មរាជាវិញ ព្រះអង្គអិមលើកទ័ពមានទាំងសេនារេហ៍ពលយួនផង ទៅទទួលតយុទ្ធ (នៅខែត្រពោធិសាត់) ប៉ុន្តែព្រះអង្គអិមឈ្វេងយល់ថាជើងសឹកខាងសៀមខ្លាំងហួស ក៏មានព្រះរាជសព្វអក្សរទៅដល់មេទ័ពសៀមសុំឱ្យដកទ័ពថយទៅវិញ ឱ្យបង្ខាំងព្រះធម្មរាជាព្រមទាំងព្រះរាជបុត្រានឹងព្រះអង្គតន់ក៏ជាព្រះអនុជនៅឯស្រុកសៀម សន្យាថាដាក់នគរខ្មែរ ជាចំណុះប្រទេសសៀម មាន "ផ្កាមាស-ផ្កាប្រាក់" ជាសួយនាំទៅថ្វាយព្រះចៅក្រុងអយុធ្យា ។

តាំងពីកាលគ្រានោះមក សៀមចេះតែប្រកាន់ថានគរខ្មែរ ជានគរសួយប្រទេសសៀម ។

កិច្ចដែលព្រះកែវហ្វាអង្គអិម ទ្រង់ប្រកបដោយកិរិយាយ៉ាងនេះ បណ្ដាជនទូទៅអស់

www.budinst.gov.kh www.elibraryofcambodia.org

ទាម៉ឺនសព្វមុខមន្ត្រីធំពុំសប្បាយចិត្ត ថ្វាយព្រះនាមព្រះអង្គជា "ស្តេចសៀម" ព្រះអង្គក៏ដាក់រាជសម្បត្តិប្រទានមកព្រះរាជបុត្រនៃព្រះអង្គព្រះនាមព្រះអង្គជ័យ (ព្រះសត្ថា) ។

## ព្រះសត្ថាទី ២ (ព្រះនាមដើមព្រះអង្គជ័យ)

(ពី គ.ស ១៧២២ ដល់ ១៧២៩ - ពី ១៧៣០ ដល់ ១៧៣៦)

អំពីខែត្រវិញឡុង(លងហោរ) និងមិថរ (មេ-ស)បានទៅយួន(គ.ស១៧៣១)។

ព្រះសត្ថាទ្រង់សោយរាជសម្បត្តិ រហូតមកដល់ គ.ស ១៧២៩ ព្រះអង្គអិមជាព្រះវររាជបិតាមកយករាជសម្បត្តិវិញ បានតែរវាង ៧ ខែ បណ្តាជនពុំសូវសប្បាយចិត្ត ទ្រង់ក៏ដាក់រាជ្យថ្វាយមកព្រះសត្ថាវិញ ហើយទ្រង់យកទីឧបយោរាជរហូតទៅ (គ.ស ១៧៣០) ។

ព្រះសត្ថាទី ២ ទ្រង់ទទួលរាជសម្បត្តិឡើងវិញបានមួយឆ្នាំ (គ.ស ១៧៣១)មានលាវម្នាក់ភូមិប្រសូត (ក្នុងខែត្រស្វាយរៀងសព្វថ្ងៃ) អួតអាងថាជាអ្នកមានបុណ្យខ្លាំងពូកែបញ្ចុះបញ្ចូលរាស្ត្រលើកគ្នាទៅកាប់សម្លាប់យួន ព្រះសត្ថាទ្រង់បានជ្រាបក៏ចាត់ព្រះរាជបំរើឱ្យទៅហាមឃាត់ ប៉ុន្តែយួនបានឱកាសលើកទ័ពពីរលើកចូលមកច្បាំងនឹងនគរកម្ពុជា ចេះតែចាញ់ព្រះសត្ថា ក្នុងលើកក្រោយចយទៅវិញ តាំងជាប់នៅខែត្រវិញឡុង (លង់ហោរ) នឹងខែត្រមិថរ (មេ-ស) គ.ស ១៧៣១ ។

មកដល់ គ.ស ១៧៣៨ មិនដឹងជាមានបើអ្វី ព្រះសត្ថាសង្ស័យនឹងព្រះមហេសីនៃព្រះអង្គនិងព្រះរាជានុវង្សព្រះឧទ័យ (ជាព្រះរាជបុត្រនៃព្រះអង្គតន់)ព្រះអង្គស្ងួនក្រោយមកជាព្រះជ័យជេដ្ឋាទី ៥ និងព្រះអង្គច័ន្ទ (ព្រះរាជបុត្រនៃព្រះធម្មរាជា) ថានឹងផ្តួលចេញអំពីរាជ្យ ក៏ប្រារព្ធនឹងធ្វើគតព្រះមហេសីនិងព្រះរាជវង្សនេះ ។ភិតភ័យក៏ទៅកេណ្ឌកងទ័ពមកតយុទ្ធនឹងទ័ពព្រះសត្ថាបរាជ័យ ព្រះសត្ថាក៏ដោះព្រះអង្គចូលទៅឯដែនក្ងសាំងស៊ុនបាត់ទៅ ដោយមានទ័ពព្រះរាជវង្សត្រៀមផ្ទប់ផ្លូវមិនឱ្យវិលមកវិញបាន។ ជួនពេលនោះ ព្រះបាទធម្មរាជានិងព្រះអង្គតន់ក៏លើកទ័ពពីប្រទេសសៀមចូលនគរកម្ពុជាដែរ ព្រះស្រីសុជាតិមហេសីនៃព្រះសត្ថាទ្រង់ព្រះដំរិះប្រឹក្សានឹងនាម៉ឺនសព្វមុខមន្ត្រីទៅជួយព្រះធម្មរាជានិងព្រះអង្គតន់ សុំអញ្ជើញព្រះធម្មរាជាមកសោយរាជសម្បត្តិ

www.budinst.gov.kh www.elibraryofcambodia.org

វិញ (គ.ស ១៧៣៨) ។

ព្រះអគ្គមហេសីព្រះសត្ថាត្រូវជាព្រះមាតុលានៃព្រះអង្គ គឺព្រះរាជបុត្រីនៃព្រះជ័យជេដ្ឋាទី ៤- ជាព្រះរាជអនុជនៃព្រះធម្មរាជាទី ២) ។

## ព្រះធម្មរាជាទី ២ (រាជ្យលើកទី ២)

(ពី គ.ស ១៧៣៨ ដល់ ១៧៤៧)

-រាជ្យព្រះបាទធម្មរាជាលើកក្រោយនេះ បានសុខរហូតដល់ទ្រង់ព្រះសុវណ្ណគត។

-ទ្រង់លើកព្រះអង្គទងព្រះរាជអនុជជាព្រះឧបយោរាជ តាំងព្រះឧទ័យរាជបុត្រនៃព្រះអង្គទងជាព្រះឧបរាជ ឯព្រះអង្គអិមជារាជបុត្រច្បងតាំងជាព្រះកែវហ្វា ។

-ព្រះបាទធម្មរាជាទ្រង់ព្រះសុវណ្ណគត ក្នុង គ.ស ១៧៤៧ ក្នុងព្រះជន្ម៥៧វស្សា។

## ព្រះបាទធម្មរាជាអង្គអិម

(គ.ស ១៧៤៧)

ដល់ព្រះបាទធម្មរាជាទ្រង់សុវណ្ណគតទៅ ព្រះអង្គអិមជារាជបុត្រសោយរាជសម្បត្តិមក ទ្រង់ព្រះនាមជាព្រះធម្មរាជាអង្គអិម ។

ព្រះបាទធម្មរាជាអង្គអិមនេះហើយដែលជាព្រះរាជបុត្រច្បងកំសត់ ទៅគង់នៅឯប្រទេសសៀមជាមួយនឹងព្រះវររាជបិតា កាលព្រះបាទកែវហ្វាអង្គអិមដណ្តើមយករាជ្យ។

ព្រះបាទធម្មរាជាអង្គអិមទ្រង់សោយរាជសម្បត្តិបានតែរវាងមួយឆ្នាំ ព្រះរាជអនុជនៃព្រះអង្គព្រះនាមអង្គអិង ធ្វើគតព្រះអង្គ ។

(ព្រះអង្គអិងជាព្រះមាតាសៀម ហើយកាលព្រះរាជសុកាន្ត ព្រះវររាជបិតាប្រទានព្រះនាមជាព្រះស្រីសុរិយោ) ។

## ព្រះបាទអង្គឌិច

(ពី គ.ស ១៧៤៧ ដល់ ១៧៤៩)

ព្រះរាជានេះជាព្រះអនុជនៃព្រះបាទធម្មរាជាទី ២ ហើយដែលកំសត់នឹងគ្នា កាលគ្រាដែលព្រះកែវហ្វាអង្គអិមដណ្តើមយករាជសម្បត្តិពីព្រះបាទធម្មរាជាជាព្រះរៀម ។

www.budinst.gov.kh www.elibraryofcambodia.org

កាលបើព្រះអង្គអិងធ្វើគតព្រះបាទធម្មរាជាអង្គអិមរួចហើយ ព្រះអង្គអិងចង់យករាជសម្បត្តិ ប៉ុន្តែព្រះរាជវង្សានុវង្សទូវអស់នាម៉ឺនសព្វមុខមន្ត្រីពុំព្រម គេថ្វាយរាជសម្បត្តិមកព្រះអង្គទង (កាលពេលនោះព្រះអង្គទងព្រះជន្មបាន ៥៦វស្សា ទ្រង់ឧបយោរាជតាំងពី ១០ ឆ្នាំមកហើយ) ។

ព្រះអង្គទងទ្រង់រាជសម្បត្តិបានតែរវាងពីរឆ្នាំ ព្រះសត្ថាទី ២ ដែលសោយរាជ្យមុន ហើយដែលខ្ចាត់ទៅដែនកូសាំងស៊ីននោះ នាំកងទ័ពយួនចូលមកច្បាំងនឹងព្រះអង្គ (គ.ស ១៧៤៩) ព្រះសត្ថានេះ ក៏ត្រូវជាព្រះភគិនិយោនៃព្រះអង្គដែរ) ។

-មេកងទ័ពរបស់ព្រះអង្គទងពីរនាក់ (លោកក្រឡាឧក លោកឧកញ៉ាសួរតា លោកឧកចៅហ្វាយជីពោធិសាត់) ក៏បណ្ដោះព្រះអង្គឱ្យទៅគង់នៅឯដែនសៀម ទុកងារឱ្យលោកតយុទ្ធនឹងទ័ពព្រះសត្ថា ទ័ពយួនរបស់ព្រះសត្ថាក៏បាក់បរាជ័យចាញ់ទៅថយទេវិញ ហើយព្រះសត្ថាក៏ទ្រង់ទីវង្គតទៅ ។ រួចមេកងទ័ពប្រារព្ធឱ្យមានព្រះរាជាម្ចាស់ផែនដីឡើងវិញ ទៅសុំព្រះចៅក្រុងសៀមយកព្រះជ័យជេដ្ឋាទី ៥ (ព្រះអង្គស្ងួន) មកជាស្ដេចម្ចាស់ផែនដី ។

(ព្រះជ័យជេដ្ឋាទិ ៥ ឬព្រះអង្គស្ងួននេះជាព្រះរាជបុត្រនៃព្រះធម្មរាជាអង្គអិមដែលព្រះអង្គអិងធ្វើគត) ។

## ព្រះបាទជ័យជេដ្ឋាទី ៥ (ព្រះអង្គស្ងួន)

(ពី គ.ស ១៧៤៩ ដល់ ១៧៥៥)

(ព្រះបាទជ័យជេដ្ឋាទី ៥ ពេលទ្រង់ទទួលរាជសម្បត្តិ ព្រះជន្មបាន ៤២ ព្រះវស្សាទៅហើយ) ។

## - សារបានព្រះរាជា

ព្រះជ័យជេដ្ឋាទី ៥ ជាព្រះរាជបុត្រនៃព្រះបាទធម្មរាជាអង្គអិម ដែលព្រះអង្គអិងធ្វើគត ជាព្រះឧត្ដោនៃព្រះបាទធម្មរាជាទី ២ ។

ព្រះអង្គអិងជាព្រះរាជអនុជព្រះបាទធម្មរាជាអង្គអិម ប៉ុន្តែព្រះមាតាសៀម ។

-ព្រះបាទអង្គទងជាព្រះរាជអនុជនៃព្រះបាទធម្មរាជាទី ២ ។

www.budinst.gov.kh www.elibraryofcambodia.org

-ព្រះឧទ័យ (ទី១) ឧបរាជ ជាព្រះរាជបុត្រនៃព្រះអង្គទង ។

-ព្រះឧទ័យ(ទី២) ឬព្រះបាទឧទ័យអង្គតន់ ជាព្រះរាជបុត្រនៃព្រះឧទ័យទី ១ ។ ព្រះបាទឧទ័យអង្គតន់ ជាព្រះវររាជបិតានៃព្រះបាទអង្គអេង ។

## ពត៌មានក្នុងរាជ្យព្រះបាទជ័យជេដ្ឋាទី ៥

១-ព្រះជ័យជេដ្ឋាទី ៥ កាលបើទ្រង់រាជសម្បត្តិហើយ ទ្រង់តាំងលោកឧកញ៉ាសួរគា លោកឧកដែលមានសគុណការពារផែនដី ឈ្មោះយួនដែលជាកងទ័ពព្រះសត្ថាទី ២ នោះ ជាទីសម្តេចចៅហ្វា ប៉ុន្តែអស់នាម៉ឺនឯទៀតមានសេចក្តីច្រណែននិន្ទា រករឿងបង្ខុស ទូលព្រះរាជាថាលោកចៅហ្វាឧកចង់ក្បត់យករាជសម្បត្តិ ព្រះរាជាក៏ទ្រង់ព្រះសណ្តាប់តាម មានព្រះតម្រាស់ឱ្យធ្វើទណ្ឌកម្មលោកចៅហ្វាឧកផុតជីវិត លោកចៅហ្វាឧកបានដឹងសេចក្តីក៏ភៀសខ្លួន ចូលទៅក្នុងដែនសៀមទៅ ។

២-រវាងពីរឆ្នាំក្រោយមក (គ.ស ១៧៥១) មាននាម៉ឺនខ្មែរម្នាក់ (ឈ្មោះក្សត្រឯក) ដែលទៅជ្រកនៅដែនសៀម ចូលមកយកមនុស្សម្នាក់ឈ្មោះស្លួស ថាជាអ្នកសិល្បមានបុណ្យខ្លាំងពូកែកាប់មិនមុតបាញ់មិនចេញ ហើយមនុស្សខ្ទិនម្នាក់ទៀតលើកថាជាត្រកូលស្តេច នាំដើររាតត្បាតស្រុកបញ្ចុះបញ្ចូលរាស្ត្របានជាច្រើន (ប្រមាណ៣០០០នាក់) លើកជាកងទ័ពមកច្បាំងនឹងព្រះរាជាអម្ចាស់ផែនដី ។ ទ័ពហ្លួងក៏លើកទៅវាយខ្ចាត់ខ្ចាយអស់ ចាប់បានមេបះទាំងប៉ុន្មានសម្លាប់ចោលអស់ ប៉ុន្តែយូរដែរ ។

៣-ព្រះបាទអង្គទងដែលមិនសោយរាជ្យវិញ ក៏ទ្រង់ស្តេចមកគង់នៅឧដុង្គ ជាមួយនឹងព្រះបាទជ័យជេដ្ឋាទី ៥ នេះជាព្រះភាគិនេយ្យា ។

៤-ព្រះមហាឧបរាជឧទ័យទ្រង់ឈប់ស្តីទីជាឧបរាជ ទៅទ្រង់ព្រះផ្នួសនៅឯអង្គរវត្តរហូតលុះតែទ្រង់ព្រះសុវណ្ណគត ព្រះរាជបុត្រនៃព្រះអង្គក៏ទ្រង់ព្រះនាមជាព្រះឧទ័យដែរ (ព្រះឧទ័យទី ២) ឬព្រះអង្គតន់ ទទួលទីមហាឧបរាជស្នងឡើង ។

ព្រះបាទជ័យជេដ្ឋាទី ៥ ទ្រង់ព្រះរាជសុវណ្ណគតក្នុងព្រះជន្ម ៤៦ វស្សា (គ.ស ១៧៥៥ សោយរាជសម្បត្តិជាប់ ៧ ឆ្នាំ) ។

www.budinst.gov.kh www.elibraryofcambodia.org

## ព្រះបាទអង្គទង (រាជ្យលើកទី ២)

(ពី គ.ស ១៧៥៦ ដល់ ១៧៥៧)

ព្រះបាទជ័យជេដ្ឋាទិ ៥ ទ្រង់ព្រះសុវណ្ណគតទៅ ។ ក្រុមបាវគូនិងអស់សេនាបតី ជំនុំព្រមសម្រេចថ្វាយរាជសម្បត្តិមកព្រះបាទអង្គទងវិញ (ព្រះបាទសម្តេចព្រះរាមាធិបតី ព្រះជន្ម ៥៧ វស្សា) (គ.ស ១៧៥៦) ។

ក្រោយនោះព្រះអង្គអិងស្រីសុរិយោ ដែលបានធ្វើគតព្រះបាទធម្មរាជាអង្គអិមនោះ ប្រើមនុស្សឱ្យទៅលុកមហាឧបរាជ ឧទ័យអង្គតន់ (ព្រះឧទ័យទី ២) នោះសម្តេចព្រះ ឧទ័យអង្គតន់ ស្តេចដោះព្រះអង្គចេញពីក្រុងឧដុង្គ ស្តេចទៅគង់ឯខែត្រពាម (ហា ទៀងសព្វថ្ងៃ) ជាមួយនឹងសម្តេចព្រះសុទាត់ ជាព្រះធម៌បិតា ។លើកទ័ពមកច្បាំងនឹង ព្រះអង្គអិងស្រីសុរិយោឯក្រុងឧដុង្គ ។ (សម្តេចព្រះសុទ័ត គឺចិនព្រះនាម "ម៉ាក់តុង" ជាបុត្រនៃ "ម៉ាក់គិវ" ដែលចូលមកនគរកម្ពុជា សុំតាំងធ្វើជាអ្នកមេល្បែងស៊ីសង រួច ក្រោយមកបានតាំងជាសម្តេចរាជានៅពាម) ។

ទ័ពព្រះសុទ័តនិងទ័ពសម្តេចព្រះឧទ័យរាជាអង្គតន់ លើកពីដែនកួសាំងស៊ីនមក វាយទ័ពព្រះអង្គអិងសុរិយោខ្ចាត់ខ្ចាយអស់ ធ្វើគតព្រះអង្គអិងទាំងព្រះរាជវង្ស រួចតែព្រះ អង្គនន់ជាព្រះរាជបុត្រនៃព្រះជ័យជេដ្ឋាទី ៥ ដោះព្រះអង្គរួចចូលទៅក្នុងដែនសៀម ។ (រីឯព្រះអយ្យកោ គឺព្រះបាទសម្តេចព្រះអង្គទង ទ្រង់ចាកក្រុងឧដុង្គ ស្តេចទៅគង់ឯ ពោធិ៍សាត់ ហើយទ្រង់ព្រះរាជសុវណ្ណគតនៅទីនោះ ក្នុងព្រះជន្ម ៦៥ វស្សា) ។

## ព្រះបាទឧទ័យអង្គតន់ (ព្រះឧទ័យទី ២)

(ពី គ.ស ១៧៥៨ ដល់ ១៧៧៥)

អំពីខែត្រស្រុកត្រាំង (ស្រុកឃ្លាំង) និងខែត្រត្រាវិញ (ព្រះត្រពាំង) បានទៅ យួន ។

កាលបើសម្តេចព្រះឧទ័យអង្គតន់ទ្រង់មានជ័យជំនះ លើព្រះអង្គអិងស្រីសុរិយោ ហើយទ្រង់គ៏ឡើងសោយរាជសម្បត្តិ ទ្រង់ព្រះនាមថា (ព្រះនារាយណ៍រាជាធិរាជរាមា ធិបតី) ។

www.budinst.gov.kh www.elibraryofcambodia.org

កាលបើសម្ដេចព្រះឧទ័យអង្គតន់ ទ្រង់រាជសម្បត្តិហើយ ហើយដើម្បីឱ្យបានសេចក្ដីសុខនឹងយួននៅដែនភ្នំសាំងស៊ីន ដែលនៅក្នុងព្រះរាជអាណាចក្រនៃព្រះសុទ័តជាព្រះធម៌បិតា ទ្រង់ក៏ឱ្យយួនតាំងនៅខែត្រត្រាំង (ស្រុកឃ្លាំង) និងខែត្រត្រាវិញ (ព្រះត្រពាំង) ប៉ុន្តែយួនមិនចេះស្កប់ ចូលមករានបោះបន្ទាយទៀតផង នៅដែនសាដែក (ខែត្រផ្សារដែក) ភ្នំឡៅយ៉ាង (កោះតែង) និងចូដុក (មាត់ជ្រូក) ។

លុះវិលងពីដើមរាជ្យព្រះអង្គបានប្រមាណ ៧ឆ្នាំ (ក្នុង គ.ស ១៧៦៥) នៅប្រទេសសៀមមានកើតវិបរិតជាធំក្រៃលែង រាជសម្បត្តិក្រឡាប់បានមកចៅហ៊្វា ខែត្រមេទ័ពកូនកាត់ចិនហៃហុងម្នាក់ ទ្រង់នាមពញាតាក់ ។ ផ្លាស់ព្រះរាជធានីពីស្រីអយុធ្យាមកគង់នៅក្រុងបឹងកក ហើយមានព្រះរាជសុភអក្សរមកព្រះបាទសម្ដេចព្រះឧទ័យអង្គតន់ ឱ្យស្ដេចទៅចំណុះជាស្លួយ ព្រះបាទសម្ដេចព្រះឧទ័យអង្គតន់ទ្រង់រឹងមានះតាមជាតិក្សត្រ ។

លុះរវាង គ.ស ១៧៦៩ ពញាតាកក៏ញុះ នាំព្រះអង្គនន់ដែលរត់ទៅជ្រកនៅដែនសៀមនោះលើកទ័ពយ៉ាងធំ មកច្បាំងនឹងព្រះបាទសម្ដេចព្រះឧទ័យអង្គតន់ផ្លូវតាមជើងទឹកផង (មកតាមសមុទ្រ) តាមជើងគោកផង ព្រះឧទ័យអង្គតន់ក៏ស្ដេចដោះព្រះអង្គចេញពីក្រុងឧដុង្គ ទៅគង់នៅព្រៃនគរ ។

ទ័ពសៀមនិងព្រះអង្គនន់លើកច្បាំងនឹងសម្ដេចព្រះឧទ័យអង្គតន់ ជាច្រើនលើកច្រើនគ្រា រាស្ត្រអ្នកស្រុកដល់នូវសេចក្ដីវេទនាណាស់ ។ ព្រះបាទសម្ដេចព្រះឧទ័យអង្គតន់ ក៏ទ្រង់បារម្ភដាក់រាជសម្បត្តិថ្វាយមកព្រះអង្គនន់ សៀមក៏តាំងធ្វើព្រះរាជពិធីប្រាប្តាភិសេកថ្វាយព្រះបាទអង្គនន់ឡើង (គ.ស ១៧៧៥) ។

ព្រះបាទសម្ដេចព្រះឧទ័យអង្គតន់ទ្រង់ឧបយោរាជ ។

ព្រះបាទសម្ដេចព្រះឧទ័យអង្គតន់ ទ្រង់ប្រកបនូវព្រះរាជធម៌ មានព្រះទ័យករុណាដល់អាណាប្រជានុរាស្ត្រណាស់ ទ្រង់ស៊ូតែដាក់រាជសម្បត្តិឱ្យទៅព្រះអង្គនន់ កុំឱ្យតែរាស្ត្រមានសេចក្ដីវេទនា ។

**សេចក្តីពិស្តារ**- ព្រះអង្គ(តន់)ជាព្រះរាជនត្តា ព្រះបាទសម្ដេចព្រះរាមា ធិបតីអម្ចាស់ដែនដីក្រុងកម្ពុជា ជាព្រះរាជបុត្រសម្ដេចព្រះឧទ័យរាជាមហាឧបរាជក្រុងកម្ពុជា ។

www.budinst.gov.kh www.elibraryofcambodia.org

ក្រោយនោះសម្តេចព្រះឧទ័យរាជាជាមហាឧបរាជ ជាព្រះវរបិតាសុគតទៅ ព្រះបាទសម្តេចព្រះរាមាធិបតី ជាព្រះបរមរាជអយ្យកោ ទ្រង់តាំងព្រះអង្គតន់ ព្រះរាជនត្តាឡើងជាសម្តេចព្រះឧទ័យរាជា មហាឧបរាជស្នងព្រះវរបិតា នោះព្រះអង្គ "អឹង" ព្រះស្រីសុរិយោ ប្រើមនុស្សឱ្យទៅលុកសម្តេចព្រះឧទ័យរាជាមហាឧបរាជអង្គ "តន់" នោះសម្តេចព្រះឧទ័យរាជាអង្គ "តន់" ស្តេចដោះព្រះអង្គចេញពីក្រុងឧដុង្គ ស្តេចទៅគង់ឯខែត្រពាមជាមួយនឹងសម្តេចសុទ័តជាព្រះធម៌បិតា ព្រះធម៌បិតាលើកទ័ពទៅច្បាំងនឹងព្រះស្រីសុរិយោព្រះអង្គ "អឹង" ឯក្រុងឧដុង្គ ។

ឯសម្តេចព្រះឧទ័យរាជាព្រះអង្គ "តន់" ស្តេចចេញពីខែត្រពាមលើកផ្លូវមាត់ជ្រូកចុះព្រះទីនាំងនាវាសង្កត់រាស្ត្រ តាមខែត្រជាយទន្លេរៀងដល់ខែត្រភ្នំពេញរហូតដល់ក្រុងឧដុង្គ ឯសម្តេចព្រះស្រីសុរិយោព្រះអង្គ "អឹង" រត់ទៅអាស្រ័យនៅស្រុកព្រៃក្តី សម្តេចព្រះកែវហ្វាព្រះអង្គ "ខ្វង" រត់ទៅទ្រង់ព្រះផ្នួសនៅវត្តស្មៀង អ្នកអង្គ "ទង" អ្នកអង្គ "ជី" រត់ទៅទ្រង់ព្រះផ្នួសឯវត្តព្រៃ ។

ព្រះបាទសម្តេចព្រះរាមាធិបតី អម្ចាស់ផែនដីក្រុងកម្ពុជា បានទ្រង់ជ្រាបហើយត្រាស់បង្គាប់ឱ្យលើកទាហានទៅចាប់ សម្តេចព្រះស្រីសុរិយោ "ព្រះអង្គអឹង" ពីស្រុកព្រៃក្តី ហើយឱ្យទៅផ្សឹកព្រះកែវហ្វា ព្រះអង្គ "ខ្វង" នាំទៅសំរេចនោះ ។

សម្តេចព្រះឧទ័យរាជាអង្គ "តន់" ស្តេចឡើងទៅថ្វាយបង្គំ ព្រះបាទសម្តេចព្រះរាមាធិបតី ជាព្រះបរមរាជអយ្យកោនៅឯព្រះបរមរាជវាំងក្រុងឧដុង្គឫជ័យ គង់ព្រះរាជវាំងភាក់ នោះសម្តេចព្រះជាតិស្ត្រីព្រះជាយា ព្រះស្រីសុរិយោព្រះអង្គអឹង ប្រើសម្តេចចៅ "ពៅ" និងឧកញ៉ាវង្សាធិរាជ "សោម" ឱ្យលុកព្រះសម្តេចឧទ័យរាជាព្រះអង្គតន់ នោះព្រះអង្គតន់ស្តេចដោះព្រះអង្គចេញពីក្រុងឧដុង្គទៅកំពង់ឆ្នាំង ចុះព្រះទីនាំងនាវាមកគង់ឯត្រើយពោធិព្រះបាទ ស្តេចឱ្យលើកទ័ពទៅច្បាំងនឹងសម្តេចចៅហ្វា "ពៅ" ។

ព្រះបាទសម្តេចព្រះរាមាធិបតី អម្ចាស់ផែនដីក្រុងកម្ពុជាបានទ្រង់ជ្រាបហើយត្រាស់បង្គាប់ឱ្យចាប់ពួកកការកម្មវីបធ្វើទោស ព្រះអង្គ "ទន់" រត់រួចរហូតទៅដល់ស្រុកស្យាម ឯអង្គ "ជី" ព្រះបាទជាអម្ចាស់ផែនដីទ្រង់ឱ្យសម្រេចទោសក្នុងក្រុងឧដុង្គ ។

ព.ស ២៣០០ ច.ស ១១២០ ឆ្នាំខាលសំរិទ្ធិស័ក ព្រះបាទសម្តេចព្រះរាមាធិបតី

www.budinst.gov.kh www.elibraryofcambodia.org

អម្ចាស់ផែនដីក្រុងកម្ពុជា ទ្រង់ព្រះសុវណ្ណកត សម្ដេចព្រះឧទ័យរាជាមហាឧបរាជឡើងសោយរាជសម្បត្តិ ស្នងព្រះបរមរាជអយ្យកោ ទ្រង់ព្រះនាមព្រះបាទសម្ដេចព្រះនារាយណ៍រាជាធិរាជរាមាធិបតី ព្រះស្រីសុរិយោ បរមសុរិន្ទ្រ ។

ព.ស ២៣១០ ច.ស ១១២៩ ឆ្នាំកុរនព្វស័ក ក្រុងស្រីអយុធ្យាបែកបានទៅកុមារផុត្តវង្ស ក្សត្រិយស្យាម ក្រោយនោះមានកូនចិនហៃហុងធ្វើជាចៅហ្វាយស្រុកតាកបញ្ចុះបញ្ចូលនាម៉ឺននិងរាស្ត្របានច្រើន បង្កើតឡើងជាទ័ពច្បាំងនឹងកុមារ បានស្រីក្រុងអយុធ្យាត្រឡប់មកវិញ ពញាតាកឡើងសោយរាជសម្បត្តិតាំងក្រុងធនបុរី មានសព្វអក្សរមកបង្គាប់ឱ្យក្រុងកម្ពុជានាំសួយទៅថ្វាយ ។

ព្រះបាទសម្ដេចព្រះនារាយណ៍រាជាធិរាជរាមាព្រះអង្គតន់ មានសព្វអក្សរតបទៅវិញថា មិនព្រមថ្វាយសួយ មិនព្រមទទួលស្គាល់ជាក្សត្រម្ចាស់ផែនដី ព្រះចៅរាមាក្រុងធនបុរី បានទទួលសព្វអក្សរបានជ្រាបសេចក្ដីហើយ ទ្រង់ពិរោធឱ្យពញាអភ័យរណរិទ្ធិពញាអនុជិតរាជា ជាមេទ័ព មានបង្គាប់ឱ្យយកព្រះអង្គ "នន់" ស្ដេចខ្មែរមកជាមួយផងលើកមកតាមផ្លូវខែត្រ បសឹមបុរី ឱ្យពញាកោសាជាមេទ័ព ១ ទៀតលើកមកវាយខែត្រនគរសៀមរាប ។

ព្រះបាទសម្ដេចព្រះនារាយណ៍រាជាអម្ចាស់ផែនដី ក្រុងកម្ពុជាធិបតីបានទ្រង់ជ្រាបហើយ ត្រាស់បង្គាប់ឱ្យកងទ័ពឱ្យពញាក្រឡាហោម ជាមេទ័ពលើកទៅទទួលច្បាំងឯខែត្របាត់ដំបង ព្រះបាទសម្ដេចព្រះនារាយណ៍រាជាអម្ចាស់ផែនដី ស្ដេចចេញជាមេពលទៅទទួលច្បាំងឯខែត្រនគរសៀមរាប ខាងទ័ពចៅពញាអភ័យរណប្ញទ្ធិសង្កត់បាន ខែត្របាត់ដំបងនិងស្រុកយើង . . .

ក្រោយនោះព្រះសុទ្ធទូ សំរេចរាជការស្រុកពាម បញ្ចូលបានច្រើនតាំងឡើងជាទ័ពលើកទៅវាយខែត្រក្រាត ខែត្រចន្ទបុរី កៀរគ្រួបានមកជាច្រើន . . .

ព្រះចៅរាមាក្រុងធនបុរី បានជ្រាបហើយ ត្រាស់បង្គាប់ឱ្យចាត់កងទ័ពសថលមាគ៍ជលមាគ៌ ឱ្យយកព្រះអង្គ "នន់" ស្ដេចខ្មែរមកជាមួយផង . . .

ខាងទ័ពទូកព្រះចៅរាមាក្រុងធនបុរីជាពលលើកមក តាមផ្លូវសមុទ្រវាយខែត្រពាមបន្ទាយមាស លើកចូលមកតាមព្រែក រហូតដល់ខែត្រភ្នំពេញ . . .

www.budinst.gov.kh www.elibraryofcambodia.org

ខាងទ័ពចៅពញាចក្រីវាយបានខែត្របាត់ដំបង ពោធិ៍សាត់ ខែត្របរិបូណ៌ រហូតដល់ក្រុងឧដុង្គ . . .

ព្រះបាទសម្តេចព្រះនារាយណ៍រាជា "ព្រះអង្គតន់" អម្ចាស់ផែនដីក្រុងកម្ពុជាទ្រង់ព្រះដំរិះ ឃើញជាជើងសឹកខ្លាំងហួស ក៏ដោះព្រះអង្គស្តេចចេញពីក្រុងកម្ពុជាទៅស្រុកព្រៃនគរ . . .

ឯទ័ពចៅពញាចក្រីលើកទៅវាយខែត្របាត់ដំបងមួយទៀត ហើយលើកសទ្ធប់ទ័ពព្រះចៅក្រុង "ធនបុរី" តាំងព្រះអង្គ "ទន់" ឱ្យជាម្ចាស់ផែនដីក្រុងកម្ពុជា ឱ្យតាំងនៅខែត្រកំពត ព្រះចៅក្រុងធនបុរីតាកសិន លើកទ័ពត្រឡប់ទៅវិញទុកនាម៉ឺនសៀមឱ្យនៅរក្សា ព្រះអង្គ "ទន់" ហើយតាំងនាម៉ឺនសៀម ឱ្យជាចៅហ្វាយខែត្របន្ទាយមាស តាំងនាម៉ឺនសៀមឱ្យធ្វើជាព្រះរាជអាជ្ញាហ្លួងត្រួតត្រារក្សាខែត្រកំពត ខែត្របាត់ដំបង ខែត្រនគរសៀមរាប ខែត្រពោធិ៍សាត់ ខែត្របាភ្នំ ។

ចៅពញាចក្រីលើកទ័ពត្រឡប់ទៅវិញ កៀរគ្រួខ្មែរយកទៅជាច្រើន ។

ព្រះបាទសម្តេចព្រះនារាយណ៍រាជាព្រះអង្គ "តន់" ស្តេចត្រឡប់ពីស្រុកព្រៃនគរមកវិញ គង់នៅព្រែកពាក់ព្រ័ត្រទ្រង់មានព្រះរាជហឫទ័យនឿយណាយនឹងការព្រះរាជសង្គ្រាម ទើបដាក់ព្រះអង្គជាឧបយោរាជ ។

ព្រះចៅរាមាក្រុងធនបុរី ចាត់ខាងហ្លួងឱ្យចេញមករៀប អភិសេកព្រះអង្គ "ទន់" ជាម្ចាស់ផែនដី ក្រុងកម្ពុជាធិបតី . . .

**សម្តេចក្សត្រី មាលិកា**

សម្តេចព្រះបាទឧទ័យអង្គតន់ ទ្រង់ព្រះរាជសុវណ្ណគតក្នុង គ.ស ១៧៧៧ (ក្នុងព្រះជន្ម ៣៨ វស្សា) ។

## ព្រះបាទអង្គទន់ទី ២

(ពី គ.ស ១៧៧៥ ដល់ ១៧៧៩)

ព្រះរាជានេះជាព្រះរាជបុត្រនៃព្រះបាទជ័យជេដ្ឋាទី ៥ ។

វិបុលរាជស្រី

www.budinst.gov.kh www.elibraryofcambodia.org

ទែន ចៅហ្វាយខែត្រកំពង់ស្វាយ
ពាង ចៅហ្វាយស្រុកបាភ្នំណី
សំ ចៅហ្វាយស្រុកព្រៃក្តី
ចៅហ្វាមូ ចៅហ្វាយខែត្រទ្រាំង
} ជាកូនជំទាវឡង់

ព្រះបាទអង្គនន់ កាលបើសោយរាជសម្បត្តិហើយ មាននាម៉ឺនម្នាក់ឈ្មោះស្រីស្តីទិវិបុលរាជ ភ្ជួយក្រឡាហោមប្រាថ្នានឹងធ្វើគតព្រះអង្គ លុះដល់រឿងនេះបែកការណ៍ព្រះរាជាឱ្យចាប់វិបុលរាជស្រី ដាក់ឱ្យចៅក្រមជំនុំជំរះ ចៅក្រមធ្វើទណ្ឌកម្មឱ្យសម្លាប់វិបុលរាជស្រី ។ ជំទាវឡង់ជាម្តាយវិបុលរាជស្រី ក៏ប្រមូលកូនប្រុសប្អូននាក់ឯទៀតគឺ ទែន ពាង សំ មូ ហើយបង្គាប់ឱ្យសងសឹកព្រះបាទអង្គនន់ ។ ទទួលពេលនោះស្តេចសៀមពញាតាកលើកទ័ពទៅច្បាំងនឹងលាវ ហើយឱ្យព្រះរាជាខ្មែរជួយព្រួត ព្រះអង្គនន់ក៏កេណ្ឌកងទ័ពខ្មែរទៅជួយ ហើយឱ្យយកស្រូវអ្នកស្រុក ឱ្យវាយបង្ខំរាស្ត្រ ស្រីឱ្យបុកអង្ករបញ្ជូនទៅឱ្យកងទ័ព កើតក្តីក្តៅក្រហាយនាម៉ឺននិងរាស្ត្រចូលដៃគ្នាលើកជាកងទ័ពមកច្បាំងចាប់ព្រះអង្គនន់ យកទៅផ្ទេងទឹកបឹងក្សិណក្ស័យព្រះជន្មទៅ គ.ស ១៧៧៩។ ក្នុងកងទ័ពនេះមានចៅហ្វាមូមានរិទ្ធិខ្លាំងពូកែជាងគេ ។ ពេលនោះកងទ័ពចូលលុកក្រុងឧដុង្គ អញ្ជើញយកព្រះអង្គអេងព្រះជន្មទើបបាន ៦វស្សាមកនឹងថ្វាយរាជសម្បត្តិ ។

**សេចក្តីពិស្តារ** - ផែនដីសម្តេចព្រះរាជាព្រះអង្គនន់

នាម៉ឺននិងរាស្ត្រមានសេចក្តីក្តៅក្រហាយនឹងម្ចាស់ផែនដី ព្រះអង្គនន់ឱ្យកេណ្ឌរាស្ត្រខ្មែរ ឱ្យទៅជួយសៀមច្បាំងនឹងលាវ ហើយវាយបង្ខំរាស្ត្រស្រីៗ ឱ្យបុកអង្ករបញ្ជូនទៅស្រុកលាវ នាម៉ឺននិងរាស្ត្រចូលដៃគ្នាចាប់សម្តេចព្រះនាមរាជាព្រះអង្គនន់ ម្ចាស់ផែនដីក្រុងកម្ពុជាដែលសៀមតាំងនោះផ្ទេងទឹកបឹងខ្យងក្ស័យព្រះជន្មទៅ នាម៉ឺននិងរាស្ត្រលើករាជសម្បត្តិក្រុងកម្ពុជាថ្វាយទៅព្រះអង្គអេង ជារាជបុត្រព្រះបាទសម្តេចព្រះនារាយណ៍រាជាព្រះអង្គតន់ ឆ្នាំកុរឯកស័ក ព.ស ២៣២២ ច.ស ១២០១ ។

ព្រះអង្គអេង ព្រះជន្ម ៦ ឆ្នាំឡើងគ្រងរាជសម្បត្តិជាអម្ចាស់ផែនដីក្រុងកម្ពុជា

www.budinst.gov.kh www.elibraryofcambodia.org

សម្តេចចៅហ្វាមូ លើកខ្លួនឡើងជាសម្តេចចៅហ្វាមហាបពិត្រ ឱ្យឧកញ៉ាវិបុលរាជសេនា "សួ" ជាសម្តេចចៅពញា ឱ្យឧកញ៉ាយោមរាជ "បែន" ទៅនៅជាមួយនឹងឧកញ៉ាតេជោ "ទែន" ឯខែត្រកំពង់ស្វាយ ទៅនៅខែត្របាត់ដំបង ធ្វើសំបុត្រប្តឹងចូលទៅក្រុងធនបុរី តាមប្រព្រឹត្តហេតុសឹងកើតឡើងក្នុងក្រុងកម្ពុជាធិបតី ។

ព្រះចៅរាមាក្រុងធនបុរីបានជ្រាបហើយ មានបង្គាប់មកឱ្យបញ្ជូនខ្លួនឧកញ៉ាយោមរាជបែន ចូលទៅក្រុងធនបុរី ហើយត្រាស់ប្រើឧកញ៉ាមហាក្សត្រសឹកជាមេទ័ពកាន់អាជ្ញាសិទ្ធិ ឱ្យឧកញ៉ាសួរសិហ៍ពិស្ណុវាទីរាជជាទ័ពមុខ ហើយឱ្យព្រះរាជបុត្រក្រុមខយុនឥន្ទ្រពីធ៌ត្រលាផ្នួស ឱ្យមកជាមួយនឹងពញាកំហែងសង្គ្រាម ចៅហ្វាយស្រុកនគររាជសីមាជាភៀកភាយទ័ពឱ្យពញានគរសុវណ្ណជាយោក្បាត់ទ័ព ឱ្យក្រុមយុនរាមភូបែសជាកងក្រោយ ឱ្យពញាធរអាជ្ញាកងលំអៀងទាំង ៦ ទ័ពឱ្យលើកមកវាយក្រុងកម្ពុជាធិបតី ។

ចៅពញាមហាក្សត្រសឹកលើកទ័ពចេញពីក្រុងធនបុរី សុំយកឧកញ៉ាយោមរាជ "បែន" ខ្មែរមកជាមួយផង កាលមុនចៅពញាមហាក្សត្រសឹកនឹងលើកទ័ពចេញមកនោះ ព្រះចៅរាមាក្រុងធនបុរីទ្រង់បណ្តាំថាឱ្យចាប់ខ្លួនចៅហ្វាទលហៈ និងនាម៉ឺនដែលជាស្ម័គ្រព័ន្ធកាប់ចោលឱ្យអស់ ប្រាប់ប្រាមរៀបទ័ព ហើយឱ្យចៅពញាមហាក្សត្រសឹកតាំងក្រុមយុនឥន្ទ្រពីធ៌ត្រ រាជបុត្រព្រះចៅរាមាក្រុងធនបុរី ឱ្យគ្រងក្រុងកម្ពុជាធិបតីជាស្រេចទៅ។ ចៅពញាមហាក្សត្រសឹក "ឌួង" លើកទ័ពមកតាំងទ័ពនៅខែត្រនគរសៀមរាប ពញាសួរសិហ៍ពិស្ណុវាទីរាជ "ប៊ុន" តាំងទ័ពនៅខែត្របាត់ដំបង ក្រុមយុនឥន្ទ្រពីធ៌ត្រ និងពញានគររាជសីមា ក្រុមយុនរាមភូបែសនិងពញានគរសវណៈ តាំងទ័ពនៅខែត្រកំពង់ស្វាយ ។

ឯសម្តេចចៅហ្វាមូ បានដឹងថាទ័ពសៀមលើកមកជាច្រើន ក៏ដោះមកនៅខែត្រភ្នំពេញ មានសំបុត្រទៅសុំកងទ័ពយួនឱ្យមកជួយ ។ ចំណែកខាងក្រុងស្យាមព្រះចៅក្រុងធនបុរី អង្គុយព្រះកម្មដ្ឋាន សំគាល់ព្រះអង្គថាបានសំរេចសោតាបត្តិផលប្រព្រឹត្តវិបរិតផ្សេងៗ មាននាម៉ឺនខ្លះលើកទាហានព្រះរាជវាំង ព្រះចៅក្រុងធនបុរីទទួលសារភាពសុំចេញទៅបួស ។

ឯចៅពញាមហាក្សត្រសឹក សឹងតាំងទ័ពនៅខែត្រនគរសៀមរាបក្រុងកម្ពុជាធិបតី

www.budinst.gov.kh www.elibraryofcambodia.org

បានដឹងហេតុពីក្រុងធនបុរីដូច្នោះ ក៏លើកទ័ពត្រឡប់ចូលទៅក្រុងស្យាម អស់នាម៉ឺននិងរាស្ត្រអញ្ជើញឱ្យឡើងសោយរាជសម្បត្តិជាអម្ចាស់ផែនដីក្រុងស្យាម ឱ្យរឹបព្រះចៅរាមា "តាកសិន" សឹងបួសនៅវត្តនោះមកជំនុំជំរះសំរេចទោសដាក់ប្រហារជីវិត តាំងក្រុងរត្នកោសិន ។

កាលចៅពញាមហាក្សត្រសឹកលើកចេញពីក្រុងកម្ពុជាទៅក្រុងស្យាម ទុកឧកញ៉ាយោមរាជ "បែន" ខ្មែរឱ្យទៅចាត់ការប្រាប់ប្រាមក្នុងក្រុងកម្ពុជាធិបតីផ្តាំឱ្យចាប់ខ្លួនសម្តេចចៅហ្វា "មូ" និងនាម៉ឺនដែលស្ម័គ្របក្សពួកនោះសម្លាប់អស់ទៅ ហើយលើកទៅចាប់ខ្លួនឧកញ៉ាតេជោ "បែន" តាំងខ្លួនឡើងជាសម្តេចចៅហ្វាមហាបពិត្រ សម្រេចរាជការក្រុងកម្ពុជាធិបតី តាំងឧកញ៉ាវិបុលរាជសេនា "សួ" ឱ្យជាសម្តេចចៅពញា។ ឯចៅហ្វា "បែន" និងចៅពញា "សួ" ជាសំឡាញ់ផឹកទឹកសម្បថនឹងគ្នាធ្វើការអ្វីៗ រួមចិត្តគំនិតតួជាមួយ ។

ក្រោយនោះឧកញ៉ាមហាទេព ១ ឧកញ៉ាអរជូនចៅហ្វាយខែត្រត្បូងឃ្មុំកេណ្ឌរាស្ត្រខ្មែរ-ជ្វា-ចាម ក្នុងខែត្រត្បូងឃ្មុំ លើកទ័ពចូលមកក្នុងខែត្រភ្នំពេញ ដើម្បីនឹងចាប់ខ្លួនសម្តេចចៅហ្វាបែន និងឧកញ៉ាក្រឡាហោម "ប៉ុក" ។ នោះសម្តេចចៅហ្វា "បែន" និងឧកញ៉ាក្រឡាហោម "ប៉ុក" យល់ឃើញថានឹងតស៊ូមិនបាន ដោយមិនបានរៀបការទឹងច្បាំង ទើបអញ្ជើញព្រះអង្គ "អេង" អម្ចាស់ផែនដីនិងសម្តេចព្រះជំទាវមហាក្សត្រិយ៍ និងព្រះរៀមក្សត្រីទាំង ៣ ព្រះអង្គស្តេចចូលទៅក្រុងទេព ។

ក្រោយនោះក្រុងកម្ពុជាបានសាន្តត្រាណហើយ អស់នាម៉ឺនសព្វមុខមន្ត្រីខ្មែរមានសំបុត្រប្តឹងទៅក្រុងទេពសុំព្រះអង្គ "អេង" ឱ្យចេញមកជាម្ចាស់ផែនដីក្រុងកម្ពុជា ព្រះបាទសម្តេចព្រះយ៉តហ្វាព្រះចៅក្រុងស្យាមមិនបើកឱ្យព្រះអង្គ "អេង" ស្តេចចេញមកថាស្ថិតនៅកុមារតូចណាស់ តាំងសម្តេចចៅហ្វា "បែន" ឱ្យងារជាចៅពញាអភ័យភូបែសឱ្យចេញមកតាំងក្រុងកម្ពុជាធិបតី ។

ក្នុងឆ្នាំរោង ព.ស ២៣២៧ ច.ស ១១៤៦ ចៅពញាអភ័យភូបែស "បែន" ប្រើឧកញ៉ាព្រះខ្មែរ ឱ្យអញ្ជើញព្រះខ័នជ័យសិរីក្រុងកម្ពុជាទៅថ្វាយព្រះបាទសម្តេចព្រះពុទ្ធយ៉តហ្វា ព្រះចៅក្រុងស្យាម ខាងស្យាមថាព្រះខ័ននោះពីព្រះបទុមសិរីវង្ស ក្នុងប្រវត្តិ

www.budinst.gov.kh www.elibraryofcambodia.org

ព្រះន័ននោះថា ពួកអ្នកប្រមង់រើសបានពីក្នុងទន្លេសាប ។

សម្ដេចក្សត្រី មាលិកា

## ព្រះបាទសម្ដេចព្រះអង្គអេង (១)

(ពី គ.ស ១៧៧៩ ដល់ ១៧៩៦)

ព្រះបាទសម្ដេចព្រះអង្គអេង ជាព្រះរាជបុត្រនៃព្រះបាទឧទ័យអង្គធំ ។

សម្ដេចចៅហ្វ៊ាប៉ុកជាព្រះធម្មបិតានៃព្រះបាទអង្គអេង ។

យោមរាជបែនក្បត់នៃត្រពាត់ដំបងនិងសៀមរាបបានទៅសៀម(គ.ស ១៧៩៤)។

កាលបើធ្វើគតព្រះអង្គនន់រួចហើយ ចៅហ្វ៊ាមូតាំងខ្លួនជាសម្ដេចចៅហ្វ៊ាកាន់កាប់រាជការផែនដី វិបុលរាជស្ងួជាសំឡាញ់ជាក្រឡាហោម (ក្រសួងសឹកសង្គ្រាមជើងទឹក) លោកពាងជាចក្រី (ក្រសួងសឹកសង្គ្រាមជើងគោក) លោកទែនជាស្ដេចត្រាញ់ដីកំពង់ស្វាយឡើងវិញ លោកប៉ុកដែលជាព្រះធម្មបិតានៃព្រះបាទសម្ដេចព្រះអង្គអេងជាឧកញ៉ាវាំង (ក្រសួងកិច្ចការក្នុងព្រះរាជវាំង) អញ្ជើញព្រះបាទសម្ដេចព្រះអង្គអេងឡើងគ្រងរាជសម្បត្តិ (ព្រះជន្ម ៧វស្សា) ។ ឯយោមរាជបែនជាសត្រូវសម្ដេចចៅហ្វ៊ាមូឱ្យទៅនៅជាមួយនឹងលោកទែនស្ដេចត្រាញ់ដីកំពង់ស្វាយ យោមរាជបែនមិនសុខចិត្តសុំព្រះចៅសៀមចូលទៅនៅក្រុងសៀម ។ ពេលនោះព្រះចៅសៀមគឺពញាតាកដែលតាំងព្រះអង្គនន់ជាស្ដេចម្ចាស់ផែនដីខ្មែរនោះ ក៏ចាត់កងទ័ពឱ្យចូលមកវាយនគរកម្ពុជា ទ័ពសៀមមានកម្លាំងវាយធ្លាយលើកដំរង់មកក្រុងឧដុង្គទៅហើយ ទទួលមានដំណឹងមកស្រុកសៀមថាមានកើតចលាចលគេរំលំសម្លាប់ពញាតាកយករាជសម្បត្តិ ទ័ពសៀមដែលចូលមកនគរខ្មែរនេះក៏ថយទៅវិញអស់ទៅ (គ.ស ១៧៨២) ។

ក្រោយមក (គ.ស ១៧៨២) វិបុលរាជស្ងួដែលជាសំឡាញ់ចៅហ្វ៊ាមូ ហើយដែលចៅហ្វ៊ាមូតាំងជាទីក្រឡាហោមនោះ មិនដឹងជាមានហេតុអ្វីមកជាសត្រូវនឹងចៅហ្វ៊ាមូ ។ ធ្វើសំបុត្រទៅឯយោមរាជបែន ដែលនៅឯដែនសៀមឱ្យចូលមកនគរកម្ពុជាពួតដៃនឹងគ្នាលើកទ័ពច្បាំងសម្លាប់ចៅហ្វ៊ាមូ ។ ក្រឡាហោមស្ងួ ត្រៀមនៅចាំឯបាត់ដំបង គេណួរាស្ត្រជាកងទ័ពមកច្បាំងនឹងសម្ដេចចៅហ្វ៊ាមូ ។ ទ័ពយោមរាជបែននិងទ័ពចៅហ្វ៊ាមូតយុទ្ធនឹងគ្នាជាធំសំបើមអស្ចារ្យ រួចដល់ចុងក្រោយទ័ពសម្ដេចចៅហ្វ៊ាមូទន់

www.budinst.gov.kh www.elibraryofcambodia.org

កម្លាំងបរាជ័យ យោមរាជបែនសម្លាប់អស់ត្រកូលចៅហ្វាមូ ព្រមទាំងជំទាវឡង់ជាម្ដាយនោះផង ។ រួចយោមរាជបែនក្បត់ តាំងខ្លួនជាសម្ដេចចៅហ្វាវិញ ។ ក្រោយនោះមកនគរកម្ពុជាកើតចលាចល ដោយចៅហ្វាយខែត្រស្ដេចត្រាញ់ស្នងឃុំលើកទ័ពយ៉ាងធំចូលមកនឹងចាប់ចៅហ្វាបែន និងលោកក្រឡាហោមប៉ុកជាព្រះធម្មបិតានៃព្រះបាទអង្គអេង ។ សម្ដេចចៅហ្វាបែននិងឧកញ៉ាក្រឡាហោមប៉ុកយល់ឃើញថាតស៊ូមិនបានក៏អញ្ជើញបរមរាជកុមារព្រះបាទអង្គអេងស្ដេចចូលទៅក្រុងសៀម (កាលនោះព្រះជន្ម ១០ វស្សា) ព្រះចៅក្រុងសៀមឃាត់ព្រះអង្គទុកនៅក្រុងសៀមរហូតដល់ព្រះជន្ម ២២ វស្សា ទើបព្រះរាជាភិសេកថ្វាយ បើកឱ្យស្ដេចមកជាអម្ចាស់ផែនដីអាណាចក្រកម្ពុជា ហើយសុំយកខែត្របាត់ដំបងនិងសៀមរាប ដាក់ឱ្យចៅហ្វាបែននិយាយរាជការឡើងផ្ទាល់ក្រុងសៀម (១៧៩៤) ប៉ុន្តែសៀមតាំងចៅហ្វាបែនឱ្យគ្រួតខែត្របាត់ដំបងតាំងពី គ.ស ១៧៩១ ។

ព្រះបាទសម្ដេចព្រះអង្គអេង ទ្រង់ព្រះរាជសុវណ្ណកោដ្ឋនៅ គ.ស ១៧៩៦ ក្នុងព្រះជន្ម ២៥ វស្សា សោយរាជសម្បត្តិតាំងពីទទួលព្រះរាជាភិសេកមកបានតែ ៣ ឆ្នាំ ប៉ុណ្ណោះ ទ្រង់ពុំទាន់បានប្រារព្ធនូវការអ្វីជាសំខាន់ផង ។ កាលដើមរាជ្យព្រះអង្គក្នុងរវាង ៣ ឆ្នាំ (គឺដល់ គ.ស ១៧៨២) រាជការព្រះអង្គអេង ព្រះរាជឱរសព្រះបាទសម្ដេចព្រះនារាយណ៍រាជារាមាធិបតីព្រះអង្គ "តន់" អម្ចាស់ផែនដីក្រុងកម្ពុជា កាលព្រះជន្ម ៧ ឆ្នាំ បានឡើងគ្រងរាជសម្បត្តិជាអម្ចាស់ផែនដីក្រុងកម្ពុជា ដល់ឆ្នាំខាល ព.ស ២៣២៥ ច.ស ១១៤៤ ព្រះអង្គអេងព្រះជន្ម ១០ ឆ្នាំ ខណៈនោះក្រុងកម្ពុជាកើតចលាចលដោយឧកញ៉ាមហាមន្ត្រី ឧកញ៉ាអរជូនចៅហ្វាយខែត្រស្នងឃុំលើកទ័ពចូលក្នុងក្រុង ដើម្បីនឹងចាប់ខ្លួនសម្ដេចចៅហ្វាមហាបពិត្របែន និងឧកញ៉ាក្រឡាហោមប៉ុកព្រះធម្មបិតា នោះសម្ដេចចៅហ្វាមហាបពិត្របែននិងឧកញ៉ាក្រឡាហោមប៉ុក ព្រះធម្មបិតាយល់ឃើញថានឹងតស៊ូមិនបានដោយមិនបានត្រៀមការនឹងច្បាំង ទើបអញ្ជើញព្រះបរមរាជកុមារព្រះអង្គអេង ស្ដេចចូលទៅក្រុងវត្តកោសិន ព្រះអង្គអេងគង់ក្នុងក្រុងវត្តកោសិន តាំងអំពីព្រះជន្ម ១០ ឆ្នាំដល់ព្រះជន្ម ២២ឆ្នាំ ខណៈនោះប្រជួបវេលាព្រះរាជបុត្រសម្ដេចម្ចាស់ហ្វាក្រុមឃុនសេនានុរ័ក្ស មានព្រះជន្មគំរប់ ២១ រៀងឆ្នាំដល់កំណត់

www.budinst.gov.kh www.elibraryofcambodia.org

ចូលឧបសម្បទជាភិក្ខុក្នុងខែអាសាធ ឆ្នាំខាលសប្តស័ក គ.ស ២៣៣៧ នោះ ។

ព្រះបាទសម្តេចព្រះពុទ្ធយ៉តហ្វា ព្រះចៅក្រុងរ័ត្នកោសិន ព្រះរាជទានគ្រឿងផ្នួស រៀបផង្គៃព្រះរាជបុត្រសម្តេចម្ចាស់ហ្វា ក្រុមឃុនសេនានុរ័ក្ស, ព្រះអង្គអេង, ព្រះពង្ស អមរិន្ទ្រ, ទាំងបីព្រះអង្គឧបសម្បទនៅវត្តព្រះស្រីរត្នសស្តារាមសម្តេចព្រះសង្ឃរាជ (ស៊ុខ) ជាឧបជ្ឈាយ៍ទ្រង់ព្រះផ្នួសហើយស្តេចទៅគង់ចាំវស្សានៅវត្តសារាយ ។

ដល់ចេញព្រះវស្សាព្រះអង្គអេង ដាក់ព្រះផ្នួសលាសិក្ខាព្រះបាទសម្តេចព្រះពុទ្ធ យ៉តហ្វាព្រះចៅក្រុងស្យាម រៀបពិធីរាជាភិសេកព្រះអង្គ "អេង" ត្រាស់បង្គាប់ភ្នាក់ងារ ឱ្យចារិក ព្រះសុវណ្ណប័ត្រសញ្ញាប័ត្រតាំងព្រះនាមជាសម្តេចព្រះនារាយណ៍រាមាធិបតីសីរី សុរិយោពណ៌បរមសុរិន្ទ្រាមហាចក្រពត្តិរាជបរមនាថបរមបពិត្រ ជាអម្ចាស់ផែនដីក្រុង កម្ពុជាធិបតី ។ ឱ្យឧកញ៉ាក្រឡាហោមប៉ុកព្រះធម្មបិតា ជាសម្តេចចៅហ្វាយទលហះឯក ឧកមន្ត្រីអភ័យភេរីក្រុងពាហុ ឱ្យអំណាចដាច់ខាតបង្គាប់បញ្ជាការរាជការគ្រប់ជំពូក ព្រះ បាទសម្តេចព្រះពុទ្ធយ៉តហ្វាព្រះចៅក្រុងរ័ត្នកោសិន រៀបអភិសេកព្រះអង្គ "អេង" តាំងឡើងជាអម្ចាស់ផែនដីក្រុងកម្ពុជារួចស្រេចហើយ មានព្រះតម្រាស់សុំខែត្របាត់ ដំបង ខែត្រនគរសៀមរាបនិងស្រុកឡើង ឱ្យចៅពញាអភ័យភូបែស "បែន" និយាយ រាជការឡើងផ្ទាល់រ័ត្នកោសិន ។ ព្រះបាទសម្តេចព្រះនារាយណ៍រាមាព្រះអង្គ "អេង" សោយរាជសម្បត្តិជាអម្ចាស់ផែនដីក្រុងកម្ពុជាធិបតីបាន ៣ ឆ្នាំ, ២ខែ, ១៤ថ្ងៃ សីរី ព្រះជន្មបាន ២៥រៀងឆ្នាំទ្រង់ព្រះប្រឈួនសាសរោគ ពេទ្យប្រកបព្រះឱសថមិនជល់ ទ្រង់ព្រះសុវណ្ណគតនៅថ្ងៃសុក្រ ១៤ រោចខែកត្តិក ឆ្នាំម្សាញ់នព្វស័ក ព.ស ២៣៤០ ច.ស ១១៥៩ ទ្រង់ព្រះសុវណ្ណគតនៅមានព្រះរាជបុត្រា ៥ ព្រះអង្គ ទី១ព្រះអង្គចន្ទ, ទី២ព្រះអង្គភឹម, ទី៣ព្រះអង្គស្ងួន, ទី៤ព្រះអង្គអិម, ទី៥ព្រះអង្គឌួង, ឯព្រះអង្គភឹមព្រះ រាជបុត្រទី ២ ព្រះជន្ម ៧ឆ្នាំសុវណ្ណគតទៅ, កាលព្រះបរមរាជបិតាទ្រង់ព្រះសុវណ្ណគត នោះ ព្រះអង្គចន្ទព្រះរាជបុត្រទី ១ ព្រះជន្ម ៦ឆ្នាំ បើតាមច្បាប់ត្រូវលើកឡើងគ្រង រាជសម្បត្តិជាអម្ចាស់ផែនដី តែព្រះចៅក្រុងស្យាមមានព្រះតម្រាស់ថានៅកុមារតូច ណាស់ ឱ្យតែសម្តេចចៅហ្វាទលហៈ ឯអគ្គមហាសេនាសម្រេចរាជការបណ្តើរសិន ក្នុង

www.budinst.gov.kh www.elibraryofcambodia.org

រវាងនោះក្រុងអណ្ណាមកើតសង្គ្រាមនឹងពួកតៃសើន មានសារត្រាពីក្រុងស្យាមបង្គាប់មកឱ្យកេណ្ឌរាស្ត្រខ្មែរទៅជួយអុងជៀងស៊ី ច្បាំងកំចាត់ពួកតៃសើន ។

* ☺ *

ព្រះចៅក្រុងស្យាមឃាត់ព្រះអង្គ "អេង" ទុកក្នុងក្រុងស្យាមតាំងអំពីព្រះអង្គ "អេង" ព្រះជន្ម ១០ឆ្នាំដល់ព្រះជន្ម ២២ឆ្នាំតាំងឱ្យធ្វើជាម្ចាស់ផែនដីក្រុងកម្ពុជា ហើយត្រឡប់ជាសុំយកខែត្របាត់ដំបង ខែត្រនគរសៀមរាបឱ្យចៅពញាអភ័យភូបែស "បែន" និយាយរាជការឡើងផ្ទាល់ក្រុងស្យាមដូច្នោះ គឺសេចក្តីគិតរបស់ចៅពញាអភ័យភូបែស "បែន" ខណៈនោះប្រសិនបើព្រះអង្គអេងមិនព្រមទទួលតាម ខាងក្រុងស្យាមនឹងមានគំនិតផ្សេងទៅទៀត ព្រះអង្គ "អេង" ក៏នឹងមិនបានស្តេចចេញមកក្រុងកម្ពុជាធិបតីឯចិត្តគំនិតរបស់ស្យាម ដើម្បីនឹងប្រាថ្នារំលុះរំលាងវង្សក្សត្រខ្មែរមកជាច្រើនគ្រាហើយ កាលបែកព្រះមហានគរនៅវវាង ព.ស ១៩៦៥ ច.ស ៧៨៣ ខាងស្យាមតាំងរាជបុត្រឱ្យគ្រងកម្ពុជា គឺព្រះឥន្ទរាជា សឹងព្រះបរមរាជា ចៅពញា "យ៉ាត" ស្តេចឱ្យលុកក្ស័យព្រះជន្មទៅនោះ ក្រោយនោះព្រះចៅរាមា "តាក-សិន" ក្រុងធនបុរីបំណងនឹងព្រះរាជបុត្រក្រុមហ្លួងឥន្ទពិធ័ក្ស គ្រងក្រុងកម្ពុជាម្តងទៀតជាបុព្វនិស្ស័យនឹងមិនឱ្យផុតវង្សក្សត្រខ្មែរ បណ្តាលហេតុឱ្យកលិយុគក្នុងក្រុងធនបុរីឱ្យគ្រងក្រុងកម្ពុជានោះក៏ខានទៅ ។ ក្នុងគ្រានោះមានសម័យហេតុជាថ្មីទៀត ព្រះបាទសម្តេចព្រះពុទ្ធយ៉តហ្វាព្រះចៅក្រុងស្យាមឃាត់ព្រះអង្គ "អេង" ម្ចាស់ផែនដីក្រុងកម្ពុជា ទុកក្នុងក្រុងស្យាមតាំងអំពីព្រះជន្ម ១០ឆ្នាំដល់ ២២រៀងឆ្នាំ តាំងព្រះពញាអភ័យភូបែស "បែន" ឱ្យសម្រេចរាជការក្រុងកម្ពុជាឡើងផ្ទាល់ក្រុងស្យាមដូច្នោះ គឺបំណងនឹងឱ្យសូន្យនឹងវង្សត្រកូលខ្មែរ បើមិនបំណងនឹងឱ្យសូន្យវង្សត្រកូលខ្មែរទេ ត្រូវតាំងចៅពញាអភ័យភូបែស "បែន" ឱ្យសម្រេចរាជការក្រុងកម្ពុជា ហើយត្រូវតែងរាជកុមារព្រះអង្គ "អេង" ជាម្ចាស់ផែនដីក្រុងកម្ពុជា ។ មួយនឹងចៅពញាអភ័យភូបែស "បែន" ជាអ្នកសម្រេចរាជការផែនដីក្រុងកម្ពុជាធិបតី។

**សម្តេចក្សត្រី មាលិកា**

ផែនដីសម្រេចនៅសម្តេចចៅហ្វាមូ ។ ពី គ.ស ១៧៨២ ដល់ ១៧៩៣ (រវាង

www.budinst.gov.kh www.elibraryofcambodia.org

១១ ឆ្នាំ) រាជការផែនដីសំរេចនៅសម្តេចចៅហ្វា "បែន" ។ វេលាដែលព្រះចៅក្រុងសៀមរៀបពិធីព្រះរាជាភិសេកថ្វាយហើយ គឺពី គ.ស ១៧៩៣ ព្រះចៅក្រុងសៀមឱ្យអំណាចដាច់ខាតមកសម្តេចចៅហ្វាប៉ុកស្តីរាជការផែនដី ។

តាំងពីព្រះចៅក្រុងសៀម បានរៀបពិធីព្រះរាជាភិសេក ព្រះបាទសម្តេចព្រះអង្គអេងនោះមក ព្រះចៅសៀមតាំងព្រះអង្គជាអ្នកព្យាបាល ហើយប្រកាន់យកនគរកម្ពុជាដាក់ជាចំណុះរៀងមក ។

## សម្តេចចៅហ្វាប៉ុក

(១៧៩៦ - ១៨០៦)

កាលសម្តេចព្រះអង្គ "អេង" ទ្រង់ព្រះរាជសុវណ្ណគតទៅ ទ្រង់មានព្រះរាជបុត្រា ៥ ព្រះអង្គនៅកុមារតូចៗនៅឡើយ ឯស្តេចឯទៀតក្នុងព្រះរាជវង្សាគ្មាន ។

ព្រះរាជបុត្រា ៥ ព្រះអង្គនោះ គឺ :

ទី ១ - ព្រះអង្គចន្ទ (ព្រះជន្ម ៦ វស្សា)

ទី ២ - ព្រះអង្គភឹម

ទី ៣ - ព្រះអង្គស្ងួន

ទី ៤ - ព្រះអង្គអិម

ទី ៥ - ព្រះអង្គឌួង

ឯព្រះអង្គភឹមជាព្រះរាជបុត្រាទី ២ ព្រះជន្មបាន ៧ វស្សាសុវណ្ណគតទៅ ។

កាលបើសម្តេចព្រះអង្គអេង ព្រះរាជសុវណ្ណគតទៅហើយ នគរកម្ពុជាឥតមានស្តេចជាអម្ចាស់ផែនដី ១០ ឆ្នាំ (១៧៩៦-១៨០៦) ។ ព្រះអង្គចន្ទព្រះជន្ម ៦ វស្សា បើតាមច្បាប់ត្រូវលើកឡើងគ្រងរាជសម្បត្តិជាម្ចាស់ផែនដីបាន ប៉ុន្តែព្រះចៅក្រុងសៀមមិនព្រមទុកឱ្យសម្តេចចៅហ្វា "ប៉ុក" ស្តីរាជការ ។ សម្តេចចៅហ្វាប៉ុកជាព្រះធម្មបិតានៃព្រះរាជបុត្រនៃព្រះបាទសម្តេចព្រះអង្គអេងទៀត ។

ក្នុងរាជការសម្តេចចៅហ្វាប៉ុក មានពត៌មានពីរប្រការសំខាន់ :

១- គឺព្រះចៅក្រុងសៀមសុំឱ្យសម្តេចចៅហ្វាប៉ុក លើកទ័ពទៅជួយសៀមច្បាំង

www.budinst.gov.kh www.elibraryofcambodia.org

ទឹងកួឡាដែលចូលមកច្បាំងនឹងសៀម សម្តេចចៅហ៊្វាប៉ុកក៏ចាត់កងទ័ពទៅជួយច្បាំងឈ្នះកួឡា ។

២- ក្រោយនោះបន្តិចព្រះរាជាយ៉ាឡុងក្រុងអណ្ណាម ដែលយួនតែស៊ើនដណ្តើមយករាជសម្បត្តិនោះ ទៅពឹងព្រះចៅក្រុងសៀម ។ មានបង្គាប់មកសម្តេចចៅហ៊្វាប៉ុក ។ ក៏ចាត់កងទ័ពលើកទៅជួយច្បាំងមានជ័យជំនះ បានរាជសម្បត្តិមកព្រះរាជយ៉ាឡុងវិញ ។

## ព្រះបាទសម្តេចព្រះអង្គចន្ទទី ២ (ព្រះឧទ័យរាជា)

(ពី គ.ស ១៨០៦ ដល់ ១៨៣៤)

## អំពីខេត្រមង្គលបុរី-បាត់ដំបង-សៀមរាប-សេ្ទឹងត្រែង ធ្លាក់ទៅសៀម

(គ.ស ១៨១៤)

លុះព្រះអង្គចន្ទព្រះជន្ម ១៦ វស្សាល្មមនឹងទទួលរាជសម្បត្តិ (គ.ស ១៨០៦) សម្តេចចៅហ៊្វាប៉ុកជាព្រះធម្មបិតាអញ្ជើញព្រះអង្គស្តេចទៅទទួលព្រះរាជាភិសេកឯក្រុងទេព (ទីក្រុងបាងកក) ព្រះចៅក្រុងសៀមក៏រៀបពិធីរាជាភិសេកថ្វាយតាំងជាស្តេចអម្ចាស់ផែនដីនគរកម្ពុជា ហើយចាត់កងទ័ពហែហាមស្តេចចូលក្រុងឧដុង្គវិញ ។

ព្រះរាជាអណ្ណាម (ព្រះបាទយ៉ាឡុង) មានសេចក្តីច្រណែនក៏ចាត់កងទ័ពមកបង្ខំព្រះបាទព្រះអង្គចន្ទថា បើចំណុះប្រទេសសៀមត្រូវតែចំណុះប្រទេសអណ្ណាមផង ហើយត្រូវនាំសួយសារអាករទៅថ្វាយព្រះរាជាអណ្ណាមរាល់ឆ្នាំ ដំរីឈ្មោលកំពស់ ៥ហត្ថពីរ, កុយរមាស២, ភ្លុកដំរី ៣គូ, ក្រវាញ, ក្រមួន ។ល។ ព្រះអង្គចន្ទនិងសេនាបតីពុំដឹងត្រិះរិះដូចម្តេច ក៏ទ្រង់យល់ព្រម (ប្រហែលជាខ្លាចក្រែងមានកើតកលិយុគធំ)

កិច្ចដែលដាក់នគរកម្ពុជា ជាប្រទេសរាជនៃប្រទេសអណ្ណាមផងនេះ ព្រះចៅក្រុងសៀមមានសេចក្តីអាក់អន់ព្រះទ័យជាច្រើន ។

**សេចក្តីពិស្តារ** - ឆ្នាំខាលអដ្ឋស័ក ព.ស ២៣៤៩ ច.ស ១១៦៨ សម្តេចចៅហ៊្វាទលហះព្រះធម្មបិតា សម្រេចរាជការក្រុងកម្ពុជាធិបតី យល់ឃើញថាព្រះអង្គចន្ទព្រះរាជបុត្រព្រះបាទសម្តេចព្រះនារាយណ៍រាមាធិបតីព្រះអង្គ "អេង" ព្រះជន្ម ១៦ឆ្នាំ

www.budinst.gov.kh www.elibraryofcambodia.org

ល្មមនឹងទទួលរាជសម្បត្តិតាមខត្តិយរាជប្រវេណី ទើបសម្តេចចៅហ្វាទលហៈ ឯកអគ្គមហាសេនា "ប៉ុក" អញ្ជើញព្រះអង្គច័ន្ទស្តេចចូលទៅក្រុងទេព ក្រាបបង្គំទូលព្រះបាទសម្តេចព្រះពុទ្ធយ៉តហ្វាព្រះចៅក្រុងស្យាម សុំឱ្យទ្រង់តាំងព្រះអង្គច័ន្ទជាអម្ចាស់ផែនដីក្រុងកម្ពុជា ក៏បានសំរេចដូចប្រាថ្នា នោះសម្តេចចៅហ្វា "ប៉ុក" ក៏មានជម្ងឺឈឺធ្ងន់ដល់អនិច្ចកម្មក្នុងខណៈនោះ ព្រះបាទសម្តេចព្រះពុទ្ធយ៉តហ្វាព្រះចៅក្រុងស្យាម ត្រាស់បង្គាប់ភ្នាក់ងារឱ្យរៀបពិធីឈាបនកិច្ចសពសម្តេចចៅហ្វា "ប៉ុក" ។

ថ្ងៃ ២ ៥ ៨ ឆ្នាំខាលអដ្ឋស័ក ព.ស ២៣៤៩ ច.ស ១១៦៨ ត្រូវនឹង គ.ស ១៨០៥ រៀបពិធីតាំងព្រះអង្គច័ន្ទជាអម្ចាស់ផែនដីក្រុងកម្ពុជាធិបតី ខានព្រះនាមជាសម្តេចព្រះឧទ័យរាជាធិរាជរាមាធិបតី ស៊ីរីសុរិយោពណ៌ បរមសុទិន្ទ្រា មហាចក្រព័ត្តិធិរាជ បរមបពិត្រ ស្ថិតជាឥស្សរកម្ពុជរដ្ឋសាស្ត្រ និកាសជាតិវង្ស កម្រង់ក្រុងកម្ពុជាធិបតីសិរីយសោធរនគរឥន្ទប័ត្តកុរុរដ្ឋបុរីរម្យ ឧត្តមមហាស្ថាន ។

ស្តេចចេញពីក្រុងទេពមកសោយរាជសម្បត្តិ គង់នៅព្រះបរមរាជវាំងក្រុងឧដុង្គមានជ័យ ដល់ខែមិគសិរឆ្នាំខាលនោះ ចៅពញាអភ័យភូបែស "បែន" សំរេចរាជការខែត្របាត់ដំបង នគរសៀមរាប នាំកូនស្រី ១ ឈ្មោះអ្នកទេពមកថ្វាយ ព្រះបាទសម្តេចព្រះឧទ័យរាជា អម្ចាស់ផែនដីក្រុងកម្ពុជាទ្រង់តាំងជាព្រះម្នាងក្នុងខណៈនោះព្រះបាទជាអម្ចាស់ផែនដីក្រុងកម្ពុជាទ្រង់ព្រះប្រារព្ធអំពីខែត្របាត់ដំបង ខែត្រនគរសៀមរាប ខែត្រស៊ីសុផុន ។

ឆ្នាំពេងស័ក្តិស័ក ព.ស ២៣៥១ ច.ស ១១៧០ ព្រះបាទឧទ័យរាជាព្រះអង្គច័ន្ទស្តេចចូលទៅក្រុងទេព ស្តេចនឹងត្រឡប់មកវិញ វេលាមួយនោះព្រះបាទសម្តេចព្រះពុទ្ធយ៉តហ្វាព្រះចៅក្រុងស្យាម ស្តេចចេញពីព្រះទីនាំងគំនាល់នោះព្រះបាទសម្តេចព្រះឧទ័យរាជា ព្រះអង្គច័ន្ទអម្ចាស់ផែនដីក្រុងកម្ពុជាចូលថ្វាយបង្គំលាសម្តេចព្រះពុទ្ធយ៉តហ្វាព្រះចៅក្រុងស្យាមទ្រង់ព្រះពិរោធត្រាស់ត្មះតិះដៀលចាប់ឲ្យាប់ថា ព្រះបាទសម្តេចព្រះឧទ័យរាជាចូលគាល់មិនចាំសេនាបតីក្រាបបង្គំទូលបើកមុន ។

ព្រះបាទសម្តេចព្រះឧទ័យរាជាព្រះអង្គច័ន្ទស្តេចចូលក្រុងទេព ក្នុងខណៈនោះដើម្បីនឹងសុំខែត្របាត់ដំបង ខែត្រនគរសៀមរាប ឱ្យបានមកជាអាណាខែត្រក្រុងកម្ពុជាដូច

www.budinst.gov.kh www.elibraryofcambodia.org

កាលអំពីដើមវិញ បានថ្វាយសេចក្តី អំពីខែត្រទាំងនោះខ្លះហើយ ព្រះបាទសម្តេចព្រះចៅក្រុងស្យាមមិនទ្រង់យល់ព្រម ដល់ថ្ងៃក្រោយចាប់ហេតុអំពីចូលគាល់មិនចាំសេនាបតី ក្រាបបង្គំទូលបើកជាមុន ។

ព្រះបាទសម្តេចព្រះឧទ័យរាជា ស្តេចត្រឡប់ពីក្រុងទេពមកក្រុងភ្នំពេញ រវាងក្រោយនោះមិនយូរប៉ុន្មាន មានទូតត្រាអំពីក្រុងទេពប្រាប់ដំណឹងមកថា ព្រះបាទសម្តេចព្រះពុទ្ធយ៉តហ្វាព្រះចៅក្រុងស្យាម ទ្រង់សុរិវណ្ណគតនៅថ្ងៃ ៥ ១៣ ៩ ឆ្នាំម្សាញ់ឯកស័ក ច.ស ១១៧១ បើតាមទំនៀមទំនងរសើងជាចមមកុជត្រូវស្តេចប្រទេសរាជ ចូលថ្វាយបង្គំព្រះបរមសពអម្ចាស់ផែនដីសឹងអស់ព្រះជន្មទៅ នឹងទទួលស្គាល់អម្ចាស់ផែនដីសឹងឡើងសោយរាជសម្បត្តិថ្មីនោះ ព្រះបាទសម្តេចព្រះឧទ័យរាជាព្រះអង្គច័ន្ទ ទ្រង់ស្តេចមិនចូលទៅក្រុងទេព ទ្រង់ចាត់ព្រះរាជអនុជព្រះអង្គស្ងួន ព្រះរាជអនុជព្រះអង្គអិម សម្តេចព្រះអង្គកែវ ឧកញ៉ាក្រឡាហោម ឧកញ៉ាចក្រីនឹងឧកញ៉ាព្រះហ្លួង ឱ្យចូលទៅក្រុងទេព នាំគ្រឿងរាជបណ្ណាការត្រៃចីវរទៅថ្វាយបង្គំព្រះបរមសព និងថ្វាយបង្គំអម្ចាស់ផែនដីក្រុងស្យាមសឹង ឡើងសោយរាជសម្បត្តិថ្មី ។

ក្នុងសម័យនោះព្រះបាទសម្តេចព្រះចៅក្រុងស្យាម សឹង ឡើងសោយរាជសម្បត្តិថ្មី តែងតាំងព្រះរាជអនុជព្រះអង្គស្ងួន ជាព្រះជ័យជេដ្ឋាមហាឧបយោរាជ តាំងព្រះរាជអនុជអង្គ (អិម) ជាព្រះស្រីជ័យជេដ្ឋមហាឧបយោរាជក្រុងកម្ពុជា ។

អម្ចាស់ផែនដីគង់ព្រះជន្មនៅក្នុងរាជសម្បត្តិ ហើយតាំងព្រះអនុជជាមហាឧបយោរាជ ដូច្នោះខុសទំនៀមរាជប្រវេណី ឯឧបយោរាជនោះសម្រាប់អម្ចាស់ផែនដីផាក់រាជសម្បត្តិ ។

កាលសម្តេចព្រះជ័យជេដ្ឋា ព្រះអង្គស្ងួន សម្តេចព្រះស្រីជ័យជេដ្ឋព្រះអង្គ (អិម) ស្តេចពីក្រុងទេពត្រឡប់មកក្រុងកម្ពុជាវិញ នោះរាជការក្រុងទេពមានសុភអក្សរ ១ច្បាប់ផ្ញើនឹងសម្តេចព្រះជ័យជេដ្ឋា (ព្រះអង្គស្ងួន) កាន់មកថ្វាយអម្ចាស់ផែនដីក្រុងកម្ពុជា ក្នុងសុភអក្សរនោះជាសេចក្តីបង្គាប់ឱ្យកេណ្ឌរាស្ត្រខ្មែរទៅជួយរក្សាក្រុងទេពបំរុងការសង្គ្រាមនឹងប្រទេសភូមា ។

ព្រះបាទព្រះឧទ័យរាជាព្រះអង្គច័ន្ទ អម្ចាស់ផែនដីក្រុងកម្ពុជា បានទ្រង់ទទួល

www.budinst.gov.kh www.elibraryofcambodia.org

សុភអក្សរជ្រាបសេចក្ដីហើយ ទ្រង់ព្រះសន្និតស្មៀមនោះព្រះរាជអនុជផ្ទាល់ព្រះអង្គស្ងួនសឹងព្រះចៅក្រុងស្យាម តាំងជាព្រះជ័យជេដ្ឋាមហាឧបរាជ និងឧកញ៉ាក្រឡាហោម (មឿង) និងឧកញ៉ាចក្រី (ប៉ែន) មានបង្គាប់ឱ្យឧកញ៉ាសួគ៌ាលោកចៅហ្វាយខែត្រពោធិសាត់ កេណ្ឌរាស្ត្រខ្មែរខែត្រពោធិសាត់ ដើម្បីនឹងលើកទៅជួយក្រុងស្យាម បំរុងការសង្គ្រាមនឹងប្រទេសភូមា ។

ព្រះបាទសម្ដេចព្រះឧទ័យរាជាព្រះអង្គច័ន្ទ អម្ចាស់ផែនដីក្រុងកម្ពុជាបានទ្រង់ជ្រាបហើយ ត្រាស់បង្គាប់ឱ្យចាប់ខ្លួនឧកញ៉ាក្រឡាហោមមឿង ឧកញ៉ាចក្រីប៉ែន ដាក់ព្រះរាជទណ្ឌដល់ប្រហារជីវិតបង់ ឯឧកញ៉ាសួគ៌ាលោកចៅហ្វាយខែត្រពោធិសាត់ដឹងខ្លួន រត់ចូលទៅក្រុងទេពនាំដំណើរទៅបរិយាយប្ដឹងសេនាបតីក្រុងស្យាម ។ នាំដំណើរក្រាបបង្គំទូលព្រះចៅក្រុងស្យាមតាមដែលកើតឡើងក្នុងក្រុងកម្ពុជា ។

ព្រះរាជអនុជព្រះអង្គស្ងួន មានសេចក្ដីរង្កៀសក៏ភៀសខ្លួនព្រះអង្គចេញពីក្រុងទៅតាំងនៅខែត្រពោធិសាត់ ។

ព្រះបាទសម្ដេចព្រះឧទ័យរាជា អម្ចាស់ផែនដីត្រាស់ប្រើនាម៉ឺនឱ្យទៅនិយាយលួងលោមព្រះរាជអនុជឱ្យស្ដេចត្រឡប់ចូលក្រុងវិញ នោះព្រះរាជអនុជព្រះជ័យជេដ្ឋាព្រះអង្គស្ងួន មិនទ្រង់ស្ដេចត្រឡប់វិលវិញ ព្រះរាជបំរើទៅនិយាយជាច្រើនផងនោះព្រះអនុជឃាត់ ឯខ្លួនព្រះរាជបំរើមិនឱ្យត្រឡប់មកក្រុងវិញ ចៅពញាអភ័យភូបែស (ប៉ែន) ភូសម្រេចរាជការខែត្របាត់ដំបងបានដឹងហេតុផ្ទេះ ធ្វើសំបុត្រមកចូលទៅក្រុងទេពព្រះបាទសម្ដេចព្រះពុទ្ធឡើតឡា ព្រះចៅក្រុងស្យាមបានជ្រាបហើយត្រាស់ប្រើចៅពញាយោមរាជលើកទ័ពមក តែថាឱ្យមកផ្សះផ្សាព្រះរៀមព្រះអនុជសឹង មានសាហេតុទាស់ទែងចៅពញាយោមរាជលើកទ័ពចេញពីក្រុងទេព ក្នុងរវាងនោះព្រះបាទសម្ដេចព្រះឧទ័យរាជា អម្ចាស់ផែនដីក្រុងកម្ពុជា ត្រាស់បង្គាប់ឱ្យចាត់ទ័ពលើកទៅចាប់ព្រះរាជអនុជព្រះជ័យជេដ្ឋាព្រះអង្គស្ងួន ចៅពញាអភ័យភូបែសសម្រេចរាជការខែត្របាត់ដំបង បានដឹងហើយចាត់ក្រុមការខែត្របាត់ដំបងឱ្យមកឃាត់ ។

ឯចៅពញាយោមរាជស្មៀមលើកទ័ពមកឈប់នៅខែត្របាត់ដំបង បានដឹងសេចក្ដីហើយ ក៏លើកចូលមកតាំងនៅខែត្រពោធិសាត់ មានសំបុត្រថ្វាយដល់ព្រះឧទ័យរាជា

www.budinst.gov.kh www.elibraryofcambodia.org

បានទ្រង់ជ្រាបហើយក៏ទ្រង់សង្កិតសៀមទៅ ។

ចៅពញាយោមរាជមេទ័ពសៀមបង្អង់ចាំជាយូរ មិនមានថាអ្វីក៏ចាត់បំរើឱ្យអញ្ជើញព្រះសុភអក្សរមក នោះឧកញ៉ាយោមរាជខ្មែរសឹងព្រះបាទសម្តេចព្រះឧទ័យរាជាត្រាស់ប្រើឱ្យលើកទ័ពទៅស្កាក់ផ្លូវនោះ ឱ្យឃាត់សុភអក្សរទុក បំរើត្រឡប់ទៅប្រាប់ឧកញ៉ាយោមរាជសៀម ។ ក៏លើកទ័ពនាំព្រះជ័យជេដ្ឋាព្រះអង្គស្ងួនមកតាំងនៅក្រុងឧដុង្គ ។ ព្រះបាទសម្តេចព្រះឧទ័យរាជាព្រះអង្គច័ន្ទបានទ្រង់ជ្រាបថា ទ័ពសៀមមកតាំងនៅក្រុងឧដុង្គ ទើបស្តេចចេញពីក្រុងភ្នំពេញទៅស្រុកព្រៃនគរ ឯពញាយោមរាជមេទ័ពសៀមមានសំបុត្រថ្វាយទៅព្រះបាទព្រះឧទ័យរាជា និងចៅហ្វាយស្រុកព្រៃនគរឱ្យអញ្ជើញព្រះបាទសម្តេចព្រះឧទ័យរាជាស្តេចឡើងមកទីងផ្សះផ្សា ថ្វាយសំបុត្រទៅនាយច្រើនខែមិនមានតបមកវិញ ទើបប្រឹក្សានាយទ័ពនាយកងឱ្យដុតក្រុងភ្នំពេញ-ដុតកំពង់ហ្លួង-ដុតបន្ទាយពេជ្រក្រុងឧដុង្គ ហើយលើកទ័ពត្រឡប់ទៅវិញ យកទាំងព្រះអនុជព្រះជ័យជេដ្ឋាមហាឧបយោរាជព្រះអង្គស្ងួន ព្រះរាជអនុជព្រះស្រីជ័យជេដ្ឋាមហាឧបយោរាជព្រះអង្គ (អិម) ព្រះរាជអនុជព្រះអង្គឌួងទាំងបីព្រះអង្គចូលទៅក្រុងទេពទុកខាងហ្លួង ១ ឱ្យនៅស្នាប់រាជការ ។ ក្រោយនាំសៀមលើកទៅដុតចៅហ្វាយស្រុកព្រៃនគរ រៀបដង្ហែព្រះបាទសម្តេចព្រះឧទ័យរាជាស្តេចត្រឡប់មកក្រុងកម្ពុជាវិញ ។ ក្រោយនោះចៅហ្វាយស្រុកខេត្តព្រៃនគរក្បត់ក្រុងអណ្ណាម ខាងស្យាមឃើញថាជាឱកាសចាត់ឱ្យចៅពញាបឌិន្ទ្រដែលជាមេទ័ពជើងគោក លើកមកឱ្យព្រះស្រីជ័យជេដ្ឋាអង្គ (អិម) និងព្រះអង្គឌួងស្តេចមកជាមួយផង ។ ឱ្យចៅពញាព្រះឃ្លាំងជាមេទ័ពជើងទឹកលើកចេញពីក្រុងទេពមានបង្គាប់ឱ្យកេណ្ឌរាស្ត្រសៀមស្រុកក្រាតស្រុកចន្ទបូរ ឱ្យកេណ្ឌខ្មែរខេត្តកំពង់ លើកទៅវាយខេត្តបន្ទាយមាស ។ ខាងទ័ពគោក ចៅពញាបឌិន្ទ្រដែលវាលើកមកដល់ខេត្តបាត់ដំបង ។

ព្រះបាទសម្តេចព្រះឧទ័យរាជា ត្រាស់ប្រើសម្តេចចៅពញានិងឧកញ៉ាមនោមេត្រីទៅចាំទទួលច្បាំង នោះមេទ័ពខ្មែរបាក់ទ័ពត្រឡប់មកវិញ ព្រះបាទសម្តេចព្រះឧទ័យរាជាបានទ្រង់ជ្រាបហើយទ្រង់ព្រះពិរោធអស់សេនាបតី អញ្ជើញស្តេចចុះព្រះទីនាំងនាវាចេញពីក្រុងភ្នំពេញទៅស្រុកព្រៃនគរ ។

សម្តេចក្សត្រី មាលិកា

www.budinst.gov.kh www.elibraryofcambodia.org

ក្រោយមកក្នុង (គ.ស ១៨១០) ព្រះចៅក្រុងសៀមទ្រង់ព្រះសុវណ្ណកត ព្រះបាទសម្តេចព្រះអង្គច័ន្ទ ទ្រង់ចាត់ព្រះរាជអនុជព្រះអង្គស្ងួន ព្រះអង្គអិម និងនាម៉ឺនគ្រប់តំណែងនាំបណ្ណាការគ្រែចីវរចូលទៅថ្វាយបង្គំព្រះបរមសព និងអម្ចាស់ផែនដីក្រុងសៀមដែលឡើងសោយរាជសម្បត្តិថ្មី ។ ក្នុងសម័យនោះ ព្រះចៅក្រុងសៀមដែលសោយរាជសម្បត្តិថ្មីតែងតាំងព្រះរាជអនុជព្រះអង្គស្ងួនជាឧបយោរាជ ព្រះអង្គអិមជាឧបយោរាជ ។ កិច្ចដែលតែងតាំងយ៉ាងនេះឥតមានប្រឹក្សានឹងព្រះបាទអង្គច័ន្ទ ជាអម្ចាស់ផែនដីផង ព្រះបាទអង្គច័ន្ទទ្រង់មានសេចក្តីអាក់អន់ព្រះទ័យ ។ ដល់ព្រះអង្គស្ងួន ព្រះអង្គអិមនិងនាម៉ឺនទាំងអម្បាលម៉ានត្រឡប់មកពីក្រុងបាងកកវិញ ថែមទាំងមានសុភអក្សរពីព្រះចៅក្រុងសៀម ឱ្យព្រះអង្គស្ងួនកាន់មកថ្វាយព្រះបាទសម្តេចព្រះអង្គច័ន្ទទៀតផង បង្គាប់ថាឱ្យកេណ្ឌរាស្ត្រខ្មែរទៅជួយរក្សាក្រុងទេព (ក្រុងបាងកក) បំរុងការសង្គ្រាមនឹងប្រទេសភូមា ព្រះបាទអង្គច័ន្ទទ្រង់បានជ្រាបហើយទ្រង់ព្រះសន្ធិតស្ងៀម

ព្រះអង្គស្ងួន ឧកញ៉ាក្រឡាហោមមឿងនិងឧកញ៉ាចក្រីបែន មានបង្គាប់ទៅចៅហ្វាយខែត្រពោធិសាត់ ឱ្យកេណ្ឌរាស្ត្រខ្មែរខែត្រពោធិសាត់លើកទៅជួយរក្សាក្រុងសៀម (ក្រុងបាងកក) ព្រះបាទសម្តេចព្រះអង្គច័ន្ទបានជ្រាបហើយ ទ្រង់ត្រាស់បង្គាប់ឱ្យចាប់ឧកញ៉ាក្រឡាហោម(មឿង) និងឧកញ៉ាចក្រី(បែន) ដាក់ព្រះរាជទណ្ឌកម្មដល់ប្រហារជីវិតបង់ ។ ចៅហ្វាយខែត្រពោធិសាត់នឹងខ្លួនរត់ចូលទៅក្រុងសៀម ។ ឯព្រះអង្គស្ងួនមានសេចក្តីរង្កៀសក៏ភៀសព្រះអង្គពីក្រុងឧដុង្គទៅតាំងនៅខេត្តពោធិសាត់ ។ ព្រះបាទសម្តេចព្រះអង្គច័ន្ទទ្រង់ចាត់នាម៉ឺនមានទាំងលោកសង្ឃផង ឱ្យទៅនិយាយលួងលោមជាច្រើនលើកច្រើនគ្រា ឱ្យស្តេចត្រឡប់ចូលមកក្រុងវិញ ព្រះអង្គស្ងួនមិនព្រមស្តេចចូលសោះ ។ តាំងពីនោះមកចេះតែកើតចំបាំង សៀមខាងនាម៉ឺនស្បត់ខាងព្រះអង្គស្ងួនយួនខាងព្រះបាទសម្តេចព្រះអង្គច័ន្ទ ។

ក្រោយនោះបន្តិច (គ.ស ១៨១១) សៀមនិងព្រះអង្គស្ងួន លើកទ័ពយ៉ាងធំរាយដំរង់ចូលមកក្រុងឧដុង្គ ព្រះបាទសម្តេចព្រះអង្គច័ន្ទទ្រង់ស្តេចថយមកគង់នៅឯភ្នំពេញដល់ទ័ពព្រះអង្គតយុទ្ធពុំឈ្នះទ័ពសៀមនឹងព្រះអង្គស្ងួនដែលចូលមកដល់ក្រុងឧដុង្គ ព្រះបាទអង្គច័ន្ទទ្រង់ស្តេចចេញពីភ្នំពេញទៅស្រុកព្រៃនគរ ។ មេកងទ័ពសៀមមានសំបុត្រ

www.budinst.gov.kh www.elibraryofcambodia.org

ទៅថ្វាយព្រះបាទអង្គច័ន្ទនឹងចៅហ្វាយស្រុកព្រៃនគរ អញ្ជើញព្រះបាទអង្គច័ន្ទឡើងមកនឹងផ្សះផ្សា ព្រះបាទអង្គច័ន្ទស្ដេចមិនតបវិញ ទើបមេកងទ័ពសៀមឱ្យដុតក្រុងភ្នំពេញ-កំពង់ហ្លួង-បន្ទាយពេជ្រ-ក្រុងឧដុង្គ ហើយនាំព្រះអង្គស្ងួនព្រះអង្គ(អិម) ព្រះអង្គឌួងទាំងបីព្រះអង្គលើកទ័ពចូលទៅក្រុងសៀមវិញ ទុកខាហ្លួងមួយទៅក្រុងឧដុង្គស្ដាប់រាជការ ។ ព្រះអង្គស្ងួនទ្រង់សុវណ្ណគតនៅក្រុងបាងកក ពីរ-បីខែក្រោយនោះ (គ.ស ១៨១១) ។

រវាងពីរឆ្នាំក្រោយមក (គ.ស ១៨១៣)ទ័ពយួនដង្ហែព្រះបាទសម្ដេចព្រះអង្គច័ន្ទចូលមកគង់នៅក្រុងឧដុង្គវិញ (២០ ០០០ នាក់ ទាំងយួនទាំងខ្មែរដង្ហែចូលមក) ។ ឯខាហ្លួងសៀមដែលនៅស្ដាប់រាជការនៅក្រុងឧដុង្គ ក៏ត្រឡប់ចូលទៅក្រុងសៀមវិញអស់ទៅ ។

ក្រោយនោះបន្តិច ចៅហ្វាយខេត្តដីកំពង់ស្វាយឈ្មោះ "ម៉ែង" ក្បត់គិតបង្កជាកងទ័ពលើកមកច្បាំងនឹងស្ដេចជាអម្ចាស់ផែនដី ទ័ពហ្លួងលើកទៅវាយខ្ចាត់ខ្ចាយអស់ ចៅហ្វាយខេត្តក្បត់នោះ រត់ចូលទៅគិតនឹងព្រះចៅក្រុងសៀម ។

ដល់ គ.ស ១៨១៤ សៀមលើកទ័ពចូលមកយកខេត្តម្លូព្រៃ-ទន្លេរពៅ-ធ្នងទន្លេ យកខេត្តស្ទឹងត្រែងទៀត ឥតមានបានច្បាំងទេ ពីព្រោះនៅឆ្ងាយពីក្រុងឧដុង្គពេក ។

នៅក្នុង គ.ស ១៨១៦ មានពត៌មានមួយដែលខ្មែរៗពុំភ្លេចសោះ គឺមេទ័ពយួនឱ្យជីកព្រែកមួយពីមាត់ជ្រូកទៅពាម (ហាទៀង) យួនឱ្យឈ្មោះថាព្រែកវិញតេ ខ្មែរហៅថាព្រែកជីកឬព្រែកយួន កំណែនយួន ៥០០០នាក់ កំណែនខ្មែរ ៥០០០នាក់ ជីកព្រែកនោះ (បណ្ដោយ ៥៣ គ.ម ទទឹង ៣៣ ម. ជំរៅ ២ម.៦០) សឹងតែគ្រប់កន្លែង ព្រែកនេះនឹងយកធ្វើជាព្រំប្រទល់ប្រទេសខ្មែរនិងយួនផង គឺដីណាដែលនៅខាងត្បូងព្រែកជារបស់យួន ។

**អំពីសេចក្ដីវេទនា** - មួយឆ្នាំក្រោយមកក្នុង (គ.ស ១៨១៧) មានទឹកជំនន់ធំក្រៃលែង ស្រូវធ្វើរចំណាំទាំងឡាយលិចលង់រលួយអស់ អ្នកស្រុកអត់បាយវេទនាខ្លោចផ្សាឥតបើគណនាបានឡើយ ខ្លះស្លាប់ដោយដាច់ពោះនៅដោយស្រុកស្រែចំការ មានពួកអ្នកអត់ឃ្លានដើរកាប់សម្លាប់គ្នាយកអាហារចិញ្ចឹមជីវិត ហើយថែមទាំងមានកើតជំងឺ

www.budinst.gov.kh www.elibraryofcambodia.org

អហិវាតរោគទៀតផង ស្លាប់អស់មនុស្សជាច្រើន ។

ព្រះបាទអង្គច័ន្ទទ្រង់សោយរាជសុខនឹងសៀមបានតែរវាង ១០ឆ្នាំ ។ ដល់មក គ.ស ១៨២៩ ចៅហ្វាយខេត្តពោធិសាត់ឈ្មោះ "កា" ចាំរាស្ត្រពីខេត្តពោធិសាត់ ចូលទៅក្រុងសៀម ទូលសុំព្រះចៅសៀមលើកទ័ពមកច្បាំងនឹងនគរកម្ពុជា ព្រះចៅសៀមក៏ចាត់ចៅពញា (បឌិន) ជាមេកងទ័ពយកទាំងព្រះអង្គអិមនឹងព្រះអង្គឌួងមកផង លើកមកច្បាំងឥតមានប្រកាសសង្គ្រាមជាមុនសោះ ទ័ពសៀមធ្លាយដល់ពោធិសាត់ ហើយព្រះបាទសម្តេចព្រះអង្គច័ន្ទ គង់នៅភ្នំពេញរៀបចំទិងរបច្បាំងមិនទាន់ ក៏ទ្រង់ស្តេចដោះព្រះអង្គទៅឯខេត្តលង់ហោ (វិញឡុង) ទ័ពសៀមដេញតាមទៅ ប៉ុន្តែចាញ់ទ័ពយួនក៏ថយត្រឡប់ទៅក្រុងសៀមវិញ ព្រមទាំងព្រះអង្គ (អិម) និងព្រះអង្គឌួង ។ ទ័ពយួនក៏ដង្ហែព្រះបាទសម្តេចព្រះអង្គច័ន្ទចូលមកនគរកម្ពុជាវិញ (គ.ស ១៨៣១) ។

ព្រះបាទសម្តេចព្រះអង្គច័ន្ទ ទ្រង់ព្រះរាជសុវណ្ណគតក្នុង គ.ស ១៨៣៤ ។

## ព្រះរាជសត្រីយ៍អង្គម៉ី

(ពី គ.ស ១៨៣៤ ដល់ ១៨៤១)

-សៀមប្រាថ្នាបំបាត់វង្សក្សត្រិយ៍ខ្មែរតាំងពីយូរមកហើយ ។

ព្រះបាទសម្តេចព្រះអង្គច័ន្ទព្រះរាជសុវណ្ណគតទៅ ទ្រង់គ្មានព្រះរាជបុត្រាទេ មានតែព្រះរាជបុត្រី ៤ព្រះអង្គ តាំងព្រះអង្គអិមឬព្រះអង្គឌួងជាស្តេចអម្ចាស់ផែនដីក៏បាន ប៉ុន្តែមិនព្រមតាំង ទៅផ្គងនឹងតាំងព្រះរាជធីតាព្រះអង្គ "បែន" ជាព្រះរាជបុត្រីទី ១ នៃព្រះបាទអង្គច័ន្ទឱ្យឡើងគ្រងរាជសម្បត្តិទេវិញ ប៉ុន្តែព្រះរាជសត្រី "បែន" នេះទ្រង់រឹងមានះនឹងយួនណាស់ រួចក្រោយមករាជការយួនតាំងព្រះអង្គម្ចាស់សត្រី "ម៉ី" ជាព្រះរាជធីតាទី ២ នៃព្រះបាទអង្គច័ន្ទឡើងជាអម្ចាស់ផែនដីវិញ ។

ក្នុងរាជ្យព្រះរាជសត្រីអង្គម៉ី អំណាចនៅលើមេទ័ពយួនទាំងអស់ មេទ័ពធំសំរេចរាជការ ឱ្យរាជការខ្មែរទទួលរកស្បៀងអាហារចិញ្ចឹមថែរក្សាទាហាន ដែលនៅក្នុងស្រុក។

កាប់ដើមពោធិ-គ្រវាត់ព្រះពុទ្ធរូប រំលាយចេតិយក្នុងវត្តចោល ដើម្បីនាំរាស្ត្រខ្មែរឱ្យលះបង់ព្រះពុទ្ធសាសនា ។

www.budinst.gov.kh www.elibraryofcambodia.org

-រករឿងយកព្រះអង្គអិមទៅឃាំងទុកឯក្រុងហ្វេ យកព្រះរាជក្សត្រីអង្គមុី ទាំងព្រះរាជវង្សានិងសេនាបតីទៅឃាំងទុកឯព្រៃនគរ ។

-កាលបើដូច្នេះក៏មានសេចក្តីក្តៅក្រហាយពរាស់ មានបះបោរពេញទាំងព្រះរាជនគរ ហើយមានខ្មែរអ្នកមេគំនិតពើ ៗគ់ត្បាដោយសំងាត់ ។ ចំណែកឯខាងនាមុឺនធំៗក៏ប្រជុំគ្នាជំនុំសម្រេចចាត់បំរើទៅឯព្រះចៅក្រុងសៀម សុំព្រះអង្គឌួងមកជាអម្ចាស់ផែនដី. ព្រះចៅក្រុងសៀមយល់ឃើញថា ជាឱកាសយកនគរកម្ពុជាជាប្រទេសរាជ ក៏ចាត់ចៅពញាបឌិនជាមេទ័ពឱ្យតែងទ័ពលើកដង្ហែព្រះអង្គឌួងចូលមកនគរកម្ពុជា (គ.ស ១៨៤១) ។

**សេចក្តីពិស្តារ** - ព្រះបាទសម្តេចព្រះឧទ័យរាជា ព្រះអង្គច័ន្ទអម្ចាស់ផែនដីក្រុងកម្ពុជា គង់នៅព្រះរាជវាំងទំនាបត្រើយពោធិព្រះបាទ ទ្រង់ប្រឈួនពេទ្យប្រកបព្រះឱសថមិនជល់ ទ្រង់ព្រះសុវណ្ណគតនៅថ្ងៃ ៦ ១១ ២ ឆ្នាំមមីឯស័ក ព.ស ២៣៧៧ សិរីព្រះជន្មបាន ៤៤ឆ្នាំ សិរីរាជសម្បត្តិបាន ២៨ឆ្នាំ ព្រះបាទសម្តេចព្រះឧទ័យរាជាព្រះអង្គច័ន្ទ ទ្រង់ព្រះសុវណ្ណគតទៅគតមានព្រះរាជឱរសនឹងសោយរាជសម្បត្តិស្នង មានតែព្រះរាជធីតា ៤ ព្រះអង្គ ដូចមានព្រះនាមខាងក្រោមនេះ :

ទី ១ - ព្រះអង្គម្ចាស់ស្រ្តី បែន

ទី ២ - ព្រះអង្គម្ចាស់ស្រ្តី មុី

ទី ៣ - ព្រះអង្គម្ចាស់ស្រ្តី ពៅ

ទី ៤ - ព្រះអង្គម្ចាស់ស្រ្តី ស្ងួន

នោះរាជការយួនក្រុងវៀតណាម ផ្តងនឹងតាំងព្រះរាជធីតាទី ១ ព្រះអង្គបែន ឱ្យឡើងគ្រងរាជសម្បត្តិជាអម្ចាស់ផែនដីក្រុងកម្ពុជា ឱ្យនាមុឺនយួនទៅត្រួតត្រារាជការគ្រប់ជំពូក ។

ក្រោយនោះអម្ចាស់ផែនដីក្រុងវៀតណាម មានសុភអក្សរមកដល់លោកសម្រេចរាជការក្រុងកម្ពុជា ឱ្យនិយាយបញ្ចុះបញ្ចូលអស់សេនាបតីខ្មែរថា ក្រុងកម្ពុជាក្នុងខណៈនេះមានតែស្តេចស្រីជាម្ចាស់ផែនដី ប្រសិនបើមានការសឹកសង្រ្គាមចូលព្រះនគរ ក៏ជាលំបាកអស់ប្រជាជន ជាអម្ចាស់ផែនដី. ក្រុងវៀតណាម មានព្រះរាជហឫទ័យនឹងតែង

www.budinst.gov.kh www.elibraryofcambodia.org

ព្រះរាជនិរសខាងយួនមកអភិសេកនឹងព្រះអង្គ បែន ម្ចាស់ស្ត្រីខ្មែរ នឹងបានជួយរក្សាផែនដី ក្រុងកម្ពុជាធិបតីឱ្យជាវឌ្ឍនាការ តវង្សក្សត្រីខ្មែរដល់អស់កាលាវសាន ។

ខណៈនោះ សេនាបតិខ្មែរយល់ឃើញថា បើនឹងទទួលព្រមឱ្យរាជនិរសយួនមកអភិសេកនឹងម្ចាស់ផែនដីស្ត្រីខ្មែរនោះ ផែនដីព្រះនគរក្រុងកម្ពុជានិងរាជវង្សក្សត្រីខ្មែរនឹងទៅជាយួនទាំងអស់តរៀងទៅ ។

អស់សេនាបតីខ្មែរឆ្លើយតបនឹងក្រុងយួនថា ខ្មែរនិងយួនជាតិភាសាផ្សេងគ្នាហើយខាងខ្មែរក៏ជានគរតូច មិនគួរជាគូអភិសេកនឹងព្រះរាជនិរសយួន សឹងជាព្រះនគរធំ ។ ខណៈនោះ ក្រុងយួនបានដឹងថា សេនាបតីខ្មែរនិយាយទាស់អធ្យាស្រ័យក៏នៅស្ងៀមមួយអន្ទើ ។

ក្រោយនោះព្រះអង្គ បែន មានសេចក្តីក្តៅព្រះទ័យនឹងយួនធ្វើសង្កត់សង្កិនទ្រង់ប្រារព្ធនិងរត់ទៅគង់នៅជាមួយនឹងព្រះមាតាឯក្រុងទេព ទើបមានចុតហ្មាយថ្លែងសេចក្តីទៅដល់ព្រះមាតាឯក្រុងទេព នោះអ្នកមាតាទេពឱ្យបំរើកាន់សំបុត្រមកនេះ ណាត់ឱ្យព្រះអង្គកែវ ម៉ា មកទទួលព្រះអង្គស្ត្រី បែន អញ្ជើញស្តេចយកទៅក្រុងទេពនោះ អ្នករាជការខាងយួន ក្នុងក្រុងភ្នំពេញចាប់សំបុត្របាន នោះអុងយួនសំរេចរាជការក្រុងកម្ពុជាឱ្យចាប់ព្រះអង្គម្ចាស់ស្ត្រី បែន ដាក់ច្រវាក់ឃុំទុកក្នុងបន្ទាយឈ្មួន ក្រុងភ្នំពេញ ហើយឱ្យបញ្ជូនព្រះរាជអនុជស្ត្រីទាំងបីព្រះអង្គ និងនាម៉ឺនខ្មែរជាច្រើនទៅក្រុងវ៉េ ហើយឱ្យនាំត្រឡប់មកទុកនៅស្រុកព្រៃនគរ ។

ក្រោយនោះអុងយួនសំរេចរាជការក្រុងកម្ពុជា ចាប់ព្រះអង្គម្ចាស់ស្ត្រី បែន ច្រកក្នុងថង់នាំយកទៅទំលាក់ទឹកសមុទ្រមេចរក្សៀយព្រះជន្មទៅ ។ ក្រោយនោះនាម៉ឺននិងរាស្ត្រខ្មែរជាច្រើន ព្រមគំនិតគ្នាសរសេរសំបុត្រចុះឈ្មោះថ្វាយដល់ព្រះអង្គឌួង សូមឱ្យទ្រង់ព្រះដំរិះថា ស្តេចចេញមកក្រុងកម្ពុជា ហើយព្រមគំនិតគ្នា សរសេរសំបុត្រចុះឈ្មោះប្រថាប់ត្រាជូនដល់ចៅពញាបឌិន ដែលជាមេទ័ពសៀម សូមឱ្យយកសេចក្តីក្រាបបង្គំទូលព្រះចៅក្រុងស្យាម សូមព្រះអង្គឌួងឱ្យស្តេចចេញមកជាអម្ចាស់ផែនដីក្រុងកម្ពុជាធិបតី ។

ចៅពញាបឌិនដែលជាមេទ័ពស្យាម បានទទួលសំបុត្រនាម៉ឺនខ្មែរក្រុងកម្ពុជាហើយ

www.budinst.gov.kh www.elibraryofcambodia.org

ឱ្យបំរើនាំចូលទៅក្រុងទេព ខាងរាជការក្រុងទេពបានដឹងសេចក្ដីសំបុត្រដូច្នោះ ក៏យល់ឃើញថាជាឱកាសដ៏ងយកក្រុងកម្ពុជា ជាប្រទេសរាជ មានបង្គាប់ឱ្យកេណ្ឌរាស្ត្រខែត្រ ចតុរាជសីមា ខេត្តចម្បាស័ក ខេត្តសុរិន ខេត្តសិង្ហៈបុរី ខេត្តសុវណ្ណភូមិ ខេត្តយសោធរ ជំនុំព្រមទាំងសេនាបតីស្យាមតាំងព្រះអង្គឌួង ជាម្ចាស់ផែនដីក្រុងកម្ពុជា ចាត់ខាហ្លួងស្យាម ៨ នាយពល ២០០ ឱ្យដង្ហែព្រះអង្គឌួងស្ដេចពីក្រុងទេព នៅថ្ងៃ ៤ ៦ ២ ឆ្នាំជូតទោស័ក ព.ស ២៣៨៤ ច.ស ១២០២ ស្ដេចយាងមកដល់ខេត្តបាត់ដំបងនៅថ្ងៃ ៥ ១៣ ៣ ឆ្នាំជូតទោស័កដដែលនេះ ចៅពញាបឌិនដែលជាមេទ័ពស្យាមឱ្យតែងសំបុត្រប្រកាសអស់ឧកញ៉ា-ពញាព្រះខ្មែរទាំងអស់ឱ្យបានដឹង ក្នុងសេចក្ដីប្រកាសនោះថា ដឹងមានសំបុត្រសូមព្រះអង្គឌួងមកជាម្ចាស់ផែនដីក្រុងកម្ពុជានោះ បានសំរេចដូចសេចក្ដីប្រាថ្នា ហើយសូមឱ្យឧកញ៉ា-ពញាព្រះខ្មែរទទួលអំណាចបារមី នឹងបានទទួលទឹកពិភទ្ទសច្ចា នោះពួកមន្ត្រីខ្មែរដែលមានចិត្តស្ម័គ្រចង់បានព្រះអង្គឌួងមកជាម្ចាស់ផែនដីក្រុងកម្ពុជាក៏មានសេចក្ដីត្រេកអរ បបួលគ្នាទៅថ្វាយបង្គំព្រះអង្គឌួងឯខេត្តបាត់ដំបង។

ចៅពញាបឌិនដែលជាមេទ័ពស្យាម រៀបពិធីឱ្យអស់នាម៉ឺនខ្មែរទទួលទឹកពិភទ្ទសច្ចារួចស្រេចហើយ ទើបឱ្យធ្វើការច្បាំងនឹងយួន ។

ខាងយួនក៏ឱ្យកេណ្ឌរាស្ត្រខេត្តបាសាក់-ខេត្តព្រះត្រពាំង ខេត្តក្រមួនសច្បាំងនឹងស្យាម ។

ក្រោយនោះស្ដេចទេព្វាក្រុងវៀតណាម បានបង្គាប់មកចៅហ្វាយខែត្រព្រៃនគរឱ្យរៀបបញ្ជូនស្ដេចស្ត្រីខ្មែរទាំង ៣ ព្រះអង្គ និងសម្ដេចព្រះស្រីជ័យជេដ្ឋព្រះអង្គ (អិម) និងលោកមាតារស់ ព្រះមាតាព្រះអង្គ អិម ព្រះអង្គឌួងមកក្រុងកម្ពុជា ឱ្យរៀបសង់ព្រះដំណាក់ក្នុងខេត្តមាត់ជ្រូក ថ្វាយសម្ដេចជ័យជេដ្ឋមហាឧបរាជព្រះអង្គ អិម ព្រះអង្គស្ត្រី ម៉ី ព្រះអង្គស្ត្រី ពៅ ព្រះអង្គស្ត្រី ស្ងួន និងលោកមាតារស់ ។

សម្ដេចព្រះស្រីជ័យជេដ្ឋព្រះអង្គ អិម បានព្រះអង្គស្ត្រី ពៅ ធ្វើជាព្រះជាយា មានព្រះរាជបុត្រ ១ ព្រះនាមព្រះអង្គម្ចាស់ស្ត្រី សំនិ ព្រះអង្គភិមជាព្រះរាជបុត្រសម្ដេចព្រះស្រីជ័យជេដ្ឋព្រះអង្គ អិម បានព្រះអង្គម្ចាស់ស្ត្រី ស្ងួន ធ្វើជាព្រះជាយា មានព្រះរាជបុត្រព្រះអង្គ ១ ព្រះនាមជាអ្នកអង្គថ្មមវង្ស ក្រោយនោះសម្ដេចព្រះស្រីជ័យជេដ្ឋ

www.budinst.gov.kh www.elibraryofcambodia.org

ព្រះអង្គ អិម សុវណ្ណគតទៅស្រុកមាត់ជ្រូក មានព្រះរាជបុត្រ ២ ព្រះអង្គ ព្រះរាជធីតា ៤ ព្រះអង្គ ។

ក្រោយនោះរាជការខាងយួនតាំងព្រះអង្គម្ចាស់ស្រី ម៉ី ព្រះរាជធីតាទី ២ នៃព្រះបាទសម្ដេចព្រះឧទ័យរាជាព្រះអង្គចន្ទ ឡើងជាអម្ចាស់ផែនដីក្រុងកម្ពុជាធិបតី ថ្វាយព្រះនាមតាមពាក្យយួនថា ឯាកងជួរ ហើយឱ្យអញ្ជើញផ្លូវព្រះវលញ្ឆរសម្រាប់អម្ចាស់ផែនដី និងព្រះខ័នរាជជ័យសិរីទៅថ្វាយព្រះអង្គ ម៉ី អម្ចាស់ផែនដីស្រីឯស្រុកមាត់ជ្រូក ។

សម្ដេចក្សត្រី មាលិកា

## ព្រះបាទសម្ដេចព្រះអង្គឌួង (ព្រះហរិរក្សរាមា)

(ពី គ.ស ១៨៤១ ដល់ ១៨៦០)

នៅពេលដែលទ័ពចៅពញាបឌិន ដង្ហែព្រះបាទអង្គឌួងចូលមកយករាជសម្បត្តិ មេទ័ពយួនក៏កេណ្ឌគងទ័ពមកច្បាំងរាំងរាដែរ ប៉ុន្តែចាក់ទ័ពគ្រប់តែអធ្វើ ព្រះបាទសម្ដេចព្រះអង្គឌួង ទ្រង់ស្ដេចចូលមកដល់ក្រុងឧដុង្គ ទ្រង់តាំងព្រះរាជបញ្ជាចាត់ការរាជការ។

រាជការយួនកេណ្ឌទ័ពចូលមកច្បាំងតទៅទៀត ខាងខ្មែរមានចៅពញាបឌិនជាមេទ័ពជាឧភ័យ។ ឯចំបាំងនឹងយួននេះជាប់ ៤ ឆ្នាំ តាំងពី គ.ស ១៨៤១ ដល់ ១៨៤៥ មិនចាញ់មិនឈ្នះ ។ ដល់ពេលក្រោយបំផុត មេទ័ពទាំងសងខាងបានព្រមព្រៀងនឹងគ្នាឈប់ច្បាំង ព្រមលើកព្រះបាទសម្ដេចព្រះអង្គឌួងជាស្ដេចអម្ចាស់ផែនដីនគរកម្ពុជា រាជការក្រុងសៀមនិងរាជការក្រុងអណ្ណាមសំរេចសិទ្ធិសញ្ញាក្នុង គ.ស ១៨៤៦ យួនព្រមបើកព្រះស្រីអង្គម៉ី ទាំងព្រះរាជវង្សានុវង្សនាម៉ឺនទាំងប៉ុន្មាន ដែលនាំទៅខាំងទុកឯស្រុកយួននោះ ឱ្យត្រឡប់មកស្រុកខ្មែរវិញ ។

ព្រះបាទសម្ដេចព្រះអង្គឌួងទ្រង់ទទួលប្រាប្ដាភិសេក នៅក្រុងឧដុង្គក្នុង គ.ស ១៨៤៧ ព.ស ២៣៩០ មានព្រះរាជបំរើពីក្រុងសៀម និងពីក្រុងវៀតណាម (អាណ្ណាម) មកក្នុងព្រះរាជពិធីនេះ ។

ព្រះបាទសម្ដេចព្រះអង្គឌួងជាអម្ចាស់ផែនដី ឈ្លាសវៃណាស់ កាលបើទ្រង់បានទទួលប្រាប្ដាភិសេករួចហើយ សៀមសុំព្រះអង្គសំរេចសិទ្ធិសញ្ញាផ្ដាច់យកខេត្តម្លូព្រៃ-ទន្លេរពៅ ហើយនឹងខេត្តឯទៀត ។ ដែលសៀមយកបានកាលពីមុន ព្រះបាទសម្ដេច

www.budinst.gov.kh www.elibraryofcambodia.org

ព្រះអង្គឌួង ទ្រង់មានព្រះតម្រាស់ថា "ខ្ញុំមិនឱ្យអ្វីទៅសៀមទាំងអស់ ប៉ុន្តែសៀមខ្លាំងពូកែ សៀមទុកសិនទៅចុះ ខេត្តណាដែលសៀមយកបានពីមុនៗនោះ" ។

កាលព្រះបាទសម្តេចព្រះអង្គឌួង ទ្រង់ឡើងសោយរាជសម្បត្តិ នគរបាក់បែកហិនហោចខ្ទេចខ្ទី អាណាប្រជានុរាស្ត្រអត់ឃ្លានវេទនាណាស់ទៅហើយ ពីព្រោះតែសឹកសង្គ្រាមជាញឹកញាប់ពីរាជ្យមុនៗមក ទ្រង់ព្រួយព្រះរាជហឫទ័យណាស់ ប៉ុន្តែដោយទ្រង់ឈ្លាសវៃ ហើយប្រកបដោយទសពិធរាជធម៌ ទ្រង់ប្រោសព្រួសស្រោចស្រង់ព្រះរាជនគរនូវអាណាប្រជានុរាស្ត្រឱ្យចំរើនខ្លះឡើងវិញបាន ។ ព្រះអង្គពុំសូវសព្វព្រះហឫទ័យខាងការសឹកសង្គ្រាមទេ ពីព្រោះទ្រង់ឈ្វេងថា ការសឹកសង្គ្រាមនេះនាំឱ្យហិនហោចខ្ទេចខ្ទី ទ្រង់មានតម្រាស់ប្រាប់ប្រាមថា ត្រូវតែរក្សារបស់ដែលនៅសល់ទាំងអម្បាលម៉ានឱ្យគង់សិន។

១- ទ្រង់បានសាងវត្តវិហារជាច្រើននៅឧដុង្គ តាំងអាចារ្យប្រដៅបរិយត្តិធម៌ បង្រៀនព្រះត្រៃបិដក (វត្តភ្នំចាស់) វត្តព្រះពុទ្ធនិព្វាន វត្តវិហារសំណ វត្តប្រាង្គ វត្តក្រាំងពន្លៃ វត្តសាលាគូ ។

២- ទ្រង់ឱ្យសាងសាលាទានសំរាប់ធ្វើសង្ឃទាន និងធ្វើទានដល់បណ្តាជនក្រីក្រលំបាកកំសត់អត់ឃ្លាន ។

៣- ទ្រង់ឱ្យរាជបណ្ឌិត្យ បុរោហិត ហោរាចារ្យ-កវីជាតិ ផ្ទៀងច្បាប់ កែច្បាប់ តែងច្បាប់សំរាប់ប្រើក្នុងព្រះរាជនគរឱ្យស្របតាមសម័យ ។

៤- ទ្រង់ជ្រើសតាំងជានាម៉ឺនមន្ត្រីតែអ្នកមានចំណេះវិជ្ជាជ្រៅជ្រះ ។

៥- ទ្រង់ព្រះរាជបញ្ជាឱ្យកុមារចូលទៅរៀនឱ្យច្រើននៅវត្ត ។

៦- ទ្រង់ព្រះរាជបញ្ញត្តិដាក់ទណ្ឌកម្មយ៉ាងធ្ងន់ដល់នាម៉ឺនជក់អាភៀន នាម៉ឺនទុច្ចរិតទទួលសំណូក ។

៧- ទ្រង់ព្រះរាជបញ្ញត្តិមិនឱ្យយកពន្ធពីរាស្ត្រ មិនឱ្យយកការប្រាក់ធ្ងន់ទេ ។

៨- ទ្រង់ឈ្វេងថា ប្រាក់សំរាប់ចាយជាប្រាក់បាតមកពីសៀមហើយតិចបានមក ផង ទ្រង់ឱ្យធ្វើពុម្ពបោះប្រាក់ជារាងសំប៉ែតមានគ្រុឌប្រាសាទម្ខាង រូបសត្វរាជហង្សម្ខាង ។

www.budinst.gov.kh www.elibraryofcambodia.org





៩- ទ្រង់សាងផ្លូវមួយពីឧដុង្គទៅកំពត យកកំពតជាកំពង់សមុទ្រ ហើយស្ពាងសំពៅមួយសំរាប់ផ្ទុកទំនិញទៅសិង្ហបូរ (សិង្ហបូរៈ) ពីព្រោះយួនបិទមិនឱ្យចេញចូលតាមផ្លូវព្រែកនគរ ។

១០- ទ្រង់ចំណាយព្រះរាជទ្រព្យ ចាត់កូនខ្មែរឱ្យទៅរៀនភាសាបារាំងសែសឯសិង្ហបូរសំរាប់ប្រើការក្នុងរាជការ ពីព្រោះពេលនោះ មានបារាំងសែសមកពាក់ព័ន្ធនឹងប្រទេសយួនហើយ ទ្រង់ឈ្វេងថា ថ្ងៃក្រោយមុខជាបារាំងសែសមកជាឥស្សរៈនៅឥណ្ឌូចិន ។

**សេចក្តីពិស្តារ** - ថ្ងៃ ១ ᧱ ៤ ឆ្នាំមមែនព្ស័ក ព.ស ២៣៩០ ច.ស ១២០៩ ត្រូវនឹងថ្ងៃ ៥ ខែម៉ាឲ្យ គ.ស ១៨៥៦ រៀបពិធីប្រាព្ធភិសេកព្រះអង្គឌួង ចំរើនពុទ្ធមន្តស័យមន្ត ៣ ថ្ងៃ ដល់ថ្ងៃ ៤ ᧤ ៤ ឆ្នាំមមែនព្ស័ក បានវេលាជាឧត្តមឫក្ស ព្រះមហារាជគ្រូបុរោហិត ថ្វាយស្រង់មុទ្ធាភិសេក ថ្វាយព្រះនាមព្រះបាទសម្តេចព្រះហរិរក្សរាមាមហាឥស្សរាធិបតី ព្រះស្រីសុរិយោពង្សិកវរោត្តម បរមសុរិន្ទ្រាមហាចក្រពត្តិរាជពិសាលនារថ ស្ថិតជាឥស្សរវរៈកម្ពុជរដ្ឋរាស្ត្រ វរោភាសជាតិវង្សមម្រង់ក្រុងកម្ពុជា មហាឥន្ទបត្ថ-គុរុរដ្ឋរាជធានីបវរវិឡិវេក ឯកអគ្គមហាខេមរាធិបឌិន សុរិន្ទ្រវិសុទ្ធិ ឧត្តមបរមបពិត្រ។

ក្នុងខែពិសាខឆ្នាំវកសំរិទ្ធិស័ក ព.ស ២៣៩១ ច.ស ១២១០ គ.ស ១៨៥៦ ព្រះបាទសម្តេចព្រះហរិរក្សរាមាព្រះអង្គឌួង ត្រាស់បង្គាប់ឧកញ៉ាសួគ៌ាលោក(តោះ) ១ ឧកញ៉ាពិជ័យរឿនវង់សង្គ្រាម "ប៊ី" ១ ឧកញ៉ាពិភក្តិរាជា ហែម ១ ឱ្យរើសបុត្រមន្ត្រីឱ្យតាមហែព្រះរាជឱរស ព្រះអង្គម្ចាស់រាជាវតីស្តេចទៅក្រុងទេព មន្ត្រីនិងបុត្រមន្ត្រីបណ្តាជាខ្ញុំតាមហែស្តេចចូលទៅក្រុងទេព ចំនួន ១០៥ នាក់ . . .

www.budinst.gov.kh www.elibraryofcambodia.org

ព្រះបាទសម្តេចព្រះហរិរក្សរាមាមហាឥស្សរាធិបតីព្រះអង្គឌួង អម្ចាស់ផែនដីក្រុងកម្ពុជា ស្តេចមានព្រះរាជហឫទ័យប្រកបដោយទសពិធរាជធម៌ បំរុងរាជប្រពៃណីជាទីសវនាទៃអស់អាណាប្រជារាស្ត្រផងទាំងពួង ទ្រង់ព្រះសទ្ធាស្ថាងវត្តវិហារជាច្រើនស្ថានតាំងអាចារ្យប្រដៅបរិយុត្តិធម៌ បង្រៀនព្រះត្រៃបិដក សុត្តន្តបិដក ចំណាយព្រះរាជទ្រព្យឱ្យទានអាហារ មនុស្សកំសត់ទុរគតអ្នកគោចរអនាថា ទ្រង់ឱ្យស្ថាងផ្លូវថ្នល់ពីក្រុងឧដុង្គ ចុះតាមកំពង់ហ្លួងមកខេត្តភ្នំពេញទៅខេត្តកំពត ។

ក្នុងឆ្នាំឆ្លូវបញ្ចស័ក ព.ស ២៣៩៦ ច.ស ១២១៥ ត្រូវនឹង គ.ស ១៨៥៣ ព្រះបាទសម្តេចព្រះហរិរក្សរាមា មហាឥស្សរាធិបតី ជាអម្ចាស់ផែនដីក្រុងកម្ពុជា ស្តេចចេញគង់នៅព្រះទីនាំងមង្គលាភិសេក ជួបជុំអស់មាត្យាភិមុខមន្ត្រី រាជបណ្ឌិត បុរោហិតា ហោរាចារ្យ គរីជាតិ មានព្រះរាជតម្រាស់ត្រាស់បរិហារឱ្យផ្ទៀងច្បាប់ កែច្បាប់តែងច្បាប់សំរាប់ប្រើក្នុងព្រះនគរបវររាជធានី ដើម្បីតម្រូវសេចក្តីឱ្យត្រូវតាមសម័យ ហើយទ្រង់ព្រះដំរិះឱ្យធ្វើពុម្ពអក្សរខ្មែរ ឱ្យធ្វើពុម្ពបោះប្រាក់ជាតិ រូបត្រាប្រាសាទម្ខាង រូបសត្វរាជហង្សម្ខាង សម្រាប់ចាយប្រើក្នុងព្រះនគរបវររាជធានី ។

ក្នុងរវាងនោះរាជការបារាំងសែស មានការពាក់ព័ន្ធនឹងប្រទេសយួនកូសាំងស៊ីន ព្រះបាទសម្តេចព្រះហរិរក្សរាមាអម្ចាស់ផែនដីក្រុងកម្ពុជា ទ្រង់ព្រះដំរិះយល់ឃើញថាជាតិបារាំងសែសនឹងមុខជាឥស្សរៈលើប្រទេសឥណ្ឌូចិននេះ ទើបទ្រង់ប្រារព្ធនឹងមានសុភអក្សរទៅក្រុងបារាំងសែស ដើម្បីជាប្រយោជន៍ដល់ជនជាតិខ្មែរនេះ ១ ១១ទៀតជាហេតុនឹងរកឱកាសទ្រង់ប្រារព្ធអំពីអាណាខេត្តក្រុងកម្ពុជា សឹងយួនដណ្តើមយកទៅគ្រប់គ្រងជារបស់យួន ។

ក្នុងឆ្នាំឆ្លូវបញ្ចស័ក ព.ស ២៣៩៦ ច.ស ១២១៥ ព្រះបាទសម្តេចព្រះហរិរក្សរាមាអម្ចាស់ផែនដីក្រុងកម្ពុជា ទ្រង់តាំងឈ្មោះ កុយ ម៉ុងតេរ៉ូ ជាព្រះថ្វជិតសេដ្ឋី ។

តែងព្រះថ្វជិតសេដ្ឋី កុយ ម៉ុងតេរ៉ូ ១ ក្រុមព្រះអាលក្សណ៍មានទាមព្រះស្មៀនកើត ១ ស្មៀនមុម ១ ទាំងបីនាក់ជាព្រះរាជបំរើអញ្ជើញព្រះសុភអក្សរ នឹងគ្រឿងរាជបណ្ណាការទៅដល់កុងស៊ុលបារាំងសែសប្រចាំក្រុងសិង្ហបុរី សុំឱ្យផ្ញើទៅថ្វាយអម្ចាស់ផែនដីក្រុងបារាំងសែស ។

www.budinst.gov.kh www.elibraryofcambodia.org

ការសឹងព្រះរាជបំពិធីខ្មែរក្រុងកម្ពុជា អញ្ជើញព្រះសុភអក្សរ និងគ្រឿងរាជបណ្ណាការ នៅក្នុងខណៈនោះ ម៉ុងសៃញ៉រ មិស ជាអ្នកណែនាំបំភ្លឺផ្លូវ កិរិយាសឹងព្រះរាជបំរើទៅនោះថាជាទៅដោយផ្លូវជំនួញ ដោយព្រះបាទជាអម្ចាស់ផែនដីទ្រង់ព្រះដំរិះជាសេចក្ដីសុខុម ។

ព្រះរាជនិវេសព្រះអង្គម្ចាស់រាជាវតី គង់ក្នុងក្រុងទេព ព្រះជន្ម ២០ឆ្នាំ ៥ខែ ថ្ងៃ ៣ ១៣ ៨ ឆ្នាំរោងអដ្ឋស័ក ព.ស ២៣៩៩ ច.ស ១២១៨ ព្រះបាទសម្ដេចព្រះចមក្សាវ ព្រះទានគ្រឿងផ្នួសឧបសម្បទកម្មជាភិក្ខុនៅវត្តព្រះស្រីរត្នសាស្ដារាមក្រុងទេព ក្រុមហ្លួនបវរវង្សជាព្រះឧបជ្ឈាយ៍ បានព្រះនាមឆាយាក្នុងព្រះពុទ្ធសាសនា ជាព្រះនរោមត្តមគង់ចាំវស្សានៅវត្តបវរនីវេតក្រុងទេព ។

ក្នុងឆ្នាំរោងអដ្ឋស័កនោះ មានសារត្រាសេនាបតីក្រុងស្យាមច្បាប់ ១ ជាផ្លូវរាជការប្រាប់ដំណឹងមករាជការក្រុងកម្ពុជា អំពីរាជទូតក្រុងបារាំងសែសមកក្រុងស្យាម ធ្វើសញ្ញាព្រះរាជមេត្រីក្រុងបារាំងសែសនឹងក្រុងស្យាម ហើយថារាជទូតបារាំងសែសនឹងមកនគរកម្ពុជា មានសុភអក្សរឡាយព្រះហស្ដលេខា ព្រះបាទសម្ដេចព្រះចមក្សាវព្រះចៅក្រុងស្យាមច្បាប់ ១ ទៀត ជាសេចក្ដីផ្ទាល់ព្រះអង្គ ព្រះបាទសម្ដេចព្រះហរិរក្សរាមាអម្ចាស់ផែនដីក្រុងកម្ពុជា ក្នុងសុភអក្សរនោះមានសេចក្ដីថា ម៉ុងតេញីរាជទូតនិយាយអង់គ្លេសបានទាំងខ្លួនទាំងកូនស្រីទាំងពីរ បានចូលទៅក្នុងព្រះបរមរាជវាំងច្រើនវេលា ទៅនិយាយដោយភាសាអង់គ្លេសមិនបាច់មានអ្នកប្រែភាសា ពន្យល់សេចក្ដីថាអម្ចាស់ផែនដីក្រុងបារាំងសែសជ្រាបសេចក្ដីថា សម្ដេចព្រះហរិរក្សរាមាមានទឹកព្រះទ័យនឹងចងមេត្រីនឹងជាតិបារាំងសែស បានចាត់មុខរបស់ក្នុងស្រុកខ្មែរនិងរបស់ឯទៀតធ្វើទៅ ដើម្បីថ្វាយដល់អម្ចាស់ផែនដីក្រុងបារាំងសែស របស់ទាំងនោះក៏មិនបានទៅដល់សាបសូន្យនៅកណ្ដាលផ្លូវ គ្រាន់តែអម្ចាស់ផែនដីក្រុងបារាំងសែសជ្រាបសេចក្ដីជាងក្រោយ . . . ។

ព្រះបាទហរិរក្សរាមាមហាឥស្សរាធិបតីអម្ចាស់ផែនដីក្រុងកម្ពុជា បានទ្រង់ទទួលដំណឹងពីក្រុងទេព ជ្រាបសេចក្ដីថារាជទូតក្រុងបារាំងសែសនឹងមកក្រុងកម្ពុជា ទើបត្រាស់បង្គាប់កំណាន់ខេត្តឱ្យមានសំបុត្រទៅចៅហ្វាយខេត្តកំពត ឱ្យសង់រោងទំនៀបចាំ

www.budinst.gov.kh www.elibraryofcambodia.org

ទទួល ហើយទ្រង់ចាត់ឧកញ៉ាព្រះខ្មែរ ឱ្យទៅចាំទទួលឯខេត្តកំពត ត្រាស់បង្គាប់ឱ្យភ្នាក់ងារជំរឹទាំជំរឹជំនិះទៅចាំទទួលពីខែត្រកំពតមកក្រុងឧដុង្គ តែមុនស៊ីអ៊ីជីម៉ុងតេញីរាជទូតក្រុងបារាំងសែសមិនមកដល់ក្រុងឧដុង្គមានជ័យ មកតែត្រឹមខេត្តកំពត ហើយហួសតាមផ្លូវសមុទ្រទៅខែត្រកូសាំងស៊ីន . . . ។

ឯនាម៉ឺនខ្មែរដែលទៅទទួលក៏ត្រឡប់ចូលក្រុងឧដុង្គវិញ ។

ព្រះរាជនិរស ព្រះអង្គម្ចាស់រាជាវតី ទ្រង់ព្រះផ្នួសគង់នៅវត្តបវរនិវេសក្រុងទេពចាំវស្សាអស់ត្រីមាស ។

ព្រះបាទសម្តេចព្រះចមក្លាវព្រះចៅក្រុងស្យាម ទ្រង់ព្រះដំរិះយល់ឃើញថា គួរគប្បីឱ្យព្រះអង្គម្ចាស់រាជាវតី ភិក្ខុនរោត្តម និមន្តមកក្រុងកម្ពុជា នាំខ្លួនភិក្ខុមកថ្វាយព្រះរាជកុសលដល់ព្រះវរបិតាមាតា ទ្រង់ព្រះដំរិះដូច្នោះហើយ ត្រាស់បង្គាប់ភ្នាក់ងារឱ្យរៀបកបាល់ភ្លើង ហើយត្រាស់បង្គាប់ឱ្យក្រសួងធម្មការឱ្យអារាធនាព្រះអមរាភិរក្ខិតឱ្យនាំព្រះអង្គម្ចាស់រាជាវតី ភិក្ខុនរោត្តមស្តេចមកក្រុងកម្ពុជាធិបតី ស្តេចចេញពីក្រុងទេពដោយវិធីជលមាគ៌ មកខែត្រកំពត ។

ព្រះបាទសម្តេចព្រះហរិរក្សរាមាអម្ចាស់ផែនដីក្រុងកម្ពុជា បានទ្រង់ជ្រាបថា ព្រះរាជនិរស ភិក្ខុនរោត្តម នឹងស្តេចមកក្រុងកម្ពុជាតាមវិធីជលមាគ៌ ត្រាស់បង្គាប់ឱ្យភ្នាក់ងារសង់ព្រះពន្លារៀបពិធីទទួល ឱ្យមន្ត្រីក្រសួងធម្មការទៅចាំទទួល អញ្ជើញស្តេចព្រះដំណើរដោយវិធីសថលមាគ៌ពីខេត្តកំពតមកក្រុងឧដុង្គរៀបពិធីទទួល រៀបសេនាសនៈថ្វាយព្រះរាជនិរស ភិក្ខុនរោត្តមព្រះអមរាភិរក្ខិត គង់សំណាក់ព្រះមហាវិមលធម្ម មហាបានបញ្ញាសីលោ វត្តសាលាគួក្រុងឧដុង្គ ខ្នើតខែបុស្សឆ្នាំរោងអដ្ឋស័ក រៀបពិធីឆ្លងព្រះផ្នួសព្រះបាទសម្តេចព្រះហរិរក្សរាមា មានព្រះដម្រាស់ថា នឹងដាក់ព្រះផ្នួសក្នុងខណៈនេះ មិនគួរគប្បីត្រូវចូលទៅក្រុងទេពដាក់ផ្នួសឯក្រុងទេព ទើបគប្បីនឹងសេចក្តីព្រះចៅទ្រង់ប្រទានគ្រឿងផ្នួស ដល់ខ្នើតខែផល្គុន ឆ្នាំរោងចត្វាស័ក ត្រាស់បង្គាប់ភ្នាក់ងារឱ្យរៀបព្រះទីនាំងដង្ហែព្រះរាជនិរស ភិក្ខុនរោត្តម ស្តេចចេញពីក្រុងឧដុង្គដោយវិធិសថលមាគ៌ព្រមទាំងព្រះអមរាភិរក្ខិតរាជាគណសង្ឃ ស្តេចដល់ខេត្តកំពតចុះកបាល់ព្រះរាជដំណើរដោយវិធីជលមាគ៌ដល់ក្រុងទេព ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះបាទសម្ដេចព្រះហរិរក្សរាមា ព្រះអង្គឌួង ទ្រង់ព្រះដំរិះដល់ការប្រយោជន៍រាជការផែនដីក្រុងកម្ពុជា ដោយទ្រង់ព្រះយោបល់ឈ្វេងយល់ថា មិនយូរប៉ុន្មានជាតិបារាំងសែសនឹងមកជាឥស្សរៈក្នុងឥណ្ឌូចិន ទើបទ្រង់ព្រះប្រារព្ធព្រមនឹងម៉ុងសៃញ៉រ មិស ឱ្យជ្រើសរើសពួកសិស្សានុសិស្សក្នុងសាលាបង្រៀនមិស ទ្រង់ចំណាយព្រះរាជទ្រព្យ ឱ្យទៅរៀនឯស្រុកសិង្ហបុរី ដើម្បីទុកបំរុងប្រើការខាងផ្លូវរាជការនិងប្រើការផ្សេងៗ ។

ម៉ុងសៃញ៉រ មិស ជ្រើសរើសពួកសិស្សានុសិស្សដូចមាននាមខាងក្រោមនេះ ទាំងប្រាំបីនាក់ :

នាយ អម អាឡេសិស ដឺឡូប៉េស ១
នាយ គល់ ម៉ុងតេរ៉ូ ១
នាយ យ៉ន ម៉ុងតេរ៉ូ ១ រៀនសំបុត្រភាសា
នាយ ប៉ូល ម៉ុងតេរ៉ូ ១ រៀនសំបុត្រភាសា
នាយ ប៉ែន .. ១ }
នាយ អ៊ុង .. ១ } រៀនអាចារ្យ
នាយ រស់ .. ១ }
នាយ យ៉ាន .. ១ }

ព្រះបាទសម្ដេចព្រះហរិរក្សរាមា ត្រាស់បង្គាប់សេនាបតីក្រសួងព្រះឃ្លាំងឱ្យចំណាយប្រាក់ព្រះរាជទ្រព្យ ផ្ញើជិតសេដ្ឋី គុយ ម៉ុងតេរ៉ូ និងក្រុមព្រះអាលក្សណ៍ មាននាមស្មៀន កើត ឱ្យនាំសិស្សានុសិស្ស ៨នាក់ទៅរៀនឯសិង្ហបុរី ។

សម្ដេចក្សត្រី មាលិកា

ព្រះបាទសម្ដេចព្រះអង្គឌួង ទ្រង់ឆ្លាសវៃណាស់ ទ្រង់ឈ្វេងថា តទៅមុខជាមិនសុខនឹងសៀមហើយនឹងយួន ។ កាលបើទ្រង់មានព្រះដំរិះដូច្នេះ ទ្រង់ក៏ប្រារព្ធនឹងម៉ុងសៃញ៉រ "មិស" ព្រះសុគណាសាសនាកាតូលិកតាំងនៅពញាឮជាទីប្រឹក្សាណែនាំតែងព្រះរាជសុភអក្សរ និងព្រះរាជបណ្ណាការចាត់ព្រះរាជបំរើអញ្ជើញទៅដល់អ្នកតំណាងជាតិបារាំងសែស (កុងស៊ុល) នៅសិង្ហបុរី សុំឱ្យផ្ញើទៅថ្វាយអម្ចាស់ផែនដីក្រុងបារាំងសែស ជាព្រះរាជមេត្រី (គ.ស ១៨៥៤) ។

www.budinst.gov.kh www.elibraryofcambodia.org

ឆ្នាំក្រោយមក (គ.ស ១៨៥៦) លោកដឺម៉ុងតេញីរាជទូតបារាំងសែសចាត់មកធ្វើសន្ធិសញ្ញាអំពីផ្លូវជំនួញនឹងប្រទេសសៀម ហើយនឹងប្រទេសចិន បានទទួលបង្គាប់អំពីអម្ចាស់ផែនដីបារាំងសែសថា ឱ្យចូលថ្វាយបង្គំគាល់ព្រះបាទសម្ដេចអង្គឌួង ប្រារព្ធអំពីសន្ធិសញ្ញាព្រះរាជមេត្រីនោះផង នោះលោកដឺម៉ុងតេញី មកដល់ត្រឹមតែកំពតហើយហួសតាមផ្លូវសមុទ្រទៅដែនកូសាំងស៊ីនទៅ ។

រាជ្យព្រះបាទសម្ដេចព្រះបាទអង្គឌួង បានសុខណាស់រហូតដល់ចុងរាជ្យ (គ.ស ១៨៥៩) ទើបមានបះបោរមានទៅខេត្តត្បូងឃ្មុំលើកជាកងទ័ពមកច្បាំង ប្រាថ្នាចង់បង្កើតជាខេត្តដែនចាមមួយដាច់ដោយឡែក. ស្ដាប់តែនាយកចាមដួចគ្នា ទ័ពហ្លួងក៏លើកទៅវាយខ្ចាត់ខ្ចាយអស់ ខ្លះរត់ទៅចូលខេត្តមាត់ជ្រូកយកយួនជាទីអាង. ទ័ពខ្មែរក៏ដេញតាមទៅយួនប្រុងប្រៀបនឹងជួយចាមទៅហើយ ទទួលបារាំងសែសវាយយកបានខេត្តព្រៃនគរក៏ខានទៅវិញ ។

នៅឯក្រុងឧដុង្គ ព្រះបាទសម្ដេចព្រះអង្គឌួងជាអម្ចាស់ផែនដីទ្រង់ព្រះឈួនហើយព្រះរាជសុវណ្ណគត ទ័ពខ្មែរក៏ឈប់ដេញតាមទៅ ត្រឡប់ចូលមកក្រុងឧដុង្គវិញ (គ.ស ១៨៦០) ។

ព្រះបាទសម្ដេចព្រះហរិរក្សរាជាព្រះអង្គឌួងសុវណ្ណគតទៅ ទ្រង់មានព្រះរាជបុត្រា ៣ ព្រះអង្គព្រះមាតាទីទៃ :

ទី ១ ព្រះអង្គរាជាវតី (ដល់បានរាជ្យ ព្រះនាមព្រះបាទសម្ដេចព្រះនរោត្តម) ។

ទី ២ ព្រះអង្គសិរីសុវត្ថិ (ដល់បានសោយរាជ្យ ព្រះនាមជាព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ) ។

ទី ៣ ព្រះអង្គវរវៀតា ឬស៊ីវត្ថា ។

## ព្រះបាទសម្ដេចព្រះនរោត្តម

(ពី គ.ស ១៨៦១ ដល់ ១៩០៤)

ព្រះបាទសម្ដេចព្រះហរិរក្សរាមា ទ្រង់ព្រះរាជសុណ្ណគតទៅព្រមអស់សេនាទាម៉ឺនសព្វមុខមន្ត្រី សមណជីព្រាហ្មណាចារ្យ នូវអស់ព្រះរាជវង្សាប្រជុំព្រម អញ្ជើញ

www.budinst.gov.kh www.elibraryofcambodia.org



នរោត្តម ព្រហ្មបរិរក្សាមហាឧបរាជ ឡើងគ្រងរាជសម្បត្តិជាអម្ចាស់ ផែនដីនគរកម្ពុជាធិបតី គង់នៅក្រុងឧដុង្គមានជ័យ ។

នៅពេលដែលរៀបព្រះពិធី ថ្វាយព្រះបាទសម្តេចព្រះនរោត្តមគ្រងរាជសម្បត្តិ ព្រះចៅក្រុងសៀមក៏បើកព្រះអង្គវ័រវត្ថា (ស៊ីវត្ថា) ជាព្រះរាជអនុជដែលគង់នៅឯក្រុងបាងកក(ក្រុងទេព) ឱ្យចូលមកក្រុងឧដុង្គដែរ។

ព្រះបាទសម្តេចព្រះនរោត្តមក៏ទ្រង់ទទួលព្រះអនុជដោយរាក់ទាក់ មានទាំងប្រទាន មាសប្រាក់ហើយរៀបនឹងព្រះអង្គម្ចាស់ស្រី (ស៊ីវង្ស) ឱ្យជាព្រះជាយាផង ។

**សេចក្តីពិស្តារ** - ព្រះរាជនិរសព្រះអង្គម្ចាស់រាជាវតី (ភិក្ខុនរោត្តម) ស្តេចចូលទៅក្រុងទេព ក្នុងដើមឆ្នាំមមីស័រិទ្ធិស័ក ព.ស ២៤០១ ព្រះបាទសម្តេច ព្រះហរិរក្សរាមា មហាឥស្សរាធិបតី អម្ចាស់ផែនដីក្រុងកម្ពុជា តែងឧកញ៉ារាជតេជះ ឧកញ៉ានរិន្ទ្រាធិបតី ជាព្រះរាជបំរើអញ្ជើញសុភអក្សរទៅក្រុងទេព ។ ក្នុងសុភអក្សរនោះសេចក្តីថា ព្រះអង្គទ្រង់ព្រះជរា សុំព្រះចៅក្រុងស្យាមទ្រង់តែងតាំងរាជាវតីរាជនិរស ជាទីមហាឧបរាជក្រុងកម្ពុជា សុំឱ្យចេញទៅជួយរក្សាផែនដីក្រុងកម្ពុជា. ១ទៀត ទំនៀមខ្មែរធ្លាប់មានទីព្រះកែវហ្វា សុំឱ្យតាំងអង្គស៊ីសុវត្ថិ ជាទីព្រះកែវហ្វា ចេញទៅជាមួយផង ។ ខាងក្រុងទេព ព្រះបាទសម្តេចព្រះចមក្លៅ ព្រះចៅក្រុងស្យាម បានទ្រង់ជ្រាបសេចក្តីសុភអក្សរនៃព្រះបាទសម្តេចព្រះហរិរក្សរាមា មហាឥស្សរាធិបតី សុំឱ្យតែងតាំងអង្គរាជាវតីឡើងទីមហាឧបរាជក្រុងកម្ពុជា ទើបស្តេចត្រាស់បង្គាប់ភ្នាក់ងារឱ្យរកឫក្សធ្វើ

www.budinst.gov.kh www.elibraryofcambodia.org

ពិធីចារិកព្រះសុវណ្ណប័ត្រ តាំងអង្គរាជាវតីជាព្រះនរោត្តម ព្រហ្មបរិរក្សមហាឧបរាជ ក្រុងកម្ពុជាធិបតីតាំងអង្គសិរីសុវត្ថិ ជាព្រះហរិរាជតះណៃយក្រៃកែវហ្វា ត្រាស់បង្គាប់ ភ្នាក់ងារឱ្យចាត់ទូកទីនាំងពីរ ព្រះទានព្រះអង្គនរោត្តម ព្រហ្មបរិរក្សមហាឧបរាជក្រុង កម្ពុជាធិបតី នឹងអង្គព្រះហរិរាជតះណៃក្រៃកែវហ្វា ស្ដេចព្រះដំណើរមកក្រុងកម្ពុជា ធិបតី ទ្រង់ព្រះរាជបញ្ញត្តិឱ្យព្រមស្រេច នៅថ្ងៃ ៥ ៨ ឆ្នាំមមីស័រិទ្ធិស័ក ដល់បាន វេលាជាឧត្តមឫក្ស ព្រះបាទសម្ដេចព្រះចមក្លៅ ព្រះចៅក្រុងស្យាមចេញព្រះទានទឹក ស័ង្ខទៅទីព្រះដំណាក់ទឹក (តឹក?) ។

ថ្ងៃ៥ ៗ ៨ ឆ្នាំមមីស័រិទ្ធិស័ក ព.ស ២៤០១ ច.ស ១២២០ ត្រូវនឹងថ្ងៃ១៧ ខែ យូរ៉ាំង គ.ស ១៨៥៧ ព្រះរាជនិរសាធិរាជសម្ដេចព្រះនរោត្តម ព្រហ្មបរិរក្សមហា ឧបរាជ ក្រុងកម្ពុជាធិបតី និងព្រះរាជបុត្រព្រះហរិរាជតះណៃយក្រៃកែវហ្វា ស្ដេចព្រះ រាជដំណើរចេញពីក្រុងទេព ដោយវិថីជលមាគ៌ ទន្លេប្រាចិណបុរី ។

ព្រះបាទសម្ដេចព្រះហរិរក្សរាមា មហាឥស្សរាធិបតី ត្រាស់បង្គាប់សម្ដេចចៅហ្វា ទល្ហៈ ឯកអគ្គមហាសេនាធិបតី ឱ្យតែងឧកញ៉ាព្រះហ្លួងឱ្យទៅទទួលហែព្រះរាជនិរសា ធិរាជ មហាឧបរាជ ក្រុងកម្ពុជាធិបតី ចំនួនមនុស្ស ៥៣៣ ជាជាតិខ្មែរ សៀមតាម ហែស្ដេចចេញពីក្រុងទេព ចំនួន ៦៧២ នាក់ រួមទាំងតាមហែស្ដេចចេញពីក្រុងទេព នឹងចេញពីក្រុងឧដុង្គទៅទទួលទាំងអស់ចំនួនមនុស្ស ១២៦៥ ។

ព្រះរាជនិរសាធិរាជ សម្ដេចព្រះនរោត្តម ព្រហ្មបរិរក្សមហាឧបរាជក្រុងកម្ពុជា ធិបតីស្ដេចដល់ខេត្តបាត់ដំបង ព្រះសុផានពិសាន (ព្រះសុពណ្ណពិសាល) (កេត) ថ្វាយកូនស្រីមួយអាយុ ១៥ ឆ្នាំ តាមរយៈវិថីស្ដេចដល់ក្រុងឧដុង្គនៅថ្ងៃ ៣ ១៣ ៨ ឆ្នាំមមីស័រិទ្ធិស័ក ព.ស ២៤០១ ត្រូវនឹងថ្ងៃ ៦ ខែស្វយេត គ.ស ១៨៥៧ ។

ព្រះបាទសម្ដេចព្រះហរិរក្សរាមាមហាឥស្សរាធិបតី ព្រះបរមជនកនាថ ទ្រង់ ស្ថាបនាព្រះរាជវាំងប្របស្ទឹងក្រាំងពន្លៃ ព្រះរាជទានព្រះរាជនិរសាធិរាជ សម្ដេចព្រះ នរោត្តម ព្រហ្មបរិរក្សមហាឧបរាជ ក្រុងកម្ពុជាធិបតី ។

រៀបពិធីឧបរាជាភិសេក សំភោឡព្រះរាជមន្ទីរតាំងស្វេតច្ឆ័ត្រ ៥ ជាន់ ចំរើន សៃយមន្ត ពុទ្ធមន្តបីថ្ងៃ ហើយស្រង់មុទ្ធាភិសេក តាមយ៉ាងខត្តិយរាជប្រពៃណី ។

www.budinst.gov.kh www.elibraryofcambodia.org

ទ្រង់ចែកខេត្តសំរាប់ទៅ ព្រះរាជទានព្រះរាជនិរសាធិរាជសម្តេចព្រះនរោត្តម ព្រហ្ម បរិរក្ស មហាឧបរាជ តាមយ៉ាងខេមររាជប្រពៃណី . . . ។

ក្នុងរវាងនោះ ឯស្រុកព្រៃនគរដែលជាអាណាខេត្តក្រុងកម្ពុជា សឹងយួនដណ្តើម យកទៅគ្រប់គ្រងជារបស់យួន បារាំងសែសមានការពាក់ព័ន្ធនឹងយួនស្រុកព្រៃនគរ ចំណែកខាងខ្មែរខេត្តទ្រាំងត្រើយត្រាស់ ក៏កំរើកច្បាំងនឹងយួន . . . ។

ព្រះបាទសម្តេចព្រះហរិរក្សរាមាមហាឥស្សរាធិបតី បានទ្រង់ជ្រាបហើយត្រាស់ បង្គាប់មេកងការឱ្យស្លាងទូកចម្បាំង ឱ្យបំរុងគ្រឿងអាវុធហើយតែងឧកញ៉ាសភាធិបតីជា នាយទ័ព លើកកងទ័ពខ្មែរក្រុងកម្ពុជា ទៅតាំងប្រទល់នឹងកងទ័ពយួនព្រែកជីកត្រើយ ខាងជើង បំរុងនឹងជួយខ្មែរខែត្រទ្រាំងត្រើយត្រាស់. . . ។

ថ្ងៃ ៦ ១៣ ៥ ឆ្នាំវកទោស័កស័ក ព.ស ២៤០២ ព្រះបាទសម្តេចព្រះ ហរិរក្សរាមាអម្ចាស់ផែនដីក្រុងកម្ពុជា ស្តេចព្រះរាជដំណើរព្រះពាតជាយសមុទ្រខេត្ត កំពត ខណៈនោះមានមនុស្សជាតិបារាំងសែសមាននាម ម.ម៉ូអូ ក្រសួងដើរតួរផែនទី បានជួបគាល់ព្រះបាទសម្តេចព្រះហរិរក្សរាមា នៅទីព្រះរាជវាំងទំនៀបខេត្តកំពត ។

ព្រះបាទសម្តេចព្រះហរិរក្សរាមា ទ្រង់ទទួលរាប់អាន ម. ម៉ូអូ ដោយសេចក្តីគួរ សម ។ ម.ម៉ូអូ ក្រាបទូលថា នឹងចង់ចូលមកក្រុងឧដុង្គដែរ តែថាបង្ហើយការដែល ធ្វើនោះឱ្យរួចសិន ។ ព្រះបាទសម្តេចព្រះហរិរក្សរាមាស្តេចគង់នៅខេត្តកំពតបីខែ ហើយស្តេចព្រះរាជដំណើរចូលក្រុងឧដុង្គវិញ ត្រាស់បង្គាប់ព្រះរាជនិរសាធិរាជ សម្តេច ព្រះនរោត្តមព្រហ្មបរិរក្សមហាឧបរាជ ឱ្យចាត់រៀបផ្ទះត្រៀមចាំទទួល ម.ម៉ូអូ ។ ក្រោយ នេះមិនយូរប៉ុន្មាន ម.ម៉ូអូ ក៏ចូលដល់ក្រុងឧដុង្គមានជ័យ ទៅជួបគាល់ព្រះរាជនិរសាធិ រាជសម្តេចព្រះនរោត្តម ព្រហ្មបរិរក្សមហាឧបរាជ ទ្រង់ធ្វើបដិសណ្ឋារៈជាគួរសមហើយ ក៏ស្តេចនាំ ម. ម៉ូអូ ចូលថ្វាយបង្គំគាល់ព្រះបាទជាអម្ចាស់ផែនដី ។

ព្រះបាទសម្តេចព្រះហរិរក្សរាមាមហាឥស្សរាធិបតី ទ្រង់ទទួលម.ម៉ូអូដោយគួរសម។

ព្រះបាទសម្តេចព្រះហរិរក្សមហាឥស្សរាធិបតី ស្តេចសោយរាជសម្បត្តិជាអម្ចាស់ ផែនដីក្រុងកម្ពុជា បាន១២ឆ្នាំ ១០ខែ រួមទាំងគ្រងរាជ្យ ៧ឆ្នាំផង ត្រូវជា ១៩ឆ្នាំ ១០ ខែ ព្រះជន្ម ៦៤រៀងឆ្នាំ ទ្រង់ប្រឈួន ពេទ្យប្រកបថ្វាយព្រះឱសថមិនជល់ ។

www.budinst.gov.kh www.elibraryofcambodia.org

នៅថ្ងៃ ៦ ៗ ១២ ឆ្នាំវកទោស័ក ព.ស ២៤០៣ ត្រូវនឹងថ្ងៃ ១៩ខែតុលា គ.ស ១៨៦០ វេលា ម៉ោង ១ បាទ ៧ ឯរសៀលទ្រង់សោយទីវង្គត ។

ព្រមអស់សេនាបតីមន្ត្រី ខ្ញុំរាជការ សមណៈជីព្រាហ្មណាចារ្យ បុរោហិត រាជបណ្ឌិត កវីជាតិ ប្រជុំអញ្ជើញព្រះរាជនិរសាធិរាជសម្តេចព្រះនរោត្តម ព្រហ្មបរិរក្ស មហាឧបរាជ ឱ្យឡើងគ្រងរាជសម្បត្តិជាអម្ចាស់ផែនដីប្រទេសកម្ពុជា គង់នៅព្រះបរមរាជវាំងស្រះសារពើយុទ្ធ ក្រុងឧដុង្គមានជ័យ . . . ។

សម្តេចព្រះនរោត្តមព្រហ្មបរិរក្សមហាឧបរាជក្រុងកម្ពុជា បានឡើងគ្រងរាជសម្បត្តិជាអម្ចាស់ផែនដីក្រុងកម្ពុជា ទ្រង់ព្រះប្រារព្ធអំពីអាណាខេត្តកម្ពុជាសីងយួនដណ្តើមយកទៅគ្រប់គ្រងជារបស់យួន ទើបត្រាស់ប្រើឧកញ៉ាយមរាជ សេនាបតីក្រសួងយុត្តិធម៌នគរបាល ឱ្យទៅជាមេទ័ពខេត្តទ្រាំងត្រើយខាងជើង ជាបន្ទាស់ឧកញ៉ាសភាធិបតី បោះទ័ពប្រទល់នឹងកងទ័ពយួនព្រៃកដឹក ដើម្បីជួយខ្មែរខេត្តទ្រាំងត្រើយត្រាស់ ។

ក្នុងឆ្នាំរកាត្រីស័ក មានសំបុត្រឧកញ៉ាធម្មាតេជោចៅហ្វាយខេត្តបាភ្នំ ប្តឹងចូលមកថា : ស្នង (សួរ) ជាស្នងឆ្វេងខេត្តបាភ្នំបានបញ្ចុះបញ្ចូលរាស្ត្រក្នុងខេត្ត មិនឱ្យស្តាប់បង្គាប់ចៅហ្វាយខេត្ត សេនាបតីនាំសេចក្តីឡើងក្រាបបង្គំទូលព្រះករុណាជាអម្ចាស់ផែនដី

ព្រះបាទសម្តេចព្រះនរោត្តម ព្រហ្មបរិរក្ស ជាអម្ចាស់ផែនដីក្រុងកម្ពុជា បានទ្រង់ជ្រាបសេចក្តីហើយ ត្រាស់បង្គាប់លើកកំណាន់ខេត្តឱ្យចេញទៅយកខ្លួនស្នង "សួរ" មកឃុំក្នុងក្រុង ដាក់ឱ្យសេនាបតីជំនុំជំរះ ។

រាជការខេត្តបានយកខ្លួន ស្នង "សួរ" បញ្ជូនមកឃុំក្នុងក្រុង សេនាបតីពុំទាន់ជំនុំជំរះ នោះស្នង "សួរ" រត់ចេញពីក្នុងឃុំទៅពួននៅក្នុងដំណាក់ព្រះអង្គម្ចាស់វ៉ែវត្ថា (?) សេនាបតីបានឱ្យបំរើទៅសុំខ្លួនស្នង "សួរ" ពីព្រះអង្គម្ចាស់វ៉ែវត្ថា ទ្រង់មិនព្រមប្រគល់ខ្លួនស្នង "សួរ" ឱ្យ ។

អស់សេនាបតីនាំសេចក្តីឡើងក្រាបបង្គំទូលព្រះករុណា ជាអម្ចាស់ផែនដីបានទ្រង់ជ្រាប ហើយត្រាស់បង្គាប់ឧកញ៉ាវិបុលរាជសេនា ប៉ែន ម៉ុងតៀ ឱ្យលើកទាហានទៅចាប់ខ្លួនស្នង "សួរ" ឯដំណាក់ព្រះអង្គវ៉ែវត្ថា ។

ថ្ងៃ ១ ៗ ៥ ឆ្នាំរកា ព.ស ២៤០៤ ត្រូវនឹងថ្ងៃ ៣១ ខែមីនា គ.ស ១៨៦១

www.budinst.gov.kh www.elibraryofcambodia.org

វេលាម៉ោង ៧ ព្រឹក ឧកញ៉ាវិបុលរាជសេនា ប៉ែន ម៉ុងតៀ លើកទាហានទៅព័ទ្ធ ជំណាក់ព្រះអង្គម្ចាស់វៃវត្ថា ដើម្បីនឹងចាប់ខ្លួនស្នង "សូរ" នោះស្នង "សូរ" និងមនោ "កែវ" នាំមនុស្ស ៥០ នាក់ កាន់គ្រឿងអាវុធចេញច្បាំងតស៊ូនឹងពួកទាហាន ឧកញ៉ាវិបុលរាជសេនា បានច្បាំងគ្នាបាញ់កាំភ្លើងទៅវិញទៅមក ស្លាប់ពួកព្រះអង្គម្ចាស់វៃវត្ថា ព្រះអង្គម្ចាស់សិរីវង្ស ៨ នាក់ ។

ឯព្រះអង្គម្ចាស់វៃវត្ថានិងព្រះអង្គម្ចាស់សិរីវង្ស យល់ឃើញថានឹងទ្រាំច្បាំងមិនបាន ទើបឡើងសេះគេចវេះចេញពីក្នុងក្រុងទៅខេត្តក្រៅ ។

ព្រះអង្គម្ចាស់វៃវត្ថាជាព្រះរាជបុត្រទី ៣ នៃសម្តេចព្រះបាទព្រះហរិរក្សរាមមហាឥស្សរាធិបតី ព្រះអង្គម្ចាស់វៃវត្ថានិងព្រះអង្គម្ចាស់សិរីវង្ស ពុំបានឡើងគាល់ព្រះបាទសម្តេចព្រះនរោត្តម ជាអម្ចាស់ផែនដីក្រុងកម្ពុជា ។ កាលនៅថ្ងៃដែលខាហ្លួងស្យាមមករៀបពិធីព្រះបរមសពព្រះបាទសម្តេចព្រះហរិរក្សរាមមហាឥស្សរាធិបតី ជាព្រះបរមរាជបិតា នោះព្រះអង្គម្ចាស់វៃវត្ថា ព្រះអង្គម្ចាស់សិរីវង្ស ក៏ពុំព្រមចូលថ្វាយបង្គំព្រះបរមសពដែរ ។

ក្រោយនោះ ព្រះអង្គម្ចាស់វៃវត្ថាតាំងស្នង "សូរ" ឱ្យងារជាឧកញ៉ាឫទ្ធិវង្គជាញជ័យ តាំងមនោ "កែវ" ឱ្យងារជាឧកញ៉ាកំហែងយោធា ឱ្យទៅបញ្ចុះបញ្ចូលបណ្តារាស្ត្រក្នុងខេត្តបាភ្នំជាស៊ីគ្របក្សពួក . . . ។

ឯព្រះអង្គម្ចាស់វៃវត្ថា ព្រះអង្គម្ចាស់សិរីវង្ស រត់ចេញពីក្រុងឧដុង្គទៅពួននៅក្នុងខេត្តសៀមរាប ក្រោយនោះ ចេញពីខេត្តសៀមរាបទៅក្នុងខេត្តបាត់ដំបង ។

ក្រោយនោះ មានសំបុត្រអ្នកឧកញ៉ាអរជូនទៅចៅហ្វាយខេត្តត្បូងឃ្មុំ ចុះថ្ងៃ ២ ៤ ៧ ឆ្នាំរការត្រីស័ក ប្តឹងចូលមកថា បានឃើញស្នង "សូរ" ដែលតាំងខ្លួនជាមហាឫទ្ធិវង្គជាញជ័យ និងស៊ីគ្របក្សពួកជាច្រើន កាន់អាវុធមកពីខេត្តកំពង់សៀមឆ្លងកំពង់ចាមទៅទន្លេបិទ ។

មានសំបុត្រឧកញ៉ាធម្មតេជោជាចៅហ្វាយខេត្តបាភ្នំ ចុះថ្ងៃ ៧ ៨ ៧ ឆ្នាំរការត្រីស័ក ប្តឹងចូលមកថា បានឃើញស្នង "សូរ" ដែលតាំងខ្លួនជាមហាឫទ្ធិវង្គជាញជ័យ និង មនោ "កែវ" ដែលតាំងខ្លួនជា កំហែងយោធា ចូលមកក្នុងខេត្តបាភ្នំ បញ្ចុះ

www.budinst.gov.kh www.elibraryofcambodia.org

បញ្ចូលរាស្ត្រខ្មែរ ស្មៀង បង្កើតឡើងជាទ័ពលើកតាំងនៅភូមិខ្សាង. ឯឧកញ៉ាធម្មតេជោចៅហ្វាយខេត្តបាភ្នំ បានចាត់ឱ្យតាំងរាជការតទល់នៅភូមិស្វាយពក ហើយបានចាត់បំរើឱ្យទៅកេណ្ឌកំលាំងខេត្តរំដួល ស្វាយទាប បង្គាប់ឱ្យបានមកជាប្រញាប់កុំឱ្យបង្អង់ ។

ឯស្នង "សួរ" និងមនោ "កែវ" ឱ្យបញ្ចុះបញ្ចូលរាស្ត្រស្រុករមាសហែកនិងស្រុកជិតខាង តាំងឡើងជាទ័ពលើកទៅដេញឧកញ៉ាធម្មតេជោចៅហ្វាយខេត្តបាភ្នំ ឯឧកញ៉ាធម្មតេជោក៏ដោះខ្លួនចេញទៅអាស្រ័យនៅភូមិកំពង់ព្រៃក្តួច ចាំកំលាំងកងទ័ពដែលឱ្យទៅកេណ្ឌពុំទាន់បានមកដល់ ។ ស្នង "សួរ" និងមនោ "កែវ" លើកទ័ពទៅដេញឧកញ៉ាធម្មតេជោ ឯឧកញ៉ាធម្មតេជោដោះខ្លួនចេញពីកំពង់ព្រៃក្តួច ទៅដល់ស្រុកស្វាយទាប កេណ្ឌរាស្ត្របានខ្លះ លើកទៅច្បាំងនឹងស្នង "សួរ" មនោ "កែវ" នោះទ័ពខាងឧកញ៉ាធម្មតេជោទន់កម្លាំង ទើបធម្មតេជោដោះខ្លួនឆ្លងទន្លេកំពាបទៅអាស្រ័យនៅឯកំពង់សាលា ។

ឯស្នង "សួរ" និងមនោ "កែវ" បញ្ចុះបញ្ចូលរាស្ត្របានច្រើនលើកទៅសង្កត់ខេត្តឯខាងកើត ពួករាស្ត្រខេត្តទាំងនោះ ក៏ស្ម័គ្រចិត្តចុះចូលជាច្រើន ។

ឯស្នង "សួរ" មនោ "កែវ" កំរើកចិត្តថែមគោរម្យខ្លួនឯងថាជាថ្មីទៀត ហើយតាំងចៅហ្វាយខេត្ត ចៅហ្វាយស្រុក នាយទ័ព នាយកង នាយឃ្លាំងទូវអស់នាម៉ឺនផងជាច្រើនក្រសួង ។

សម្តេចព្រះនរោត្តមព្រហ្មបរិរក្ស ជាអម្ចាស់ផែនដីក្រុងកម្ពុជា បានទ្រង់ជ្រាបហើយត្រាស់ប្រើឧកញ៉ាក្រឡាហោម "សុខ" ឱ្យលើកទ័ពទៅរក្សាបន្ទាយល្វាឯមខេត្តភ្នំពេញ ត្រាស់ប្រើឧកញ៉ាតុរង្គធិបតី "សួស" ឱ្យនាំកងទ័ពទៅតាំងនៅពាមមានជ័យ ត្រាស់ប្រើឧកញ៉ាវរនាថសេនា "ភិម" ឱ្យជាព្រះរាជអាជ្ញាហ្លួងចេញទៅរក្សាខេត្តត្បូងឃ្មុំនិងខេត្តចំហៀងខាងទន្លេធំ . . . ។

ក្រោយនោះមានសំបុត្រឧកញ៉ាក្រឡាហោម "សុខ" ប្តឹងចូលមកថា ឧកញ៉ាតុរង្គធិបតី "សួស" សឹងត្រាស់ប្រើចេញទៅរក្សាខេត្តបាភ្នំនោះ ប្រែចិត្តចូលទៅខាងពួកក្បត់ឯកំហែងយោធា "កែវ" សង្កត់បានស្រុកកៀនស្វាយ-ល្វាឯម ពាមជរ ឮថានឹងលើកមកភ្នំពេញទៀត ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះបាទសម្តេចព្រះនរោត្តម ព្រហ្មបរិរក្ស ជាអម្ចាស់ផែនដីក្រុងកម្ពុជា បានទ្រង់ជ្រាបហើយត្រាស់បង្គាប់ភ្នាក់ងារឱ្យចាត់កងទ័ព ។

ថ្ងៃ ៤ ៥ ៨ ឆ្នាំរកាត្រីស័ក ព.ស ២៤០៤ ត្រូវនឹងថ្ងៃទី ១២ខែមិថុនា គ.ស ១៨៦១ ព្រះបាទសម្តេចព្រះនរោត្តម ស្តេចព្រះរាជដំណើរចេញពីព្រះបរមរាជវាំងក្រុងឧដុង្គមានជ័យ ព្រមទាំងអង្គព្រះបរិវារជតៈណៃយក់ក្រែកែវហ៊ា លើកព្យូហៈតាមវិថីសូលមាគ៌ដល់កំពង់ហ្លួង ស្តេចព្រះរាជដំណើរដោយក្បួនព្យូហៈជលមាគ៌ដល់ខេត្តភ្នំពេញប្រទះកងទ័ពពួកក្បត់នៅត្រើយលាងមខ្វះ នៅជ្រោយតាព្រហ្មខ្វះ ស្តេចនាំសេនាទាហានដេញច្បាំងនឹងពួកក្បត់

ខាងពួកក្បត់បាញ់កាំភ្លើងត្រូវផងព្រះក្ឋស់ដែលចាំងថ្វាយ ព្រះបាទសម្តេចព្រះនរោត្តមត្រាស់បង្គាប់ឱ្យពួកសេនាទាហានដេញបាញ់ពួកក្បត់វត់ខ្ចាត់ ខ្ចាយបាត់អស់ទៅ ទើបត្រាស់បង្គាប់ឱ្យលើកក្បួនព្យូហៈត្រឡប់មកនៅក្រុងភ្នំពេញចតុមុខ គង់នៅភ្នំពេញ ១ថ្ងៃ ១យប់ ត្រាស់បង្គាប់ឱ្យលើកក្បួនព្យូហៈត្រឡប់ទៅកំពង់ហ្លួង ស្តេចព្រះរាជដំណើរដោយក្បួនព្យូហៈសូលមាគ៌ចូលព្រះបរមរាជវាំងក្រុងឧដុង្គមានជ័យ ដើម្បីនឹងប្រឹក្សាអស់សេនាបតីអំពីប្រាបប្រាមពួកក្បត់ផែនដី . . . ។

ក្រោយនោះមានសំបុត្រមេកងខាងទន្លេបិទ ប្តឹងចូលមកថា ស្នង ស្វរ លើកទ័ពទៅសង្កត់ឧកញ៉ាវរនាថសេនាជាព្រះរាជអាជ្ញាហ្លួង និងចៅហ្វាយខេត្តស្រុកខាងលើ ហើយលើកទ័ពចូលមកខេត្តភ្នំពេញ ហើយចាត់ទ័ពឱ្យទៅសង្កត់ខេត្តបាទី ព្រៃកប្បាស សំរោងទង ឱ្យកេណ្ឌរាស្ត្រតាំងទ័ពនៅខេត្តភ្នំពេញ ។

ព្រះបាទសម្តេចព្រះនរោត្តមជាអម្ចាស់ បានទ្រង់ជ្រាបហើយ ទ្រង់ប្រារព្ធថា ពួកក្បត់កការកំរើកនេះ កាលដើមគ្រាន់តែជាទ័ពតូចបន្តិចបន្តួច ក្រោយនោះមករឹងរិតមានកម្លាំងឡើង លើកទ័ពទៅសង្កត់ទីណា ក៏សឹងតែមានស្លាប់បង្ខាប់ ចុះចូលពាសពេញទួទៅទាំងព្រះរាជអាណាចក្រ ទើបទ្រង់ព្រះប្រារព្ធព្រមអស់សេនាបតី មានសុភអក្សរទៅក្រុងទេព សុំកងទ័ពស្យាមឱ្យមកជួយប្រាបប្រាមពួកក្បត់ ហើយត្រាស់បង្គាប់ភ្នាក់ងារឱ្យចាត់ទូកព្រះទីនាំង ទូកមេលៀង អញ្ជើញសម្តេចព្រះវររាជជននីនិងពួកខ្ញុំរាជការខាងក្នុងឱ្យទៅកាក់ឯខេត្តបាត់ដំបង . . . ។

www.budinst.gov.kh www.elibraryofcambodia.org

ឯព្រះបាទសម្ដេចព្រះនរោត្ដម ស្ដេចព្រះរាជដំណើរដោយក្បួនព្យុហៈទៅតាំងនៅខេត្តពោធិសាត់ កេណ្ឌទាហានខ្មែរហាត់បំរុងចាំកងទ័ពក្រុងទេពលើកមកផ្ទប់ នឹងលើកទ័ពមកកម្រាបពួកខ្មែរក្បត់ក្នុងក្រុងកម្ពុជា ។

ក្រោយនោះមានសារត្រាពីក្រុងទេព បង្គាប់មកចៅហ្វាយខេត្តបាត់ដំបង ឱ្យបញ្ជូនព្រះអង្គម្ចាស់វរវត្ថានិងព្រះអង្គម្ចាស់ស៊ីវង្សចូលទៅក្រុងទេព. ព្រះអង្គម្ចាស់វរវត្ថាមិនចូលទៅក្រុងទេពដោយដំណោះថាឈឺ នោះរាជការក្រុងទេព មានសារត្រាប្រជ្ជូនថែមទៀត ទើបព្រះអង្គម្ចាស់វរវត្ថា ព្រះអង្គម្ចាស់ស៊ីវង្សចូលទៅក្រុងទេព ដោយសេចក្ដីទុញទាល់គេចមិនរួច . . . ។

ក្រោយនោះ រាជការក្រុងទេពបានចាត់ព្រះយ៉ាមុខមន្ត្រីជាមេទ័ពលើកទ័ពមកជួយព្រះបាទសម្ដេចព្រះនរោត្ដម ប្រាបប្រាមពួកខ្មែរក្បត់ តែមានបង្គាប់ឱ្យតាំងទ័ពនៅខេត្តបាត់ដំបង មានព្រះហស្ដលេខាសម្ដេចព្រះចមក្លៅព្រះចៅក្រុងស្យាមចុះថ្ងៃ ២ ១៣៩ ឆ្នាំរកាត្រីស័ក បង្គាប់មកឱ្យអង្គសម្ដេចព្រះនរោត្ដមអម្ចាស់ផែនដីក្រុងកម្ពុជា ស្ដេចទៅជួបប្រឹក្សាការទ័ពសឹកនឹងព្រះយ៉ាមុខមន្ត្រី មេទ័ពស្យាមឯខេត្តបាត់ដំបង ។

ព្រះបាទសម្ដេចព្រះនរោត្ដម ស្ដេចព្រះរាជដំណើរចេញពីខេត្តពោធិសាត់ ទៅជួបនឹងព្រះយ៉ាមុខមន្ត្រីមេទ័ពស្យាមឯខេត្តបាត់ដំបង . . . ។

ក្រោយនោះទៀត មានសារត្រាចៅព្រះយ៉ាចក្រីអគ្គមហាសេនាបតីក្រុងស្យាម ចុះថ្ងៃ ៧ ៤ ២ ឆ្នាំរកាត្រីស័ក មកដល់ព្រះយ៉ាមុខមន្ត្រីមេទ័ពស្យាមបង្គាប់មកឱ្យពញារាជវរានុកូល ពញាអនុជិតជាញជ័យ ប្រញាប់នាំសម្ដេចព្រះនរោត្ដមចូលដល់ក្រុងទេពនៅថ្ងៃ ៦ ៤ ២ ឆ្នាំរកាត្រីស័ក. ឱ្យព្រះយ៉ាមុខមន្ត្រីមេទ័ពព្រះយ៉ាគទាធរ ធរនិន្ទ្រ ចៅហ្វាយខេត្តបាត់ដំបងនិងព្រះយ៉ាអានុភាពត្រៃភព ចៅហ្វាយខេត្តនគរសៀមរាប មកតាំងរក្សាក្រុងឧដុង្គមានជ័យ . . . ។

តាំងអំពីព្រះបាទសម្ដេចព្រះនរោត្ដមចេញពីព្រះនគរ ពួកក្បត់វីងវិតមានកម្លាំងលើសមុន ស្នង "ស្វរ" មនោ "កែវ" ជាមេក្លោងបានប្រើពួកថ្មា-ចាម នៅភូមិឃ្លាំងស្បែកឱ្យនាំដំណឹងទៅមកថ្វាយអង្គព្រះហរិរាជតះណែយក្រែកែវហ្វាសុរាល័យ ។

ក្រោយនោះស្នង "ស្វរ" និងមនោ "កែវ" ទាំងពីរនាក់ចូលគាល់អង្គព្រះហរិរាជ

www.budinst.gov.kh www.elibraryofcambodia.org

តះណៃយក្រែកែវហ្វា . . . ។

ក្រោយនោះទៀត ស្នង "ស្វរ" មនោ "កែវ" ទាំងពីរនាក់សុំឱ្យអង្គព្រះហរិរាជតះណៃក្រែកែវហ្វា ធ្វើសំបុត្រតាំងឧកញ៉ាក្រឡាហោម តាំងឧកញ៉ាសេនាចក្រវត្តិឱ្យនិយាយរាជការផែនដី នោះអង្គព្រះហរិរាជតះណៃយក្រែកែវហ្វាទទួលព្រមតាម . . . ។

ក្រោយនោះ ស្នង "ស្វរ" និង មនោ "កែវ" សុំឱ្យយកងារសម្ដេចចៅពញា ១ ឧកញ៉ាវាំងសេនាបតីក្រសួងព្រះរាជវាំង ព្រះឃ្លាំង ១ ឧកញ៉ាចក្រីសេនាបតីក្រសួងយុទ្ធនាធិការ ១ ថាទីងទីងឱ្យទាហានទៅច្បាំងនឹងខ្លួនវា នោះព្រះអង្គហរិរាជតះណៃក្រែកែវហ្វាក៏ព្រមទទួលតាម ហើយព្រះអង្គព្រះហរិរាជតះណៃយក្រែកែវហ្វា បានហៅខ្លួនសម្ដេចចៅពញា ១ ឧកញ៉ាវាំង ១ ឧកញ៉ាចក្រី ១ ទាំង៣នាក់បង្គាប់ឱ្យទទួលព្រមថ្វាយត្រាសំរាប់ងារ ហើយអង្គព្រះហរិរាជតះណៃយក្រែកែវហ្វានិងខាហ្លួងស្យាម ធ្វើសំបុត្រហាមប្រាមអស់នាយទ័ពនាយកង កុំឱ្យច្បាំងគ្នាតទៅ ។

ក្រោយនោះ ឧកញ៉ាធម្មតេជោ "ទាំង" ចៅហ្វាយខែត្រថាភ្នំ ដែលរត់ទៅជ្រកនឹងបន្ទាយខែត្ររោងដំរី ចាត់បំរើឱ្យមកស៊ើបរាជការខែត្ររំដួល ខែត្រស្វាយទាប បានសេចក្ដីថា ចៅហ្វាយខែត្រ ចៅហ្វាយស្រុក ទូវអស់អ្នករាជការទាំងអស់ ប្រជារាស្ត្រគង់ចិត្តសុចរិតនឹងព្រះបាទសម្ដេចព្រះនរោត្តម ទើបឧកញ៉ាធម្មាតេជោ "ទាំង" ចេញពីបន្ទាយរោងដំរីមកតាំងកេណ្ឌកម្លាំងធ្វើទ័ពជាថ្មីទៀត ។

ព្រះបាទសម្ដេចព្រះនរោត្តម ស្ដេចព្រះរាជដំណើរទៅដល់ក្រុងទេពនៅថ្ងៃ៤ ៨ ២ ឆ្នាំរកាត្រីស័ក ព.ស ២៤០៤ ច.ស ១២២៣ ព្រះបាទសម្ដេចព្រះចមក្លៅ ព្រះចៅក្រុងស្យាមប្រជុំអស់សេនាបតីស្យាម ព្រមទាំងអង្គសម្ដេចព្រះនរោត្តមប្រឹក្សារាជកិច្ចរាជការក្រុងកម្ពុជាធិបតីនោះ ព្រះបាទព្រះនរោត្តមទ្រង់ព្រះប្រារព្ធថ្លែងថា ចុះក្នុងសេចក្ដីជំនុំ សេនាបតីស្យាមថា ឯការសឹកសង្គ្រាមក្រុងកម្ពុជានោះ មិនមែនជាធំស្នាប៉ុន្មានទេ បើជាទ្រង់ប្រោសព្រះរាជទានកម្លាំងកងទ័ពឱ្យទៅជួយ នោះទ្រង់នឹងទទួលបន្ទុកធ្វើការឱ្យត្រាតែរាបទាបបាន ។

ព្រះបាទសម្ដេចព្រះចមក្លៅព្រះចៅក្រុងស្យាម បានទ្រង់ជ្រាបនូវសេចក្ដីថ្លែងថាពីព្រះបាទសម្ដេចព្រះនរោត្តម ទើបត្រាស់ប្រើចៅពញាមន្ត្រីសុរិវង្ស ឱ្យរៀបកចាល់បីហែ

www.budinst.gov.kh www.elibraryofcambodia.org

ព្រះបាទសម្តេចព្រះនរោត្តម ចេញពីក្រុងទេពមកក្រុងកម្ពុជាតាមផ្លូវសមុទ្រខេត្តកំពត។

ចំណែកខាងក្រុងកម្ពុជា អស់ពួកមន្ត្រីខ្មែរបានដឹងថា ព្រះបាទសម្តេចព្រះនរោត្តម ស្តេចព្រះរាជដំណើរចេញពីក្រុងទេពតាមសមុទ្រ ក៏បបួលគ្នាជាច្រើនទៅចាំទទួលហែស្តេចពីខេត្តកំពតមកក្រុងឧដុង្គ ។

ថ្ងៃ ២ ^{}_{១១} ៤ ឆ្នាំរកាត្រីស័ក ព.ស ២៤០៤ ត្រូវនឹងថ្ងៃទី ៥ ខែមីនា គ.ស ១៨៦១ ព្រះបាទសម្តេចព្រះនរោត្តម ស្តេចព្រះរាជដំណើរដល់ព្រះបរមរាជវាំងក្រុងឧដុង្គមានជ័យ ។

ឯឧកញ៉ាចក្រី "កែប" និងឧកញ៉ាធម្មាធិរាជ "ប៉ុក" លើកកងទ័ពទៅដេញចាប់ខ្លួនស្នង "សួរ" និងមនោ "កែវ" នោះស្នង "សួរ" និងមនោ "កែវ" បាក់ទ័ពរត់ខ្ចាត់ខ្ចាយទៅ ។

ឯឧកញ៉ាធម្មាតេជោ "ម៉ាង" ចៅហ្វាយខែត្រពាភ្នំ លើកទ័ពទៅស្ទាក់ចាប់បានខ្លួនមនោ "កែវ" សម្លាប់ស្លាប់ទៅ កាត់យកតែក្បាលច្រកក្នុងជាលឲ្យបំរើនាំយកមកក្រាបបង្គំទូលថ្វាយព្រះករុណាជាអម្ចាស់ផែនដីក្រុងកម្ពុជា សេនាបតីនាំសេចក្តីឡើងក្រាបបង្គំទូល ព្រះបាទជាអម្ចាស់ផែនដី ត្រាស់បង្គាប់ឱ្យយកក្បាលអា "កែវ" កំហែងយោធាដាក់លើថាស ឱ្យហោរា "ឡាយ" ដែលចូលស្មត់ជាមួយនោះ ទូលលើក្បាលដើរស្រែកអាក្រោសពេញផ្លូវថ្នា ហើយឱ្យយកក្បាលអាកែវកំហែងយោធានោះ ទៅដាក់ផ្ទាលឱ្យអស់ជនានុជនឃើញគ្រប់ភ្នែក ។

ឯស្នង "សួរ" ដែលតាំងខ្លួនជាមហាបូទ្ធិវង្គជាញជ័យនោះរត់រួច ទៅប្រមូលស្ម័គ្របក្សពួកបានច្រើន តាំងឡើងជាទ័ពលើកទៅច្បាំងនឹងឧកញ៉ាធម្មាតេជោ "ម៉ាង" ជាថ្មីទៀតនោះ ឧកញ៉ាធម្មតេជោ "ម៉ាង" ចាប់បានខ្លួនអាសួរ មហាបូទ្ធិវង្គមានជ័យ ដាក់ទ្រុងឱ្យរក្សាទុកបំរុងនឹងឱ្យបំរើនាំខ្លួនទាំងរស់មកក្រាបបង្គំទូលថ្វាយព្រះបាទជាអម្ចាស់ផែនដីក្រុងកម្ពុជា ដល់វេលាយប់ជួនមានភ្លៀងធំ នោះអា "សួរ" មហាបូទ្ធិវង្គជាញជ័យហែកទ្រុងរត់រួចទៅជួបនឹងឧកញ៉ាតុរង្គធិបតី "សួស" នឹងស្នង "គឹង" ជាគូ ជាមួយគ្នានោះស្នង "សួរ" ឱ្យសម្លាប់ឧកញ៉ាតុរង្គធិបតីស្លាប់ទៅ ហើយស្នង "សួរ" រត់ទៅ

www.budinst.gov.kh www.elibraryofcambodia.org

ចូលមេទ័ពចាំងសែសឯបន្ទាយកោងឥវ៉ា ។

ក្រាដែលប្រាបប្រាមពួកក្បត់រាបទាបហើយ ព្រះបាទសម្តេចព្រះនរោត្តម ទ្រង់ប្រោសព្រះរាជទានរង្វាន់អស់សេនាទាហាន តាមដែលមានបំណាច់គុណគាប់ក្នុងការចលាចលគ្រានោះ ។

ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានលឿនឧកញ៉ាធម្មាតេជោ "ម៉ាង" ចៅហ្វាយខេត្តបាភ្នំឡើងជាឧកញ៉ាក្រឡាហោមសេនាបតីក្រសួងជលមាតី ។

ក្នុងខែបុស្សឆ្នាំកុរបញ្ចស័ក ព.ស ២៤០៦ ច.ស ១២២៥ គ.ស ១៨៦៣ មានសំបុត្រចៅហ្វាយខេត្តទ្រាំងប្តឹងមកថា ឈ្មោះអាចារ្យ "ស្វា" តាំងខ្លួនជាអង្គភីមបញ្ចុះបញ្ចូលរាស្ត្រខេត្តទ្រាំងត្រើយត្រាស់ ហើយលើកមកបញ្ចុះបញ្ចូលរាស្ត្របន្ទាយមាសកឡើងជាទ័ពលើកមកសង្កត់យកទ្រព្យរបស់រាស្ត្រក្នុងខេត្ត ទ្រាំង-ខេត្តបាទី-ខេត្តព្រៃកប្បាស ។

ព្រះបាទសម្តេចព្រះនរោត្តមព្រហ្មបរិរក្ស បានទ្រង់ជ្រាបហើយ ត្រាស់ប្រើឧកញ៉ាចក្រីក្រសួងយុទ្ធនាធិការ ១ សម្តេចចៅពញា ១ ឧកញ៉ាមហាសេនា ១ ឱ្យលើកទ័ពទៅច្បាំងនឹងអាចារ្យ "ស្វា" ឯខេត្តទ្រាំង ។

ក្នុងខែផល្គុនឆ្នាំកុរបញ្ចស័ក មានសំបុត្រចៅហ្វាយខេត្តទ្រាំង និងសំបុត្រមេកងទ័ពប្តឹងចូលមកថាអាចារ្យ "ស្វា" ដែលតាំងខ្លួនជាព្រះអង្គភីមនោះ លើកទ័ពទៅព័ទ្ធសម្លាប់ឧកញ៉ាចក្រី "កែប" អនិច្ចកម្មក្នុងខេត្តទ្រាំង អស់សេនាបតីនាំសេចក្តីឡើងក្រាបបង្គំទូលព្រះបាទជាអម្ចាស់ ។

ព្រះបាទសម្តេចព្រះនរោត្តមព្រហ្មបរិរក្ស ត្រាស់ឱ្យចៅក្រុមភូសាមាលា អញ្ជើញព្រះមហាមកុដ គ្រឿងរាជូភោគ ភ្នាក់ងារអភិរម្យអញ្ជើញព្រះកូស់និងរាជយានទុម៉ាតព្រាហ្មណ៍និងគ្រូហោរ ជាអាចារ្យបុរោហិតាចារ្យ ហោរាចារ្យ ចុះកប៉ាល់ភ្លើងជាមួយនឹងកំម៉ង់ដង់បារាំងសែសចេញពីក្រុងទេពមកស្រុកព្រៃនគរ ជួបនឹងអាត់ម៉េរាល់បារាំងសែសជាធំនៅស្រុកព្រៃនគរ ចេញពីស្រុកព្រៃនគរមកក្រុងកម្ពុជា ចតកប៉ាល់នៅកំពង់ហ្លួងមកក្រុងឧដុង្គមានជ័យ ។

មន្ត្រីបារាំងសែស សឹងមកក្នុងការព្រះរាជពិធីប្រាប្តាភិសេកសម្តេចព្រះនរោត្តម

www.budinst.gov.kh www.elibraryofcambodia.org

ការពីតែនខេស្លឡាំង មកជំនួសយេណេរាល់ ឡាគ្រង់ឌីយែរ និងទាហានបារាំងមួយកុម្ប៉ាញី ។

## ព្រះរាជពិធីប្រាប្តាភិសេកសេចក្តីសង្ខេប

ភ្នាក់ងារសង់ព្រះទីនាំងក្រយាឆាន់ មណ្ឌបប្រាបមុខ ព្រះទីនាំងមង្គលាភិសេក. តាំងព្រះរាជវ័តិ-ឆត្រ-ទង់ តាំងព្រះរាជពិធិសង្ឃ ព្រះរាជពិធីព្រាហ្មណ៍ តាំងទៀនជ័យ ទៀនរាយ ព្រះកន្ទីមាស ព្រះកន្ទីប្រាក់ ព្រះកន្ទីសម្រឹទ្ធ ព្រះកន្ទីកែវ ព្រះនព ព្រះស័ង្ខទក្ខិណាវត្ត ព្រះសីមាធិបតី ព្រះឆត្រជ័យ តាំងព្រះទែនវ៉ែនហ្វា លើព្រះទីនាំងមង្គលាភិសេក លើកមហាឧបរាជ ជាអម្ចាស់ផែនដីក្រុងកម្ពុជា ។ ក្នុងខណៈនោះ ទ្រង់បានទទួលពត៌មានថា អាចារ្យស្វានាំបះបោរនៅតំបន់ព្រះបាទជាន់ជុំក្នុងខែត្រទ្រាំងទើបត្រាស់ប្រើឧកញ៉ាក្រឡាហោម ១ ឧកញ៉ាវង្សាអគ្គរាជ ១ ឧកញ៉ាអរជូន ១ ឱ្យលើកទ័ពទៅច្បាំងនឹងអាចារ្យស្វានៅតំបន់នោះ ។

ឯអាចារ្យស្វា. ច្បាំងចាញ់រត់ចូលទៅក្នុងខេត្តមាត់ជ្រូក ។

ព្រះបាទសម្តេចព្រះនរោត្តម ព្រហ្មណ៍បរិរក្សមហាឧបរាជ ជាអម្ចាស់ផែនដីក្រុងកម្ពុជាធិបតី ទ្រង់ប្រារព្ធនិងរៀបព្រះរាជពិធីរាជាភិសេក ទើបមានសុភអក្សរថ្វាយដល់ព្រះចៅក្រុងស្យាម ក្នុងខែផល្គុនឆ្នាំកុរបញ្ចស័ក ព.ស ២៤០៦ ។

មានសំបុត្រសេនាបតីក្រុងបារាំងសែស ក្រសួងតាងប្រទេសឱ្យរាជទូតបារាំងសែសអញ្ជើញព្រះរាជសាសន៍ទៅចំរើនផ្លូវព្រះរាជមេត្រីនឹងក្រុងស្យាម សុំឱ្យព្រះចៅក្រុងស្យាមតែងព្រះរាជបំរើមករៀបអភិសេកសម្តេចព្រះនរោត្តម ។

ព្រះបាទសម្តេចព្រះចមក្លៅព្រះចៅក្រុងស្យាម ត្រាស់ប្រើពញារាជវរានុកូលពញាប្រាចិណបុរីព្រះស្រីសេនា ឱ្យមករៀបការអភិសេកសម្តេចព្រះនរោត្តម តែងចៅពញាមន្ត្រីសូរិយវង្សទីសមុហៈ ព្រះក្រឡាហោមឱ្យមកជាអធិបតីក្នុងការរាជាភិសេកព្រមទាំងប្រទានថ្វាយព្រះជាតា ១ ព្រះសុវណ្ណប័ត្រ ១. ចាប់ព្រះទំរង់ ១. ឆ្លងព្រះអង្គ ១. ព្រះមហាមាលា ១ គ្រឿងមុទ្ធាភិសេក ១ . . . ។

✪ ✪ ✪

www.budinst.gov.kh www.elibraryofcambodia.org

## គ្រឿងបញ្ចក្កុដភណ្ឌ

ព្រះស្វេតច្ឆ័ត្រ (តាំងលើព្រះទីនាំងបល្ល័ង្ក) ១ ព្រះមហាមកុដ ១. ព្រះខ័ននជ័យសីរី ១. ព្រះវាលវិជនី ១. ព្រះសុព័ណ៌បាទុក ១ ។ គ្រឿងសាស្ត្រាវុធ- ព្រះទម្រង់លំពែងជ័យ ១. ព្រះទម្រង់អគ្គី ១. ព្រះទម្រង់អភសោ ១ (?) ព្រះទម្រង់ចក្រ ១. ព្រះទម្រង់ត្រីសូល៌ ១ ព្រះទម្រង់កៅទណ្ឌ ១ ។

ព្រាហ្មណ៍តាំងរូបព្រះឥសូរ-ព្រះនារាយណ៍. ព្រះឧមាភគវតី ព្រះលក្ស៊ី ធ្វើពិធីសៃយវេទ ។

ព្រះមហារាជគ្រូតាំងមហាសីមា-ស្បូវភ្លាំងនិងអំពោះសីមាចងយោងជុំព្រះបរមរាជវាំង តាំងរាជវតិ ជំត្រទង់ប្របព្រះទែនព្រះរាជពិធី ។ ថ្ងៃ ៣ $\frac{ៗ}{១១}$ ៦ ឆ្នាំឆ្លូតឆស័ក ព.ស ២៤០៧ ច.ស ១២២៦ ត្រូវនឹងថ្ងៃ៣១ខែម៉េ គ.ស ១៨៦៦ វេលារសៀល ព្រាហ្មណ៍អញ្ជើញទេវរាជចូលព្រះរាជពិធី ព្រះបាទសម្តេចព្រះនរោត្តម ព្រហ្មណ៍បរិវង្ស មហាឧបរាជ ជាអម្ចាស់ផែនដីក្រុងកម្ពុជាធិបតី ស្តេចព្រះរាជដំណើរចូលក្នុងព្រះទីនាំងមង្គលាភិសេក ព្រមអស់បរមវង្សានុវង្សសេនាបតី មន្ត្រី ខុំរាជការ បម្រើគាល់គ្រៀបត្រាគ្រប់ក្រសួង ។ ព្រះបាទជាអម្ចាស់ផែនដី ទ្រង់ប្រគេនត្រៃចីវរដល់ព្រះសង្ឃរួចស្រេចហើយ ទ្រង់ប្រារព្ធទៀនជ័យ សម្តេចព្រះសោតន្ទាធិបតីឧជទៀនរាយ ព្រះបាទជាអម្ចាស់ផែនដីទ្រង់ឧជបូជាព្រះជ័យព្រះជន្មវស្សា ស្តេចព្រះរាជដំណើរចូលក្នុងព្រះមហាមន្ទីរ ទ្រង់ឧជទៀនធមស្សការ ព្រះមហារាជគ្រូបុរោហិតចំរើនសៃយវេទ ព្រះសង្ឃចំរើនព្រះទិព្វមន្ត ព្រះបាទជាអម្ចាស់ផែនដី ទ្រង់និច្ចសីល ហើយទ្រង់អម្បោះមង្គល ទ្រង់ព្រះសណ្តាប់ព្រះសង្ឃចំរើនព្រះបរិត្ត ចប់ហើយស្តេចព្រះរាជដំណើរចូលខាងក្នុង។ ព្រឹកឡើងថ្ងៃ ៤ $\frac{ៗ}{១២}$ ៤ ឆ្នាំឆ្លូតឆស័ក ព្រះបាទជាអម្ចាស់ស្តេចចេញទ្រង់សីល ទ្រង់ប្រគេនសម្រាប់ដល់ព្រះសង្ឃ ហើយស្តេចព្រះរាជដំណើរចូលខាងក្នុង ។

វេលារសៀលព្រះសង្ឃចំរើនព្រះបរិត្តទិព្វមន្ត របៀបពិធីដូចថ្ងៃមុន ។ ព្រឹកឡើងថ្ងៃ ៥ $\frac{ៗ}{១៣}$ ៦ ស្តេចចេញទ្រង់សីល ទ្រង់ប្រគេនសម្រាប់ វេលារសៀលចំរើនព្រះបរិត្តរបៀបពិធីដូចថ្ងៃមុន ។

ថ្ងៃ៦ $\frac{ៗ}{១៤}$ ៦ ឆ្នាំឆ្លូតឆស័ក ព.ស ២៤០៧ ច.ស ១២២៦ ត្រូវនឹងថ្ងៃ ៣ ខែយូ

www.budinst.gov.kh www.elibraryofcambodia.org

វាំង គ.ស ១៨៦៤ វេលាព្រឹកថ្ងៃពេញពន្លឺតូច ព្រះបាទជាអម្ចាស់ស្ដេចឡើងលើព្រះទីនាំងមង្គលាភិសេក ទ្រង់និច្ចសីល ប្រគេនសម្រាប់ព្រះសង្ឃ ហើយព្រះមហារាជគ្រូអញ្ជើញព្រះជ័យនាំមុខ ស្ដេចព្រះរាជដំណើរចុះទៅរោងក្រយាធាន់ ព្រះសង្ឃសឹងត្រៀមនៅទីនោះ ក៏ចុះទៅចាំឫក្ស អស់ព្រះបរមវង្សានុវង្ស នៅអស់សេនាបតីមន្ត្រីខ្មែរ ទាម៉ឺនចាវាំង ទាម៉ឺនសៀម ក៏ត្រៀមនៅចាំឫក្ស ម៉ោង ៩ព្រឹក ព្រះអាទិត្យរះពេញពន្លឺ វេលាឧត្តមឫក្ស ហោរាគោះគងជ័យ ចៅក្រសួងភូសាមាលាថ្វាយសហ័សធារា ទ្រង់មុទ្ធាភិសេក ព្រះមហារាជគ្រូ ថ្វាយទឹកក្លស់-ទឹកស័ង្ខ ព្រាហ្មណ៍ប្រគំត្រែស័ង្ខត្រីបណ្ដោះ ពីងពាំង ក្រុមមហោស្រព ក៏ប្រគំគងស្គរតូរ្យតន្ត្រីយ៍ ស្រង់ស្រេចស្ដេចចុះផ្លាស់ព្រះភូសា ទ្រង់ព្រះភូសាឆ្លងព្រះអង្គថ្មី ស្ដេចព្រះរាជដំណើរឡើងលើព្រះទីនាំងមង្គលាភិសេក ប្រថាប់លើព្រះទែនឈើឧទុម្ពរ ព្រះមហារាជគ្រូបង្វិលពពិល ១៩ ជុំ ហើយថ្វាយទឹកព្រះមហាស័ង្ខទក្ខិណាវដ្ដ ហើយស្ដេចឡើងព្រះទីនាំងភទ្ទបិដ្ឋ ចៅក្រុមព្រះអាល័ក្ខណ៍ ថ្វាយព្រះសុវណ្ណប័ត្រ ថ្វាយព្រះនាម "ព្រះបាទសម្ដេចព្រះនរោត្តមបរមរាមទេវតារគុណសារសុទ្ធរឫទ្ធិមហិស្សរាធិបតី សិរីសូរិយវង្ស នរពុទ្ធពង្ស តម្រង់រាស្ដ្រមហាកម្ពុជាធិបតិន្ទ្រ សព្វសិល្បសិទ្ធិស្ថិតស្ថាពរ ព្រហ្មាមរអំណោយជ័យ ជាមហេស្វរិយាធិបតីនៃប្រថពីតលសកលកម្ពុជាអាណាចក្រ អគ្គមហាបុរសរត្ន វិវឌ្ឍនាតិរេកឯកឧត្ដម បរមនាថ បរមបពិត្រ ជាអម្ចាស់ផែនដីក្រុងកម្ពុជាធិបតី" ។

ព្រះមហារាជគ្រូ ថ្វាយគ្រឿងបញ្ចកកុធភ័ណ្ឌ ថ្វាយសម្ពត់រតនកម្ពល ថ្វាយព្រះមហាសង្វារ ព្រាហ្មណ៍ថ្វាយព្រះខ័នជ័យ ថ្វាយគ្រឿងសាស្ត្រាវុធ មានព្រះទម្រង់លំពែងជ័យជាដើម . . . ។

ថ្ងៃ ៧ ៦ ឆ្នាំជូតឆស័ក ព.ស ២៤០៧ ច.ស ១២២៦ ត្រូវនឹងថ្ងៃ ៤ ខែយូវាំង គ.ស ១៨៦៤ វេលាព្រឹកថ្ងៃពេញពន្លឺ រៀបដង្ហែស្ដេចចេញប្រទក្សិណព្រះនគរ ស្ដេចព្រះរាជដំណើរចេញដោយក្បួនព្យូហៈ ព្រះរាជយានុម៉ាត ព្រះរាជរថ ព្រះទីនាំងរាជគជេន្ទ្រ ព្រះទីនាំងរាជអស្សតរ . . . ។

ស្ដេចព្រះរាជដំណើរចេញប្រទក្សិណជុំវិញព្រះនគរ ហើយស្ដេចព្រះរាជដំណើរចូលមកព្រះបរមរាជវាំង ស្រេចពិធីប្រាប្ដាភិសេក ។

សម្ដេចត្បូត្រ៊ី មាលិកា

www.budinst.gov.kh www.elibraryofcambodia.org

## អំពីបះព្រះអង្គវ៉ែវត្ថា

ព្រះអង្គវ៉ែវត្ថាពុំសូវប្រកបនឹងព្រះបាទសម្តេចព្រះនរោត្តមទេ ហើយមានព្រះទ័យច្រណែននឹងរាជសម្បត្តិផង ។

ដូច្នេះបានរវាង ១ឆ្នាំ គ.ស ១៨៦១ ព្រះអង្គវ៉ែវត្ថាយកមនុស្សពីរនាក់ តាំងជាមេបះ ឈ្មោះស្នង "សួរ" ១ ត្រូវជាញាត់ខាងព្រះមាតានៅបាភ្នំ និងមនោ "កែវ" ១ ឱ្យបញ្ចុះបញ្ចូលអស់ស្រុកបក្សពួកក្នុងខែត្របាភ្នំ លើកជាកងទ័ពមកច្បាំងនឹងស្តេចជាអម្ចាស់ផែនដី ។

ទ័ពនេះក៏រឹងខ្លាំងណាស់ដែរ មិនងាយនឹងបង្រ្កាប លុះត្រាតែព្រះបាទសម្តេចព្រះនរោត្តមស្តេចទៅឯក្រុងបាងកក (ក្រុងទេព) ហើយនៅឯអាយព្រះកែវហ្វាព្រះស៊ីសុវត្ថិ (ព្រះស៊ីសុវត្ថិ) ស្ដីរាជការ ។ ឯរាជការក្រុងសៀម ក៏ថាព្រមជួយព្រះបាទសម្តេចព្រះនរោត្តម ហើយដង្ហែព្រះអង្គតាមផ្លូវសមុទ្រមកឡើងនៅកំពត រួចចូលមកក្រុងឧដុង្គវិញ ។ មេទ័ពខ្មែរក៏រកចាប់ខ្លួនស្នង "សួរ" មនោ "កែវ" សម្លាប់មនោកែវបាន ឯស្នង "សួរ" រត់រួចចូលទៅក្នុងដែនកូសាំងស៊ីន ក្នុងខែត្ររោងដំរី (តៃនិញ) សព្វថ្ងៃនេះ . . . ។ រីឯព្រះអង្គវ៉ែវត្ថា ក៏ភៀសព្រះអង្គទៅបាត់ (គ.ស ១៨៦២) រួចស្រុកក៏បានសាន្តត្រាណ ។

ក្រោយមករវាង គ.ស ១៨៧០ ព្រះអង្គវ៉ែវត្ថាចេញមកម្តងទៀត លុកលុយខេត្តកំពង់ធំប្រាថ្នាយកខេត្តនេះ ប៉ុន្តែទ័ពហ្លួងនិងទ័ពបារាំងខ្លះ (កាលនោះបារាំងចូលមកនៅក្នុងនគរហើយ) លើកទៅវាយខ្ចាត់ខ្ចាយអស់ ព្រះអង្គវ៉ែវត្ថាភៀសទៅគង់នៅផ្នែកខាងជើងខេត្តសំបួរ ត្រើយខាងលិចទន្លេមេគង្គហៅថាភូមិ "គ្រាក់" លុះតែសុគតនៅទីនោះ (គ.ស ១៨៩១) ។

## អំពីសន្ធិសញ្ញាក្នុង គ.ស ១៨៦៣ ដាក់នគរកម្ពុជាក្នុងអាណាព្យាបាលនៃប្រទេសបារាំងសែស ។

កាលបើបង្រ្កាបពួកក្បត់ព្រះអង្គវ៉ែវត្ថាបានអស់ហើយ ព្រះបាទសម្តេចព្រះនរោត្តមស្តេចប្រារព្ធអំពីព្រះនគរ ។ ពេលនោះ បារាំងសែសបានយកដែនកូសាំងស៊ីនហើយ

www.budinst.gov.kh www.elibraryofcambodia.org

។បានចូលមកតាំងនៅហើយ មេទ័ពបារាំងសែស ចៅហ្វាយស្រុកព្រៃនគរបានចាត់មេទ័ពរង ឱ្យចូលមកក្រាបថ្វាយបង្គំគាល់ព្រះបាទសម្តេចព្រះនរោត្តម ស្នើអំពីព្រះរាជមេត្រីម្តងជាពីរដងរួចទៅហើយ ព្រោះថាដែនកូសាំងស៊ីននិងនគរកម្ពុជានៅជាប់គ្នា រួចទើបមេទ័ពសម្រេចរាជការដែនកូសាំងស៊ីន (នាមដឺឡាក្រង់ឌីយេរ) ចូលមកថ្វាយបង្គំគាល់ប្រឹក្សាអំពីប្រយោជន៍ដាក់នគរកម្ពុជា ក្នុងអាណាព្យាបាលនៃប្រទេសបារាំងសែស ។ ព្រះបាទសម្តេចព្រះនរោត្តម ទ្រង់ឈ្វេងយល់ព្រម (គ.ស ១៨៦៣) សន្ធិសញ្ញាផ្ញើទៅថ្វាយស្តេចអម្ចាស់ផែនដីក្រុងបារាំងសែសសំរេច ត្រឡប់មកដល់វិញក្នុង គ.ស ១៨៦៤ រួចក៏រៀបពិធីរាជាភិសេកថ្វាយព្រះបាទសម្តេចព្រះនរោត្តមជាស្តេចអម្ចាស់ផែនដី ។ ឯខាហ្លួងសៀមក៏ត្រឡប់ចូលទៅក្រុងសៀមវិញអស់ទៅ ។

លុះព្រះរាជាភិសេករួចហើយ ព្រះបាទសម្តេចព្រះនរោត្តមទ្រង់ព្រះដំរិះ ផ្លាស់រាជធានីពីឧដុង្គមកគង់នៅឯក្រុងភ្នំពេញ ជាប់រហូតមកដល់សព្វថ្ងៃនេះ (គ.ស ១៨៦៣) មកដល់ គ.ស ១៨៦៥ មានបះធំពីរទៀត : ១- គឺមនុស្សម្នាក់ឈ្មោះ "ស្វា" តាំងខ្លួនជាអាចារ្យ ឱ្យហៅថាអាចារ្យ "ស្វា" ហើយថាខ្លួនជាអង្គភឹម ជាព្រះរាជបុត្រនៃព្រះអង្គអិម ។ អង្គភឹមសុគតនៅបាងកក ។ អង្គភឹមជាព្រះជេដ្ឋានៃព្រះបាទសម្តេចព្រះហរិរក្ស ។

អាចារ្យ "ស្វា" នេះ កំណើតជាមនុស្សពលរួតអាងថាខ្លួនជាមនុស្សមានបុណ្យខ្លាំងពូកែ គេចាប់យកទៅថ្វាយព្រះបាទព្រះហរិរក្សម្តងហើយកាល (គ.ស ១៨៥៩) ទ្រង់ព្រះរាជទានលើកទោសហើយ តាំងពីកាលនោះមក ចេះតែដើរអនាថាបញ្ចុះបញ្ចូលរាស្ត្រខេត្តបាទី ពាម(ហាទៀង) ព្រៃកប្បាសបានពួកជាច្រើន មានពួកមនោ "កែវ" និងស្នង "សួរ" ពីមុននោះរត់ចូលផង លើកជាកងទ័ពច្បាំងប្រាថ្នាយករាជសម្បត្តិ។

ទ័ពហ្លួងមានទ័ពបារាំងជួយផង លើកទៅវាយខ្ចាត់ខ្ចាយអស់ហើយមិនយូរប៉ុន្មានចាប់បានខ្លួនអាចារ្យ "ស្វា" សម្លាប់ទៅ(នៅមាត់ជ្រូក) គ.ស ១៨៦៥ ខែសីហា ។ ២- រួចអំពីចម្បាំងនឹងអាចារ្យ "ស្វា" នេះមក មានចម្បាំងនឹងម្នាក់ទៀតឈ្មោះ "ពោកំបោរ" ។ ច្បាំងបង្ក្រាបនេះយូរបន្តិច ១៨ខែ ទើបចាប់ពោកំបោរបាន សម្លាប់នៅឯខេត្តកំពង់ធំ (គ.ស ១៨៦៧) ។ ពោកំបោរនេះ តាំងខ្លួនជាកូនព្រះបាទអង្គច័ន្ទ

www.budinst.gov.kh www.elibraryofcambodia.org

ទី ៣ ឈ្មោះពៅ កំណើតពីស្រុកកំពង់ស្វាយ ចូលទៅព្រៃនគររួចទៅបញ្ចុះបញ្ចូលយកបក្សពួកទៅស្រុកព្មង លើកចូលមកលុកលុយតាំងដើមពីខេត្តក្រចេះ សម្លាប់ចៅហ្វាយស្រុកសំបូរ និងចៅហ្វាយស្រុកក្រចេះ ដែលមិនស្ដាប់បង្គាប់ ។

រួចអំពីចម្បាំងនេះមក ទគរក៏បានសុខសាន្តត្រាណរៀងមក មានតែបះបោរបន្ដិចបន្តួចងាយនឹងបង្ក្រាបទេវិញ ។

ព្រះបាទសម្ដេចព្រះនរោត្ដម ទ្រង់ក៏តាំងព្រារព្ធអំពីរាជការក្នុងព្រះនគរ ។

ក្នុង គ.ស ១៨៧២ ទ្រង់ស្ដេចព្រះរាជដំណើរមួយអន្លើនិងបារាំងទៅក្រុង "ហុងកុង" ក្រុងកន្ដាំង ដែលជាក្រុងធំក្នុងប្រទេសចិន ដើម្បីទតរបៀបស្រុកគេ ហើយដល់ទ្រង់ស្ដេចត្រឡប់មកវិញ ស្ដេចចូលក្រុង "ម៉ានិល" នាំយកភ្លេងម៉ានិលមួយវង់ព្រមទាំងអ្នកភ្លេងមកព្រះរាជនគរផង ។

ក្នុង គ.ស ១៨៨២ ចៅហ្វាយស្រុកដំណាងប្រទេសបារាំងសែស ចូលមកថ្វាយបង្គំគាល់ព្រះបាទសម្ដេចព្រះនរោត្ដម សំរេចអំពីរបៀបរាជការគ្រប់ដំណែងក្នុងនគរ ។

ឯការកែប្រែរបៀបរាជការជាថ្មីនេះ ក៏មានកើតចលាចលក្នុងព្រះនគរដែរ ពីព្រោះមានសេចក្ដីងៀងឆ្ងែកអំពីរាជការពីដើម ប៉ុន្ដែក្រោយមកក៏បានស្រួលទេវិញ ហើយកាន់តែចំរើនរៀងៗមក ។

ព្រះបាទសម្ដេចព្រះនរោត្ដម ទ្រង់បានសាងព្រះវិហារព្រះកែវមរកត នៅខាងត្បូងព្រះបរមរាជវាំង ជាព្រះវិហារយ៉ាងល្អក្រៃលែង អ្នកទេសចរនានាតែងតែចូលមកមើល ។

ព្រះបាទសម្ដេចព្រះនរោត្ដមព្រះរាជសុវណ្ណគតក្នុង គ.ស ១៩០៤ នៅក្រុងភ្នំពេញ (ក្នុងព្រះជន្ម ៧០ ព្រះវស្សា) ។

## ព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ

(ពី គ.ស ១៩០០ ដល់ ១៩២៧)

អំពីខេត្តម្លូព្រៃ - ទន្លេរពៅ - កោះកុង - សៀមរាប ស្ទឹងត្រែង បានមកខ្មែរវិញ (១៩០៧) ។

www.budinst.gov.kh www.elibraryofcambodia.org

នៅថ្ងៃដែលព្រះបាទព្រះនរោត្តម ទ្រង់ព្រះរាជសុវណ្ណគតនោះ ក្រុមជំនុំធំសំរាប់ព្រះនគរ គឺគណៈសេនាបតី សម្តេចព្រះសង្ឃនាយកទាំងពីរគណៈនិងចាងហ្វាងបារគូ ហើយនឹងលោករ៉េស៊ីដងត៍ស៊ុប៉េរិយើរ ប្រជុំអញ្ជើញសម្តេចព្រះឧបរាជទ្រង់ទទួលរាជសម្បត្តិស្នងសម្តេចព្រះរៀម ។

កាលនោះសម្តេចព្រះឧបរាជ ព្រះជន្មបាន ៦៤ឆ្នាំ បណ្តារាស្ត្រស្រឡាញ់ចូលចិត្តនឹងព្រះអង្គណាស់ ពីព្រោះទ្រង់មានព្រះទ័យល្អសុភាពរាក់ទាក់ ហើយទ្រង់អធ្យោកអធ្យាស្រ័យអ្នកផងទាំងពួង ។

ព្រះឧបរាជក៏ជាក្សត្រក្លាហាន មិនខ្លាចញញើតឡើយ ព្រះអង្គបាននាំកងទ័ពទៅបង្ក្រាបដេញពួកបះ កាល គ.ស ១៨៦១ និង ១៨៨៤ ។

ព្រះរាជាភិសេក (គ.ស ១៩០៦) សម្តេចព្រះឧបរាជទ្រង់ទទួលព្រះរាជាភិសេកក្នុង គ.ស ១៩០៦ រួចហើយព្រះអង្គទ្រង់ព្រះនាមជាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ។ ក្នុងពិធីព្រះរាជាភិសេកនោះ មានលោកគូវែរណឺរសេណេរ៉ាល់ថ្វាយព្រះរាជមកុដ ។

កាលបើបានទទួលព្រះរាជាភិសេក ព្រះបាទសម្តេចព្រះស៊ីសុវត្ថិស្តេចទៅមហានគរបារាំងសែស ដើម្បីទតរបៀបរាជការនគរគេ ។

កាលព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ទ្រង់ស្តេចទៅដល់ក្រុងប៉ារីសនោះ លោកអធិបតីប្រជាជាតិបារាំងសែស ក៏រៀបទទួលដោយអឹកធឹក ដូចទទួលមហាក្សត្រនគរទាំងពួង ដល់ទ្រង់ត្រឡប់មកវិញ ទ្រង់មានព្រះទ័យសោមនស្សណាស់នឹងរបៀបរាជការបារាំងសែស ។

ក្នុងរាជ្យព្រះបាទសម្តេចព្រះស៊ីសុវត្ថិ មានពត៌មានមួយសំខាន់ណាស់ គឺកាល គ.ស ១៩០៧ នគរសៀមចុះសញ្ញានឹងនគរបារាំងសែស ប្រគល់ខេត្តបាត់ដំបង-ស្រីសោភណ-សៀមរាបមកនគរខ្មែរយើងវិញ ឯខែត្រស្ទឹងត្រែង-ម្លូព្រៃ-ទន្លេរពៅ ក៏សៀមបានប្រគល់មកឱ្យនគរខ្មែរយើងម្តងរួចហើយ ពីកាល គ.ស ១៩០៤ ។

អំពីបណ្តាជនខ្មែរ និងមហាសង្គ្រាមនៅប្រទេសអឺរ៉ុប ក្នុង គ.ស ១៩១៤ ក្នុងឆ្នាំ ១៩១៤ កាលមហានគរបារាំងសែស កើតសង្គ្រាមនឹងនគរអាល្លឺម៉ង់នោះ ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ទ្រង់បានអនុញ្ញាតបើកឱ្យបណ្តាជនខ្មែរដែលមានចិត្តស្ម័គ្រទៅ

www.budinst.gov.kh www.elibraryofcambodia.org

ជួយច្បាំងបារាំងសែស ឯឈ្មោះខ្មែរទាំងប៉ុន្មានដែលអនិច្ចកម្មក្នុងសង្គ្រាមនោះ ស៊ីង មានចារឹកទុកនៅចេតិយអនុស្សាវរីយ៍ ស្ថាងនៅភ្នំពេញ ក្នុងឆ្នាំ ១៩២៥ ។

អំពីសេចក្ដីចំរើនក្នុងរាជ្យព្រះបាទព្រះស៊ីសុវត្ថិ ក្នុងរាជ្យព្រះករុណាព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ នគរស្គាល់តែពីសេចក្ដីសុខក្សេមក្សាន្ត មានបះបោរបន្តិចបន្តួចក្នុងឆ្នាំ ១៩១៧ ។

ព្រះករុណាព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ ជាស្ដេចប្រសើរទ្រង់ធម៌មានព្រះរាជហឫទ័យសប្បុរសជ្រះថ្លាសាធារណ៍ ហើយដោយហេតុនេះ រាស្ត្រក៏ស្រឡាញ់ជាទីបំផុត វេលាទ្រង់យាងកណ្ដាលផ្លូវក្ដី បណ្ដារាស្ត្រទាំងអស់គ្នាឈរមើលព្រះអង្គបាន មិនចាំបាច់ ក្រាបក្បាលដល់ដី ដូចកាលពីដើមឡើយ ។

តាំងពីព្រះបាទសម្ដេចព្រះស៊ីសុវត្ថិទ្រង់រាជសម្បត្តិមក នគរខ្មែរបានចំរើនច្រើនណាស់ :

១- ទ្រង់តាំងព្រារព្ធអំពីចំណេះវិជ្ជា ឱ្យបង្កើតវិទ្យាល័យនៅកន្លែងព្រះរាជវាំងរបស់ព្រះអង្គ កាលទ្រង់នៅជាព្រះឧបរាជ ដែលគេហៅថាវិទ្យាល័យវាំងចាស់ ។ ឯវិទ្យាល័យសព្វថ្ងៃ គឺវិទ្យាល័យវាំងចាស់លើកមកសាង ហេតុនេះបានជាបំនាមហៅថា "វិទ្យាល័យស៊ីសុវត្ថិ" រួចយូរក្រោយមកទ្រង់ឱ្យសាងព្រះរាជបណ្ណាល័យ ជាមន្ទីរដំកល់សៀវភៅធម៌និងក្បួនច្បាប់សំរាប់ជនទាំងឡាយទៅសិក្សា ហើយនឹងសាងសាលាបរិយុត្តិធម៌ជាន់ខ្ពស់សំរាប់បង្រៀនព្រះត្រៃបិដក (សាលាបាលីជាន់ខ្ពស់) សាលារចនានិងមន្ទីរតាំងវត្ថុបុរាណ វត្ថុសំរាប់អ្នកទាំងពួងសិក្សាពង្សាវតារ សាលាបង្រៀនច្បាប់សំរាប់ធ្វើរាជការ ។

២- កើតផ្លូវថ្នល់ទៅដល់គ្រប់ខេត្ត មានរថយន្តបើកបរឆ្លាត់ឆ្លេងដឹកទំនិញនិងអ្នកដំណើរ ។

ព្រះរាជាសោយរាជសម្បត្តិតាំងពីកំណើតនគរ គឺតាំងពីសតវត្សទី ១ នៃគ្រឹស្ត សករាជ ដល់សតវត្សទី ៩ -

ព្រះស្ត្រីលីវយី (សំដីដើមឬសំដីចិនមិនចំតាមសំដីដើម)
១-ព្រះបាទហ្វ៊ុនទៀន (រវាង គ.ស ៦៨ បានព្រះស្រី

www.budinst.gov.kh www.elibraryofcambodia.org

លីវយីជាព្រះជាយា)

២-ព្រះបាទហ្វ៊ឹតហ្វានហៀង (តាំងពីចុងសតវត្សទី២)

៣-ព្រះបាទហ្វាន់ហ្វាន (សោយរាជ្យបានតែបីឆ្នាំសុគត)

៤-ព្រះបាទហ្វានម៉ាន់ (ដល់រវាង គ.ស ២៣០)

៥-ព្រះបាទហ្វានចាន (រវាង ២៣០ ដល់ ២៥០)

(ត្រូវជាព្រះភគិនិយោនៃព្រះបាទហ្វានម៉ាន ធ្វើគតព្រះបាទហ្វានម៉ានយករាជ្យ)

៦-ព្រះបាទហ្វានស៊ុន(ពីរវាង ២៥០)

(ធ្វើគតព្រះបាទហ្វានចានវិញ)

តាមសំដីដើមឬសំដីចិនមិនចំ

. . . . . . . . . . . . . . . . . . . . . . . . .

- ព្រះបាទជូចិន្តាន (ពីរវាង ៣៥៧)
- ព្រះបាទសុត្រវ៉ឺន (ពីរវាង គ.ស ៤០០)
- ព្រះបាទស្រីសត្វវ៉ឺន ( . . . . . . )
- ព្រះបាទកោណ្ឌញ្ញ-ជ័យវ៉ឺន (៤៨៥-៥១៤)

↓

- ព្រះបាទរុទ្រវ៉ឺន (ពី ៥១៤ ហើយក្នុង ៥៣៩ នៅសោយរាជ្យនៅឡើយ)
- ព្រះបាទភវវ៉ឺនទី ១ (រវាងពាក់កណ្តាលសតវត្សទី ៦)
- ព្រះបាទមហិន្ទ្រវ៉ឺន(រវាងឆ្នាំទី៦០០ ហើយក្នុង៦០៤នៅសោយរាជ្យនៅឡើយ)

(ជាព្រះអនុជនៃព្រះបាទភវវ៉ឺន)

- ព្រះបាទឦសាណវ៉ឺន (មុន៦១៦ ហើយក្នុង៦២៦នៅសោយរាជ្យនៅឡើយ)
- ព្រះបាទភវវ៉ឺនទី ២ (ពី ៦៣៩ . . .)
- ព្រះបាទជយវ៉ឺនទី ១ (៦៦៤-៦៦៨)

. . . . . . . . . . . . . . . . . . . . . . . . . . . . . .

- ព្រះបាទជ័យវ៉ឺនទី ២ (ចូលសតវត្សទី ៩)

www.budinst.gov.kh www.elibraryofcambodia.org

ជំនាន់ព្រះមហាក្សត្រអង្គរ គឺតាំងពីសតវត្សទី ៩ ដល់ក្នុងសតវត្សទី ១៣ -

- ព្រះបាទជ័យវរ្ម័នទី ២
  (គ.ស ៨០២-៨៦៩)
- ព្រះបាទជ័យវរ្ម័នទី ៣
  (គ.ស ៨៦៩-៨៧៧)
- ព្រះបាទឥន្ទ្រវរ្ម័នទី ១ (ជាព្រះរាជវង្សនៃព្រះបាទជ័យវរ្ម័នទី ២)
  (គ.ស ៨៧៧-៨៨៩)

ព្រះបាទយសោវរ្ម័ន
(គ.ស ៨៨៩-៩០៨)

ព្រះបាទហស៍វរ្ម័នទី ១
(គ.ស ៩០៨ . . .)

  ព្រះបាទឦសាណវរ្ម័នទី ២
  (គ.ស . . . ៩២៨)

    ព្រះបាទជ័យវរ្ម័នទី ៤ (ច្បាំងដណ្តើមយករាជ្យ)
    (គ.ស ៩២៨-៩៤២)

ព្រះបាទហស៍វរ្ម័នទី ២ (ព្រះអនុជ)
(គ.ស ៩៤២-៩៤៤)

    ព្រះបាទរាជិន្ទ្រវរ្ម័ន (ព្រះរៀម)
    (គ.ស ៩៤៤-៩៦៨)

- ព្រះបាទជ័យវរ្ម័នទី ៥
  (គ.ស ៩៦៨-១០០១)
- ព្រះបាទឧទយាទិត្យវរ្ម័នទី ១
  (គ.ស ១០០១-១០០២)
- ព្រះបាទសុរិយវរ្ម័នទី ១ (ជាព្រះរាជវង្សនៃព្រះបាទយសោវរ្ម័ន ច្បាំងដណ្តើមយករាជ្យ) (គ.ស ១០០២-១០៤៩)

www.budinst.gov.kh www.elibraryofcambodia.org

- ព្រះបាទឧទយាទិត្យវរ្ម័នទី ២ (ជាព្រះរាជវង្សនៃព្រះបាទសុរ្យវរ្ម័នទី ១)
  (គ.ស ១០៥៩-១០៧៩)
- ព្រះបាទហស៌វរ្ម័នទី ៣ (ជាព្រះអនុជនៃព្រះបាទឧទយាទិត្យវរ្ម័នទី ២)
  (គ.ស ១០៧៩ - ១០៩០)
- ព្រះបាទជយវរ្ម័នទី ៦
  (គ.ស ១០៩០ - ១១០៩)
- ព្រះបាទធរណិន្ទ្រវរ្ម័នទី ១ (ជាព្រះរៀមនៃព្រះជយវរ្ម័នទី ៦)
  (គ.ស ១១០៩ - ១១១២)
- ព្រះបាទសុរ្យវរ្ម័នទី ២ (ជាព្រះរាជនត្តានៃព្រះធរណិន្ទ្រទី ១ផង នៃព្រះជយវរ្ម័នទី ៦ ផង ខាងព្រះបិតានិងខាងព្រះមាតា)
  (គ.ស ១១១២ - ១១៦២)
- ព្រះបាទធរណិន្ទ្រវរ្ម័នទី ២ (ជាព្រះរាជវង្សជីដូនមួយនឹងព្រះសុរិយវរ្ម័នទី ២)
  (គ.ស ១១៦២ - ១១៦៣)
- ព្រះបាទជយវរ្ម័នទី ៧
  (គ.ស ១១៦៣ - ១២០១)
- ព្រះបាទឥន្ទ្រវរ្ម័នទី ២ (តាំងពីក្នុងរាជ្យព្រះមហាក្សត្រនេះហើយ ដែលសៀម តាំងបះបោរលើកទ័ពមកច្បាំងយករាជ្យ)
  (គ.ស ១២០១ - ១២២១)

ព្រះបាទឥន្ទ្រវរ្ម័នទី ២

ព្រះស្រិន្ទ្រវរ្ម័ន
(១២២. . . . )

ព្រះជយវរ្ម័នបរមេស្វរៈ
(..........................)

www.budinst.gov.kh www.elibraryofcambodia.org

## ជំណាវង្សព្រះរាជវង្សានុវង្សដែលបានសោយរាជសម្បត្តិ តាំងពីសតវត្សទី ១៤ មកដល់ សព្វថ្ងៃនេះ " គ.ស ១៩៥១" -

ព្រះបាទត្រសក់ផ្អែម

ព្រះសិទ្ធានរាជា
(គ.ស ១៣៤៦ - ១៣៤៧)

ព្រះនិព្វានបទ
(គ.ស ១៣៤០ - ១៣៤៦)

ព្រះលំពង្សរាជា
(គ.ស ១៣៤៧ - ១៣៥៣)

ព្រះស្រីសុរិយោទ័យ (ជាព្រះឧបរាជ ព្រះរៀមប្រឈួន ទទួលរងច្បាំងនឹងសៀម ទ្រង់សុគតក្នុងសង្គ្រាម)
(គ.ស ១៣៥៣)

ព្រះស្រីសុរិយោវង្សទី ១
(គ.ស ១៣៥៧-១៣៦៦)

ព្រះបរមរាជា
(១៣៦៦-១៣៧៣)

ពី ១៣៥៣ ដល់ ១៣៥៧
សៀមតាំងនៅក្រុងនគរធំ

ព្រះធម្មាសោក
(គ.ស ១៣៧៣-១៣៩៤)

ព្រះស្រីសុរិយោទ័យ

(ព្រះធម្មាសោក ទ្រង់សុគត ក្នុងសង្គ្រាមតយុទ្ធនឹងសៀម)

តាំងពី ១៣៩៤ ដល់ ១៤០១ សៀមតាំងនៅនគរធំទៀត

www.budinst.gov.kh www.elibraryofcambodia.org

ព្រះស្រីសុរិយោវង្សទី ២
(គ.ស ១៤០១-១៤១៧)

ព្រះបរមសុខា (ជាព្រះភគិនិយោនៃព្រះស្រីសុរិយោវង្សទី២ ហើយទ្រង់សុគត ក្នុងសង្គ្រាមតយុទ្ធនឹងសៀម)
(គ.ស ១៤១៧-១៤២០)

តាំងពី ១៤២០ ដល់ ១៤២១
សៀមតាំងនៅក្រុងនគរធំទៀត

ព្រះបាទពញាយ៉ាត
(គ.ស ១៤២០-១៤៦២)

ព្រះនារាយណ៍រាជា
(គ.ស ១៤៦២-១៤៦៧)

ព្រះស្រីសុរិយោទ័យ
(១៤៦៨-១៤៧៤)

ព្រះស្រីរាជា
(១៤៦៧-១៤៧៤)

ព្រះធម្មរាជាទី ១
(១៤៦៨-១៤៩៨)

ព្រះបាទធម្មរាជាទី ១

ព្រះបាទសុគន្ធបទ
(គ.ស ១៤៩៨-១៥០៥)

ពី ១៥០៤ ដល់ ១៥១៥ ស្តេចកន

ព្រះបាទអង្គចន្ទទី ១
(គ.ស ១៥១៥-១៥៥៥)

www.budinst.gov.kh www.elibraryofcambodia.org

ព្រះបាទបរមិន្ទរាជា
(គ.ស ១៥៥៥-១៥៦៧)

ព្រះសត្ថាទី ១
(គ.ស ១៥៦៧-១៥៧៤)

ព្រះជ័យជេដ្ឋាទី ១
(គ.ស ១៥៧៤-១៥៩៣)

ធាក់បែកក្រុងលង្វែក ១៥៩៣

ព្រះវង្ស រាមាជើងព្រៃ
(១៥៩៤-១៥៩៦)

ពញាតន់
(១៥៩៦-១៥៩៧)

ពញាយ៉ុម
(១៥៩៩-១៦០០)

ពញាអាន
(១៥៩៧-១៥៩៩)

ព្រះបាទស្រីសុរិយោពណ៌
(១៦០០-១៦១៨)

ព្រះជ័យជេដ្ឋាទី ២
(១៦១៨-១៦២៨)

ព្រះធម្មរាជសំភារ
(១៦២៩-១៦៣៩)

www.budinst.gov.kh www.elibraryofcambodia.org

ព្រះឧទ័យ (មិនបានសោយរាជ្យសម្បត្តិទេ ជាឧបរាជ ឧបយោរាជ រាជានុសិទ្ធិ)

ព្រះអង្គទងទី ១
(១៦៣៤-១៦៤០)

ព្រះរាមាធិបតីចន្ទ
មហាម៉ាត់
(១៦៤២-១៦៥៨)

ព្រះអង្គនន្ទទី ១
(១៦៤០-១៦៤២)

ព្រះជ័យជេដ្ឋាទី ៣
(១៦៧២-១៦៧៣)

ព្រះបទុមរាជា
(១៦៥៨-១៦៧២)

ព្រះអង្គជ័យ
(១៦៧៣-១៦៧៥)

ព្រះជ័យជេដ្ឋាទី ៤
(១៦៧៤-១៦៩៥)
(១៦៩៦-១៧០០)
(១៧០១-១៧០២)
(១៧០៤-១៧០៦)

ព្រះអង្គនន់ (មិនបានសោយរាជសម្បត្តិទេ ប្រជែងរាជ្យនឹងព្រះបាទជ័យជេដ្ឋាទី ៤)

ព្រះជ័យជេដ្ឋាទី ៤

ព្រះអង្គនន្ទ

ព្រះធម្មរាជាទី ២
(១៧០២-១៧០៤)
(១៧០៦-១៧១០)
(១៧៣៨-១៧៤៧)

ព្រះកែវហ្វាអង្គអឹម
(១៧០០-១៧០១)
(១៧១០-១៧២២)
(១៧២៩-១៧៣០)

www.budinst.gov.kh www.elibraryofcambodia.org

ព្រះធម្មរាជា អង្គអឹម
(១៧៤៧)

ព្រះសត្ថាទី ២
(១៧២២-១៧២៩)
(១៧៣០-១៧៣៦)

ព្រះជ័យជេដ្ឋាទី ៥
(១៧៤៩-១៧៥៥)

ព្រះអង្គធនទី ២
(១៧៧៥-១៧៧៩)

ព្រះអង្គទងទី ២
(១៧៤៧-១៧៤៩)
(១៧៥៦-១៧៥៧)

ព្រះអង្គអេង
(១៧៧៩-១៧៩៦)

ព្រះអង្គចន្ទទី ២
(១៨០៦-១៨៣៤)

ព្រះរាជក្សត្រីអង្គមី
(១៨០៤-១៨៤១)

ព្រះអង្គឌួង
(១៨៤១-១៨៦០)

ព្រះអង្គឌួង

ព្រះនរោត្តម
(១៨៥៩-១៩០៤)

ព្រះស៊ីសុវត្ថិ
(១៩០៤- . . .)

ព្រះមុនីវង្ស
(.............)

ព្រះស៊ីហនុ
(.............)

★ ចប់ ★

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org



www.budinst.gov.kh www.elibraryofcambodia.org